អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

LOLC (Cambodia) Plc.

# របាយការណ៍ប្រចាំឆ្នាំ

# ២០១៩

www.lolc.com.kh

# ផែនទីតំបន់ប្រតិបត្តិការ




**កំណត់សម្គាល់៖**

- ការិយាល័យ អិលអូអិលស៊ី កំពុងធ្វើប្រតិបត្តិការ
- ការិយាល័យដែលនឹងបើកក្នុង ឆ្នាំ២០២០
- តំបន់ប្រតិបត្តិការរបស់ អិលអូអិលស៊ី

**ចំនួនការិយាល័យ**

**៧៩**

**ចំនួនខេត្តកំពុងធ្វើប្រតិបត្តិការ**

**២៥**

*ចំណាំ៖ ផែនទីនេះប្រើសម្រាប់តែបង្ហាញបណ្ដាញសាខារបស់ អិលអូអិលស៊ី តែប៉ុណ្ណោះ។*

# ទស្សនវិស័យ និងបេសកកម្ម



## ទស្សនវិស័យ

ក្រុមគ្រួសារដែលស្ថិតនៅកម្រិតមូលដ្ឋានពីរ៉ាមីតនៃសេដ្ឋកិច្ចសង្គម ទទួលបានសក្តានុពលភាព ដើម្បីរស់នៅប្រកបដោយជីវភាពថ្លៃថ្នូរ សុវត្ថិភាពសេដ្ឋកិច្ច សុវត្ថិភាពសង្គម និងយុត្តិធម៌។



## បេសកកម្ម

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី គឺជាគ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុដែលមានទស្សនវិស័យសង្គម និងទិសដៅអាជីវកម្ម ដែលផ្តល់ឱ្យសហគ្រិន និងក្រុមគ្រួសារដែលស្ថិតនៅកម្រិតមូលដ្ឋានពីរ៉ាមីតនៃសេដ្ឋកិច្ចសង្គម នូវឱកាសសេដ្ឋកិច្ច ដើម្បីផ្លាស់ប្តូរជីវភាពរស់នៅ និងសហគមន៍របស់ពួកគេឱ្យប្រសើរឡើង តាមរយៈការផ្តល់ឱ្យអតិថិជននូវសេវាកម្មហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

# គុណតម្លៃ

## អិលអូអិលស៊ី

**ការទំនាក់ទំនងជាមួយអតិថិជន**

អាទិភាពទីមួយរបស់យើងគឺធានាថា អតិថិជនមានការពេញចិត្តទាំងស្រុង ចំពោះការបម្រើសេវារបស់យើង។

**គុណភាព**

យើងនឹងខិតខំបម្រើអតិថិជនរបស់យើងឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពបំផុត។

**សុចរិត យុត្តិធម៌ និងភាពស្មោះត្រង់**

ការទុកចិត្តគឺជាមូលដ្ឋានគ្រឹះនៃអាជីវកម្មរបស់យើងហើយយើងនឹងមិនផ្លាស់ប្តូរទស្សនៈនេះឡើយ។

**ភាពទីទៃគ្នា និងអព្យាក្រឹត**

យើងបម្រើប្រជាជនក្រីក្រទៅតាមតម្រូវការជាមូលដ្ឋាន ដោយមិនប្រកាន់ជាតិសាសន៍ សាសនា ឬនិន្នាការនយោបាយឡើយ។

**តុល្យភាពសង្គម និងផលចំណេញរបស់ស្ថាប័ន**

តុល្យភាពនេះធានាអនាគតរបស់អតិថិជនយើង និងខ្លួនយើង។

**ការគោរពវិន័យ**

យើងមានជំនឿលើការគោរពច្បាប់របស់ក្រុមហ៊ុន អ្នកដែលពាក់ព័ន្ធ និងប្រទេស។

**ការខិតខំប្រឹងប្រែងធ្វើការងារ**

យើងមានជំនឿថា ការជឿជាក់លើអនាគតរបស់យើងនឹងត្រូវបានធានា តាមរយៈការខិតខំប្រឹងប្រែងជាអតិបរមាចំពោះការទទួលខុសត្រូវរបស់យើង។

**ការអប់រំ**

យើងមានជំនឿថា ការអប់រំគឺជាមូលដ្ឋានគ្រឹះនៃភាពជ័យជម្នះយូរអង្វែង។

# សមិទ្ធផលហិរញ្ញវត្ថុជាក់ស្តែង និងការរំពឹងទុក

| | សមិទ្ធផលសម្រេចបាន | | | ការរំពឹងទុក * |
|---|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ | ២០២០/p |
| ទ្រព្យសកម្មសរុប (ដុល្លារ) | ៣៧១,៤៣០,៧៥៤ | ៦១០,៣២៨,៣៦៩ | ១,០០៩,៣៥១,៥០៤ | ១,៤៥៥,៤៧៣,១២៩ |
| ផលប័ត្រឥណទានដុល (ដុល្លារ) | ៣២២,៦៤៧,៦៩៨ | ៤៨៣,៨៤៥,៣០៧ | ៧៧២,២១៤,២៦៦ | ១,១៩៩,៩៩៣,៤២៣ |
| មូលធនភាគទុនិក (ដុល្លារ) | ៦០,៣៧៩,១៣០ | ៨១,១៧០,៦១៤ | ១៣៥,៨០៥,៤៤១ | ២២២,៧៤០,៩៥៨ |
| ប្រាក់ចំណេញសុទ្ធ (ដុល្លារ) | ១៥,៥៨៨,០៥៧ | ១៥,៦៣៧,៨១៣ | ៣៤,០២០,១១៨ | ៥១,៧១៧,៧០២ |
| ចំនួនអតិថិជនឥណទាន | ២១០,២២៧ | ២៣៥,៦១៣ | ២៩៤,១៥២ | ៤០៨,៣២៧ |
| សមតុល្យប្រាក់បញ្ញើ (ដុល្លារ) | ៩១,៨៣៤,៦៧៨ | ២៣៦,៩១០,៣៨៥ | ៤៥៧,៦៦១,៤៧០ | ៧២៤,៦៣៣,០៧៦ |
| ចំនួនគណនីប្រាក់បញ្ញើ | ៧២,៧០៥ | ១៩៨,៨៧៩ | ៣៨១,៦១៣ | ៤១៧,៣៧៧ |
| ចំនួនអតិថិជនដាក់ប្រាក់បញ្ញើ | ៦៥,៦៩៤ | ១៨០,៣០៥ | ៣៣៦,០០២ | ៣៦៧,៤៩១ |
| ចំនួនសាខា (រួមបញ្ចូលការិយាល័យកណ្តាល) | ៧៧ | ៧៨ | ៨០ | ៨២ |
| ចំនួនបុគ្គលិក | ២,០៦៥ | ២,៣២៧ | ២,៧៥៧ | ៣,២០៩ |
| ចំណាយប្រតិបត្តិការ/ផលប័ត្រឥណទាន | ៨.០៨% | ៧.៣៣% | ៦.០៧% | ៥.១៦% |
| ហានិភ័យឥណទានធំជាង ៣០ថ្ងៃ | ១.៤០% | ០.៩៦% | ០.៦១% | ១.២៥% |
| អនុបាតឥណទានលុបចេញពីបញ្ជី | ០.៤០% | ០.៤៤% | ០.២៧% | ០.៥០% |
| អនុបាតសាធនភាព | ២០.៦៨% | ១៧.៩៣% | ២០.០៥% | ១៦.៧៧% |
| អនុបាតបំណុលធៀបមូលធនភាគទុនិក | ៥.០x | ៦.៤x | ៦.០x | ៥.៤x |
| អនុបាតចំណាយធៀបចំណូល (រួមបញ្ចូលសំវិធានធន) | ៥៥.៩១% | ៦១.២៨% | ៥២.៥៣% | ៥២.០០% |
| អត្រាចំណេញពីទ្រព្យសកម្ម | ៤.៩៩% | ៣.១៩% | ៤.២០% | ៤.២៨% |
| អត្រាចំណេញពីមូលធនភាគទុនិក | ២៨.៦៣% | ២២.៩៤% | ៣២.១៣% | ២៨.០៦% |

** ផែនការឆ្នាំ ២០២០ ត្រូវបានរៀបចំមុនពេលជំងឺរាតត្បាត កូវីដ-១៩ មកដល់។*

ផលប័ត្រឥណទានសរុប
(គិតជាលានដុល្លារ)




អតិថិជនឥណទានសកម្ម
(គិតជាពាន់នាក់)




ប្រាក់ចំណេញសុទ្ធ
(គិតជាលានដុល្លារ)




ហានិភ័យឥណទានធំជាង ៣០ថ្ងៃ




អត្រាចំណេញពីទ្រព្យសកម្ម




អត្រាចំណេញពីមូលធនភាគទុនិក



# មាតិកា


ទំព័រ

ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល ........ ៦-៧
របាយការណ៍របស់ប្រធាននាយកប្រតិបត្តិ ........ ៨-១០

## អំពី អិលអូអិលស៊ី

ចក្ខុវិស័យប្រទេសកម្ពុជា ........ ១២
អំពី អិលអូអិលស៊ី ........ ១៣
ប្រវត្តិ អិលអូអិលស៊ី ........ ១៣
ម្ចាស់កម្ចី និងដៃគូ ........ ១៤
សកម្មភាពចម្បងរបស់ អិលអូអិលស៊ី ........ ១៥

## អំពី អាជីវកម្ម

ការរីកចម្រើនប្រកបដោយការទទួលខុសត្រូវ ........ ១៨
និន្នាការនៃផលិតផល ........ ១៩
សមិទ្ធផលអាជីវកម្ម ........ ២០-២៣
សេចក្តីសង្ខេបអំពីសមិទ្ធផលហិរញ្ញវត្ថុ ........ ២៤-២៥
ទស្សនវិស័យអំពីអតិថិជន ........ ២៦
ការអភិវឌ្ឍធនធានមនុស្ស ........ ២៦

## អំពី ការគ្រប់គ្រងសកម្មភាពសង្គម និងបរិស្ថាន

តើយើងពន្យល់អត្ថន័យនៃបេសកកម្មរបស់យើងយ៉ាងដូចម្តេច? ........ ២៨
ការវាស់វែងគោលដៅសង្គមរបស់ អិលអូអិលស៊ី ........ ២៨
ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ........ ២៩
ការវាស់វែងសកម្មភាពសង្គមតាមរយៈ PPI ........ ៣០
Green Lending ........ ៣០
កម្ចីទឹកស្អាត និងអនាម័យ (WASH Loan) ........ ៣១
សកម្មភាពសង្គមផ្សេងៗទៀត ........ ៣១-៣៣

## អភិបាលកិច្ច

រចនាសម្ព័ន្ធភាគទុនិក ........ ៣៦
រចនាសម្ព័ន្ធនៃការគ្រប់គ្រង ........ ៣៧
គោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់អភិបាលកិច្ចសាជីវកម្ម ........ ៣៨-៤១
តួនាទី និងទំនួលខុសត្រូវរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ........ ៤២-៤៤
របាយការណ៍ក្រុមប្រឹក្សាភិបាល ........ ៤៥-៤៧
គណៈគ្រប់គ្រង ........ ៤៨-៥៤
ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុង ........ ៥៥

## របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករឯករាជ្យ

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ ៥៨-៦០
របាយការណ៍របស់សវនករឯករាជ្យ ........ ៦១-៦២
តារាងតុល្យការ ........ ៦៣-៦៤
របាយការណ៍លទ្ធផល ........ ៦៥
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ........ ៦៦
របាយការណ៍លំហូរទឹកប្រាក់ ........ ៦៧-៦៩
កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ........ ៧០-១៤៥

បណ្តាញប្រតិបត្តិការ របស់ អិលអូអិលស៊ី ........ ១៤៧-១៥០

# ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



“ ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ អិលអូអិលស៊ី សម្រាប់ឆ្នាំ២០១៩។ ២០១៩ គឺជាឆ្នាំដ៏ពិសេសមួយដែល អិលអូអិលស៊ី បានបន្តកំណើនយ៉ាងល្អប្រសើរ ដែលបានជម្រុញដោយភាពច្នៃប្រឌិត គំនិតផ្តួចផ្តើមថ្មីៗ និងគំនិតឆ្ពោះទៅឧត្តមភាព។ ”

លោក ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា
ប្រធានក្រុមប្រឹក្សាភិបាល
នៃ អិលអូអិលស៊ី (ខាមបូឌា) ភីអិលស៊ី

ថ្វីត្បិតតែមានបញ្ហាប្រឈមមួយចំនួនពីកត្តាខាងក្នុង និងខាងក្រៅ កម្ពុជាអាចសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាងឆ្នាំមុនទៅទៀត នៅក្នុងឆ្នាំ២០១៩ ដែលរាជរដ្ឋាភិបាលបានបង្ហាញរបាយការណ៍កំណើនសេដ្ឋកិច្ចចំនួន ៧,១% ដែលខ្ពស់ជាងគេនៅក្នុងតំបន់អាស៊ាន។ កំណើនសេដ្ឋកិច្ចត្រូវបានរំពឹងទុកថានឹងធ្លាក់ចុះមកត្រឹម ៦,៥% នៅក្នុងឆ្នាំ២០២០ ភាគច្រើនដោយសារតែការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក និងការថយចុះនៃតម្រូវការសកល ក៏ដូចជាហានិភ័យដែលបណ្តាលមកពីការធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសចិន ការបាត់បង់មួយផ្នែកនៃការអនុគ្រោះពន្ធលើការនាំចេញផលិតផលទៅកាន់ទីផ្សារសហភាពអឺរ៉ុបក្រោមគម្រោងអនុគ្រោះពន្ធនាំចេញ Everything But Arms (EBA) និងភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេស។ វិស័យបន្ទាប់បន្សំផ្នែកលក់ដុំ និងរាយ រួមមានសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានរំពឹងថានឹងរក្សាបានកំណើនដូចឆ្នាំមុន។ វិស័យកសិកម្មក៏ត្រូវបានរំពឹងថានឹងរក្សាបានអត្រាកំណើននៅដដែលចំនួន ១,៧% ដូចឆ្នាំ២០១៩។

ទាក់ទងនឹងបញ្ហាប្រឈមខាងក្រៅដែលអាចប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចនៅឆ្នាំនេះ គួរកត់សម្គាល់ផងដែរថាការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកអាចនឹងមានការធ្លាក់ចុះខ្លាំងជាងការរំពឹងទុក ហើយយើងនៅមិនទាន់អាចព្យាករណ៍បានថាផលប៉ះពាល់នៃជម្ងឺឆ្លង កូវីដ-១៩ ប៉ះពាល់កម្រិតណាទៅលើកំណើនសេដ្ឋកិច្ចនោះទេ។

ចំពោះហានិភ័យផ្ទៃក្នុង ការផ្តោតលើវិស័យអចលនទ្រព្យអាចបង្កឱ្យមានហានិភ័យដល់ស្ថេរភាពវិស័យហិរញ្ញវត្ថុ។ ហានិភ័យសំខាន់មួយទៀតគឺគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ដែលអាចនឹងកើតមានឡើងនៅក្នុងឆ្នាំនេះ។ ប្រទេសកម្ពុជា ក៏កំពុងប្រឈមនឹងបញ្ហាដ៏សំខាន់មួយទៀត គឺគម្លាតជំនាញ ដែលបណ្តាលមកពីភាពខ្វះចន្លោះរវាងជំនាញដែលផ្គត់ផ្គង់ដោយកម្លាំងពលកម្មដែលមានស្រាប់ និងតម្រូវការរបស់និយោជក។

**អិលអូអិលស៊ី** បានបញ្ចប់ឆ្នាំសារពើពន្ធ ២០១៩ ជាមួយនឹងសមិទ្ធផលហិរញ្ញវត្ថុ និងសង្គមគួរជាទីគាប់ចិត្ត។ តាមរយៈការអនុវត្តគោលនយោបាយយុទ្ធសាស្រ្ត និងការគ្រប់គ្រងផ្ទៃក្នុងយ៉ាងមានប្រសិទ្ធភាព អិលអូអិលស៊ី (ខេមបូឌា) សម្រេចបាននូវកំណើនប្រកបដោយគុណភាព និងការទទួលខុសត្រូវសង្គម។ ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនិងការជឿទុកចិត្តរបស់អតិថិជនមកលើផលិតផល និងសេវាកម្មរបស់ អិលអូអិលស៊ី ធ្វើឱ្យ អិលអូអិលស៊ី ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំជាងគេលំដាប់ទី៤ នៅក្នុងប្រទេសកម្ពុជា គិតលើសមតុល្យប្រាក់បញ្ញើ និងចំនួនផលប័ត្រឥណទាន និងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំជាងគេលំដាប់ទី៣ បើគិតលើចំនួនអតិថិជន។ អត្រាចំណេញពីទ្រព្យសកម្មរបស់ អិលអូអិលស៊ី ទទួលបានលទ្ធផលល្អឈានមុខគេ ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលធំជាងគេទាំង៧ ហើយអត្រាចំណេញពីមូលធនភាគទុនិករបស់ អិលអូអិលស៊ី ជាប់លំដាប់ថ្នាក់លេខ២ ពីរឆ្នាំជាប់គ្នានៅក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ និងឈានមុខគេក្នុងឆ្នាំ២០១៩។

សម្រាប់ឆ្នាំ២០១៩ អិលអូអិលស៊ី បានពង្រីកអាជីវកម្មនិងសេវាកម្មរបស់ខ្លួនជាមួយនឹងការបង្កើតផលិតផល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនដែលមានចំណូលកម្រិតមធ្យម ដែលមានការកើនឡើងយ៉ាងឆាប់រហ័ស។ ការរីកចម្រើនក្នុងវិស័យសហគ្រាសធុនមធ្យមធ្វើឱ្យមានតម្រូវការផលិតផលកាន់តែសម្បូរបែបជាងមុន។ ជាមួយនឹងការគាំទ្រផ្នែកបច្ចេកទេសពី អិលអូអិលស៊ី គ្រុប អិលអូអិលស៊ី (ខេមបូឌា) នឹងបន្តកែលម្អផលិតផល និងសេវាកម្មដែលមានស្រាប់ដើម្បីបំពេញតម្រូវការរបស់អតិថិជន។ បន្ថែមលើនេះ អិលអូអិលស៊ី នឹងបន្តពង្រឹងសេវាអតិថិជន និងផ្តល់ផលិតផលព្រមទាំងសេវាកម្មថ្មីៗសម្បូរបែបទៅតាមតម្រូវការទីផ្សារ រួមមានគណនីសន្សំសម្រាប់ប្រើប្រាស់ក្នុងគម្រោងពេលអនាគត និងសេវាទូទាត់វិក្កយបត្រ។ លើសពីនេះទៀត ក្នុងឆ្នាំ២០១៩ អិលអូអិលស៊ី បានផ្តោតសំខាន់លើសេវាហិរញ្ញវត្ថុ ឌីជីថល ដែលជាលទ្ធផល អិលអូអិលស៊ី បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធី iPay Mobile Banking Application ដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការបានដោយខ្លួនឯងនៅក្នុងទូរស័ព្ទដៃ និងបានចូលជាសមាជិកប្រព័ន្ធ FAST ក្រោមគម្រោងរបស់ ធនាគារជាតិនៃកម្ពុជា។ លើសពីនេះទៀត អិលអូអិលស៊ី បានដាក់ឱ្យប្រើប្រាស់កាត ATM របស់ខ្លួន ដល់បុគ្គលិកទាំងអស់ ដែលអាចធ្វើប្រតិបត្តិការនៅតាមម៉ាស៊ីន ATM របស់គ្រឹះស្ថានជាច្រើនដែលជាសមាជិកប្រព័ន្ធ CSS ហើយ អិលអូអិលស៊ី គ្រោងនឹងដាក់ឱ្យប្រើប្រាស់កាត ATM របស់ខ្លួន ដល់អតិថិជនទាំងអស់នៅក្នុងឆ្នាំ២០២០។

គណៈគ្រប់គ្រង និងបុគ្គលិក អិលអូអិលស៊ី បានបង្ហាញនូវភាពរឹងមាំ និងសមត្ថភាព ក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរម៉ាក្រូសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជា ទន្ទឹមគ្នានឹងការធានាបាននូវអនុលោមភាពលើរាល់ច្បាប់ និងបទបញ្ញត្តិទាំងឡាយ។ អិលអូអិលស៊ី អនុលោមតាមបទបញ្ញត្តិ និងអនុបាតដ៏រឹងមាំ ដែលចេញដោយធនាគារជាតិនៃកម្ពុជា និងមានសមត្ថភាពអនុវត្តតាមបទបញ្ញត្តិថ្មីៗដែលបានចេញនៅក្នុងឆ្នាំ២០១៨ ដូចជាការកំណត់ទ្រនាប់ដើមទុន របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ការចូលជាសមាជិកប្រព័ន្ធទូទាត់រហ័ស FAST និងប្រព័ន្ធ Cambodia Shared Switch (CSS) អនុបាតក្របខណ្ឌសន្ទនីយភាព និងចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមែន។ ចាប់ពីឆ្នាំ២០១៩ អិលអូអិលស៊ី បានអនុវត្តស្តង់ដារគណនេយ្យ IFRS ដើម្បីបំពេញតាមតម្រូវការរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ និងជាពិសេស IFRS 9 ដើម្បីអនុលោមពេញលេញតាមប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមែន។ បន្ថែមលើនេះ អិលអូអិលស៊ី ធ្វើប្រតិបត្តិការក្នុងក្របខណ្ឌអភិបាលកិច្ចមួយដែលរួមបញ្ចូលគ្នារវាងបទបញ្ញត្តិអភិបាលកិច្ចសាជីវកម្មដែលចេញដោយ ធនាគារជាតិនៃកម្ពុជា និងចំណុចល្អៗនៃអភិបាលកិច្ចសាជីវកម្មដទៃទៀត ដើម្បីធានាបាននូវអភិបាលកិច្ចដែលមានគុណភាពខ្ពស់ និងនិរន្តរភាពដ៏យូរអង្វែងរបស់ក្រុមហ៊ុន។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់អ្នកដែលពាក់ព័ន្ធទាំងអស់រួមមាន អតិថិជន វិនិយោគិន និយ័តករ ធនាគារ និងដៃគូម្ចាស់កម្ចីទាំងក្នុង និងក្រៅប្រទេស សម្រាប់ការជឿជាក់ការទុកចិត្ត និងសហប្រតិបត្តិការ គាំទ្រ ចំពោះការរីកចម្រើនរបស់អិលអូអិលស៊ី ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ខ្ញុំបាទក៏សូមកោតសរសើរចំពោះក្រុមប្រឹក្សាភិបាលទាំងអស់ សម្រាប់ការណែនាំ និងផ្តល់យោបល់ល្អៗ និងបុគ្គលិក អិលអូអិលស៊ី ទាំងអស់ដែលស្ថិតនៅក្រោមការដឹកនាំរបស់គណៈគ្រប់គ្រងដែលមានសមត្ថភាពសម្រាប់ការខិតខំប្រឹងប្រែងក្នុងការបំពេញការងារ។ អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំប្តេជ្ញាចិត្តចូលរួមជាផ្នែកមួយដ៏សំខាន់ក្នុងការផ្តល់ឱកាសសេដ្ឋកិច្ចដល់អតិថិជន និងប្រជាជនកម្ពុជា។

យើងសូមបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងចំពោះអតិថិជន វិនិយោគិន និងភាគទុនិកទាំងអស់របស់យើងថា នៅឆ្នាំ២០២០ យើងនឹងបន្តផ្តោតសំខាន់លើវិស័យដែលផ្តល់នូវឱកាសដ៏ល្អបំផុតសម្រាប់ អិលអូអិលស៊ី (ខេមបូឌា) ដើម្បីសម្រេចបាននូវអត្រាកំណើនដ៏រឹងមាំ និងមានស្ថេរភាព និងដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្ររបស់យើងក្នុងការលើកកម្ពស់អត្រាចំណេញ ក៏ដូចជាពង្រឹងទីតាំងរបស់អិលអូអិលស៊ី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។



ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

# របាយការណ៍របស់ប្រធាននាយកប្រតិបត្តិ



“ វិស័យមីក្រូហិរញ្ញវត្ថុសម្រេចបាននូវកំណើនយ៉ាងរឹងមាំនៅក្នុងឆ្នាំ២០១៩ ជាមួយនឹងផលប័ត្រឥណទានសរុបនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុទាំងមូលកើនឡើងដល់ ៧,៣ប៊ីលានដុល្លារអាមេរិក ដែលកើនឡើងចំនួន ៣៣% ខណៈដែលអត្រាឥណទានមិនដំណើរការមានត្រឹមតែ ០,៨១% ដែលមានភាពល្អប្រសើរជាងឆ្នាំមុន។ ចំនួនអតិថិជនសរុបកើនឡើងដល់ជាង ២,២ លាននាក់។ សមតុល្យប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើកើនឡើងដល់ ៣,៨ ប៊ីលានដុល្លារអាមេរិក ដែលអតិថិជនប្រាក់បញ្ញើមានចំនួន ២,៨ លាននាក់ ( ទិន្នន័យពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧៣ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ៥ និងគ្រឹះស្ថានឥណទានជនបទចំនួន ៦ )។ ”

លោក សុខ វឿន
ប្រធាននាយកប្រតិបត្តិ
នៃ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

ប្រទេសកម្ពុជាសម្រេចបានកំណើនផលិតផលក្នុងស្រុកសរុបចំនួន ៧,១% នៅក្នុងឆ្នាំ២០១៩ ហើយត្រូវបានរំពឹងទុកថានឹងធ្លាក់ចុះមកត្រឹម ៦,៥% នៅក្នុងឆ្នាំ២០២០ ដោយសារតែការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក និងការថយចុះនៃតម្រូវការសកល ក៏ដូចជាហានិភ័យដែលបណ្ដាលមកពីការធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសចិន ការបាត់បង់មួយផ្នែកនៃការអនុគ្រោះពន្ធលើការនាំចេញផលិតផលទៅកាន់ទីផ្សារសហភាពអឺរ៉ុប ក្រោមគម្រោងអនុគ្រោះពន្ធនាំចេញ Everything But Arms (EBA) និងភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេស។

នៅរយៈពេល ៥ ឆ្នាំខាងមុខនេះ ប្រជាជនកម្ពុជា ត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ១៧,៣ លាននាក់ នៅត្រឹមឆ្នាំ២០២៣ ដែលក្នុងនោះ ៥៤% ជាប្រជាជនសកម្ម មានអាយុចន្លោះពី ២០ ទៅ ៦០ឆ្នាំ។ ដូច្នេះ នេះគឺជាឱកាសដ៏ល្អសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការបង្កើតផលិតផល និងសេវាកម្មរបស់ខ្លួនឱ្យសមស្របទៅតាមតម្រូវការរបស់អតិថិជន និងពង្រីកប្រតិបត្តិការរបស់ខ្លួនបន្ថែមទៀត ដើម្បីផ្ដល់សេវាហិរញ្ញវត្ថុដល់ប្រជាជននៅទីប្រជុំជន និងជនបទដាច់ស្រយាលដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុ។

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០១៩

ខ្ញុំបាទនឹងលើកឡើងពីសមិទ្ធផលសំខាន់ៗដែល អិលអូអិលស៊ី សម្រេចបាននៅក្នុងឆ្នាំ២០១៩។

### ផលប័ត្រឥណទាន

អិលអូអិលស៊ី រក្សាបាននូវកំណើនប្រកបដោយគុណភាព នៅក្នុងឆ្នាំ២០១៩ ដែលផលប័ត្រឥណទានកើនឡើងចំនួន ៦០% ដែលមានសមតុល្យសរុបប្រមាណ ៧៧២ លានដុល្លារអាមេរិក ខណៈដែលហានិភ័យផលប័ត្រឥណទានមានត្រឹមតែ ០,៦១%។ ចំនួនអតិថិជនបានកើនឡើង ២៥% ដែលមានចំនួនសរុបប្រមាណ ២៩៤ ពាន់នាក់។ ចំនួនអតិថិជនរួមមានអតិថិជនក្រុម ៤២% និងអតិថិជនឯកត្តជន ៥៨%។ ផលប័ត្រឥណទានភាគច្រើនគឺផ្ដល់ដល់អតិថិជនក្រុម និងអតិថិជនឯកត្តជនដែលមានចំណូលទាប ដែលនេះឆ្លុះបញ្ចាំងពីបេសកកម្មរបស់ អិលអូអិលស៊ី ក្នុងការផ្ដល់កម្ចីដល់សហគ្រិន និងក្រុមគ្រួសារដែលស្ថិតនៅកម្រិតមូលដ្ឋានពីរ៉ាមីតនៃសេដ្ឋកិច្ចសង្គមនៅតាមតំបន់ជនបទ។

### គុណភាពផលប័ត្រឥណទាន

អិលអូអិលស៊ី នៅតែអាចរក្សាបាននូវកំណើនផលប័ត្រឥណទានប្រកបដោយគុណភាពខ្ពស់ និងការត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំ ដែលធ្វើឱ្យ

អិលអូអិលស៊ី អាចសម្រេចបាននូវលទ្ធផលល្អប្រសើរជាងលទ្ធផលជាមធ្យមរបស់វិស័យមីក្រូហិរញ្ញវត្ថុទាំងមូល។ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង អិលអូអិលស៊ី បានសហការគ្នាយ៉ាងជិតស្និទ្ធដើម្បីពង្រឹងលើការគ្រប់គ្រងហានិភ័យឥណទាន និងការត្រួតពិនិត្យផ្ទៃក្នុង ដែលរួមមាន៖

- បន្តពង្រឹងលើដំណើរការឥណទាន និងការត្រួតពិនិត្យផ្ទៃក្នុង
- បន្តពង្រឹងការត្រួតពិនិត្យឥណទានបន្ទាប់ពីទម្លាក់ទុនរួចតាមរយៈវិធីសាស្ត្រផ្សេងៗគ្នា
- ការបង្រាបវប្បធម៌នៃការគ្រប់គ្រងហានិភ័យនៅទូទាំង អិលអូអិលស៊ី
- បន្តពង្រឹងក្រុមការងារធានាគុណភាពឥណទាន ដើម្បីធានាបានប្រសិទ្ធភាពនៃការអនុវត្ត និងការត្រួតពិនិត្យផ្ទៃក្នុង
- នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យបាននូវប្រសិទ្ធភាពនៃការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង
- កែលម្អរចនាសម្ព័ន្ធនៃការលើកទឹកចិត្តមន្ត្រីឥណទាន និងបុគ្គលិកសហគមន៍ផ្សេងទៀត ដោយផ្អែកលើគុណភាពឥណទានជាចម្បង
- ការត្រួតពិនិត្យការិយាល័យឥណទាននៃកម្ពុជា ឱ្យបាន ១០០% ចំពោះអ្នកខ្ចី និងអ្នករួមខ្ចី មុនពេលទម្លាក់ទុន ដើម្បីវាយតម្លៃឥណទានរបស់អតិថិជនម្នាក់ៗឱ្យបានហ្មត់ចត់
- បន្តផ្តល់វគ្គបណ្តុះបណ្តាលដើម្បីពង្រឹងផលិតភាពរបស់បុគ្គលិក
- ការអនុវត្តគោលការណ៍ការពារអតិថិជន ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការគ្រប់គ្រងហានិភ័យ
- ការអនុវត្តដ៏មានប្រសិទ្ធភាពក្នុងកម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដើម្បីផ្តល់ឱ្យអតិថិជន និស្សិតសាកលវិទ្យាល័យ និងប្រជាជនក្នុងសហគមន៍ នូវជំនាញក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។

## ការប្រមូលប្រាក់បញ្ញើសន្សំ

សមតុល្យប្រាក់បញ្ញើសន្សំ កើនឡើងយ៉ាងឆាប់រហ័សដល់ជាង ៤៥៨ លានដុល្លារអាមេរិក ដែលមានកំណើន ៩៣% ធៀបនឹងដំណាច់ឆ្នាំ២០១៨។ ចំនួនអតិថិជនប្រាក់បញ្ញើកើនឡើងដល់ជាង ៣៣៦ ពាន់នាក់ ជាមួយនឹងកំណើន ៨៦%។ កំណើនយ៉ាងឆាប់រហ័សនៃសមតុល្យប្រាក់បញ្ញើសន្សំបង្ហាញឱ្យឃើញថា អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្តខ្ពស់ដែលផ្តល់នូវសេវាហិរញ្ញវត្ថុដ៏ល្អប្រសើរដល់អតិថិជនការការពារអតិថិជន និងផ្តល់នូវផលិតផលប្រាក់បញ្ញើ និងផលិតផលឥណទានថ្មីៗ ដែលមានលក្ខណៈប្រកួតប្រជែង។ អិលអូអិលស៊ី មានគោលដៅសម្រេចឱ្យបាននូវកំណើនសមតុល្យប្រាក់បញ្ញើទ្វេដង ដើម្បីតាមឱ្យទាន់ដៃគូនៅត្រឹមដំណាច់ឆ្នាំ ២០២០។

## គម្រោងធនាគារឌីជីថល

ដើម្បីគាំទ្រអាជីវកម្ម និងការអភិវឌ្ឍផលិតផលថ្មីៗ អិលអូអិលស៊ី (ខេមបូឌា) បាននឹងកំពុងវិនិយោគលើគម្រោងធនាគារ ឌីជីថល ដែលនឹងជួយលើកកម្ពស់សេវាអតិថិជន និងបង្កើនប្រសិទ្ធភាពការងារដូចជា Tablet, ATM, Mobile Banking Application និង Third-Party Connection។

ជាលទ្ធផល អិលអូអិលស៊ី បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីធនាគារចល័តរបស់ខ្លួនគឺកម្មវិធី iPay Mobile Application ដែលអនុញ្ញាតឱ្យអតិថិជនអាចពិនិត្យមើលគណនីធនាគាររបស់ខ្លួន និងធ្វើប្រតិបត្តិការបានដោយខ្លួនឯងនៅក្នុងទូរស័ព្ទដៃ ដូចជាពិនិត្យមើលសមតុល្យគណនី របាយការណ៍សង្ខេប ផ្ទេរប្រាក់ ទូទាត់ការចំណាយ បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ បើកគណនីបញ្ញើមានកាលកំណត់ បញ្ជាការទូទាត់តាមកាលកំណត់ គណនាប្រាក់បញ្ញើ គណនាប្រាក់កម្ចី បង្ហាញទីតាំងការិយាល័យ និងព័ត៌មានផ្សេងៗជាដើម។

បន្ថែមលើនេះ អិលអូអិលស៊ី បានដាក់ឱ្យប្រើប្រាស់កាត ATM សម្រាប់បុគ្គលិករបស់ខ្លួននៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ និងគ្រោងដាក់ឱ្យប្រើប្រាស់សម្រាប់អតិថិជនទាំងអស់នៅក្នុងត្រីមាសទី១ ឆ្នាំ២០២០ ដែលអនុញ្ញាតឱ្យអតិថិជនអាចប្រើប្រាស់កាតរបស់ខ្លួននៅគ្រប់ម៉ាស៊ីន ATM របស់គ្រឹះស្ថានដែលជាសមាជិកប្រព័ន្ធ Cambodia Share Switch - CSS។

លើសពីនេះទៀតនៅក្នុងឆ្នាំ២០២០ អិលអូអិលស៊ី នឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធធនាគារ Tablet Banking ដែលអនុញ្ញាតឱ្យបុគ្គលិកឥណទានអនុវត្តការងារ (ដូចជាការវាយតម្លៃឥណទាន ការប្រមូលកម្ចីយឺតយ៉ាវ បើកគណនីបញ្ញើសន្សំ) ពីឧបករណ៍ Tablet Devices ដែលនឹងជួយបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ។

## អត្រាចំណេញពីទ្រព្យសកម្ម និងអត្រាចំណេញពីមូលធនរបស់ភាគទុនិក

អត្រាចំណេញពីទ្រព្យសកម្ម និងអត្រាចំណេញពីមូលធនភាគទុនិករបស់ អិលអូអិលស៊ី កើនឡើងដល់ ៤,២% និង ៣២,១៣% រៀងគ្នានៅក្នុងឆ្នាំ២០១៩។ បើធៀបជាមួយនឹងដៃគូប្រកួតប្រជែង អត្រាចំណេញពីទ្រព្យសកម្មរបស់អិលអូអិលស៊ី ទទួលបានលទ្ធផលល្អឈានមុខគេក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលធំជាងគេទាំង ៧ ខណៈដែលអត្រាចំណេញពីមូលធនភាគទុនិករបស់ អិលអូអិលស៊ី ជាប់លំដាប់ថ្នាក់លេខ ២ ពីរឆ្នាំជាប់គ្នានៅក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ និងឈានមុខគេនៅក្នុងឆ្នាំ២០១៩។ ជាលទ្ធផល អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេលំដាប់ទី ៤ នៅក្នុងប្រទេសកម្ពុជា គិតទៅលើសមតុល្យប្រាក់បញ្ញើ និងផលប័ត្រឥណទាន និងជាប់លំដាប់ទី ៣ នៅក្នុងប្រទេស គិតទៅលើចំនួនអតិថិជន។

## សកម្មភាពសង្គម

អិលអូអិលស៊ី បន្តផ្តល់សេវាហិរញ្ញវត្ថុដែលមានភាពសម្បូរបែប មានការទទួលខុសត្រូវសង្គម និងបរិស្ថាន ដល់ប្រជាជនកម្ពុជានៅជនបទ។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ អតិថិជនឥណទានជាង ៩២% រស់នៅតំបន់ជនបទ ៧០% ជាអតិថិជនស្ត្រី ៣៩% នៃអតិថិជនមានមុខរបរក្នុងវិស័យកសិកម្ម ដែលមិនមានហានិភ័យប៉ះពាល់ទៅលើបរិស្ថានគួរឱ្យកត់សម្គាល់ឡើយ អតិថិជន ១១.០២៤នាក់ មានទីជម្រកសមរម្យ អតិថិជន ៩.៥៩៤នាក់ មានទឹកស្អាតសម្រាប់ប្រើប្រាស់ អតិថិជន ៩.៩៥៧នាក់ មានថាមពលអគ្គិសនីដែលមិនប៉ះពាល់ដល់បរិស្ថានសម្រាប់ប្រើប្រាស់ អតិថិជន ៣៣៦.០០២នាក់ ទទួលបានសេវាប្រាក់បញ្ញើសន្សំ ហើយអតិថិជនប្រមាណ ៣០% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ១៥០% (ដោយប្រើប្រាស់សន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ PPI ដើម្បីវាស់វែងកម្រិតនៃភាពក្រីក្រ)។

ដោយសារការខិតខំប្រឹងប្រែងក្នុងការអនុវត្តតាមស្តង់ដាជាសាកលស្តីពីការគ្រប់គ្រងសកម្មភាពសង្គម (USSPM) អិលអូអិលស៊ី បានធ្វើការវាយតម្លៃពីការគ្រប់គ្រងសកម្មភាពសង្គមរបស់ខ្លួនម្តងទៀតនៅក្នុងឆ្នាំ២០១៩ ដែលវាយតម្លៃដោយស្ថាប័ន Microfinanza និងទទួលបានលទ្ធផលកម្រិត BB+ ដែលជាកម្រិតមួយល្អប្រសើរជាងការវាយតម្លៃកាលពីលើកមុន។ ការវាយតម្លៃនេះត្រូវបានពិនិត្យមើលលើលក្ខខណ្ឌដូចជា ប្រព័ន្ធគ្រប់គ្រងសកម្មភាពសង្គម ការការពារអតិថិជន និងការទទួលខុសត្រូវសង្គម បណ្តាញចែកចាយ និងគុណភាពនៃសេវាកម្ម។

ស្របតាមយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ស្តង់ដានៃការគ្រប់គ្រងសកម្មភាពសង្គមត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ នីតិវិធីការបណ្តុះបណ្តាល វិធីសាស្ត្រក្នុងការផ្តល់ផលិតផល និងសេវាកម្មជូនអតិថិជន និងឧបករណ៍ត្រួតពិនិត្យរបស់គ្រឹះស្ថាន។ ទាំងនេះដោយសារតែគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលយល់ច្បាស់អំពីទស្សនវិស័យដែលថា “ក្រុមហ៊ុនទទួលបានជោគជ័យ លុះត្រាតែអតិថិជនជោគជ័យ”។

បន្ថែមលើនេះផ្នែកគ្រប់គ្រងសកម្មភាពសង្គមរបស់ អិលអូអិលស៊ី បានផ្តល់វគ្គបណ្តុះបណ្តាលអំពីការយល់ដឹងផ្នែកហិរញ្ញវត្ថុលើប្រធានបទ “ការគ្រប់គ្រងហិរញ្ញវត្ថុ” ដល់និស្សិតសាកលវិទ្យាល័យ និងអ្នកទទួលអត្ថប្រយោជន៍នៃគម្រោង ភូមិមួយផលិតផលមួយ (One Village One Product)។ លើសពីនេះទៀត តាមរយៈកម្មវិធីវិទ្យុ “គំនិតរីកចម្រើន” អ្នកស្តាប់អាចទទួលបានចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការការពារអតិថិជន ការលើកទឹកចិត្តខ្លួនឯង និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច ពីវាគ្មិនកិត្តិយស។ ក្នុងអំឡុងឆ្នាំ២០១៩ អិលអូអិលស៊ី ក៏បានបែងចែកថវិកាដើម្បីរួមចំណែកក្នុងសកម្មភាពសង្គមផ្សេងៗទៀតដូចជា ការបរិច្ចាគដល់អតិថិជនដែលរងគ្រោះដោយសារទឹកជំនន់ គាំទ្រក្នុងកម្មវិធីផ្តល់អាហារូបត្ថម្ភជាទឹកដោះគោស្រស់ដល់កុមាររបស់រាជបណ្ឌិតសភាកម្ពុជា បោះពុម្ពខិត្តប័ណ្ណព័ត៌មានអប់រំពី បញ្ហាគ្រឿងញៀន និងគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ចូលរួមឧបត្ថម្ភពិពណ៌សៀវភៅលើកទី ៨ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងចូលរួមឧបត្ថម្ភដល់កាកបាទក្រហមកម្ពុជា ដើម្បីជាការចូលរួមចំណែកសង្គមក្នុងការងារសប្បុរសធម៌របស់កាកបាទក្រហមកម្ពុជា។

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០២០

យើងមើលឃើញឆ្នាំ២០២០ ពោរពេញទៅដោយឱកាសថ្មីៗ និងការប្រកួតប្រជែងសម្រាប់ អិលអូអិលស៊ី។

**ខាងផ្នែកឥណទាន** យើងនឹងបន្តអនុវត្តតាមយុទ្ធសាស្ត្រដែលមានស្រាប់ និងបន្តផ្តោតការយកចិត្តទុកដាក់លើឥណទានខ្នាតតូច និងមធ្យម និងឥណទានប្រើប្រាស់ផ្ទាល់ខ្លួនដែលទទួលយកទ្រព្យដែលទិញជាទ្រព្យដាក់ធានា/ភតិសន្យាហិរញ្ញវត្ថុ ដែលជាអាជីវកម្មចម្បងរបស់ អិលអូអិលស៊ី។

**ខាងផ្នែកប្រាក់បញ្ញើ** យើងនឹងបន្តពង្រឹងសេវាអតិថិជន និងផ្តល់នូវផលិតផល និងសេវាកម្មថ្មីៗសម្បូរបែបទៅតាមតម្រូវការរបស់អតិថិជន រួមមាន គណនីសន្សំសម្រាប់ប្រើប្រាស់ក្នុងគម្រោងពេលអនាគត គណនីសន្សំសម្រាប់បុត្រធីតា និងសេវាទូទាត់វិក្កយបត្រ។

**ខាងផ្នែកឌីជីថល អិលអូអិលស៊ី នឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា** ដែលអាចលើកកម្ពស់សេវាអតិថិជនឱ្យកាន់តែប្រសើរឡើង និងបង្កើនប្រសិទ្ធភាពការងារដូចជា Tablet, ATM និង Third-Party Connection ។

**ខាងផ្នែកមូលនិធិ អិលអូអិលស៊ី នឹងស្វែងរកទុនពីប្រភពផ្សេងៗគ្នា** ដើម្បីធានាភាពគ្រប់គ្រាន់នៃមូលនិធិសម្រាប់គាំទ្រកំណើនឥណទានរបស់ អិលអូអិលស៊ី។ បន្ថែមលើប្រភពទុនពីម្ចាស់ភាគទុនិក កម្ចីពីម្ចាស់កម្ចី និងប្រាក់បញ្ញើរបស់អតិថិជន អិលអូអិលស៊ី បានបោះផ្សាយលក់មូលបត្របំណុល ដើម្បីគាំទ្រនិរន្តរភាពនៃការរីកលូតលាស់របស់ អិលអូអិលស៊ី។

**ខាងផ្នែកសកម្មភាពសង្គម** អិលអូអិលស៊ី នឹងបន្តយកចិត្តទុកដាក់លើសកម្មភាពសង្គម ដើម្បីសម្រេចឱ្យបានតាមគុណតម្លៃរបស់ អិលអូអិលស៊ី ដែលចែងថា “អិលអូអិលស៊ី ឱ្យតម្លៃលើទស្សនវិស័យក្នុងការធ្វើឱ្យតុល្យភាពរវាងកិច្ចការសង្គម និងផលចំណេញ”។ តាមរយៈនេះ អិលអូអិលស៊ី នឹងបន្តផ្តល់ផលិតផល និងសេវាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវសង្គម និងបរិស្ថាន ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់អតិថិជន។ បន្ថែមលើនេះ អិលអូអិលស៊ី នឹងត្រួតពិនិត្យការអនុវត្តក្នុងការលើកកម្ពស់សកម្មភាពសង្គមឱ្យកាន់តែប្រសើរឡើង តាមរយៈការបញ្ចូលសកម្មភាពសង្គមទៅក្នុងប្រតិបត្តិការអាជីវកម្ម ដោយប្រើប្រាស់ USSPM, SPI4, ការវាយតម្លៃបរិស្ថាន និងសង្គមសម្រាប់ឥណទានខ្នាតតូច និងមធ្យម និងការការពារអតិថិជន។ លើសពីនេះទៅទៀត អិលអូអិលស៊ី នឹងបន្តកម្មវិធីវិទ្យុ “គំនិតរីកចម្រើន” ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនកម្ពុជាលើចំណេះដឹងផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ។

សរុបជារួមមក យើងនឹងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការចាប់យកឱកាសជោគជ័យ ហើយយើងជឿជាក់ថា អិលអូអិលស៊ី នឹងអាចនាំមកនូវតម្លៃបន្ថែមទៀតដល់អតិថិជន វិនិយោគិន និងម្ចាស់ភាគទុនិក។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរគុណដល់ភាគទុនិកក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការទាំងអស់ សម្រាប់ការដឹកនាំ ការគាំទ្រ និងការផ្តល់ដំបូន្មាននានាក្នុងមួយឆ្នាំកន្លងទៅនេះ។ ខ្ញុំបាទក៏សូមបង្ហាញនូវការដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះបុគ្គលិក អិលអូអិលស៊ី ទាំងអស់សម្រាប់ការខិតខំប្រឹងប្រែងបំពេញការងារអស់ពីកម្លាំងកាយចិត្ត និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញការងារប្រកបដោយសុចរិតភាព ក្រមសីលធម៌ វិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះអតិថិជន វិនិយោគិន និងដៃគូពាក់ព័ន្ធដែលតែងតែគាំទ្រ អិលអូអិលស៊ី ដើម្បីភាពរីកចម្រើនទាំងអស់គ្នា។ បន្ថែមលើនេះ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា សម្រាប់ការគាំទ្រនៅក្នុងឆ្នាំ២០១៩ និងជោគជ័យដែលរំពឹងទុកនៅឆ្នាំបន្តបន្ទាប់ទៀត។



សុខ ជឿន
ប្រធាននាយកប្រតិបត្តិ

# អំពី អិលអូអិលស៊ី




- ចក្ខុវិស័យប្រទេសកម្ពុជា
- អំពី អិលអូអិលស៊ី
- ប្រវត្តិ អិលអូអិលស៊ី
- ម្ចាស់កម្មី និងដៃគូ
- សកម្មភាពចម្បងរបស់ អិលអូអិលស៊ី

# ចក្ខុវិស័យប្រទេសកម្ពុជា

## ភូមិសាស្ត្រ និងប្រជាសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយនៅក្នុងតំបន់ត្រូពិច ជាសមាជិកនៃមហាអនុតំបន់ទន្លេមេគង្គ សមាជិកប្រទេសអាស៊ានចាប់តាំងពីឆ្នាំ ១៩៩៩ និងជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ចាប់តាំងពីឆ្នាំ២០០៤ ទទួលបានប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់សហរដ្ឋអាមេរិក (GSP) ចាប់តាំងពីឆ្នាំ១៩៩៧ និងទទួលបានប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធ (EBA) ពីសហភាពអឺរ៉ុបចាប់តាំងពីឆ្នាំ ២០០១។ ភូមិសាស្ត្រប្រទេសកម្ពុជា មានភាពអំណោយផល និងសម្បូរទៅដោយប្រភពទឹក ធនធានធម្មជាតិ ទេសចរណ៍ធម្មជាតិ (ភ្នំ ឆ្នេរខ្សាច់ ព្រៃព្រឹក្សា និងសត្វព្រៃ) និងទេសចរណ៍វប្បធម៌ ដូចជាប្រាង្គប្រាសាទជាដើម។ យោងទៅលើជំរឿននៅក្នុងឆ្នាំ ២០១៩ ប្រទេសកម្ពុជា មានប្រជាជនប្រមាណជាង ១៦,៥លាននាក់ (១៥,៣លាននាក់រស់នៅក្នុងប្រទេស និងប្រមាណជាជាង ១,២លាននាក់បានធ្វើចំណាកស្រុក) និងបន្តកើនឡើងជាមួយអត្រាកំណើន ១,២% ប៉ុន្តែអ្វីដែលសំខាន់គឺប្រទេសកម្ពុជា ជាប្រទេសដែលមានប្រជាជនវ័យក្មេងជាងគេនៅលើពិភពលោក ដែលជាងពាក់កណ្តាលនៃប្រជាជនមានអាយុក្រោម២៥ឆ្នាំ។

## ម៉ាក្រូសេដ្ឋកិច្ច

ធនាគារជាតិនៃកម្ពុជា ព្រមទាំងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសរុបទិន្នន័យកំណើនផលិតផលក្នុងស្រុកសរុបចំនួន ៧,១% នៅក្នុងឆ្នាំ២០១៩ ខណៈដែលអត្រាអតិផរណាមានចំនួន ១,៩%។ ផលិតផលក្នុងស្រុកសរុបកម្ពុជារួមមាន៖ ១. វិស័យឧស្សាហកម្ម (៣៨,៣%) ក្នុងនោះរួមមានសំណង់ វាយនភ័ណ្ឌ សម្លៀកបំពាក់ និងធនធានរ៉ែជាដើម ២. សេវាសកម្ម (៣៨,១%) ក្នុងនោះរួមមានទេសចរណ៍ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាដើម និង ៣. កសិកម្ម (១៦,១%)។

ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់កើនឡើងដល់ប្រមាណ ១,៦៥០ដុល្លារអាមេរិក ដែលធ្វើអោយប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបព្រោះជាតួលេខលើសកម្រិតកំណត់របស់ធនាគារពិភពលោកដែលមានចំនួនត្រឹមតែ ១,០៤៥ដុល្លារអាមេរិក។ ប្រទេសកម្ពុជា ត្រូវបានគេទទួលស្គាល់ថាជាសេដ្ឋកិច្ចដុល្លាររូបនីយកម្ម។ យ៉ាងណាមិញអត្រាប្តូររូបិយប័ណ្ណរវាងប្រាក់រៀល និងប្រាក់ដុល្លារនៅរក្សាស្ថេរភាពល្អក្នុងរយៈពេលជាងមួយទស្សវត្សចុងក្រោយនេះ។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩ អត្រាប្តូរប្រាក់មានចំនួន ៤,០៥៥រៀល ក្នុង ១ដុល្លារអាមេរិក ដោយផ្អែកលើរបាយការណ៍ប្រចាំឆ្នាំចេញផ្សាយដោយ ធនាគារជាតិនៃកម្ពុជា។ នៅក្នុងឆ្នាំ២០២០ ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករណ៍កំណើនផលិតផលក្នុងស្រុកសរុបចំនួន ៦,៥% ខណៈអត្រាអតិផរណាមានចំនួន ២,៥% ។

## វិស័យមីក្រូហិរញ្ញវត្ថុ

ក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា សម្រេចបានកំណើនផលប័ត្រឥណទានចំនួន ៣៣,១៦% ដែលមានចំនួនកើនឡើងដល់ ៧,៥ ប៊ីលានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៩ និងអត្រាផលប័ត្រឥណទានមានហានិភ័យ ០,៨១%។ ជាមធ្យមអតិថិជនម្នាក់មានប្រាក់កម្ចីចំនួន ៣,០០០ដុល្លារអាមេរិក ហើយអតិថិជនសរុបចំនួនរហូតដល់ជិត ២,២៥លាននាក់។ បច្ចុប្បន្នមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំៗចំនួន ៧ (ប្រាំពីរ) ដែលទទួលបានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីអតិថិជន។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ អតិថិជនប្រាក់បញ្ញើមានចំនួនជិត ៣លាននាក់នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាមួយសមតុល្យប្រាក់បញ្ញើ ៣,៨ប៊ីលានដុល្លារអាមេរិក។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា មានលក្ខណៈទូលំទូលាយដែលអាចផ្តល់សេវាដល់អតិថិជននៅទូទាំងប្រទេស និងមានផលិតផលប្រកបដោយភាពច្នៃប្រឌិតទាំងផ្នែក ឌីជីថល និងភាពសម្បូរបែបនៃផលិតផលដូចជាផលិតផលកម្ចីដែលមិនមានទ្រព្យដាក់ធានាភតិសន្យាហិរញ្ញវត្ថុ ផលិតផលកម្ចីសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដែលទទួលយកសម្ភារដែលទិញជាទ្រព្យដាក់ធានា ផលិតផលកម្ចីសហគ្រាសខ្នាតតូច និងមធ្យម និងផលិតផលកម្ចីសម្រាប់កសិកម្មជាដើម។ ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទាំង៧បានចាប់យក ៨៥% នៃចំណែកទីផ្សារផលប័ត្រឥណទាន។ លើសពីនេះទៅទៀត និន្នាការនៃបច្ចេកវិជ្ជាទំនើប Fin-Tech ក៏មានប្រជាប្រិយភាពផងដែរនៅក្នុងវិស័យនេះ ដូចជា៖ សេវាធនាគារចល័តសេវាទូទាត់វិក្កយប័ត្រ និងសេវាប្រាក់កម្ចីតាមបែបឌីជីថល។

**បន្សំនៃផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៩**



## អំពី អិលអូអិលស៊ី

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើស្របច្បាប់ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដោយផ្តោតសំខាន់ទៅលើការបម្រើសេវាដល់សហគ្រិន និងក្រុមគ្រួសារដែលស្ថិតនៅកម្រិតមូលដ្ឋានពីរ៉ាមីតនៃសេដ្ឋកិច្ចសង្គម នូវឱកាសសេដ្ឋកិច្ច ដើម្បីផ្លាស់ប្តូរជីវភាពរស់នៅរបស់ពួកគាត់។ បច្ចុប្បន្ន LOLC Private Limited កាន់កាប់ភាគហ៊ុនចំនួន ៩៦,៩៧% នៃចំនួនហ៊ុនសរុបរបស់ អិលអូអិលស៊ី (ខេមបូឌា) ហើយភាគហ៊ុនដែលនៅសល់ត្រូវបានកាន់កាប់ដោយក្រុមហ៊ុនបុគ្គលិក អិលអូអិលស៊ី ហៅកាត់ថា ធីភីស៊ី-អ៊ីសុប Employee Stock Ownership Plan (TPC-ESOP)។

អិលអូអិលស៊ី ត្រូវបានបង្កើតឡើងដោយអង្គការ Catholic Relief Services ហៅកាត់ថា (“CRS”) ក្នុងឆ្នាំ១៩៩៤ និងត្រូវបានចុះបញ្ជីក្រោមឈ្មោះ ធនាគារភូមិ (ខេមបូឌា) អិលធីឌី ក្នុងឆ្នាំ២០០២។ បន្ទាប់មកធនាគារភូមិ ទទួលបានអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា ក្នុងការធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្នុងឆ្នាំ២០០៣។ ជាមួយនឹងភាគទុនិកដ៏រឹងមាំ រួមមាន Developing World Markets (“DWM”) និង LOLC Micro Investment Ltd. (“LOMI”) នៅក្នុងឆ្នាំ២០១៥ ធនាគារភូមិ (ខេមបូឌា) អិលធីឌី បានប្តូរឈ្មោះមកជាឈ្មោះអន្តរជាតិ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី និងទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើ ពីធនាគារជាតិនៃកម្ពុជា ក្នុងពេលជាមួយគ្នា។ នៅក្នុងឆ្នាំ២០១៨ LOLC Private Limited បានទិញភាគហ៊ុនចំនួន ៣៦,៩៧% ពី Developing World Market (“DWM”) និង ៦០% ពី LOLC Micro Investment Ltd. (“LOMI”) ដែលជាលទ្ធផល LOLC Private Limited កាន់កាប់ភាគហ៊ុនចំនួន ៩៦,៩៧% នៃចំនួនហ៊ុនសរុបរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។

បច្ចុប្បន្ន អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំជាងគេលំដាប់ទី៤ នៅក្នុងប្រទេសកម្ពុជា គិតទៅលើសមតុល្យប្រាក់បញ្ញើ និងផលប័ត្រឥណទាន និងជាប់លំដាប់ទី៣ បើគិតលើចំនួនអតិថិជន។ តាមរយៈ បណ្តាញការិយាល័យចំនួន ៧៩ នៅទូទាំងប្រទេស អិលអូអិលស៊ី បាននឹងកំពុងបម្រើអតិថិជនជាង ២៩៤,០០០ នាក់ ជាមួយនឹងផលប័ត្រឥណទានប្រមាន ៧៧២ លានដុល្លារអាមេរិក។ ចាប់តាំងពីទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើ នៅក្នុងឆ្នាំ២០១៥ អិលអូអិលស៊ី បានពង្រីកផលិតផល និងសេវាហិរញ្ញវត្ថុរបស់ខ្លួន ដោយបានបញ្ចូលផលិតផលប្រាក់បញ្ញើសន្សំ និងផលិតផលប្រាក់បញ្ញើសន្សំមានកាលកំណត់។ ក្នុងឆ្នាំ២០១៦ អិលអូអិលស៊ី បានដាក់ឱ្យប្រើប្រាស់ ផលិតផលប្រាក់បញ្ញើសន្សំ ទៅគ្រប់សាខាទាំងអស់ទូទាំងប្រទេស ដែលជាលទ្ធផលទទួលបានជោគជ័យគួរជាទីគាប់ចិត្ត និងសម្រេចបានសមតុល្យប្រាក់បញ្ញើជាង ៤៥៨លានដុល្លារអាមេរិក គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩ ក្នុងរយៈពេលត្រឹមតែបួនឆ្នាំ ដែលកើនឡើងពីសមតុល្យជាង ១៩លានដុល្លារអាមេរិក នៅត្រឹមដំណាច់ឆ្នាំ២០១៦។ កំណើនយ៉ាងឆាប់រហ័សនៃសមតុល្យប្រាក់បញ្ញើសន្សំ បង្ហាញឱ្យឃើញថា អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលគួរឱ្យទុកចិត្តខ្ពស់ ដែលផ្តល់នូវសេវាហិរញ្ញវត្ថុដ៏ល្អប្រសើរដល់អតិថិជន ការពារអតិថិជន និងផ្តល់នូវផលិតផលប្រាក់បញ្ញើ និងផលិតផលឥណទានថ្មីៗដែលមានលក្ខណៈប្រកួតប្រជែង។

តទៅមុខទៀត អិលអូអិលស៊ី នឹងបន្តពង្រីកប្រតិបត្តិការរបស់ខ្លួននៅជនបទ និងទីប្រជុំជន អភិវឌ្ឍផលិតផល និងសេវាហិរញ្ញវត្ថុថ្មីៗ សម្រាប់បំពេញតម្រូវការរបស់អតិថិជន ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ ដែលនឹងជួយលើកកម្ពស់សេវាអតិថិជន បង្កើនប្រសិទ្ធភាព និងផលិតភាព។ ជាមួយនឹងគណៈគ្រប់គ្រងដែលមានបទពិសោធន៍ខ្ពស់ អភិបាលកិច្ចដ៏រឹងមាំ និងការប្តេជ្ញាចិត្តក្នុងសកម្មភាពសង្គម អិលអូអិលស៊ី បានត្រៀមខ្លួនជាស្រេចក្នុងការបន្តពង្រីកប្រតិបត្តិការ និងឥទ្ធិពលរបស់ខ្លួននៅទូទាំងប្រទេស។

## ប្រវត្តិ អិលអូអិលស៊ី

កំណត់ត្រារយៈពេល ២៦ឆ្នាំ ក្នុងការផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ ដែលមានការទទួលខុសត្រូវផ្នែកសង្គមនៅក្នុងប្រទេសកម្ពុជា។



# ម្ចាស់កម្ចី និងដៃគូ

Industrial and Commercial Bank of China Limited

ធនាគារ ស្ថាបនា ភីអិលស៊ី

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់

ធនាគារ ភ្នំពេញ ពាណិជ្ជ

ធនាគារ វឌ្ឍនៈ

responsAbility

Oikocredit

Cyrano-Management

Overseas Private Investment Corporation

Symbiotics SA

Incofin Invesment Management

Instituto de Crédito Oficial

BlueOrchard

PPB (People's Bank)

ធនាគារពាណិជ្ជទីមួយ

ធនាគារ ចិន (ហុងកុង)

Deutsche Bank

Chailease International Finance Corp.

The Shangha | Commercial & Savings Bank. LTD,

MicroVest Purposeful Investing

Fonds Desjardins

KCD-Mikrofinanzfonds

Developing World Markets

Grameen Crédit Agricole

Agence Française de Développement

FMO

MCE Social Capital

Triple Jump BV

Hatton National Bank

Alterfin c.v.b.a.

PG Impact

ធនាគារ សហពាណិជ្ជ ក.អ

ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

Nordic Microfinance Initiative

ធនាគារឯកទេស ខេមខូ

WaterEquity

J Trust Royal Bank

TAISHIN INTERNATIONAL BANK

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

ការិយាល័យឥណទានកម្ពុជា (ស៊ីប៊ីស៊ី)

The Smart Campaign

Agence Française de Développement

Water.org

Microcredit Summit Campaign

USAID

ធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត

MIX Market

# សកម្មភាពចម្បងរបស់ អិលអូអិលស៊ី

អិលអូអិលស៊ី ទទួលបានអាជ្ញាប័ណ្ណពី ធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់សេវាប្រាក់កម្ចី និងប្រាក់បញ្ញើ ដល់សាធារណជន។ បច្ចុប្បន្ន អិលអូអិលស៊ី កំពុងផ្តល់សេវាសម្បូរបែបជាច្រើនដូចជា ប្រាក់កម្ចីដែលមិនមានការធានា ប្រាក់កម្ចីដែលមានការធានា ភតិសន្យាហិរញ្ញវត្ថុ ប្រាក់កម្ចីសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដែលទទួលយកសម្ភារដែលទិញជាទ្រព្យដាក់ធានា គណនីប្រាក់បញ្ញើសន្សំ គណនីប្រាក់បញ្ញើមានកាលកំណត់ សេវាផ្ទេរប្រាក់ និងសេវាធនាគារចល័ត។

| ខែធ្នូ ឆ្នាំ ២០១៩ | ផលប័ត្រឥណទាន (ដុល្លារអាមេរិក) | ចំនួនអតិថិជនឥណទាន |
|---|---|---|
| ប្រាក់កម្ចីមិនមានការធានា | ៨៧,៧២៨,៦៩៨ | ១៤២,៣៥៣ |
| ប្រាក់កម្ចីមានការធានា | ៥៨៧,៤៣៣,៧៨២ | ១៥៤,៨៩១ |
| ភតិសន្យាហិរញ្ញវត្ថុ | ៤២៧,១៩៨ | ៣៥៩ |
| ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួនដែលទទួលយកសម្ភារដែលទិញជាទ្រព្យដាក់ធានា | ១០២,៩៦៧,៨០៩ | ៤១,៤៤២ |

| ខែធ្នូ ឆ្នាំ ២០១៩ | សមតុល្យប្រាក់បញ្ញើ (ដុល្លារអាមេរិក) | ចំនួនអតិថិជនដាក់ប្រាក់បញ្ញើ |
|---|---|---|
| គណនីប្រាក់បញ្ញើសន្សំ | ៤០,៧៤៨,១០២ | ៣៣៥,៩៧១ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ៤០៧,៧៥៩,១០១ | ៤,៧៨១ |













LA
CHRONIQUE

# អំពី អាជីវកម្ម




- ការរីកចម្រើនប្រកបដោយការទទួលខុសត្រូវ
- និន្នាការនៃផលិតផល
- សមិទ្ធផលអាជីវកម្ម
- សេចក្ដីសង្ខេបអំពីសមិទ្ធផលហិរញ្ញវត្ថុ
- ទស្សនវិស័យអំពីអតិថិជន
- ការអភិវឌ្ឍធនធានមនុស្ស

## ការរីកចម្រើនប្រកបដោយការទទួលខុសត្រូវ

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដោយសំខាន់លើការផ្តល់សេវាហិរញ្ញវត្ថុដល់សហគ្រិន និងក្រុមគ្រួសារនៅកម្រិតមូលដ្ឋានពីរ៉ាមីតនៃសេដ្ឋកិច្ចសង្គម នូវឱកាសសេដ្ឋកិច្ចដើម្បីផ្លាស់ប្តូរជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។ ជាមួយនឹងសេវាហិរញ្ញវត្ថុរបស់ អិលអូអិលស៊ី ក្រុមគ្រួសារនៅកម្រិតមូលដ្ឋានពីរ៉ាមីតនៃសេដ្ឋកិច្ចសង្គម ទទួលបាននូវសក្តានុពលភាពដើម្បីរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ សុវត្ថិភាពសេដ្ឋកិច្ច សុវត្ថិភាពសង្គម និងយុត្តិធម៌។ បច្ចុប្បន្ន អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលធំជាងគេបំផុតលំដាប់លេខ៣ នៅក្នុងព្រះរាជាណាចក្រកម្ពុជា បើគិតទៅលើចំនួនអតិថិជន និងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលធំជាងគេបំផុតលំដាប់លេខ៤ បើគិតទៅលើផលប័ត្រឥណទាន និងសមតុល្យប្រាក់បញ្ញើ។ អិលអូអិលស៊ី បន្តប្តេជ្ញាចិត្តក្នុងការបម្រើសេវាដល់អតិថិជន ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដោយផ្តោតសំខាន់ទៅលើ សេវាអតិថិជន ការផ្តល់ជូននូវផលិតផលថ្មីៗ ការរក្សាតម្លៃសមរម្យ និងតម្លាភាព។ ដោយហេតុនេះហើយ ទើបធ្វើឱ្យ អិលអូអិលស៊ី ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានទំនុកចិត្តយ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជា ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ និងសេវាផ្សេងៗទៀត។ ការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី បានបង្ហាញឱ្យឃើញយ៉ាងច្បាស់តាមរយៈការអភិវឌ្ឍផលិតផលថ្មីៗ ដើម្បីបំពេញតម្រូវការរបស់អតិថិជន ការបង្កើតនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងដែលមានប្រសិទ្ធភាព និងកម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលមានគោលបំណងផ្តល់ចំណេះដឹង និងបទពិសោធន៍ផ្នែកហិរញ្ញវត្ថុដល់អតិថិជន។

ផលប័ត្រឥណទានរបស់ អិលអូអិលស៊ី កើនឡើងចំនួន ៦០% ពីសមតុល្យឥណទានសរុបចំនួនជាង ៤៨៤លានដុល្លារអាមេរិក នៅដំណាច់ឆ្នាំ២០១៨ ទៅជាង ៧៧២លានដុល្លារអាមេរិក នៅដំណាច់ឆ្នាំ២០១៩។ អិលអូអិលស៊ី នៅតែអាចរក្សាកំណើនឥណទានប្រកបដោយគុណភាព និងកម្រិតហានិភាពទាប ដោយសម្រេចបាននូវលទ្ធផលល្អប្រសើរជាងអត្រាហានិភ័យជាមធ្យមរបស់វិស័យហិរញ្ញវត្ថុទាំងមូល។ ផលិតផលប្រាក់បញ្ញើរបស់ អិលអូអិលស៊ី ក៏សម្រេចបាននូវលទ្ធផលដ៏ល្អប្រសើរផងដែរ ដោយសមតុល្យបាក្រប់បញ្ញើ មានការកើនឡើងយ៉ាងឆាប់រហ័សដល់ចំនួនជាង ៤៥៨លានដុល្លារអាមេរិក ក្នុងរយៈពេលត្រឹមតែ ៤ឆ្នាំ គឺកើនឡើងជិត ២ដង នៃសមតុល្យប្រាក់បញ្ញើក្នុងឆ្នាំ២០១៨ ដែលមានចំនួនត្រឹមតែជាង ២៣៧លានដុល្លារអាមេរិក។ កំណើនដ៏ឆាប់រហ័សនៃសមតុល្យប្រាក់បញ្ញើ និងសមតុល្យឥណទាន បង្ហាញឱ្យឃើញថា អិលអូអិលស៊ី ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្តបំផុតពីសំណាក់អតិថិជនក្នុងការផ្តល់សេវាហិរញ្ញវត្ថុដ៏ល្អប្រសើរ ការការពារអតិថិជន តម្លាភាព ការទទួលខុសត្រូវខ្ពស់ និងការផ្តល់នូវផលិតផលប្រាក់បញ្ញើ និងផលិតផលឥណទានថ្មីៗដែលមានលក្ខណៈប្រកួតប្រជែង។

អត្រាចំណេញពីទ្រព្យសកម្ម (ROA) របស់ អិលអូអិលស៊ី មានការធ្លាក់ចុះបន្តិចពី ៣,១៩% ក្នុងឆ្នាំ២០១៨ ទៅ ៤,២០% ក្នុងឆ្នាំ២០១៩ ខណៈអត្រាចំណេញពីមូលធនភាគទុនិក (ROE) កើនឡើងបន្តិច ពី ២២,៩៤% ទៅ ៣២,១៣%។ យ៉ាងណាមិញបើធៀបទៅនឹងដៃគូប្រកួតប្រជែង អត្រាចំណេញពីទ្រព្យសកម្មរបស់ អិលអូអិលស៊ី ទទួលបានលទ្ធផលល្អជាងគេក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំៗទាំង៧ ខណៈដែលអត្រាចំណេញពីមូលធនភាគទុនិករបស់ អិលអូអិលស៊ី ជាប់លំដាប់លេខ២។ ជាលទ្ធផល អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលធំជាងគេបំផុតលំដាប់លេខ៣ នៅក្នុងព្រះរាជាណាចក្រកម្ពុជា បើគិតទៅលើចំនួនអតិថិជន និងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលធំជាងគេបំផុតលំដាប់លេខ៤ បើគិតទៅលើផលប័ត្រឥណទាន និងសមតុល្យប្រាក់បញ្ញើ។

មិនតែប៉ុណ្ណោះ ការប្តេជ្ញាចិត្តដ៏យូរអង្វែងរបស់ អិលអូអិលស៊ី ក្នុងការការពារអតិថិជនពីការជំពាក់បំណុលវ័ណ្ឌករ និងការបម្រើអតិថិជនដោយស្មើភាព ត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈការអនុវត្តយ៉ាងហ្មត់ចត់នូវគោលនយោបាយឥណទាន និងគោលនយោបាយឥណទានត្រួតគ្នាដែលត្រូវបានជម្រុញ និងយកចិត្តទុកដាក់បំផុត តាមរយៈការអនុវត្តដ៏ខ្ជាប់ខ្ជួននូវគោលការណ៍ការពារអតិថិជននៅក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ។ អិលអូអិលស៊ី ក៏បានចាត់វិធានការមួយចំនួនផងដែរដើម្បីឆ្ពោះទៅការគ្រប់គ្រងសកម្មភាពសង្គម ឱ្យមានប្រសិទ្ធភាពដូចជា ការត្រួតពិនិត្យតាមដានផលប៉ះពាល់ទៅលើបរិស្ថាន ការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថានសម្រាប់ផលិតផលឥណទានសហគ្រាសខ្នាតតូច និងមធ្យម ការអនុវត្តស្តង់ដារជាសាកលនៃការគ្រប់គ្រងសកម្មភាពសង្គម (USSPM) ការផ្តល់កម្ចី Green Lending កម្ចីទឹកស្អាត និងអនាម័យ (WASH Loan) និងការវាយតម្លៃផ្ទាល់ខ្លួន (SPI4) ដើម្បីកំណត់ជំហានបន្ទាប់នៃការអនុវត្តសកម្មភាពសង្គមឱ្យបានល្អប្រសើរក្នុងគ្រឹះស្ថាន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អិលអូអិលស៊ី សម្រេចបានជោគជ័យ និងទទួលបានវិញ្ញាបនបត្រទទួលស្គាល់ជាច្រើនលើការអនុវត្តសកម្មភាពសង្គមដូចជា វិញ្ញាបនបត្រសន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ វិញ្ញាបនបត្រ GIIRS វិញ្ញាបនបត្របញ្ជាក់ឡើងវិញពីកិច្ចការពារអតិថិជនពី SMART Campaign ដែលត្រូវបានវាយតម្លៃដោយ M-GRIL វិញ្ញាបនបត្រចំណាត់ថ្នាក់ផ្នែកសង្គម (Social Rating) ក្នុងលំដាប់ពិន្ទុ BB+ និងវិញ្ញាបនបត្រចំណាត់ថ្នាក់ ផ្នែកហិរញ្ញវត្ថុ (Financial Rating) ក្នុងលំដាប់ពិន្ទុ A ពី Microfinanza ដែលបានវាយតម្លៃ អិលអូអិលស៊ី ទៅលើផ្នែកជាច្រើនដូចជាទៅលើបរិយាកាសប្រកួតប្រជែងខាងក្រៅ អភិបាលកិច្ចនិងយុទ្ធសាស្ត្រ របាយការណ៍ហិរញ្ញវត្ថុ គុណភាពផលប័ត្រឥណទាន ប្រព័ន្ធនិងត្រួតពិនិត្យ និងកិច្ចការពារអតិថិជន។ លើសពីនេះទៀត កម្មវិធីអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដែលត្រូវបានផ្តល់ជូនទាំងអតិថិជន ដៃគូ និងប្រជាពលរដ្ឋនៅតាមសហគមន៍ តាមរយៈការបណ្តុះបណ្តាលដោយផ្ទាល់ និងកម្មវិធីវិទ្យុ “គំនិតរីកចម្រើន”។ គោលបំណងអប់រំរបស់កម្មវិធី គំនិតរីកចម្រើន គឺផ្ញើរសារចំណេះដឹងហិរញ្ញវត្ថុ ការការពារអតិថិជន និងការគ្រប់គ្រងអាជីវកម្មខ្នាតតូចទៅដល់អតិថិជននៅតាមជនបទ។ ការផ្តួចផ្តើមឱ្យមានអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុនេះ គឺជាការចូលរួមចំណែកក្នុងការកាត់បន្ថយហានិភ័យរបស់អតិថិជន និងធានាថា អិលអូអិលស៊ី បានបម្រើអតិថិជនប្រកបដោយតម្លាភាព និងយុត្តិធម៌។

សរុបសេចក្តីមក ប្រតិបត្តិការអាជីវកម្ម និងគម្រោងផែនការរបស់ អិលអូអិលស៊ី ត្រូវបានគាំទ្រតាមរយៈការបង្កើនចំនួនបុគ្គលិកពី ២.៣២៧នាក់ ក្នុងឆ្នាំ២០១៨ ទៅ ២.៧៥៧នាក់ ក្នុងឆ្នាំ២០១៩ ហើយ អិលអូអិលស៊ី មានបណ្តាញប្រតិបត្តិការចំនួន ៧៩សាខា ក្នុងឆ្នាំ២០១៩ ដែលកំពុងធ្វើប្រតិបត្តិការនៅ ២៥រាជធានី-ខេត្ត ទូទាំងប្រទេស។ បុគ្គលិក អិលអូអិលស៊ី សុទ្ធតែទទួលបាននូវការបណ្តុះបណ្តាលពីគោលនយោបាយឥណទាន និងគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុង ដើម្បីឱ្យ អិលអូអិលស៊ី បន្តការរីកចម្រើនទាំងកំណើនផលប័ត្រឥណទាន សមតុល្យប្រាក់បញ្ញើ សេវាហិរញ្ញវត្ថុផ្សេងៗ ប្រកបដោយគុណភាព និងការទទួលខុសត្រូវ។

## និន្នាការនៃផលិតផល

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អិលអូអិលស៊ី បានពង្រឹង និងបង្កើតផលិតផលផ្សេងៗជាច្រើន ដើម្បីបំពេញតម្រូវការរបស់អតិថិជនឱ្យបានកាន់តែទូលំទូលាយ។ បេសកកម្មរបស់ អិលអូអិលស៊ី ក្នុងការផ្ដល់សក្ដានុពលភាពដល់ប្រជាជនដែលស្ថិតនៅ មូលដ្ឋានពីរ៉ាមីតនៃសេដ្ឋកិច្ចសង្គម គឺជាចំណុចដ៏ចម្បងមួយដែលត្រូវបានយកមកអនុវត្តក្នុងការបង្កើត និងអភិវឌ្ឍផលិតផល។ លើសពីនេះទៅទៀត អិលអូអិលស៊ី នឹងព្យាយាមផ្ដល់សេវាហិរញ្ញវត្ថុដល់អតិថិជនប្រកបដោយការបត់បែន និងលុបបំបាត់ឧបសគ្គនានាដែលរាំងស្ទះដល់ការផ្ដល់សេវាកម្មនេះសំដៅពង្រីកការផ្ដល់ឥណទាន ការប្រមូលប្រាក់បញ្ញើ និងអភិវឌ្ឍផលិតផលផ្សេងៗទៀត ដើម្បីបំពេញទៅតាមតម្រូវការរបស់អតិថិជន។

ផលិតផលប្រាក់កម្ចីក្រុមរបស់ អិលអូអិលស៊ី នៅតែជាផលិតផលកម្ចីស្នូលដែលត្រូវបានបង្កើតឡើងយ៉ាងល្អបំផុត និងមានលក្ខខណ្ឌងាយស្រួលសម្រាប់បំពេញតម្រូវការរបស់អតិថិជនដែលភាគច្រើនស្ថិតនៅជនបទ។ បច្ចុប្បន្ន ផលិតផលប្រាក់កម្ចីក្រុម មានផលប័ត្រឥណទានចំនួន ១១% នៃផលប័ត្រឥណទានសរុប និងមានអតិថិជនចំនួន ៤២% នៃអតិថិជនសរុបរបស់ អិលអូអិលស៊ី។ ថ្វីត្បិតតែផលិតផលកម្ចីនេះបានបំពេញមុខងារយ៉ាងល្អ និងធ្វើឱ្យអតិថិជនជាច្រើនមានការពេញចិត្តខ្លាំងយ៉ាងណាក៏ដោយក៏យើងនៅតែបន្តរកវិធិសាស្រ្ត ដើម្បីបង្កើនគុណភាពផលិតផលនេះឱ្យកាន់តែល្អប្រសើរជាលំដាប់។ នៅក្នុងឆ្នាំ ២០១៩នេះ អិលអូអិលស៊ី ក៏បានបង្កើនទំហំឥណទានសម្រាប់ផលិតផលកម្ចីនេះផងដែរ ដើម្បីបំពេញតម្រូវការរបស់ប្រជាជននៅក្នុងសហគមន៍។

ក្រៅពីផលិតផលប្រាក់កម្ចីក្រុម អិលអូអិលស៊ី ក៏នៅមានផលិតផលប្រាក់កម្ចីឯកត្តជនជាច្រើនប្រភេទផងដែរ ដែលផលិតផលប្រាក់កម្ចីឯកត្តជនមានគោលដៅ និងលក្ខខណ្ឌផ្សេងគ្នាពីផលិតផលប្រាក់កម្ចីក្រុម។ ផលិតផលប្រាក់កម្ចីឯកត្តជនទាំងអស់មានផលប័ត្រឥណទានសរុបចំនួន ៨៩% នៃផលប័ត្រឥណទានសរុប និងមានអតិថិជនចំនួន ៥៨% នៃចំនួនអតិថិជនសរុប។ ជាមួយនឹងទំហំឥណទានធំជាងមុន ផលិតផលប្រាក់កម្ចីឯកត្តជន មានគោលបំណងផ្ដល់ប្រភពហិរញ្ញវត្ថុកាន់តែរឹងមាំដល់អតិថិជនទូទៅដូចជា កសិករ កម្មករ បុគ្គលិកអង្គការស្ថាប័ន ពាណិជ្ជករ និងសហគ្រិន ដើម្បីបង្កើត និងពង្រីកអាជីវកម្មបន្ថែម។ ផលិតផលប្រាក់កម្ចីតាមរដូវកាល មានគោលបំណងផ្ដល់លទ្ធភាពឱ្យអតិថិជនដែលមានសកម្មភាពអាជីវកម្មពាក់ព័ន្ធនឹងវិស័យកសិកម្មសម្រាប់ទិញវត្ថុធាតុដើមក្នុងការដាំដុះ និងត្រូវបង់សងនៅពេលប្រមូលផល។ ផលិតផលប្រាក់កម្ចីសហគ្រាសខ្នាតតូច និងមធ្យម មានទំហំឥណទានអតិបរមារហូតដល់ ៧០.០០០ដុល្លារអាមេរិក ដែលអាចផ្ដល់ដើមទុនដល់អ្នកធ្វើអាជីវកម្មខ្នាតតូច និងមធ្យម ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន។

អិលអូអិលស៊ី ក៏បានផ្ដល់ផលិតផលប្រាក់កម្ចីកែលម្អគេហដ្ឋានដែលមានទំហំរហូតដល់ ២០.០០០ដុល្លារអាមេរិក និងផលិតផលប្រាក់កម្ចីគេហដ្ឋាន ដែលមានទំហំឥណទានរហូតដល់ ១០០.០០០ ដុល្លារអាមេរិក ផងដែរ ដែលផ្ដល់ឱកាសដល់អតិថិជនក្នុងការកែលម្អគេហដ្ឋានពួកគេឱ្យបានល្អប្រសើរ សាងសង់គេហដ្ឋានថ្មី ឬទិញផ្ទះថ្មីដើម្បីបំពេញតម្រូវការរបស់អតិថិជនដែលមានការកើនឡើង ដោយពុំចាំបាច់ប្រើប្រាស់សាច់ប្រាក់សម្រាប់អាជីវកម្ម។

ស្រដៀងគ្នានេះផងដែរ ផលិតផលប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួនត្រូវបានផ្ដល់ជូនអតិថិជនដែលមានប្រភពចំណូលទៀតទាត់នូវឱកាសក្នុងការទិញសម្ភារប្រើប្រាស់ផ្ទាល់ខ្លួន ជាមួយអត្រាការប្រាក់ និងរយៈពេលកម្ចីសមរម្យ។ ផលិតផលប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន ដែលទទួលយកសម្ភារដែលទិញជាទ្រព្យដាក់ធានា និងផលិតផលភតិសន្យាហិរញ្ញវត្ថុ ផ្ដល់ឱ្យអតិថិជនដែលមានបំណងទិញសម្ភារថ្មី ឬសម្ភារដែលប្រើរួចដូចជា ម៉ូតូ រ៉ឺម៉ក ឡាន និងគ្រឿងចក្រកសិកម្ម ដើម្បីប្រើប្រាស់ក្នុងសកម្មភាពអាជីវកម្ម ឬប្រើប្រាស់ជាមធ្យោបាយផ្ទាល់ខ្លួន។ ថ្មីៗនេះ អិលអូអិលស៊ី បានបង្កើតនូវផលិតផលប្រាក់កម្ចីថ្មីមួយផ្សេងទៀត ដែលកំពុងតែពេញនិយមសម្រាប់អ្នកប្រកបអាជីវកម្ម អ្នកជំនួញ ដែលមានទំហំឥណទានដល់ ១០០.០០០ដុល្លារអាមេរិក ដោយមិនចាំបាច់មានទ្រព្យដាក់ធានាជាដី ឬជាផ្ទះឡើយ គឺផលិតផលឥណទានធានាដោយសន្និធិ។

ក្រៅពីផលិតផលប្រាក់កម្ចីខាងលើ អិលអូអិលស៊ី ក៏មានផលិតផលគ្រឿងចក្រកសិកម្ម ដែលមានទំហំឥណទានដល់ ៣៥.០០០ ដុល្លារអាមេរិក និងមានរបៀបសងប្រាក់សមស្របតាមចំណូល។ ផលិតផលប្រាក់កម្ចីគ្រឿងចក្រកសិកម្ម ត្រូវបានបង្កើតឡើងដើម្បីផ្ដល់ជូនដល់កសិករ និងអ្នកផ្ដល់សេវា (អ្នកជួលគ្រឿងចក្រ) សម្រាប់ទិញគ្រឿងចក្រកសិកម្ម ក្នុងគោលបំណងបង្កើនផលិតភាព ទិន្នផល និងប្រាក់ចំណូលបន្ថែម។

បន្ថែមលើផលិតផលប្រាក់កម្ចីស្នូលរបស់ខ្លួនដូចបានរៀបរាប់ខាងលើ អិលអូអិលស៊ី ក៏នៅមានផលិតផលប្រាក់កម្ចីផ្សេងៗដូចជា ផលិតផលប្រាក់កម្ចីទឹកស្អាត និងអនាម័យ និងផលិតផលប្រាក់កម្ចីសម្រាប់ទិញសម្ភារប្រើប្រាស់ក្នុងផ្ទះ។ ផលិតផលប្រាក់កម្ចីទាំងពីរនេះត្រូវបានផ្ដល់ជូនអតិថិជនដែលត្រូវការសាច់ប្រាក់បន្ថែមពី អិលអូអិលស៊ី ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ក៏ដូចជាអនាម័យ និងសម្ភារប្រើប្រាស់ផ្សេងៗទៀត។ ដើម្បីកាត់បន្ថយហានិភ័យនៃបំណុលវ័ណ្ឌករ អិលអូអិលស៊ី ផ្ដល់ប្រាក់កម្ចីបន្ថែមនេះដល់អតិថិជនណាដែលមានវិន័យល្អក្នុងការបង់សង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង់សងបន្ថែមទៀតប៉ុណ្ណោះ។

អិលអូអិលស៊ី ទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពី ធនាគារជាតិនៃកម្ពុជា និងដាក់ឱ្យប្រើប្រាស់សាកល្បងនូវផលិតផលប្រាក់បញ្ញើនៅសាខាមួយចំនួន ក្នុងខែតុលា ឆ្នាំ២០១៥។ នៅក្នុងឆ្នាំ២០១៦ ផលិតផលប្រាក់បញ្ញើ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅគ្រប់សាខាទាំងអស់ទូទាំងប្រទេស ដោយទទួលបានលទ្ធផលជោគជ័យគួរជាទីពេញចិត្តបំផុត និងសម្រេចបានសមតុល្យប្រាក់បញ្ញើ ជាង ៤៥៨លានដុល្លារអាមេរិក ដែលកើនពីសមតុល្យជាង ២៣៧ លានដុល្លារអាមេរិក គិតត្រឹមដំណាច់ឆ្នាំ២០១៨។ អិលអូអិលស៊ី ផ្ដល់ជូនអតិថិជននូវផលិតផលប្រាក់បញ្ញើពីរប្រភេទ គឺប្រាក់បញ្ញើសំចៃ និងប្រាក់បញ្ញើមានកាលកំណត់។ ក្រៅពីទទួលបាននូវសុវត្ថិភាពខ្ពស់ អតិថិជនប្រាក់បញ្ញើ ទទួលបាននូវសេវាល្អ និងអត្រាការប្រាក់ខ្ពស់គួរជាទីពេញចិត្ត។

# សមិទ្ធផលអាជីវកម្ម

## សមិទ្ធផលឥណទានតាមវិស័យ

ចំនួនគណនី

| ល.រ | វិស័យ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|
| ១ | កសិកម្ម | ១២០,៦៧៩ | ១១៥,៩០៣ | ១៥០,៣៦៧ |
| ២ | ផលិតកម្ម | ១,៤៧៩ | ៨,៦៥០ | ១,៤១៧ |
| ៣ | ជំនួញ និងពាណិជ្ជកម្ម | ២៦,៤៥៤ | ២៨,៣២៦ | ៣៤,២៩៥ |
| ៤ | សេវាកម្ម | ១៩,៣២៤ | ២៣,៩០០ | ៦១,៦២២ |
| ៥ | ប្រាក់បៀវត្ស និងប្រាក់ឈ្នួល | ៤៨,៦៧៨ | ៧២,៦១០ | ៨៩,៨៤២ |
| ៦ | ផ្សេងៗ | ១,៤០៦ | ៣៦២ | ១,១០២ |
| | សរុប | ២១៨,០២០ | ២៤៩,៧៥១ | ៣៣៨,៦៤៥ |

ផលប័ត្រឥណទាន (ដុល្លារអាមេរិក)

| ល.រ | វិស័យ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|
| ១ | កសិកម្ម | ១៤៣,៦២៤,៨៧៨ | ១៨៣,៨១៥,៨៦៦ | ២៦៣,៨២៩,០៦៤ |
| ២ | ផលិតកម្ម | ៥,៥៦៥,៥៨៧ | ៤,០៣៧,០៥៥ | ៤,០១៣,១៩៤ |
| ៣ | ជំនួញ និងពាណិជ្ជកម្ម | ៥២,៦៣០,៧៧២ | ៧១,៤៩២,១១២ | ១២១,០៣៩,២៣៥ |
| ៤ | សេវាកម្ម | ៦៤,៦៣៤,០៦៨ | ១០៩,៩២៥,៦៩១ | ១៨៥,១២៦,៣៤២ |
| ៥ | ប្រាក់បៀវត្ស និងប្រាក់ឈ្នួល | ៥៤,២៥២,១៣៦ | ១១១,៩៨៧,០៤៣ | ១៩៥,៩១៦,៤១៤ |
| ៦ | ផ្សេងៗ | ១,៩៤០,៣១៧ | ២,៥៨៧,៥៤០ | ២,២៩០,០៥៧ |
| | សរុប | ៣២២,៦៤៧,៦៩៨ | ៤៨៣,៨៤៥,៣០៧ | ៧៧២,២១៤,២៦៦ |

ផលប័ត្រឥណទានរបស់ អិលអូអិលស៊ី កើនឡើងចំនួន ៦០% ធៀបទៅនឹង ឆ្នាំ២០១៨ ដែលកើនឡើងដល់ចំនួនជាង ៧៧២លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩។

បើគិតទៅតាមវិស័យនីមួយៗឃើញថា ប្រាក់កម្ចីក្នុងវិស័យកសិកម្ម មានទំហំធំជាងគេបង្អស់ ដែលមានចំនួនប្រមាណជា ៣៤% នៃផលប័ត្រឥណទានសរុប ហើយវិស័យដែលមានផលប័ត្រឥណទានធំបន្ទាប់មានដូចជា វិស័យប្រាក់បៀវត្សនិងប្រាក់ឈ្នួល ២៥% សេវាកម្ម ២៤% ជំនួញនិងពាណិជ្ជកម្ម ១៦% និងផលិតកម្ម ០,៥% ។

## សមិទ្ធផលឥណទានតាមផលិតផល

ចំនួនគណនី

| ល.រ | ផលិតផល | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|
| ១ | ប្រាក់កម្ចីក្រុម | ១០៧,៥០០ | ៩៨,៩៤០ | ១៤២,៣៥៣ |
| ២ | ប្រាក់កម្ចីឯកត្តជន | ៦២,៩៤៧ | ៧៨,៣២៩ | ៩៤,៨៣៥ |
| ៣ | ប្រាក់កម្ចីសហគ្រាសខ្នាតតូច និងមធ្យម | ២,៦៦១ | ៤,៥៥៤ | ១២,២៧៨ |
| ៤ | ប្រាក់កម្ចីតាមរដូវកាល | ១៨,៩៣១ | ១៨,៩៦៣ | ២០,៤០៤ |
| ៥ | ប្រាក់កម្ចីកែលម្អគេហដ្ឋាន | ៧,១៥៦ | ១០,០៦០ | ១០,៩១២ |
| ៦ | ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន | ១០,៨២៥ | ២៩,៧៤២ | ៤៧,៨៦៦ |
| ៧ | ប្រាក់កម្ចីទឹកស្អាត និងអនាម័យ | ៧,៧៩៥ | ៨,៥៥៨ | ៩,៥៩៤ |
| ៨ | ប្រាក់កម្ចីធានាដោយសន្និធិ | - | - | ៤៤ |
| ៩ | ភតិសន្យាហិរញ្ញវត្ថុ | ២០៥ | ៦០៥ | ៣៥៩ |
| | សរុប | ២១៨,០២០ | ២៤៩,៧៥១ | ៣៣៨,៦៤៥ |

អិលអូអិលស៊ី រក្សាបាននូវចំនួនអតិថិជនយ៉ាងច្រើនក្នុង ឆ្នាំ២០១៩ ដែលមានចំនួនជាង ៣៣៨.០០០នាក់ ដែលអតិថិជនរបស់ អិលអូអិលស៊ី ភាគច្រើនជាអតិថិជន ប្រាក់កម្ចីក្រុម ប្រាក់កម្ចីឯកត្តជន ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន និងប្រាក់កម្ចីតាមរដូវកាល។

### ផលប័ត្រឥណទាន (ដុល្លារអាមេរិក)

| ល.រ | ផលិតផល | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|
| ១ | ប្រាក់កម្ចីក្រុម | ៤៥,២៧៥,០៩៨ | ៤៦,២៣៩,២៦១ | ៨៥,២៦៧,៤២៧ |
| ២ | ប្រាក់កម្ចីឯកត្តជន | ១៥០,៤២៧,៤៣២ | ២១៣,៨២៣,៧៨២ | ២៨២,៨៦៩,៣៦៧ |
| ៣ | ប្រាក់កម្ចីសហគ្រាសខ្នាតតូច និងមធ្យម | ៣៩,៨៨៤,៧៣៨ | ៦៧,១០៩,៤០២ | ១៦៤,៦៣៧,៦១៩ |
| ៤ | ប្រាក់កម្ចីតាមរដូវកាល | ៤៤,៣៨៧,៩៤៨ | ៥២,៤៧០,២៨១ | ៧០,៣១៦,១៨៣ |
| ៥ | ប្រាក់កម្ចីកែលម្អគេហដ្ឋាន | ២៣,៥០៧,៩២៥ | ៣៧,៥២៧,៤៧៧ | ៤៨,៥៤៤,៥០៥ |
| ៦ | ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន | ១៥,០៧០,១៤៣ | ៦១,៧២៩,៧៩០ | ១១៤,៣៣០,២៧៤ |
| ៧ | ប្រាក់កម្ចីទឹកស្អាត និងអនាម័យ | ៤,០១៤,២៩៦ | ៣,៨០៧,៦២៤ | ៤,២៧៤,១៨៥ |
| ៨ | ប្រាក់កម្ចីធានាដោយសន្និធិ | - | - | ១,៥៦១,១១៩ |
| ៩ | ភតិសន្យាហិរញ្ញវត្ថុ | ៨០,១១៨ | ១,១៣៧,៦៩០ | ៤១៣,៥៨៧ |
| | **សរុប** | **៣២២,៦៤៧,៦៩៨** | **៤៨៣,៨៤៥,៣០៧** | **៧៧២,២១៤,២៦៦** |

អិលអូអិលស៊ី រក្សាបាននូវចំនួនកំណើនផលប័ត្រឥណទានយ៉ាងច្រើនក្នុងឆ្នាំ២០១៩ ដែលមានចំនួនជាង ៧៧២លានដុល្លារអាមេរិក ដែលផលប័ត្រឥណទានរបស់ អិលអូអិលស៊ី ភាគច្រើនជា ប្រាក់កម្ចីឯកត្តជន ប្រាក់កម្ចីសហគ្រាសខ្នាតតូចនិងមធ្យម ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន ប្រាក់កម្ចីក្រុម និងប្រាក់កម្ចីតាមរដូវកាល។

## សង្ខេបលទ្ធផលសម្រេចបានសម្រាប់ផលិតផលប្រាក់បញ្ញើ សេវាប័ណ្ណ ATM អិលអូអិលស៊ី និងសេវា iPay Cambodia គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ២០១៩

- **សមតុល្យប្រាក់បញ្ញើ៖** សរុបចំនួន ៤៥៨លានដុល្លារអាមេរិក ដែលមានគណនីចំនួន ៣៨១.៦១៣។ សមតុល្យប្រាក់បញ្ញើមានការកើនឡើង ៩៣% និងចំនួនគណនីមានកំណើន ៩២% ធៀបនឹងឆ្នាំ២០១៨។



- **សេវា iPay Cambodia៖** ទទួលបានការចុះឈ្មោះប្រើប្រាស់ពីអតិថិជនសរុបចំនួន ៣.៧៨៨នាក់ ដែលមានប្រតិបត្តិការសរុបចំនួន ៣៦.១២៥ និងទឹកប្រាក់ចំនួន ៩៥៥.២៩៤ដុល្លារអាមេរិក។

| ខែ | ចំនួនអ្នកចុះឈ្មោះប្រើប្រាស់ | ចំនួនប្រតិបត្តិការ | ប្រតិបត្តិការគិតជា ដុល្លារ |
|---|---|---|---|
| ខែតុលា ឆ្នាំ២០១៩ | ២,៨៤៣ | ២២,៦៦៧ | ៤៥៥,៧៨៧ |
| ខែវិច្ឆិកា ឆ្នាំ២០១៩ | ៣,២៧៤ | ២៦,៩៩០ | ៦២៦,៩១៩ |
| ខែធ្នូ ឆ្នាំ២០១៩ | ៣,៧៨៨ | ៣៦,១២៥ | ៩៥៥,២៩៤ |

- **សេវាប័ណ្ណ ATM អិលអូអិលស៊ី៖** បោះពុម្ពប័ណ្ណ ATM ជូនបុគ្គលិកបានចំនួន ២១៣ ប័ណ្ណ ដើម្បីធ្វើការសាកល្បងជាមួយសមាជិកនៃប្រព័ន្ធ CSS ដែលមានប្រតិបត្តិការសរុបចំនួន ៦៥៦ គិតជាទឹកប្រាក់ចំនួន ១១.៧២៣ដុល្លារអាមេរិក។

| ខែ | ចំនួនអ្នកចុះឈ្មោះប្រើប្រាស់ | ចំនួនប្រតិបត្តិការ | ប្រតិបត្តិការគិតជា ដុល្លារ |
|---|---|---|---|
| ខែតុលា ឆ្នាំ២០១៩ | ១២ | ៣៣៩ | ១.១៥៣ |
| ខែវិច្ឆិកា ឆ្នាំ២០១៩ | ៣៨ | ៣៨៦ | ១.៦២២ |
| ខែធ្នូ ឆ្នាំ២០១៩ | ២១៣ | ៦៥៦ | ១១.៧២៣ |

## គណនីបញ្ញើសំចៃ

គឺជាប្រភេទគណនីដែលផ្តល់ជូនអតិថិជននូវភាពងាយស្រួលក្នុងការដាក់ ឬដកប្រាក់បានគ្រប់ពេលវេលា និងគ្រប់សាខានៅរៀងរាល់ម៉ោងធ្វើការដោយមិនមានកំណត់ចំនួនទឹកប្រាក់។

គណនីបញ្ញើសំចៃ

| រូបិយប័ណ្ណ | ប្រាក់រៀល/ដុល្លារ/បាត |
|---|---|
| សមតុល្យអប្បបរមា | សូន្យ |
| រយៈពេល | មិនកំណត់ |
| អត្រាការប្រាក់ប្រចាំឆ្នាំ | ៥% |
| សៀវភៅប្រាក់បញ្ញើ | មិនគិតថ្លៃពេលបើកគណនី និងប្រើប្រាស់អស់ |

## គណនីបញ្ញើមានការកំណត់

គឺជាប្រភេទគណនីដែលផ្តល់ជូនអតិថិជនក្នុងគោលបំណង សន្សំប្រាក់ទៅតាមពេលវេលាជាក់លាក់ណាមួយ ដើម្បីបង្កើនប្រាក់ចំណូលរបស់ខ្លួន ដោយទទួលបានអត្រាការប្រាក់ខ្ពស់ និងអាចដកការប្រាក់ប្រចាំខែ ឬនៅចុងការិយបរិច្ឆេទ។

តារាងសង្ខេបគណនីបញ្ញើមានការកំណត់

| រូបិយប័ណ្ណ | ប្រាក់រៀល/ដុល្លារ/បាត |
|---|---|
| សមតុល្យអប្បបរមា | ២០០.០០០ រៀល / ៥០ ដុល្លារ / ២.០០០ បាត |
| រយៈពេល | ១ ៣ ៦ ៩ ១២ ២៤ និង ៣៦ខែ |
| អត្រាការប្រាក់ប្រចាំឆ្នាំខ្ពស់បំផុត | ៨,៥០% |

## សេវាផ្ទេរប្រាក់ក្នុងស្រុក

អតិថិជនអាចផ្ទេរប្រាក់ក្នុងស្រុកទៅឱ្យបងប្អូន មិត្តភក្តិ និងដៃគូរអាជីវកម្មដែលមានគណនីសំចៃជាមួយ អិលអូអិលស៊ី លឿនរហ័សទាន់ចិត្ត និងមានភាពងាយស្រួល។

តារាងសង្ខេបសេវាផ្ទេរប្រាក់ក្នុងស្រុក

| បរិយាយ | កម្រៃសេវា | | សម្គាល់ |
|---|---|---|---|
| | រៀល | ដុល្លារ | |
| ផ្ទេរប្រាក់ក្នុងសាខាតែមួយ | មិនគិតកម្រៃ | | ផ្ទេររវាងគណនី ឬ ដក ដាក់ប្រាក់ឆ្លងសាខា |
| សងប្រាក់កម្ចីឆ្លងសាខា | | | |
| ផ្ទេរប្រាក់រវាងសាខា | | | |

## សេវាទូទាត់រហ័សតាមប្រព័ន្ធ FAST (ផ្ទេរប្រាក់ឆ្លងធនាគារ)

អតិថិជនអាចផ្ទេរប្រាក់ជារូបិយប័ណ្ណប្រាក់រៀល ចេញ ចូលឆ្លងធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលជា សមាជិក FAST បានយ៉ាងរហ័សទាន់ចិត្ត និងមានភាពងាយស្រួល។

តារាងសង្ខេបទូទាត់រហ័សតាមប្រព័ន្ធ FAST

| លក្ខខណ្ឌតម្រូវការ | បរិយាយ |
|---|---|
| រូបិយប័ណ្ណ | ប្រាក់រៀល |
| ទឹកប្រាក់ផ្ទេរអតិបរមាក្នុង១ប្រតិបត្តិការ | ៤០.០០០.០០០ រៀល |
| កម្រៃសេវាផ្ទេរប្រាក់ | ≤ ៤លានរៀល: ៤.០០០រៀល<br>> ៤លានរៀល ដល់ ២០លានរៀល: ៨.០០០រៀល<br>> ២០លានរៀល ដល់ ៤០ លានរៀល: ១២.០០០រៀល |
| គិតកម្រៃសេវា | អ្នកផ្ទេរប្រាក់ទទួលបន្ទុកបង់កម្រៃសេវា |

## សេវា iPay Cambodia

អិលអូអិលស៊ី បានដាក់ឱ្យដំណើរការសេវាធនាគារចល័ត iPay Cambodia ទៅសាធារណជន ដើម្បីឱ្យអតិថិជនងាយស្រួលចាត់ចែងគ្រប់គ្រងលំហូរសាច់ប្រាក់បានគ្រប់ពេលវេលា និងទីកន្លែង ដែលមានប្រព័ន្ធ Internet។ ជាមួយសេវា iPay Cambodia អតិថិជនអាចពិនិត្យសមតុល្យគណនីរបស់លោកអ្នកភ្លាមៗ ទូទាត់ថ្លៃវិក្កយបត្រ ផ្ទេរប្រាក់ បើកគណនីបញ្ញើមានកាលកំណត់ បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទ និងមានលក្ខណៈពិសេសក្នុងការប្រើប្រាស់ផ្សេងៗជាច្រើនទៀត។ កម្មវិធី iPay Cambodia លោកអ្នកអាចទាញយកតាមរយៈទូរស័ព្ទដៃដោយឥតគិតថ្លៃ (iOS & Android) រហ័សទាន់ចិត្ត មានសុវត្ថិភាព និងងាយស្រួលប្រើប្រាស់។

ទំហំប្រតិបត្តិការសេវា iPay Cambodia

| ប្រតិបត្តិការ | ទឹកប្រាក់អតិបរមា |
|---|---|
| ក្នុង ១ ប្រតិបត្តិការ | ៤.០០០.០០០រៀល ឬ ១.០០០ដុល្លារ ឬ ៤០.០០០ បាត |
| ប្រតិបត្តិការក្នុង ១ ថ្ងៃ | ១០.០០០.០០០រៀល ឬ ២.៥០០ដុល្លារ ឬ ១០០.០០០ បាត |

## សេវាប័ណ្ណ ATM អិលអូអិលស៊ី

តាមរយៈការចូលជាសមាជិកនៃប្រព័ន្ធ ស៊ីអេសអេស (CSS) ដែលបង្កើតឡើងដោយ ធនាគារជាតិនៃកម្ពុជា អិលអូអិលស៊ី នឹងដាក់ឱ្យសាធារណៈជនប្រើប្រាស់នូវប័ណ្ណឥណពន្ធ ATM អិលអូអិលស៊ី។ តាមរយៈប័ណ្ណ ATM អតិថិជនអាចធ្វើប្រតិបត្តិការ ដកសាច់ប្រាក់ ឬផ្ទេរប្រាក់តាមរយៈមាស៊ីន ATM របស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលជាសមាជិកប្រព័ន្ធ CSS ទូទាំង២៥ រាជធានី-ខេត្ត ក្រោយការដាក់ឱ្យសាកល្បងជាមួយបុគ្គលិកទទួលបានជោគជ័យ។

ប្រតិបត្តិការលើម៉ាស៊ីន ATM

- ដកសាច់ប្រាក់/ដកសាច់ប្រាក់រហ័ស
- ផ្ទេរប្រាក់អន្តរធនាគារ (FAST)
- ពិនិត្យសមតុល្យគណនី
- ស្នើសុំរបាយការណ៍សង្ខេបគណនី
- ប្តូរលេខកូដសម្ងាត់ PIN

ប្រតិបត្តិការលើម៉ាស៊ីន POS

- ទិញ (Purchase)
- ដកសាច់ប្រាក់ (Cash Withdrawal)
- បញ្ជូនមូលនិធិត្រឡប់វិញ (Refund)
- បង្វែរមូលនិធិលើប្រតិបត្តិការទិញ (Purchase Reversal)
- ពិនិត្យសមតុល្យ (Balance Inquiry)

ទំហំប្រតិបត្តិការតាមរយៈម៉ាស៊ីន ATM

| ប្រតិបត្តិការប័ណ្ណ ATM ក្នុង ១ប្រតិបត្តិការ/ថ្ងៃ | ចំនួនទឹកប្រាក់ | ចំនួនប្រតិបត្តិការ |
|---|---|---|
| ប្រតិបត្តិការដកប្រាក់<br>ប្រតិបត្តិការផ្ទេរប្រាក់ចេញអន្តរធនាគារ<br>ប្រតិបត្តិការផ្ទេរប្រាក់ក្នុងរង្វង់ អិលអូអិលស៊ី | ៤.០០០.០០០ រៀល<br>ឬ<br>១.០០០ ដុល្លារ | មិនកំណត់ |

ទំហំប្រតិបត្តិការតាមរយៈម៉ាស៊ីន POS

| ប្រតិបត្តិការតាមរយៈ POS ក្នុង ១ប្រតិបត្តិការ/ថ្ងៃ | ចំនួនទឹកប្រាក់ | ចំនួនប្រតិបត្តិការ |
|---|---|---|
| ប្រតិបត្តិការប័ណ្ណ ATM តាមរយៈម៉ាស៊ីន POS | ៤.០០០.០០០ រៀល<br>ឬ<br>១.០០០ ដុល្លារ | មិនកំណត់ |

# សេចក្តីសង្ខេបអំពីសមិទ្ធផលហិរញ្ញវត្ថុ

## តារាងសង្ខេបប្រាក់ចំណេញ និងខាត

| តារាងសង្ខេបប្រាក់ចំណេញ និងខាត (គិតជាពាន់ដុល្លារ) | ឆ្នាំ២០១៧ បានធ្វើសវនកម្ម | ឆ្នាំ២០១៨ បានធ្វើសវនកម្ម | ឆ្នាំ២០១៩ បានធ្វើសវនកម្ម | ប្រែប្រួល (%) |
|---|---|---|---|---|
| ចំណូលការប្រាក់សុទ្ធ | ៤១.៥០៣ | ៤៣.៥៨៣ | ៦៣.១៨០ | ៤៥,0% |
| ចំណូលផ្សេងៗ | ២.៦២៩ | ១០.០៤៥ | ១៧.៤៥៧ | ៧៣,៨% |
| **ចំណូលសុទ្ធពីប្រតិបត្តិការ** | **៤៤.១៣៣** | **៥៣.៦២៨** | **៨០.៦៣៨** | **៥០,៤%** |
| ចំណាយប្រតិបត្តិការ | (២១.៨៩៦) | (២៩.៥៤៦) | (៣៨.១០៣) | ២៩,0% |
| សំវិធានធនឥណទានអាក្រក់ និងសង្ស័យ ឧបករណ៍ហិរញ្ញវត្ថុ | (២.៧៨០) | (៣.៣១៤) | (៤.២៥៤) | ២៨,៣% |
| **ប្រាក់ចំណេញមុនដកពន្ធ** | **១៩.៤៥៨** | **២០.៧៦៧** | **៣៨.២៨១** | **៨៤,៣%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៣.៨៧០) | (៥.១២៩) | (៤.២៦១) | -១៦,៩% |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **១៥.៥៨៨** | **១៥.៦៣៨** | **៣៤.០២០** | **១១៧,៦%** |

អិលអូអិលស៊ី សម្រេចបានកំណើនប្រាក់ចំណេញសុទ្ធចំនួន ១១៧,៦% ដែលមានចំនួន ៣៤,0២លានដុល្លារអាមេរិក (កើនឡើងពី ១៥,៦៣លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨) ថ្វីត្បិតតែមានការប្រកួតប្រជែងលើបរិយាកាសប្រតិបត្តិការ។ ជាលទ្ធផល អិលអូអិលស៊ី សម្រេចបានអត្រាចំណេញពីមូលនិធិជាមធ្យមចំនួន ៣២,១៣% និងអត្រាចំណេញពីទ្រព្យសកម្មចំនួន ៤,២0%។

## តារាងតុល្យការសង្ខេប

| តារាងតុល្យការសង្ខេប (គិតជាពាន់ដុល្លារ) | ឆ្នាំ២០១៧ បានធ្វើសវនកម្ម | ឆ្នាំ២០១៨ បានធ្វើសវនកម្ម | ឆ្នាំ២០១៩ បានធ្វើសវនកម្ម | ប្រែប្រួល (%) |
|---|---|---|---|---|
| ទ្រព្យសកម្ម | ៣៧១.៤៣១ | ៦១០.៣២៨ | ១.00៩.៣៥២ | ៦៥,៤% |
| ផលប័ត្រឥណទានដុល | ៣២២.៦៤៨ | ៤៨៣.៨៤៥ | ៧៧២.២១៤ | ៥៩,៦% |
| បំណុល | ៣១១.០៥២ | ៥២៩.១៥៨ | ៨៧៣.៥៤៦ | ៦៥,១% |
| សមតុល្យប្រាក់បញ្ញើ | ៩១.៨៣៥ | ២៣៦.៩១០ | ៤៥៧.៦៦១ | ៩៣,២% |
| សមតុល្យប្រាក់កម្ចី | ២០៦.៣៤៦ | ២៧២.៩៩៧ | ៣៧៩.៦៤៣ | ៣៩,១% |
| មូលធនភាគទុនិក | ៦០.៣៧៩ | ៨១.១៧១ | ១៣៥.៨០៥ | ៦៧,៣% |

ទ្រព្យសកម្មសរុបរបស់ អិលអូអិលស៊ី កើនឡើងចំនួន ៦៥,៤% ដែលមានចំនួន ១.00៩,៣៥លានដុល្លារអាមេរិក គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩ ដែលភាគច្រើនបានមកពីកំណើនផលប័ត្រឥណទាន ដែលមានអត្រាកំណើន៥៩,៦% ធៀបនឹងឆ្នាំមុន និងចំនួនផលប័ត្រឥណទានចំនួន ៧៧២,២១លានដុល្លារអាមេរិក។

ផលិតផលប្រាក់បញ្ញើកើនឡើងយ៉ាងខ្លាំងចំនួន ៩៣,២% ដល់សមតុល្យជាង ៤៥៧,៦៦លានដុល្លារអាមេរិក ដោយសារ អិលអូអិលស៊ី នៅតែបន្តទទួលបានការជឿទុកចិត្តខ្ពស់ពីសំណាក់អតិថិជនប្រាក់បញ្ញើ។ សមាមាត្រនៃសមតុល្យប្រាក់បញ្ញើ ក្នុងចំណោមផលិតផលប្រាក់បញ្ញើទាំងពីរប្រភេទ គឺគណនីបញ្ញើសន្សំមានចំនួន ៨,៩% និងគណនីបញ្ញើមានកាលកំណត់មានចំនួន ៩១,១%។ ប្រាក់កម្ចីពីម្ចាស់កម្ចី មានការកើនឡើងចំនួន ៣៩,១% ដែលមានចំនួន ៣៧៩,៦៤លានដុល្លារអាមេរិក ក្នុងនោះប្រាក់កម្ចីពីធនាគារក្នុងស្រុកកើនឡើងចំនួន ៨៣,៩% ស្មើនឹង ៩៩,៣៣លានដុល្លារអាមេរិក (ឆ្នាំ២០១៨ មានត្រឹម ៥៤,0២ លានដុល្លារអាមេរិក) និងប្រាក់កម្ចីពីធនាគារក្រៅប្រទេសកើនឡើងចំនួន ២៨% ស្មើនឹង ២៨០,៣១លានដុល្លារអាមេរិក (ឆ្នាំ២០១៨ មានត្រឹម ២១៨,៩៨លានដុល្លារអាមេរិក)។

| សូចនាករណ៍អនុបាតសំខាន់ៗ | ឆ្នាំ២០១៧ បានធ្វើសវនកម្ម | ឆ្នាំ២០១៨ បានធ្វើសវនកម្ម | ឆ្នាំ២០១៩ បានធ្វើសវនកម្ម |
|---|---|---|---|
| អត្រាចំណេញមូលធនភាគទុនិក | ២៨,៦៣% | ២២,៩៤% | ៣២,១៣% |
| អត្រាចំណេញពីទ្រព្យសកម្ម | ៤,៩៩% | ៣,១៩% | ៤,២0% |
| ចំណាយប្រតិបត្តិការធៀបនឹងផលប័ត្រឥណទានជាមធ្យម | ៨,0៨% | ៧,៣៣% | ៦,0៧% |
| អនុបាតចំណាយធៀបចំណូល (រួមបញ្ចូលសំវិធានធន) | ៥៥,៩១% | ៦១,២៨% | ៥២,៥៣% |
| ប្រាក់បញ្ញើធៀបឥណទាន | ២៨,៤៦% | ៤៨,៩៦% | ៥៩,២៧% |
| អនុបាតគ្របខណ្ឌសន្ទនីយភាព | ២៦២,៨៨% | ២៣៤,00% | ២៨១,៩0% |
| អនុបាតសោធនភាព | ២0,៦៨% | ១៧,៩៣% | ២0,0៥% |
| អនុបាតឥណទានមិនដំណើរការ | ១,២៣% | 0,៨៣% | 0,៦0% |

អិលអូអិលស៊ី រក្សាបាននូវលទ្ធផលយ៉ាងល្អប្រសើរ ដោយធ្វើឱ្យប្រសើរឡើងនូវអនុបាតចំណាយប្រតិបត្តិការធៀបនឹងផលប័ត្រឥណទានជាមធ្យម មកត្រឹមតែ ៦,០៧% (ដែលឆ្នាំ២០១៨ មានចំនួន ៧,៣៣%) ខណៈដែលអនុបាតចំណាយធៀបនឹងប្រាក់ចំណូល (រួមបញ្ចូលសំវិធានធន) មានភាពល្អប្រសើរជាងមុនមកត្រឹម ៥២,៥៣% (ដែលឆ្នាំ២០១៨ មានចំនួន ៦១,២៨%)។

បន្ថែមលើនេះ អិលអូអិលស៊ី រក្សាបាននូវអនុបាតក្របខណ្ឌសន្ទនីយភាពខ្ពស់ ដែលមានអត្រា ២៨១,៩% ខណៈដែលតម្រូវការរបស់ធនាគារជាតិនៃកម្ពុជាមានចំនួន ៩០% ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ (ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តម្រូវឱ្យមានអត្រា ១០០%)។ លើសពីនេះទៅទៀត អនុបាតសាធនភាពក៏ត្រូវបានគ្រប់គ្រងយ៉ាងល្អដែលមានចំនួន ២០,០៥% ខណៈដែលតម្រូវការអប្បបរមារបស់ធនាគារជាតិនៃកម្ពុជាគឺមិនត្រូវតិចជាង ១៥%។

គុណភាពទ្រព្យសកម្មគឺជាចំណុចចម្បងដែលគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលផ្តោតការយកចិត្តទុកដាក់ផងដែរ។ គុណភាពទ្រព្យសកម្មមានភាពល្អប្រសើរជាងមុន ដែលមានអត្រា ០,៦០% (ដែលឆ្នាំ២០១៨ មានអត្រា ០,៨៣%)។

## ទស្សនវិស័យឆ្នាំ២០២០

អិលអូអិលស៊ី នឹងបង្កើនប្រាក់ចំណូលរបស់ខ្លួនពីកំណើនទ្រព្យសកម្មដែលមានការប្រាក់ដូចជាឥណទានសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដោយទទួលយកសម្ភារដែលទិញជាទ្រព្យដាក់ធានា/ភតិសន្យាហិរញ្ញវត្ថុ ឥណទានអាជីវកម្មខ្នាតតូច និងឥណទានសហគ្រាសខ្នាតតូចនិងមធ្យម ដែលរួមបញ្ចូលផលិតផលកម្ចីដែលមិនប៉ះពាល់ដល់បរិស្ថាន។

ដើម្បីគាំទ្រកំណើនទ្រព្យសកម្ម គណៈគ្រប់គ្រងត្រូវបន្តពង្រីកសេវាប្រាក់បញ្ញើសន្សំ ពង្រឹងភាពជាដៃគូជាមួយម្ចាស់កម្ចីបច្ចុប្បន្ន និងម្ចាស់កម្ចីថ្មីៗ និងចូលខ្លួនក្នុងទីផ្សារមូលប័ត្រកម្ពុជាដើម្បីបោះផ្សាយមូលបត្រសាជីវកម្ម។

បន្ថែមលើនេះ គណៈគ្រប់គ្រងនឹងបង្កើនផលិតភាព និងប្រសិទ្ធភាពការងាររបស់បុគ្គលិក តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដូចជាប្រព័ន្ធធនាគារដែលប្រើប្រាស់តាម Tablet ដែលអនុញ្ញាតឱ្យមន្ត្រីឥណទានធ្វើប្រតិបត្តិការធនាគារពីក្រៅការិយាល័យ និងភ្ជាប់ព័ត៌មានដោយផ្ទាល់ទៅប្រព័ន្ធធនាគារស្នូលរបស់គ្រឹះស្ថាន។ លើសពីនេះទៅទៀត គណៈគ្រប់គ្រងនឹងបន្តរក្សាឱ្យបាននូវភាពរឹងមាំក្នុងការគ្រប់គ្រងគុណភាពទ្រព្យសកម្មដើម្បីកាត់បន្ថយឥណទានមិនដំណើរការ។

ទន្ទឹមនឹងនេះផងដែរ អិលអូអិលស៊ី នឹងបន្តផ្តោតការយកចិត្តទុកដាក់លើការរក្សាកម្រិតសន្ទនីយភាពឱ្យមានសុខភាពល្អ តាមរយៈការវាស់វែងអនុបាតក្របខណ្ឌសន្ទនីយភាព និងអនុបាតសាធនភាព ដើម្បីរក្សាអនុលោមភាពជាមួយតម្រូវការពី និយ័តករ ក៏ដូចជាគាំទ្រកំណើនប្រកបដោយសុខភាពល្អ។



## ទស្សនវិស័យអំពីអតិថិជន

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ជាស្ថាប័នហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុធំៗនៅក្នុងប្រទេសកម្ពុជា ដែលតែងតែយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគុណភាពនៃការផ្តល់សេវាកម្ម សំដៅធ្វើឱ្យមានភាពងាយស្រួលសម្រាប់អតិថិជនទូទៅ ក្នុងការប្រើប្រាស់នូវផលិតផល និងសេវាកម្ម។ តាមបទពិសោធន៍នាពេលកន្លងមកនេះ អិលអូអិលស៊ី ទទួលបាននូវការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនប្រាក់កម្ចី អតិថិជនភតិសន្យាហិរញ្ញវត្ថុ និងអតិថិជនប្រាក់បញ្ញើដែលធ្វើឱ្យយើងមានការរីកចម្រើនយ៉ាងខ្លាំង និងឆាប់រហ័សក្នុងរយៈពេលដ៏ខ្លីចុងក្រោយនេះ។

ការរីកចម្រើនដ៏ខ្លាំងក្លានេះគឺដោយសារតែ អិលអូអិលស៊ី តែងតែទទួលយកនូវការរិះគន់ ការត្អូញត្អែរ គំនិតកែលម្អ និងការផ្តល់យោបល់ផ្សេងៗពីអតិថិជនដ៏មានតម្លៃរបស់ខ្លួន ដើម្បីអភិវឌ្ឍផលិតផល និងសេវាកម្មរបស់ខ្លួនឱ្យកាន់តែមានភាពល្អប្រសើរបន្ថែមទៀត និងសមស្របទៅតាមការចង់បាន ពេលវេលា ចំណូល និងតម្រូវការរបស់អតិថិជន។

អិលអូអិលស៊ី និងបុគ្គលិកទាំងអស់ក៏យកចិត្តទុកដាក់យ៉ាងខ្លាំងផងដែរចំពោះការរក្សាទំនាក់ទំនងល្អជាមួយអតិថិជនដៃគូសហការណ៍ អាជ្ញាធរ និងភាគីពាក់ព័ន្ធផ្សេងៗទៀត សំដៅទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ លើសពីនេះទៅទៀត ទោះបីជាអតិថិជនដែលបានចាកចេញពី អិលអូអិលស៊ី ទៅហើយក៏ដោយក៏ អិលអូអិលស៊ី មិនបោះបង់ចោលពួកគាត់ឡើយ ហើយផ្ទុយទៅវិញបានជម្រុញឱ្យបុគ្គលិកទាំងអស់ចុះជួបពួកគាត់ជាប្រចាំ ដើម្បីទទួលបាននូវព័ត៌មានត្រឡប់ និងបន្តជូនដំណឹងដល់ពួកគាត់បន្ថែមពីផលិតផលនិងសេវាកម្មថ្មីៗដែលមាន។

ទោះបីជាមានការគាំទ្រខ្លាំងពីសំណាក់អតិថិជនយ៉ាងណាក៏ដោយក៏ អិលអូអិលស៊ី មិននៅស្ងៀមនោះដែរ ហើយផ្ទុយទៅវិញបាន និងកំពុងតែរិះរកវិធីផ្សេងៗទៀតដើម្បីកែលម្អផលិតផល និងសេវាកម្មដែលមានស្រាប់ ព្រមទាំងអភិវឌ្ឍផលិតផល និងសេវាកម្មថ្មីទៀត ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជនទូទៅ និងថែរក្សាអតិថិជនដែលមានស្រាប់តាមរយៈការទទួលយកនូវគំនិតយោបល់ និងការត្អូញត្អែរពីអតិថិជនគ្រប់មជ្ឈដ្ឋាន។

**តារាងសង្ខេបការត្អូញត្អែររបស់អតិថិជនសម្រាប់ឆ្នាំ២០១៩**

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនដងនៃការត្អូញត្អែរ | ៣ | ៦ | ៨ | ១១ | ៥ | ៤ | ៦ | ២ | ១ | ៣ | ៣ | ៥ |

## ការអភិវឌ្ឍធនធានមនុស្ស

នៅឆ្នាំ២០១៩ នាយកដ្ឋានធនធានមនុស្សមានមោទនភាពដែលសម្រេចបានសមិទ្ធផលដ៏ធំធេង ក្រោមកិច្ចសហប្រតិបត្តិការល្អពីគណៈគ្រប់គ្រងនៅក្នុងនាយកដ្ឋាននីមួយៗ និងមានការចូលរួមយ៉ាងសកម្មពីបុគ្គលិកគ្រប់លំដាប់ថ្នាក់។ ចំនួនបុគ្គលិកសរុបគិតត្រឹមខែធ្នូ ឆ្នាំ២០១៩ មានចំនួន ២.៧៥៧ នាក់។

បុគ្គលិកត្រូវបានបំពាក់បំប៉នដោយការបណ្តុះបណ្តាលផ្សេងៗគ្នាដែលអាចឱ្យពួកគេបង្កើននូវជំនាញ និងសមត្ថភាពក្នុងការអនុវត្តន៍ការងាររបស់ពួកគេ។ មន្ត្រីឥណទានថ្មី ក៏ទទួលបានការបង្ហាត់បង្ហាញនៅការិយាល័យកណ្តាលដែលពួកគេត្រូវបានបណ្តុះបណ្តាលអំពីចក្ខុវិស័យបេសកកម្ម គុណតម្លៃ និងគោលនយោបាយ និងការអនុវត្តន៍ផ្សេងៗហើយបន្ទាប់មកពួកគេក៏ទទួលបាននូវការបណ្តុះបណ្តាលការងារនៅការិយាល័យសាខា ដែលពួកគេត្រូវបំពេញការងារជាមួយមន្ត្រីឥណទានដែលមានស្រាប់ ព្រមទាំងទទួលបានការណែនាំពីថ្នាក់គ្រប់គ្រងផ្ទាល់ និងទទួលបានការអនុវត្តន៍ជាក់ស្តែងពីការងារ។ ក្រៅពីនេះ បុគ្គលិកសាខាក៏ទទួលបានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជាប្រចាំនៅការិយាល័យសាខារបស់ខ្លួនអំពីគោលការណ៍ នីតិវិធី ជំនាញបច្ចេកទេស និងជំនាញទន់។

ក្រៅពីការបណ្តុះបណ្តាលផ្ទៃក្នុង អិលអូអិលស៊ី (ខេមបូឌា) ក៏ទាក់ទងជាមួយគ្រូបណ្តុះបណ្តាលខាងក្រៅផងដែរ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលទៅតាមតម្រូវការដល់បុគ្គលិក។ យើងក៏បញ្ជូនបុគ្គលិកទៅចូលរួមការបណ្តុះបណ្តាលខាងក្រៅ ទាំងក្នុងនិងក្រៅប្រទេស ក៏ដូចជាការចុះទៅជួបផ្ទាល់ ដើម្បីរៀនពីការអនុវត្តន៍ការងារល្អៗ ពីក្រុមហ៊ុនមេក្នុងប្រទេសស្រីលង្កា។

លើសពីនេះ ការបណ្តុះបណ្តាលក្នុងថ្នាក់រៀន អិលអូអិលស៊ី (ខេមបូឌា) ក៏ផ្តល់នូវជម្រើសរៀនតាមបែបឌីជីថលដល់បុគ្គលិកដូចជាការបណ្តុះបណ្តាលតាមរយៈវីឌីអូ និងធ្វើសន្និសីទវីឌីអូ ដែលអ្នកបណ្តុះបណ្តាលនៅកន្លែងតែមួយប៉ុន្តែអាចភ្ជាប់ទំនាក់ទំនងទៅអ្នកចូលរួម នៅទីតាំងផ្សេងៗគ្នាបាន។

មធ្យោបាយមួយទៀតនៃការអភិវឌ្ឍន៍បុគ្គលិកដែល អិលអូអិលស៊ី (ខេមបូឌា) បានធ្វើ គឺកម្មវិធីផ្លាស់ប្តូរវេនការងារ។ កម្មវិធីនេះ ត្រូវបានរចនាឡើងសម្រាប់បុគ្គលិកដើម្បីផ្លាស់ប្តូរវេនគ្នាទៅធ្វើការនៅមុខតំណែងផ្សេងទៀតក្នុងរយៈពេលជាក់លាក់ណាមួយ។ កម្មវិធីនេះ មានគោលបំណងបណ្តុះបណ្តាលបុគ្គលិកសក្តានុពលសម្រាប់ការធ្វើផែការស្នងមុខតំណែង។

បន្ថែមពីនេះទៀត អិលអូអិលស៊ី (ខេមបូឌា) ក៏ផ្តល់ឱកាសកម្មសិក្សាដល់និស្សិតផងដែរ ដើម្បីជួយដល់ពួកគេឱ្យទទួលបាននូវចំណេះដឹង និងបទពិសោធន៍ការងារតាមរយៈការរៀន ដើម្បីក្លាយជាអ្នកអាជីពការងារម្នាក់ ហើយពួកគេអាចទទួលបានឱកាសការងារជាមួយ អិលអូអិលស៊ី (ខេមបូឌា) ប្រសិនបើពួកគេអាចបង្ហាញថាពួកគេមានសមត្ថភាព។

# ការគ្រប់គ្រងសកម្មភាពសង្គម និងបរិស្ថាន



- តើយើងពន្យល់អត្ថន័យនៃបេសកកម្មរបស់យើងយ៉ាងដូចម្តេចនៅត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩?
- ការវាស់វែងគោលដៅសង្គមរបស់ អិលអូអិលស៊ី
- ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម
- ការវាស់វែងសកម្មភាពសង្គមតាមរយៈ **PPI**
- **Green Lending**
- កម្ចីទឹកស្អាត និងអនាម័យ
- សកម្មភាពសង្គម

## តើយើងពន្យល់អត្ថន័យនៃបេសកកម្មរបស់យើងយ៉ាងដូចម្តេច នៅត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩?




## ការវាស់វែងគោលដៅសង្គមរបស់ អិលអូអិលស៊ី

| គោលដៅសង្គម | ការវាស់វែង KPIs ប្រចាំឆ្នាំ ឱ្យស្របទៅនឹង USSPM | គោលដៅប្រចាំឆ្នាំ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|
| ការបង្កើនការផ្តល់សេវាហិរញ្ញវត្ថុដល់អតិថិជន | ចំនួនអតិថិជននៅតាមតំបន់ជនបទ | >= ៨៥% | ៩៤% | ៩៣% | ៩២% |
| | ចំនួនអតិថិជនក្នុងវិស័យកសិកម្ម | >= ៤០% | ៥៥% | ៤៦% | ៣៩% |
| | ភាគរយនៃអតិថិជនជាស្ត្រី | >= ៦៧% | ៧៨% | ៧២% | ៧០% |
| ការកាត់បន្ថយភាពក្រីក្រ | ភាគរយនៃអតិថិជនថ្មីដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ ១៥០% | >= ២០% | ៣៣% | ២៩,៦២% | ២៩,៤០% |
| និរន្តរភាពបរិស្ថាន | លទ្ធផលនៃការវាយតម្លៃបរិស្ថានក្នុងការត្រួតពិនិត្យ | ការត្រួតពិនិត្យ | ការត្រួតពិនិត្យ "មានផលប៉ះពាល់មធ្យម" | ការត្រួតពិនិត្យ "មានផលប៉ះពាល់មធ្យម" | ការត្រួតពិនិត្យ "មានផលប៉ះពាល់មធ្យម" |

# ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម

ការវាយតម្លៃសង្គម និងបរិស្ថានថ្មីៗនេះត្រូវបានបញ្ចូលយ៉ាងពេញលេញទៅក្នុងដំណើរការផ្តល់ប្រាក់កម្ចី សហគ្រាសខ្នាតតូចនិងមធ្យម។ ជាលទ្ធផលចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៩ កម្ចីសហគ្រាសខ្នាតតូចនិងមធ្យមចំនួន ២៧៦ នៃទំហំទឹកប្រាក់ចំនួន ៣០.០០០ដុល្លារ ត្រូវបានវាយតម្លៃ។

| ការវាយតម្លៃបរិស្ថាន និងសង្គម | ចំនួននៃគណនី | សម្គាល់ |
|---|---|---|
| ទាប | ១៣៦ | - គុណភាពនៃការគ្រប់គ្រងហានិភ័យរបស់អតិថិជនមានកម្រិតខ្ពស់<br>- កម្រិតហានិភ័យអតិថិជនមានកម្រិតទាប<br>ដូច្នេះ ពុំចាំបាច់មានវិធានការអ្វីនោះទេ។ |
| មធ្យម | ១៤០ | - គុណភាពនៃការគ្រប់គ្រងហានិភ័យរបស់អតិថិជនមានកម្រិតពីមធ្យម ទៅខ្ពស់<br>- កម្រិតហានិភ័យអតិថិជនមានកម្រិតពីទាបទៅមធ្យម<br>ដូច្នេះ ការត្រួតពិនិត្យធ្វើឡើងដើម្បីតាមដានការវិវឌ្ឍនៃហានិភ័យនេះ។ |
| សរុប | ២៧៦ | |

ការបែងចែកឥណទានទៅតាមប្រភេទផលប៉ះពាល់បរិស្ថាន និងសង្គម



## ការវាស់វែងសកម្មភាពសង្គមតាមរយៈ PPI

ឧបករណ៍វាស់សន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ (PPI) ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងសកម្មភាពសង្គមរបស់ អិលអូអិលស៊ី លើអតិថិជនក្រីក្រ និងលទ្ធភាពក្នុងការផ្លាស់ប្តូរកម្រិតជីវភាពរស់នៅរបស់អតិថិជនថែមទាំងធានាថាផលិតផលសមស្របត្រូវបានផ្តល់ជូនដល់អតិថិជនគោលដៅ។

ប្រភេទអតិថិជនក្រីក្រ




## Green Lending

បច្ចុប្បន្ន អិលអូអិលស៊ី កំពុងផ្តល់ Green Lending ទាំងការផ្តល់ភតិសន្យាហិរញ្ញវត្ថុ និងប្រាក់កម្ចីតាមរយៈផលិតផលដែលមានស្រាប់ដូចជាប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន (LIL) និងប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួនដោយយកទ្រព្យឬសម្ភារនោះដាក់ជាទ្រព្យធានា (LILAB)។ អិលអូអិលស៊ី បានទទួលជំនួយបច្ចេកទេសពី ResponAbility រួមទាំងឧបករណ៍សម្រាប់វាស់ស្ទង់ពីឥទ្ធិពលនៃការផ្តល់ Green Lending ទៅលើការបំភាយឧស្ម័នកាបូនិក និងថាមពលដែលត្រូវបានសន្សំទុក។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ អិលអូអិលស៊ី កំពុងផ្តល់ Green Lending ដល់អតិថិជន ៩.៩០០ នាក់ ដែលមានផលប័ត្រឥណទានសរុបចំនួន ៣៤,៥លានដុល្លារអាមេរិក។ ក្រាបខាងក្រោមបានបង្ហាញអំពីការកាត់បន្ថយការបំភាយឧស្ម័នកាបូនិក (តោន) និងការសន្សំថាមពល (មេហ្គាវ៉ាត់ម៉ោង) តាមរយៈ Green Lending។

កាត់បន្ថយការបំភាយឧស្ម័នកាបូនិច / ការសន្សំសំចៃការប្រើប្រាស់ថាមពល




- កាត់បន្ថយការបំភាយឧស្ម័នកាបូនិក (តោន/ឆ្នាំ) = ៤.៣៨១ (២៤,២៦%)
- ការសន្សំសំចៃការប្រើប្រាស់ថាមពល (មេហ្គាវ៉ាត់ម៉ោង/ឆ្នាំ) = ១២.២៨៣ (១៦,៨២%)

# កម្ចីទឹកស្អាត និងអនាម័យ

អិលអូអិលស៊ី បានចាប់ផ្ដើមបម្រើអតិថិជនជាមួយនឹងផលិតផលប្រាក់កម្ចីទឹកស្អាត និងអនាម័យ (Wash Loan) ចាប់តាំងពី ឆ្នាំ២០១៦។ ការប្រើប្រាស់កម្ចីប្រភេទនេះ បានជួយទៅលើអនាម័យ និងទឹកស្អាតនៅក្នុងសហគមន៍ពួកគាត់។ អតិថិជនគោលដៅរបស់យើងគឺអតិថិជនដែលមានជំហរល្អជាមួយ អិលអូអិលស៊ី ហើយចង់សាងសង់ ឬជួសជុលបង្គន់ អណ្ដូងទឹក ជីកស្រះស្តុកទឹក ឬទិញម៉ាស៊ីនចម្រោះទឹកជាដើម។ល។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ អិលអូអិលស៊ី បានកំពុងផ្ដល់ជូន ផលិតផលឥណទានទឹកស្អាត និងអនាម័យ ដល់អតិថិជនចំនួន ៩.៦០០នាក់ ដោយមានផលប័ត្រឥណទានសរុបចំនួន ៤,៤លានដុល្លារអាមេរិក។

# សកម្មភាពសង្គមផ្សេងៗទៀត

## វគ្គបណ្ដុះបណ្ដាលស្ដីពីចំណេះដឹងហិរញ្ញវត្ថុ

ចាប់តាំងពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៩ នេះមានអ្នកចូលរួមចំនួន ៥៣២នាក់ ក្នុងព្រឹត្តិការណ៍ ភូមិមួយផលិតផលមួយ មកពីខេត្តទាំង៨ (កំពង់ចាម ព្រៃវែង សៀមរាប កំពង់ធំ ពោធិសាត់ កំពង់ឆ្នាំង កំពត និងតាកែវ) និងមាននិស្សិតចំនួន ២៩៤នាក់ មកពីសកលវិទ្យាល័យព្រះសីហមុនីរាជា ដែលត្រូវបានបណ្ដុះបណ្ដាលអំពីការគ្រប់គ្រងហិរញ្ញវត្ថុ។





## កម្មវិធីវិទ្យុ

អិលអូអិលស៊ី បានដឹកនាំកម្មវិធីផ្សាយតាមវិទ្យុដោយប្រើបុគ្គលិករបស់ខ្លួនផ្ទាល់ ដែលកម្មវិធីនេះមានឈ្មោះថា (គំនិតរីកចម្រើន) និងធ្វើការផ្សាយរៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០:០០ព្រឹក ដល់ម៉ោង ១១:៥០ព្រឹក តាមរយៈវិទ្យុស្ត្រី ១០៣.៥ ដែលមានវិសាលភាពផ្សាយរហូតដល់ ១៨រាជធានី-ខេត្ត។ កាលពីខែមិនា ឆ្នាំ២០១៨ ដល់ខែកុម្ភៈ ឆ្នាំ២០១៩ កម្មវិធីវិទ្យុនេះត្រូវបានសហការផលិតដោយ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា អិលអូអិលស៊ី និងការិយាល័យឥណទានកម្ពុជា ជាមួយនឹងការចូលរួមឧបត្ថម្ភដោយ BlueOrchard Finance។ គោលបំណងអប់រំរបស់កម្មវិធីគំនិតរីកចម្រើន គឺផ្ញើរសារចំណេះដឹងហិរញ្ញវត្ថុ ការការពារអតិថិជន ការជម្រុញទឹកចិត្តខ្លួនឯង និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច ទៅដល់អតិថិជននៅតាមជនបទ។ វាគ្មិនដែលត្រូវបានអញ្ជើញចូលរួមសុទ្ធតែមានបទពិសោធន៍យ៉ាងទូលំទូលាយទាក់ទងនឹងវិស័យហិរញ្ញវត្ថុ។



## ● ព្រឹត្តិការណ៍សហគមន៍

ព្រឹត្តិការណ៍សហគមន៍គឺជាកិច្ចសហប្រតិបត្តិការមួយរវាង អិលអូអិលស៊ី ជាមួយនឹងសង្គម។ យើងមានសកម្មភាពជាច្រើនដូចជាការជួសជុលផ្លូវ ការដាក់បង់អង្គុយតាមសួនសាធារណៈ កម្មវិធីនៅតាមសាលា ការដាំដើមឈើ ការផ្តល់សៀវភៅជូនបណ្ណាល័យ ផ្តល់អណ្តូងទឹក ការសម្អាតទីធ្លាសាធារណៈ។ល។





## ● មហោស្រពតន្ត្រី និងចម្រៀងកុមារ

ដើម្បីលើកទឹកចិត្តឱ្យកុមារមានការចូលរួមក្នុងវិស័យសិល្បៈ អិលអូអិលស៊ី បានឧបត្ថម្ភជាថវិកាជូនដល់មហោស្រពតន្ត្រីប្រចាំឆ្នាំ និងជាពានរង្វាន់របស់ក្រសួងព័ត៌មាន ដែលប្រារព្ធឡើងនៅសាលចតុមុខ។





## ● បោះពុម្ពខិត្តប័ណ្ណផ្សព្វផ្សាយប្រឆាំងគ្រឿងញៀន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី ក៏តែងតែឧបត្ថម្ភក្នុងការបោះពុម្ពខិត្តប័ណ្ណផ្សព្វផ្សាយប្រឆាំងគ្រឿងញៀនចំនួន ១០០.០០០សន្លឹក ជារៀងរាល់ឆ្នាំ ហើយ អិលអូអិលស៊ី នៅតែបន្តសហការឧបត្ថម្ភ និងប្រគល់ជូន លោក លឹម តុងហួត ប្រធាននាយកដ្ឋាន នីតិកម្ម អប់រំ និងស្តារនីតិសម្បទា នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ អិលអូអិលស៊ី សង្ឃឹមថាខិត្តប័ណ្ណដែលបានបោះពុម្ពផ្សាយនេះនឹងចូលរួមចំណែកក្នុងការទប់ស្កាត់ការជួញដូរ ការចរាចរ និងការប្រើប្រាស់គ្រឿងញៀននៅក្នុងសង្គម។





## ● ការចែកអំណោយដល់អតិថិជន និងប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់

អិលអូអិលស៊ី មានទស្សនៈវិស័យក្នុងការជួយឱ្យប្រជាពលរដ្ឋរស់នៅក្នុងភាពថ្លៃថ្នូរ មានសុវត្ថិភាពសង្គម ស្ថេរភាពសេដ្ឋកិច្ច និងយុត្តិធម៌។ ក្នុងឆ្នាំនេះ បុគ្គលិកនៅតាមសាខារបស់ អិលអូអិលស៊ី បានចុះទៅជួប និងនាំយកទៅជាមួយនូវ អង្ករ ទឹកត្រី មីកញ្ចប់ និងគ្រឿងឧបភោគ និងបរិភោគផ្សេងៗទៀតជូនដល់ប្រជាពលរដ្ឋរងគ្រោះទាំងនោះ។





## ● ពិព័រណ៍សៀវភៅកម្ពុជា

ក្នុងឆ្នាំនេះផងដែរ អិលអូអិលស៊ី បានចូលរួមឧបត្ថម្ភជា (Gold Sponsor) ដល់កម្មវិធី "ពិព័រណ៍សៀវភៅកម្ពុជា" ថ្នាក់ជាតិលើកទី៨ ដែលប្រព្រឹត្តទៅចំនួន ៣ថ្ងៃ ក្នុងគោលបំណងលើកទឹកចិត្តដល់អ្នកនិពន្ធ វិទ្យាស្ថាន អង្គការ គ្រឹះស្ថានផ្សព្វផ្សាយ គ្រឹះស្ថានបោះពុម្ពនានា ធ្វើការប្រកួតប្រជែង ដាក់បង្ហាញស្នាដៃរបស់ខ្លួនដល់ សិស្ស និសិត្ស មន្ត្រីរាជការ ដើម្បីទស្សនា និងទិញនូវស្នាដៃទាំងនោះ ក៏ដូចជាដើម្បីលើកទឹកចិត្តដល់កុមារា កុមារី សិស្ស និស្សិត យុវវ័យ មន្ត្រីរាជការ ឱ្យប្តូរមកចាប់អារម្មណ៍ការអាន។ ក្នុងនោះដែរ អិលអូអិលស៊ី ក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងកម្មវិធីនេះ ដោយបានបង្កើតពាក្យស្លោកមួយថា "អានដើម្បីជីវិតកាន់តែប្រសើរ" រួមនឹងសកម្មភាពមួយចំនួនដូចជា ការចែកជូននូវខិត្តប័ណ្ណផ្សព្វផ្សាយផ្សេងៗរបស់ អិលអូអិលស៊ី ប្រតិទិនឆ្នាំថ្មី សៀវភៅអប់រំនានា ព្រឹត្តិបត្រសំខាន់ៗរបស់ ធនាគារជាតិនៃកម្ពុជា ហើយទន្ទឹមគ្នានោះដែរយើងក៏បានរៀបចំការប្រកួតប្រជែងគូររូបគំនូរដល់ប្អូនៗកុមារា កុមារី ការឆ្លើយសំណួរល្បងប្រាជ្ញា និងការប្រកួតប្រជែងក្រុមផ្អែកលើប្រធានបទទាក់ទងនឹងការអប់រំចំណេះដឹងហិរញ្ញវត្ថុ ដើម្បីទទួលយកវត្ថុអនុស្សាវរីយ៍ពី អិលអូអិលស៊ី។





## ● កាកបាទក្រហមកម្ពុជា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី ក៏បានចូលរួមឧបត្ថម្ភថវិកាដល់កាកបាទក្រហមកម្ពុជាជារៀងរាល់ឆ្នាំផងដែរ ដើម្បីជាការរួមចំណែកជាមួយសង្គមក្នុងការងារសប្បុរសធម៌ដ៏សកម្ម ដែលកាកបាទក្រហមកម្ពុជាតែងតែចុះអនុវត្តជាក់ស្តែងដល់មូលដ្ឋានផ្ទាល់ៗកន្លងមក។ ក្នុងឆ្នាំនេះ អិលអូអិលស៊ី បានឧបត្ថម្ភទឹកប្រាក់ចំនួន ៣.០០០ដុល្លារ ដើម្បីជួយដល់សកម្មភាពរបស់កាកបាទក្រហមកម្ពុជា។

## ● កម្មវិធីផ្តល់អាហារូបត្ថម្ភជាទឹកដោះគោស្រស់ដល់កុមារ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី បានចូលរួមឧបត្ថម្ភជាថវិកាចំនួន ១០.០០០ដុល្លារ ជូនដល់រាជបណ្ឌិតសភាកម្ពុជាក្នុង "កម្មវិធីផ្តល់អាហារូបត្ថម្ភជាទឹកដោះគោស្រស់ដល់កុមារ"។ កម្មវិធីនេះបានធ្វើការចែកជូនដល់មណ្ឌលកុមារកំព្រាជាច្រើនកន្លែងដូចជា អង្គការមូលនិធិកុមារកម្ពុជា សមាគមន៍អភិវឌ្ឍន៍គ្រួសារពលីនិងកុមារកំព្រា អង្គការឧបត្ថម្ភកុមារកំព្រា អង្គការខេខេអ៊ីកម្ពុជា មណ្ឌលកុមារកំព្រាខេត្តកំពង់ស្ពឺ បុរីទារកនិងកុមារជាតិ។ល។ ការចូលរួមក្នុងកម្មវិធីនេះពិតជាសំខាន់សម្រាប់សង្គមព្រោះទឹកដោះគោស្រស់នេះបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ការលូតលាស់របស់កុមារា កុមារី របស់យើង។





# អភិបាលកិច្ច




- រចនាសម្ព័ន្ធភាគទុនិក
- រចនាសម្ព័ន្ធនៃការគ្រប់គ្រង
- គោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់អភិបាលកិច្ចសាជីវកម្ម
- តួនាទី និងទំនួលខុសត្រូវរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល
- របាយការណ៍ក្រុមប្រឹក្សាភិបាល
- គណៈគ្រប់គ្រង
- ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុង

# រចនាសម្ព័ន្ធភាគទុនិក

បច្ចុប្បន្ន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី មានភាគទុនិកចំនួនពីរគឺ LOLC Private Limited និង TPC Employee Stock Ownership Plan (“TPC-ESOP/ ធីភីស៊ី-អ៊ីសុប”) ដែលមានរចនាសម្ព័ន្ធភាគហ៊ុនដូចខាងក្រោម៖






# រចនាសម្ព័ន្ធនៃការគ្រប់គ្រង



# គោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់អភិបាលកិច្ចសាជីវកម្ម

## ការជ្រើសរើសក្រុមប្រឹក្សាភិបាល

រូបវន្តបុគ្គលណាមួយមានសមត្ថភាព និងមានអាយុ១៨ឆ្នាំ យ៉ាងតិច អាចបម្រើការងារក្នុងតំណែងអភិបាលបាន។ អភិបាលមិនចាំបាច់ជាម្ចាស់ភាគហ៊ុនឡើយ។ អភិបាលត្រូវជ្រើសតាំងតាមសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន ដែលអនុម័តយល់ព្រមដោយសម្លេងភាគច្រើននៃសម្លេងបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុននៅក្នុងមហាសន្និបាត។ អភិបាលអាចទទួលលាភការសម្រាប់ការងារដែលខ្លួនធ្វើ ដែលកំណត់ក្នុងមហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន។ រាល់សមាជិកនៃក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវទទួលបានការយល់ព្រមជាមុនពី ធនាគារជាតិនៃកម្ពុជា មុននឹងត្រូវបានតែងតាំងជាអភិបាល។

## ក្រុមប្រឹក្សាភិបាល

**សមាសភាព**

| ល.រ | ឈ្មោះ | មុខតំណែង |
|---|---|---|
| ១ | លោក ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា | ប្រធានក្រុមប្រឹក្សាភិបាល |
| ២ | លោក ខនរ៉ាត ដាយអឹស | អភិបាល |
| ៣ | លោក ខូលីប វ៉ាស៊ីកា សាម៉ារ៉ាវីរ៉ា | អភិបាល |
| ៤ | លោក ម៉េឃើល ម៉ាមែន | អភិបាលឯករាជ្យ |
| ៥ | លោក អ៊ីនដ្រាជីត វីជេស៊ីរីវ៉ាដាណា | អភិបាលឯករាជ្យ |

## ជីវប្រវត្តិសង្ខេបរបស់អភិបាលនីមួយៗ



លោក ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

លោក ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា ជាប្រធានក្រុមប្រឹក្សាភិបាល របស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី និងជាអគ្គនាយកគ្រប់គ្រង របស់ អិលអូអិលស៊ី មីយ៉ាន់ម៉ា មីក្រូហិរញ្ញវត្ថុ អិលធីឌី។ មុនពេលចូលបម្រើការងារជាមួយ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី លោកជាអគ្គនាយកគ្រប់គ្រង និងជាប្រធាននាយកប្រតិបត្តិនៅ អិលអូអិលស៊ី ហ្វាយនែន ភីអិលស៊ី ក្នុងប្រទេសស្រីលង្កា។ លោកបានបម្រើការនៅក្នុងវិស័យ សេវាមិនមែនហិរញ្ញវត្ថុ អស់រយៈពេល ៣៣ឆ្នាំ កន្លងមកទាំងនៅក្រុមហ៊ុន ហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណ និងក្រុមហ៊ុនឯកទេសភតិសន្យា ដោយមានមុខតំណែងជាក្រុមប្រឹក្សាភិបាល និងអគ្គនាយកគ្រប់គ្រងទូទៅ មុនពេលទទួលតំណែងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ អិលអូអិលស៊ី (ខេមបូឌា)។ លោកមានជំនាញ និងបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យសេវាមិនមែនហិរញ្ញវត្ថុ រួមមានទីផ្សារ និងការលក់ ការគ្រប់គ្រងឥណទាន និងដោះស្រាយបំណុល និងហិរញ្ញវត្ថុ។ លោក ដេ ហ្ស៊ីលវ៉ា ជាបុគ្គលដ៏ឆ្នើមមួយរូបរបស់ Sri Lanka Institute of Credit Management ហើយលោក ត្រូវបានជ្រើសតាំងជាលេខាធិកាកិត្តិយសក្នុងឆ្នាំ២០១០។ លោកក៏ធ្លាប់ជាសមាជិកក្រុមប្រឹក្សាគ្រប់គ្រង នៃសមាគម Finance Houses Association ក្នុងប្រទេសស្រីលង្កា អស់រយៈពេល៩ឆ្នាំ ក្នុងនោះអស់រយៈពេលជាង៤ឆ្នាំ ដែលលោកកាន់តំណែងជាអនុប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយករបស់ក្រុមហ៊ុន Financial Ombudsman Sri Lanka (Guarantee) Limited ហើយលោកបានផ្តល់ការណែនាំ និងចែករំលែកបទពិសោធន៍ជាច្រើន ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុន Non-Bank Financial Services Industry ក្នុងប្រទេស ស្រីលង្កា ផងដែរ។ ក្នុងឆ្នាំ២០១៥ លោកបានលាលែងពីតំណែងទាំងអស់នេះ ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រង LOLC Group ក្នុងប្រទេស មីយ៉ាន់ម៉ា និងកម្ពុជា។ លោកក៏បានបម្រើការងារ (ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១៥) ជាអគ្គនាយកមិនប្រតិបត្តិ របស់ Navajeevana Rehabilitation – Tangalle ក្នុងប្រទេសស្រីលង្កា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ក្នុងការបម្រើដល់ជនពិការ។ លោក ប្រ៊ីនលី ចូលបម្រើការនៅ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ក្នុងខែតុលា ឆ្នាំ២០១៥។



**លោក ខនរ៉ាត ដាយអឹស**

អភិបាល

លោក ខនរ៉ាត ដាយអឹស ជាអភិបាលនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី និងជាប្រធាននាយកបច្ចេកវិជ្ជាព័ត៌មាន នៃក្រុមហ៊ុន អិលអូអិលស៊ី គ្រុប នៅប្រទេសស្រីលង្កា និងជាសហស្ថាបនិក/អភិបាលនៃក្រុមហ៊ុន iPay ។ លោកបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Leicester និងជាសមាជិកនៃវិទ្យាស្ថាន Chartered Institute ផ្នែកគណនេយ្យគ្រប់គ្រង វិទ្យាស្ថាន Chartered Global ផ្នែកគណនេយ្យគ្រប់គ្រង ជាសមាជិកនៃសមាគមប្រព័ន្ធបច្ចេកវិទ្យា នៅប្រទេសអង់គ្លេស និងជាសមាជិកនៃវិទ្យាស្ថានវិជ្ជាជីវៈគណនេយ្យ Certified Management Accountant ក្នុងប្រទេសស្រីលង្កា។ លោក ដាយអឹស មានបទពិសោធន៍ និងជំនាញឯកទេសជាង២៥ឆ្នាំ លើវិស័យពាណិជ្ជកម្ម ធនាគារ និងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម និងការផលិត។ ជាការទទួលស្គាល់ស្នាដៃចំពោះការរួមចំណែករបស់លោកដល់ក្រុមហ៊ុន អិលអូអិលស៊ី គ្រុប និងវិស័យបច្ចេកវិជ្ជាព័ត៌មាន នៅក្នុងប្រទេសទាំងមូល លោកទទួលបានពានរង្វាន់ CSSL CIO Award នៅក្នុងឆ្នាំ២០១៦ និងពានរង្វាន់ Professional Excellence Award នៅក្នុងឆ្នាំ២០១៧ ក្នុងព្រឹត្តិការណ៍រៀបចំឡើងដោយ វិទ្យាស្ថានវិជ្ជាជីវៈគណនេយ្យ Certified Management Accountant នៃប្រទេសស្រីលង្កា។ លោក ខនរ៉ាត ដាយអឹស ចូលបម្រើការនៅ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ក្នុងខែកុម្ភៈ ឆ្នាំ២០១៨។



**លោក ឌូលីប រ៉ាស៊ីកា សាម៉ារ៉ាវីរ៉ា**

អភិបាល

លោក ឌូលីប រ៉ាស៊ីកា សាម៉ារ៉ាវីរ៉ា ជាអភិបាលនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ។ លោក ឌូលីប សាម៉ារ៉ាវីរ៉ា បានបញ្ចប់សញ្ញាបត្រវិទ្យាសាស្ត្ររូបវិទ្យា ជំនាញឯកទេសផ្នែកស្ថិតិ ពីសកលវិទ្យាល័យ Sri Jayawardenepura និងបានប្រលងបញ្ចប់ការសិក្សាពីវិទ្យាស្ថាន Chartered Institute of Accountant នៅចក្រភពអង់គ្លេស។ លោកបានចាប់ផ្តើមអាជីពរបស់ខ្លួនលើការស្រាវជ្រាវការវិនិយោគ ក្នុងឆ្នាំ២០០៤ និងបានចូលបម្រើការជាមួយ LOLC Group ក្នុងឆ្នាំ២០០៧។ លោកបានបម្រើការជាអភិបាលនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី នៅប្រទេសមីយ៉ាន់ម៉ា។ លោកមានជំនាញ និងបទពិសោធន៍ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការកែលម្អដំណើរការផ្សេងៗ ការធ្វើផែនការយុទ្ធសាស្ត្រ ការវិនិយោគ និងការទិញភាគហ៊ុន។ លោកឌូលីប ចូលបម្រើការនៅ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ក្នុងខែកក្កដា ឆ្នាំ២០១៨។



**លោក ម៉ៃឃឹល ម័រម៉ែន**

អភិបាលឯករាជ្យ

លោក ម៉ៃឃឹល ម័រម៉ែន ជាអភិបាលឯករាជ្យរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។ លោកបានចាប់ផ្តើមអាជីពការងាររបស់លោកក្នុង នាយកដ្ឋានកិច្ចការបរទេសរបស់ ធនាគារ ABN AMRO នៃប្រទេសហូឡង់ ក្នុងឆ្នាំ១៩៧១ ហើយក្នុងឆ្នាំ១៩៧៣ លោកត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅ ប្រទេសឥណ្ឌូនេស៊ី។ លោក ម៉ៃឃឹល ទទួលបានបទពិសោធន៍ជាច្រើនពីការបម្រើការក្នុងមុខតំណែងខុសៗគ្នា និងការបម្រើការក្នុងប្រទេសនានាជាច្រើន មុនពេលលោក ទទួលបានតំណែងជាថ្នាក់គ្រប់គ្រងជាន់ខ្ពស់។ ក្នុងឆ្នាំ១៩៩២ លោកធ្លាប់បម្រើការក្នុងតំណែងជានាយកភូមិភាគ នៃធនាគារឯកជន ABN AMRO ក្នុងប្រទេសអាមេរិកឡាទីន ហើយចាប់ពីឆ្នាំ១៩៩៤ លោកបានបម្រើការងារឱ្យ ABN AMRO ជានាយកគ្រប់គ្រងប្រចាំប្រទេសជាច្រើនរួមមាន៖ ប្រទេសវៀតណាម ស្រីលង្កា និងហ្វីលីពីន។ ចាប់តាំងពីឆ្នាំ២០០៥ លោក ម៉ៃឃឹល បានបំពេញការងារជាច្រើនក្នុងនាមជាអ្នកប្រឹក្សាយោបល់ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងបម្រើការងារជា ប្រធានក្រុមប្រឹក្សាភិបាលក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនពីរ។ ភាពខ្លាំងនៃវិជ្ជាជីវៈរបស់លោករួមមាន៖ សវនកម្មផ្ទៃក្នុង ការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងការផ្លាស់ប្តូរ។ លោក ម៉ៃឃឹល ម័រម៉ែន ចូលបម្រើការនៅ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ក្នុងខែកុម្ភៈ ឆ្នាំ២០១៣។



**លោក អ៊ីនដ្រាជីត ទីជេស៊ីរីវ៉ាដាណា**
អភិបាលឯករាជ្យ

លោក អ៊ីនដ្រាជីត វីជេស៊ីរីវ៉ាដាណា បច្ចុប្បន្នជាអភិបាលឯករាជ្យ របស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។ លោក អ៊ីនដ្រាជីត ជាទីប្រឹក្សាយោបល់ជំនាញលើផ្នែកអភិវឌ្ឍហិរញ្ញវត្ថុអន្តរជាតិ ដែលមានបទពិសោធន៍ជាង២០ឆ្នាំ មកពីជិត ៣០ប្រទេស។ ជំនាញសំខាន់ៗរបស់លោករួមមាន៖ វិស័យមីក្រូហិរញ្ញវត្ថុ និង សហគ្រាសខ្នាតតូច និងមធ្យម និងការកសាងសមត្ថភាពនៅក្នុងវិស័យហិរញ្ញវត្ថុ។ លោកមានជំនាញ និងបទពិសោធន៍ ក្នុងការរៀបចំយុទ្ធសាស្ត្រនិងអភិវឌ្ឍអាជីវកម្ម ដូចជាប្រព័ន្ធហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យហិរញ្ញវត្ថុ ដោយផ្តោតទៅលើវិស័យមីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូច និងមធ្យម ការផ្លាស់ប្តូរស្ថាប័ន ការបង្កើតផលិតផលថ្មីៗ និងការកែលម្អដំណើរការ។ មុនពេលលោកបម្រើការជាទីប្រឹក្សាយោបល់ លោកបានបម្រើការនៅក្នុងវិស័យធនាគារ ហើយលោកបានរៀបចំ និងវាយតម្លៃសំណើផែនការ និងត្រួតពិនិត្យផែនការ។ ទំនួលខុសត្រូវរបស់លោករួមមាន ហិរញ្ញប្បទាន ឥណទានសម្រាប់សហគ្រាសខ្នាតតូច មធ្យម និងខ្នាតធំ ហិរញ្ញប្បទានពាណិជ្ជកម្ម ហិរញ្ញប្បទានមូលធន កំណែទម្រង់ បង្កើតសមាគមហិរញ្ញប្បទាន និងភតិសន្យាហិរញ្ញវត្ថុ។ លោកបានបង្កើត និង គ្រប់គ្រងសេវាគាំទ្រហិរញ្ញវត្ថុជាច្រើនដូចជា ការរៀបចំគម្រោង ការគ្រប់គ្រងថវិកា គណនេយ្យរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងប្រព័ន្ធព័ត៌មាន (MIS) ។ លោក អ៊ីនដ្រាជីត វីជេស៊ីរីវ៉ាដាណា ចាប់ផ្តើមបម្រើការនៅ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី នៅខែមករា ឆ្នាំ២០១៥។

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវបានធ្វើឡើងរៀងរាល់បីខែម្តង។ នៅក្នុងកិច្ចប្រជុំនីមួយៗ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលទ្ធផលការងាររបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាភិបាលក៏ត្រូវបានជូនដំណឹងអំពីការអភិវឌ្ឍនៅក្នុងវិស័យហិរញ្ញវត្ថុ រួមទាំងការផ្លាស់ប្តូរលក្ខន្តិកៈ ឬបទបញ្ញត្តិ និងរបៀបដែលការផ្លាស់ប្តូរទាំងនោះប៉ះពាល់មកលើក្រុមហ៊ុន។ របាយការណ៍នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រាយការណ៍អំពីលទ្ធផលការងារ និងការប្រតិបត្តិតាម ត្រូវបានត្រួតពិនិត្យ និងពិភាក្សាជាទៀងទាត់ជាមួយនឹងរបាយការណ៍ផ្សេងៗទៀតដែលរួមបញ្ចូលទាំងបញ្ហាដែលមិនមែនជាប្រតិបត្តិការប្រចាំថ្ងៃផងដែរ។

## ក្រមសីលធម៌

អាកប្បកិរិយារបស់បុគ្គលិកទាំងនៅក្នុង និងក្រៅកន្លែងធ្វើការអាចជះឥទ្ធិពលដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ អិលអូអិលស៊ី។ ដូច្នេះបុគ្គលិករបស់ អិលអូអិលស៊ី ទាំងអស់ត្រូវតែគោរពយ៉ាងម៉ឺងម៉ាត់តាមក្រមសីលធម៌របស់ក្រុមហ៊ុន។

**ក្រមសីលធម៌ដែលបុគ្គលិកត្រូវអនុវត្តៈ**

១. បុគ្គលិកត្រូវមានភាពស្មោះត្រង់ និងត្រូវប្រើប្រាស់ពាក្យសម្តីសមរម្យជាមួយបុគ្គលិក និងអតិថិជន មកធ្វើការទៀងទាត់ពេលវេលា ស្លៀកពាក់ឯកសណ្ឋានឱ្យបានខ្ជាប់ខ្ជួន ឧស្សាហ៍ព្យាយាម និងសន្សំសំចៃធនធានរបស់ក្រុមហ៊ុន។

២. បុគ្គលិកត្រូវគោរពសិទ្ធិរបស់អតិថិជនមានដូចជា៖ សិទ្ធិក្នុងការដឹង និងយល់អំពីតម្លៃសេវាកម្ម និងលក្ខខណ្ឌប្រាក់កម្ចីទាំងអស់មុនពេលទទួលប្រាក់ សិទ្ធិមិនទទួលយកប្រាក់កម្ចី សិទ្ធិតវ៉ា ឬសួរសំណួរដើម្បីបញ្ជាក់ពីសេវាកម្មផ្សេងៗរបស់ អិលអូអិលស៊ី សិទ្ធិទទួលបានតារាងកាលវិភាគសងប្រាក់ និងឯកសារសំខាន់ផ្សេងទៀតនៅពេលទទួលប្រាក់កម្ចី និងបង្កាន់ដៃបង់ប្រាក់ សិទ្ធិទទួលបាននូវភាពស្មើគ្នា ការយកចិត្តទុកដាក់ និងការគោរពដោយគ្មានការរើសអើងពីបុគ្គលិក អិលអូអិលស៊ី និងសិទ្ធិទាមទារឱ្យ អិលអូអិលស៊ី រក្សាការសម្ងាត់នូវព័ត៌មានប្រាក់កម្ចី និងព័ត៌មានផ្ទាល់ខ្លួន។

៣. បុគ្គលិកត្រូវគោរពចំពោះអតិថិជនទាំងអស់ដោយស្មើភាពគ្នាដោយគ្មានការរើសអើងពីគណបក្សនយោបាយ ជាតិសាសន៍ ឬសង្គមជាតិឡើយ។

៤. បុគ្គលិកត្រូវរក្សាទំនាក់ទំនងល្អជាមួយអតិថិជន ដូច្នេះលេខទូរសព្ទទំនាក់ទំនងរបស់មន្ត្រីឥណទានត្រូវតែអាចទាក់ទងបាន និងមានការឆ្លើយតបទាន់សភាពការណ៍។

៥. បុគ្គលិកត្រូវអានឱ្យបានឮៗទៅកាន់អតិថិជនអំពីឃ្លាដែលមានចែងនៅក្នុងកិច្ចសន្យា និងកិច្ចសន្យារក្សាការសម្ងាត់ មុនពេលអ្នកប្រមូលទិន្នន័យពីអតិថិជន និងធ្វើការបញ្ចេញសាច់ប្រាក់ជូនពួកគាត់។

៦. បុគ្គលិកត្រូវអាន យល់ច្បាស់ និងអនុវត្តតាមបទបញ្ញត្តិក្រមសីលធម៌របស់ អិលអូអិលស៊ី។ ការបំពានលើក្រមសីលធម៌អាចនឹងទទួលបានការព្រមាន ឬបញ្ឈប់ពីការងារ។

៧. បុគ្គលិកទាំងអស់មានកាតព្វកិច្ចរាយការណ៍មកកាន់ប្រធានផ្ទាល់ នាយក/នាយិកាសាខា ឬនាយក/នាយិកានាយកដ្ឋានប្រសិនបើសង្កេតឃើញមានករណីបំពានលើក្រមសីលធម៌ ឬគោលនយោបាយផ្សេងៗ។ ក្នុងករណីពិសេសណាមួយបុគ្គលិកអាចរាយការណ៍ដោយផ្ទាល់មកកាន់នាយិកានាយកដ្ឋានធនធានមនុស្ស មន្ត្រីប្រតិបត្តិតាម ឬប្រធាននាយកប្រតិបត្តិ។

**សកម្មភាពមិនអនុញ្ញាតៈ**

១. មិនត្រូវប្រើប្រាស់សម្តីគំរោះគំរើយដល់អតិថិជនដែលមានការបង់សងយឺតឡើយ ប៉ុន្តែត្រូវស្តាប់ហេតុផលរបស់អតិថិជន និងកសាងនូវវប្បធម៌ជួយគ្នា និងពិភាក្សាគ្នា។ នៅពេលដោះស្រាយបំណុលជាមួយអតិថិជនជាពិសេសអតិថិជនដែលបង់ប្រាក់យឺត មន្ត្រីឥណទានត្រូវពិភាក្សាជាមួយអតិថិជនដើម្បីដោះស្រាយ និងផ្តល់ដំបូន្មានដល់ពួកគាត់។ បុគ្គលិកមិនត្រូវបង្ខំប្រមូលប្រាក់កម្ចីភ្លាមៗដោយគ្មានអនុគ្រោះចំពោះការយឺតយ៉ាវរបស់អតិថិជនដែលជួបបញ្ហាលំបាកខ្លាំង និងជួបវិបត្តិសាច់ប្រាក់នោះឡើយ។

២. បុគ្គលិកមិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីទទួលយកកម្រៃជើងសារ និងអត្ថប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ បុគ្គលិក និងសាច់ញាតិដែលជាប់ពាក់ព័ន្ធនឹងការដាក់លក់ទ្រព្យរបស់អតិថិជនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមដេញថ្លៃទិញទ្រព្យនោះឡើយ។

៣. បុគ្គលិកមិនត្រូវលេងតុងទីននៅកន្លែងធ្វើការ សេពគ្រឿងស្រវឹងក្នុងម៉ោងការងារ សេពគ្រឿងញៀន លេងល្បែងស៊ីសង ឬប្រើប្រាស់អាវុធជាតិផ្ទុះ ឬសារធាតុដែលច្បាប់ហាមឃាត់ បន្លំឯកសារ ប្រើប្រាស់អំពើហិង្សា ជេរប្រមាថ គំរាមកំហែង ឬរំលោភបំពានផ្លូវភេទលើអ្នកដទៃឡើយ។

៤. បុគ្គលិកមិនត្រូវមានការរើសអើងដូចជា ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ អាយុ។ល។ មិនត្រូវបៀតបៀនអ្នកដទៃ ឬប្រព្រឹត្តអំពើអនាចារ និងមិនត្រូវបើកមើលឬបង្ហោះចែកចាយរូបភាពអាសអាភាសឡើយ។

៥. ក្នុងអំឡុងពេលបម្រើការងារ និងក្រោយពេលបញ្ចប់ការងារជាមួយ អិលអូអិលស៊ី បុគ្គលិកមិនត្រូវចែកចាយ ឬប្រើប្រាស់ព័ត៌មានសម្ងាត់ និងឯកសារសម្ងាត់របស់អតិថិជន និងអិលអូអិលស៊ី ដោយគ្មានការអនុញ្ញាត ឬតម្រូវការពីផ្នែកច្បាប់ឡើយ។

## ឯករាជ្យភាព និងតម្លាភាព

អនុវត្តតាមអភិបាលកិច្ចសាជីវកម្ម អិលអូអិលស៊ី មានក្រុមប្រឹក្សាភិបាលចំនួន ៥រូប ដែលក្នុងនោះ ៣រូប ជាក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ និង ២រូប ជាក្រុមប្រឹក្សាភិបាលឯករាជ្យ។ អិលអូអិលស៊ី អនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មដែលក្នុងនោះរួមមានច្បាប់ពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្ម និងប្រកាសស្តីពីអភិបាលនៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

| ក្រុមប្រឹក្សាភិបាលឯករាជ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសកម្ម | | |
|---|---|---|
| | ឆ្លងកាត់ដំណើរការសាកល្បងពីភាពសាកសម និងត្រឹមត្រូវ នៅធនាគារជាតិនៃកម្ពុជា | ✓ |
| | សមាជិកក្រុមប្រឹក្សាភិបាលត្រូវចូលរួមប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ | ✓ |
| | សមាជិកក្រុមប្រឹក្សាភិបាលត្រូវធ្វើការវិនិច្ឆ័យប្រកបដោយភាពត្រឹមត្រូវ | ✓ |
| | គណៈកម្មាធិការសវនកម្មនៃគ្រឹះស្ថានត្រូវដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ<br>ដែលមានជំនាញផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ | ✓ |
| **តម្លាភាព** | | |
| | ការបង្ហាញដល់សាធារណៈជនៈ<br>- រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងរបស់គ្រឹះស្ថាន<br>- រចនាសម្ព័ន្ធកម្មសិទ្ធិជាមូលដ្ឋាន<br>- រចនាសម្ព័ន្ធក្រុមហ៊ុនមេ និងកម្មសិទ្ធិភាគហ៊ុន ប្រសិនបើមាន<br>- ការដឹកនាំ<br>- ការលើកទឹកចិត្ត<br>- ក្រមសីលធម៌<br>- គោលនយោបាយទាក់ទងនឹងទំនាស់ផលប្រយោជន៍<br>- គោលនយោបាយកម្ចី និងកម្រិតកំណត់សម្រាប់បុគ្គលពាក់ព័ន្ធ | ✓ |
| | - របាយការណ៍ប្រចាំឆ្នាំ<br>- របាយការណ៍សវនកម្ម | ✓ |
| **ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម** | | |
| | - ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនត្រូវអនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយការអនុម័តត្រូវបង្ហាញតាមរយៈហត្ថលេខារបស់ក្រុមប្រឹក្សាភិបាលមួយរូប ឬច្រើនរូប។ | ✓ |
| | - ក្រុមហ៊ុនមិនត្រូវចេញផ្សាយ បោះពុម្ព ឬចែករំលែកច្បាប់ចម្លងនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ លុះត្រាតែរបាយការណ៍ហិរញ្ញវត្ថុនោះត្រូវបានអនុម័តរួចរាល់ ដោយក្រុមប្រឹក្សាភិបាល អមដោយរបាយការណ៍របស់សវនករ។ | ✓ |
| | - ការកោះប្រជុំៈ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងយ៉ាងហោចណាស់ម្តងក្នុងមួយត្រីមាស។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតសម្លេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាភិបាល ឬអ្នកតំណាង ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ។ | ✓ |

# តួនាទី និងទំនួលខុសត្រូវរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

## គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ

### ១. គោលនយោបាយ និងនីតិវិធី

ក. ធានាថាគោលនយោបាយផ្តល់តម្លៃការមានសង្គតិភាពជាមួយនឹងទិសដៅរយៈពេលវែង និងគុណតម្លៃរបស់ស្ថាប័ន។

ខ. ត្រួតពិនិត្យឡើងវិញរាល់ការវាយតម្លៃពីខាងក្រៅចំពោះយុទ្ធសាស្ត្រ និងគោលនយោបាយធនធានមនុស្សរបស់គ្រឹះស្ថាន ហើយរាយការណ៍ទៅក្រុមប្រឹក្សាភិបាលនូវរបកគំហើញ និងការផ្តល់អនុសាសន៍។

គ. ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាភិបាលលើយុទ្ធសាស្ត្រ និងគោលនយោបាយធនធានមនុស្សរបស់អិលអូអិលស៊ី ដោយរួមបញ្ចូលការជ្រើសរើសបុគ្គលិក ការអភិវឌ្ឍ ការថែរក្សាបុគ្គលិក ការទូទាត់ និងផលប្រយោជន៍ផ្សេងៗទៀត។

### ២. ដំណើរការតែងតាំង និងការត្រួតពិនិត្យ

ក. ផ្តល់អនុសាសន៍លើនីតិវិធីក្នុងការជ្រើសរើស និងផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាល។

ខ. ផ្តល់អនុសាសន៍អំពីបុគ្គលឯករាជ្យដែលអាចជាសមាជិកគណៈកម្មាធិការ។

គ. អនុម័តលើការតែងតាំងគណៈគ្រប់គ្រងជាន់ខ្ពស់។

### ៣. ការផ្តល់តម្លៃការ

ក. ត្រួតពិនិត្យ និងផ្តល់អនុសាសន៍លើការរៀបចំតម្លៃការសម្រាប់ក្រុមប្រឹក្សាភិបាលប្រតិបត្តិ រួមមានលក្ខខណ្ឌកិច្ចសន្យាតម្លៃការប្រចាំឆ្នាំ និងការចូលរួមនៅក្នុងផែនការប្រាក់លើកទឹកចិត្តរយៈពេលខ្លី និងរយៈពេលវែងរបស់ក្រុមហ៊ុន។

ខ. ត្រួតពិនិត្យការផ្លាស់ប្តូរ និងការអភិវឌ្ឍសំខាន់ៗរបស់ក្រុមហ៊ុនអំពីតម្លៃការ ការជ្រើសរើសបុគ្គលិក ការថែរក្សាបុគ្គលិក នីតិវិធី និងគោលនយោបាយបញ្ឈប់បុគ្គលិក សម្រាប់គណៈគ្រប់គ្រងជាន់ខ្ពស់។

គ. ត្រួតពិនិត្យ និងអនុម័តយុទ្ធសាស្ត្រប្រាក់លើកទឹកចិត្តរយៈពេលខ្លី ផែនការការងារ និងប្រាក់រង្វាន់បំណាច់ឆ្នាំ។

### ៤. នីតិវិធីរាយការណ៍

ក. គណៈកម្មាធិការនឹងផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាភិបាលទៅតាមពេលវេលាសមស្រប លើផ្នែកដែលចាំបាច់ត្រូវចាត់វិធានការ ឬកែលម្អ។

ខ. គណៈកម្មាធិការនឹងរៀបចំរបាយការណ៍ ប្រសិនបើមានការតម្រូវពីក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់គណៈកម្មាធិការសម្រាប់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។

## គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

### ១. ក្របខណ្ឌគ្រប់គ្រងហានិភ័យ

ក. ផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាភិបាលទាក់ទងនឹងហានិភ័យដែលកំពុងប្រឈមបច្ចុប្បន្ន និងហានិភ័យដែលអាចកើតមាននៅពេលអនាគត យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ និងការអនុវត្តក្នុងការគ្រប់គ្រងហានិភ័យ។

ខ. ត្រួតពិនិត្យលើការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការកំណត់អាទិភាពនៃហានិភ័យដែលអាចកើតមានចំពោះក្រុមហ៊ុន។

គ. ពិភាក្សាលើហានិភ័យនៃការគែបន្លំដែលលើកយកមកពិភាក្សានៅក្នុងគណៈកម្មាធិការ ដោយសវនករឯករាជ្យ និងអនុសាសន៍របស់សវនករ ដើម្បីចាត់វិធានការឱ្យទាន់ពេលវេលា។

ឃ. ត្រួតពិនិត្យទៅលើទស្សនវិស័យនៃហានិភ័យ យុទ្ធសាស្ត្រ និងគោលនយោបាយ ទៅតាមអនុសាសន៍របស់គណៈគ្រប់គ្រង និងធានាឱ្យបាននូវការអនុលោមតាមគោលនយោបាយទាំងនោះ ក៏ដូចជាគោលនយោបាយគ្រប់គ្រងហានិភ័យជារួមរបស់គ្រឹះស្ថាន។ ហានិភ័យដែលកើតមានឡើងជាញឹកញាប់រួមមានហានិភ័យទីផ្សារ ហានិភ័យផលប័ត្រឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យប្រតិបត្តិការ និងហានិភ័យពាណិជ្ជកម្មដែលរួមមានហានិភ័យពាក់ព័ន្ធដូចជា៖

- ហានិភ័យអត្រាការប្រាក់
- ហានិភ័យនៃការប្តូររូបិយប័ណ្ណ
- ហានិភ័យបច្ចេកវិជ្ជាព័ត៌មាន
- ហានិភ័យនៃការបង្កើតប្រតិបត្តិការឡើងវិញបន្ទាប់ពីគ្រោះមហន្តរាយ
- ហានិភ័យប្រតិបត្តិការ
- ហានិភ័យកេរ្តិ៍ឈ្មោះ
- ហានិភ័យនៃការប្រកួតប្រជែង
- ហានិភ័យផ្នែកច្បាប់
- ហានិភ័យនៃការគ្រប់គ្រង និងការអនុលោមតាមច្បាប់
- ហានិភ័យនៃសុវត្ថិភាព សុខភាព និងបរិស្ថាន
- ហានិភ័យនៃការវិនិយោគ
- ហានិភ័យនៃការវាយតម្លៃទ្រព្យសកម្ម
- ហានិភ័យផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអាជីវកម្មដែលត្រូវកត់សម្គាល់មើលជាទៀងទាត់។

### ២. គោលនយោបាយ និងរបាយការណ៍

ក. ត្រួតពិនិត្យទៅលើការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

ខ. ត្រួតពិនិត្យឡើងវិញនូវគោលនយោបាយគ្រប់គ្រងទ្រព្យសកម្ម និងអកម្មរបស់គ្រឹះស្ថានរៀងរាល់មួយឆ្នាំម្តង ឬញឹកញាប់ជាងនេះប្រសិនបើមានតម្រូវការ ហើយត្រួតពិនិត្យថាតើសាច់ប្រាក់របស់គ្រឹះស្ថានត្រូវបានចាត់ចែង និងគ្រប់គ្រងស្របទៅតាមគោលនយោបាយដែរឬទេ។

គ. ត្រួតពិនិត្យគោលការណ៍ណែនាំរបស់គ្រឹះស្ថានទៅលើការទទួលយកហានិភ័យផ្នែកហិរញ្ញវត្ថុ និងត្រួតពិនិត្យការអនុវត្តជាក់ស្តែងធៀបនឹងកម្រិតកំណត់។

ឃ. ត្រួតពិនិត្យរបាយការណ៍របស់គណៈគ្រប់គ្រង ដោយមានបញ្ចូលលម្អិតពីភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃ មុខងារគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថាន ព្រមទាំងការអនុវត្តរបស់គណៈគ្រប់គ្រងលើការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងអនុសាសន៍ និងធានាថាបានចាត់វិធានការសមស្របចំពោះហានិភ័យដែលអាចកើតមាន។

ង. ត្រួតពិនិត្យផលប៉ះពាល់លើតារាងតុល្យការគណនីប្រាក់ចំណេញ និងខាត និងសាច់ប្រាក់ងាយស្រួល ដែលកើតឡើងពីការប្រែប្រួលនៃបរិមាណ និងតម្លៃនៃផលិតផលថ្លៃដើម កំណើននៃឥណទាន និងប្រាក់កម្ចីពីម្ចាស់កម្ចី/ប្រាក់បញ្ញើ ព្រមទាំងផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលនៃយុទ្ធសាស្ត្រវិនិយោគ និងអាកប្បកិរិយារបស់អតិថិជន។

## ៣. ការធានារ៉ាប់រង និងការអនុលោមតាមច្បាប់

ក. ត្រួតពិនិត្យលើទំហំការធានា និងតម្លៃនៃកម្មវិធីធានារ៉ាប់រងសម្រាប់គ្រឹះស្ថាន។

ខ. ធានាថាគ្រឹះស្ថានបំពេញតាមតម្រូវការច្បាប់ និងបញ្ញត្តិនានា កំណត់ដោយម្ចាស់កម្ចី ដែលមានចែងនៅក្នុងកិច្ចសន្យាកម្ចី។

## ៤. បញ្ហាផ្សេងទៀត

ក. ត្រួតពិនិត្យដោយលម្អិតលើចំណុចដែលត្រូវបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់គ្រឹះស្ថាន ទាក់ទងនឹងសកម្មភាពរបស់គណៈកម្មាធិការ។

ខ. រៀបចំធ្វើសមាយិកភាពទៅលើការអនុវត្តរបស់ខ្លួនយ៉ាងហោចណាស់រៀងរាល់មួយឆ្នាំម្តង និងធានាថាគណៈកម្មាធិការមានធនធានគ្រប់គ្រាន់សម្រាប់បំពេញភារកិច្ចរបស់ខ្លួន និងធានាថាវគ្គបណ្តុះបណ្តាលចាំបាច់ត្រូវបានផ្តល់ទៅឱ្យសមាជិកគណៈកម្មាធិការទៅតាមតម្រូវការ និងជាទៀងទាត់។ គណៈកម្មាធិការនឹងផ្តល់អនុសាសន៍លើការផ្លាស់ប្តូរ ដែលគណៈកម្មាធិការគិតថាចាំបាច់ទៅក្រុមប្រឹក្សាភិបាល ដើម្បីសុំការអនុម័ត។

គ. ត្រួតពិនិត្យបញ្ញត្តិរបស់គណៈកម្មាធិការរៀងរាល់មួយឆ្នាំម្តង និង/ឬ ពេលមានតម្រូវការ។

## ៥. នីតិវិធីរាយការណ៍

ក. គណៈកម្មាធិការត្រូវផ្តល់អនុសាសន៍ ទៅក្រុមប្រឹក្សាភិបាល ទៅលើវិធានការ ឬតម្រូវការកែលម្អផ្សេងៗ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។

ខ. គណៈកម្មាធិការត្រូវរៀបចំរបាយការណ៍អំពីសកម្មភាពរបស់ខ្លួនដែលត្រូវបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាភិបាល ប្រសិនបើមានតម្រូវការពីក្រុមប្រឹក្សាភិបាល។

# គណៈកម្មាធិការសវនកម្ម

## ១. របាយការណ៍ហិរញ្ញវត្ថុ

គណៈកម្មាធិការត្រូវត្រួតពិនិត្យ និងសួរដេញដោលនៅពេលចាំបាច់ដើម្បី៖

ក. ធានាថាគោលនយោបាយគណនេយ្យ ឬការកែសម្រួលនានាមានភាពស៊ីសង្វាក់គ្នា ដែលត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ។

ខ. ធានាថាព័ត៌មានដែលត្រូវផ្តល់ជូនទៅសាធារណជន ធនាគារជាតិនៃកម្ពុជា អង្គភាពច្បាប់ និងដៃគូពាក់ព័ន្ធ មានភាពច្បាស់លាស់ត្រឹមត្រូវ និងអាចជឿទុកចិត្តបាន។

គ. ធានាថាព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានពាក់ព័ន្ធនឹងហានិភ័យនានាមានភាពត្រឹមត្រូវ ច្បាស់លាស់ និងវាយតម្លៃពីវិធីសាស្ត្រគណនេយ្យដែលត្រូវបានប្រើប្រាស់សម្រាប់បង្កើតគណនីឯកត្តជនគណនីសរុបរួម និងរបាយការណ៍ហិរញ្ញវត្ថុ។

ឃ. ធានាថាគ្រឹះស្ថានអនុលោមតាមស្តង់ដារគណនេយ្យ និងធ្វើការវាស់វែងបានយ៉ាងត្រឹមត្រូវ។

ង. សួរដេញដោលទៅលើមតិយោបល់របស់សវនករឯករាជ្យ។

ច. ធានាភាពច្បាស់លាស់នៃព័ត៌មាន និងខ្លឹមសារនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន និង

ឆ. ធានាព័ត៌មានចាំបាច់ដែលត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដូចជាព័ត៌មានអំពីប្រតិបត្តិការហិរញ្ញវត្ថុ និងអភិបាលកិច្ច (ដែលទាក់ទងនឹងសវនកម្ម និងការគ្រប់គ្រងហានិភ័យ) មានភាពត្រឹមត្រូវ។

## ២. ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការត្រូវ៖

ក. ត្រួតពិនិត្យ និងអនុម័តលើរបាយការណ៍ដែលត្រូវបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ។

ខ. វាយតម្លៃពីគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសពិនិត្យថាតើប្រព័ន្ធវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យមានភាពត្រឹមត្រូវស៊ីសង្វាក់គ្នាឬទេ និងផ្តល់អនុសាសន៍បន្ថែមពេលចាំបាច់។

## ៣. ការអនុលោមតាមច្បាប់ ប្រព័ន្ធផ្តល់ព័ត៌មានដោយ សម្ងាត់ និងការកែបន្លំ

គណៈកម្មាធិការត្រូវ៖

ក. ត្រួតពិនិត្យទៅលើភាពគ្រប់គ្រាន់ និងសុវត្ថិភាពនៃការរៀបចំរបស់គ្រឹះស្ថាន សម្រាប់ឱ្យបុគ្គលិក និងដៃគូពាក់ព័ន្ធក្នុងការលើកឡើងពីការព្រួយបារម្ភ អំពីភាពដែលគ្រឹះស្ថានអាចអនុវត្តខុសក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឬបញ្ហាដទៃទៀត។ គណៈកម្មាធិការត្រូវធានាឱ្យបានថាការរៀបចំទាំងនោះអាចឱ្យគណៈកម្មាធិការធ្វើការស៊ើបអង្កេតដោយឯករាជ្យទៅលើបញ្ហាទាំងនោះបាន និងចាត់វិធានការតាមដានសមស្រប។

ខ. ត្រួតពិនិត្យទៅលើនីតិវិធីរបស់គ្រឹះស្ថានក្នុងការរកឃើញនូវការកែបន្លំ។

គ. ត្រួតពិនិត្យទៅលើប្រព័ន្ធ និងការគ្រប់គ្រងរបស់គ្រឹះស្ថាន ក្នុងការបង្ការការសូកប៉ាន់ និងបង្ការមិនឱ្យគ្រឹះស្ថានទទួលបានរបាយការណ៍មិនអនុលោមតាមច្បាប់ ពីអង្គភាពច្បាប់ ឬដៃគូពាក់ព័ន្ធ។

## ៤. សវនកម្មផ្ទៃក្នុង

គណៈកម្មាធិការត្រូវៈ

ក. គ្រប់គ្រង និងត្រួតពិនិត្យទៅលើប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង ស្របទៅតាមប្រព័ន្ធគ្រប់គ្រងហានិភ័យជារួមរបស់គ្រឹះស្ថាន។

ខ. អនុម័តលើការតែងតាំង និងការបញ្ឈប់សវនករផ្ទៃក្នុង។

គ. ត្រួតពិនិត្យ និងវាយតម្លៃផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ការបណ្តុះបណ្តាល និងផែនការបុគ្គលិក។

ឃ. ត្រួតពិនិត្យរបាយការណ៍ដែលសវនករផ្ទៃក្នុងផ្ញើជូនគណៈកម្មាធិការ។

ង. តាមដានការអនុវត្តវិធានការកែលម្អឱ្យមានប្រសិទ្ធភាព តាមរយៈការពិនិត្យតាមដានទៅលើអនុសាសន៍របស់សវនករផ្ទៃក្នុង ដែលថ្នាក់គ្រប់គ្រងមិនទាន់បានអនុវត្តរួចរាល់ និងបន្តគាំទ្រការងាររបស់សវនកម្មផ្ទៃក្នុង។

ច. ជួបប្រជុំជាមួយដៃគូសវនកម្មផ្ទៃក្នុងយ៉ាងហោចណាស់ ៤ដងក្នុងមួយឆ្នាំ និងយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំដោយគ្មានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សាពីការទទួលខុសត្រូវ និងបញ្ហានានា ដែលរកឃើញដោយសវនករផ្ទៃក្នុង។

ឆ. សវនករផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ទៅប្រធានគណៈកម្មាធិការ និងប្រធានក្រុមប្រឹក្សាភិបាល។

## ៥. សវនកម្មឯករាជ្យ

គណៈកម្មាធិការត្រូវៈ

ក. គិតគូរ និងផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាភិបាលទាក់ទងនឹងការតែងតាំងថ្មី ការតែងតាំងឡើងវិញ និងការបញ្ឈប់សវនករឯករាជ្យរបស់គ្រឹះស្ថាន។ គណៈកម្មាធិការត្រូវត្រួតពិនិត្យលើដំណើរការជ្រើសរើសសវនករថ្មី ហើយប្រសិនបើសវនករលាឈប់ពីការងារ គណៈកម្មាធិការត្រូវស៊ើបអង្កេតពីមូលហេតុដែលបណ្តាលឱ្យឈប់ និងសម្រេចថាតើគួរចាត់វិធានដែរឬទេ។

ខ. ត្រួតពិនិត្យលើឯករាជ្យភាពរបស់សវនករឯករាជ្យ គោលដៅ និងប្រសិទ្ធភាពនៃដំណើរការសវនកម្ម ព្រមទាំងរបាយការណ៍ពីសវនករឯករាជ្យ លើនីតិវិធីត្រួតពិនិត្យគុណភាពផ្ទៃក្នុងរបស់ខ្លួន។

គ. ត្រួតពិនិត្យលើទំនាក់ទំនងជាមួយសវនករឯករាជ្យ ដូចជាៈ

- ផ្តល់អនុសាសន៍លើថ្លៃសេវា ថាតើថ្លៃសេវាប្រើប្រាស់សម្រាប់សេវាកម្មសវនកម្ម ឬមិនមែនសវនកម្ម ហើយថាតើកម្រិតនៃថ្លៃសេវាអាចប្រើប្រាស់គ្រប់គ្រាន់សម្រាប់ការធ្វើសវនកម្មដែរឬទេ។
- អនុម័តលើលក្ខខណ្ឌនៃការផ្តល់សេវា ព្រមទាំងលិខិតបញ្ជាក់ពីការផ្តល់សេវា (Engagement Letter) ដែលត្រូវចេញនៅពេលចាប់ផ្តើមធ្វើសវនកម្ម និងទំហំនៃការធ្វើសវនកម្ម។
- ធានាឱ្យបានថាគ្មានទំនាក់ទំនងណាមួយ ដូចជាទំនាក់ទំនងគ្រួសារ ប្រធានគ្រប់គ្រង និងបុគ្គលិក ការវិនិយោគ ទំនាក់ទំនងផ្នែកហិរញ្ញវត្ថុឬជំនួញ រវាងសវនករនឹងគ្រឹះស្ថានក្រៅពីទំនាក់ទំនងគ្មានធម្មតាក្នុងអាជីវកម្មឡើយ។
- ត្រួតពិនិត្យលើការអនុលោមតាមច្បាប់របស់សវនករ ជាមួយនឹងក្រមសីលធម៌ និងជំនាញវិជ្ជាជីវៈដែលពាក់ព័ន្ធទៅលើការផ្លាស់ប្តូរដៃគូសវនករ ថ្លៃសេវាដែលគ្រឹះស្ថាន ត្រូវបង់ធៀបទៅនឹងចំណូលជារួមការិយាល័យដៃគូ និងតម្រូវការពាក់ព័ន្ធផ្សេងៗទៀត។
- ធានាការសម្របសម្រួលសកម្មភាពការងាររបស់សវនករផ្ទៃក្នុង។

ឃ. ជួបប្រជុំជាប្រចាំជាមួយសវនករឯករាជ្យ ដូចជាជួបម្តងនៅដំណាក់កាលធ្វើផែនការមុនពេលធ្វើសវនកម្ម និងម្តងទៀតនៅពេលធ្វើរបាយការណ៍បន្ទាប់ពីធ្វើសវនកម្ម។ គណៈកម្មាធិការត្រូវជួបជាមួយសវនករឯករាជ្យយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដោយគ្មានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សាពីទំនួលខុសត្រូវរបស់សវនករ និងបញ្ហានានា ដែលរកឃើញដោយសវនករ។

ង. ត្រួតពិនិត្យ និងអនុម័តលើសវនកម្មប្រចាំឆ្នាំ និងធានាថាលទ្ធផលសវនកម្មស្របទៅតាមទំហំនៃសវនកម្មដែលបានព្រមព្រៀង។

ច. ត្រួតពិនិត្យរបកគំហើញសវនកម្មជាមួយសវនករឯករាជ្យរួមមានៈ

- ការពិភាក្សាទៅលើបញ្ហាសំខាន់ៗដែលរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។
- ការទទួលខុសត្រូវ និងការវិនិច្ឆ័យសវនកម្ម។
- កម្រិតនៃកំហុសដែលបានកត់សម្គាល់ក្នុងអំឡុងពេលធ្វើសវនកម្ម។
- ប្រសិទ្ធភាពនៃការធ្វើសវនកម្ម។

ឆ. ត្រួតពិនិត្យរបាយការណ៍របស់គណៈគ្រប់គ្រង និងការឆ្លើយតបរបស់គណៈគ្រប់គ្រងទៅនឹងរបកគំហើញ និងអនុសាសន៍របស់សវនករ។

ជ. បង្កើត និងអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាមិនមែនសវនកម្មដោយសវនករឯករាជ្យ និងទទួលយកការណែនាំផ្សេងៗដែលពាក់ព័ន្ធទៅនឹងបញ្ហានានាដែលអាចកើតមាន។

## ៦. បញ្ហាផ្សេងទៀត

គណៈកម្មាធិការត្រូវៈ

ក. មានធនធានគ្រប់គ្រាន់ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

ខ. ទទួលបានការបណ្តុះបណ្តាលសមស្រប និងមានពេលវេលាគ្រប់គ្រាន់ ទាំងការបណ្តុះបណ្តាលដំបូងសម្រាប់សមាជិកចូលថ្មី និងការបណ្តុះបណ្តាលជាប្រចាំសម្រាប់សមាជិកទាំងអស់។

គ. ទទួលខុសត្រូវក្នុងការសម្របសម្រួលសវនករផ្ទៃក្នុង និងសវនករឯករាជ្យ។

ឃ. ត្រួតពិនិត្យការស៊ើបអង្កេតលើសកម្មភាពនានា ដែលស្ថិតនៅក្នុងក្របខណ្ឌបញ្ញត្តិរបស់ខ្លួន។

ង. រៀបចំធ្វើសមាយិកភាពទៅលើការអនុវត្តរបស់ខ្លួន និងយ៉ាងហោចណាស់រៀងរាល់មួយឆ្នាំម្តង ធ្វើការត្រួតពិនិត្យ ទៅលើក្របខណ្ឌបញ្ញត្តិរបស់ខ្លួន ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពជាអតិបរមា និងផ្តល់អនុសាសន៍រាល់ការកែលម្អទៅក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត។

## ៧. នីតិវិធីនៃការរាយការណ៍

ក. គណៈកម្មាធិការត្រូវផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាភិបាល ទៅលើវិធានការ ឬតម្រូវការកែលម្អផ្សេងៗ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។

ខ. គណៈកម្មាធិការត្រូវរៀបចំរបាយការណ៍អំពីសកម្មភាពរបស់ខ្លួនដែលត្រូវបញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល ប្រសិនបើមានតម្រូវការពីក្រុមប្រឹក្សាភិបាល។

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយក្នុងការបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំសម្រាប់ឆ្នាំ២០១៩។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ អិលអូអិលស៊ី គឺផ្តល់សេវាហិរញ្ញវត្ថុដល់សហគ្រិន និងក្រុមគ្រួសារនៅកម្រិតមូលដ្ឋានពីរ៉ាមីតនៃ សេដ្ឋកិច្ចសង្គមនូវឱកាសសេដ្ឋកិច្ច ក្នុងការផ្លាស់ប្តូរជីវភាពរស់នៅរបស់ពួកគាត់។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៅក្នុងឆ្នាំសារពើពន្ធ មានសមាសភាពដូចខាងក្រោម៖

| ល.រ | ឈ្មោះ | មុខតំណែង |
|---|---|---|
| ១ | លោក ប្រ៊ីនលី ដេ ហ្សីលវ៉ា | ប្រធានក្រុមប្រឹក្សាភិបាល |
| ២ | លោក ខនរ៉ាត ដាយអឺស | អភិបាល |
| ៣ | លោក ឌូលីប វ៉ាស៊ីកា សាម៉ារ៉ាវីរ៉ា | អភិបាល |
| ៤ | លោក ម៉ៃឃើល ម៉រម៉ែន | អភិបាលឯករាជ្យ |
| ៥ | លោក អ៊ីនដ្រាជីត វីជេស៊ីរីវ៉ាដាណា | អភិបាលឯករាជ្យ |

## គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានតែងតាំងគណៈកម្មាធិការ៣ រួមមាន គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម និងគណៈកម្មាធិការតែងតាំងនិងផ្តល់តម្លៃការ។

គណៈកម្មាធិការទាំងនេះអនុវត្តមុខងារទៅតាមបទបញ្ញត្តិ ឬ Terms of Reference របស់គណៈកម្មាធិការនីមួយៗដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងអនុវត្តមុខងារបន្ថែមទៅតាមរបៀបវារៈដែលបានអនុម័តជាមុន ដើម្បីធានាថាគ្រប់ចំណុចសំខាន់ៗទាំងអស់ត្រូវបានបញ្ចូល ព្រមទាំងមានភាពបត់បែនគ្រប់គ្រាន់ដើម្បីលើកទឹកចិត្តដល់សមាជិកគណៈកម្មាធិការ ដើម្បីលើកឡើងនូវបញ្ហាផ្សេងៗទៀតដែលពួកគេយល់ថាគួរយកចិត្តទុកដាក់។

ក្រុមប្រឹក្សាភិបាលផ្តល់សិទ្ធិដល់គណៈកម្មាធិការក្នុងការស្នើសុំព័ត៌មានបន្ថែម និងកោះហៅគណៈគ្រប់គ្រងសំខាន់ៗដើម្បីផ្តល់ព័ត៌មានលម្អិត ឬពិភាក្សាអនុសាសន៍នានាដើម្បីចាត់វិធានការ ដើម្បីធានាថាប្រតិបត្តិការ ហានិភ័យ អភិបាលកិច្ច ឬបទបញ្ញត្តិដែលពាក់ព័ន្ធត្រូវបានពិភាក្សាស៊ីជម្រៅ និងសម្រេចបានដំណោះស្រាយល្អប្រសើរ។ ដោយសារតែកំណត់ហេតុប្រជុំរបស់គណៈកម្មាធិការនីមួយៗត្រូវបានលើកយកមកពិនិត្យឡើងវិញនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ទទួលបានព័ត៌មានទាំងអស់អំពីការពិភាក្សានៅក្នុងគណៈកម្មាធិការនីមួយៗ និងអាចចែករំលែកមតិយោបល់នៅពេលចាំបាច់។

### ១. គណៈកម្មាធិការសវនកម្ម រួមមានសមាសភាពដូចខាងក្រោម៖

| ល.រ | ឈ្មោះ | តួនាទី | មុខតំណែង |
|---|---|---|---|
| ១ | លោក ម៉ៃឃើល ម៉រម៉ែន | ប្រធាន | អភិបាលឯករាជ្យ |
| ២ | លោក ប្រ៊ីនលី ដេ ហ្សីលវ៉ា | សមាជិក | ប្រធានក្រុមប្រឹក្សាភិបាល |
| ៣ | លោក អ៊ីនដ្រាជីត វីជេស៊ីរីវ៉ាដាណា | សមាជិក | អភិបាលឯករាជ្យ |

### លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម

នៅក្នុងឆ្នាំ២០១៩ គណៈកម្មាធិការសវនកម្មបានប្រារព្ធកិច្ចប្រជុំរបស់ខ្លួនចំនួន ៤លើក (រៀងរាល់មួយត្រីមាសម្តង) ដែលបានពិភាក្សា និងអនុម័តដូចខាងក្រោម៖

- តាមដានពីការអនុវត្តរបស់គណៈគ្រប់គ្រងទៅតាមអនុសាសន៍របស់សវនករផ្ទៃក្នុង និងគណៈកម្មាធិការសវនកម្ម
- ពិភាក្សាពីដំណោះស្រាយទៅលើរបកគំហើញរបស់សវនករផ្ទៃក្នុង
- ពិនិត្យ និងពិភាក្សាពីរបាយការណ៍នៃការគៃបន្លំក្នុង ឆ្នាំ២០១៨
- អនុម័តលើរបាយការណ៍ប្រចាំឆ្នាំស្តីពីរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ២០១៨
- ត្រួតពិនិត្យ និងអនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០១៨ របស់គ្រឹះស្ថាន
- ត្រួតពិនិត្យពីដំណើរការនៃ ACL Software
- ត្រួតពិនិត្យលើរបាយការណ៍នៃការបណ្តុះបណ្តាលសវនករផ្ទៃក្នុង
- វាយតម្លៃការងារប្រចាំឆ្នាំរបស់នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ជួបប្រជុំជាមួយនឹងស្នងការគណនីឯករាជ្យរៀងរាល់ត្រីមាស
- អនុម័តលើចំណាយបន្ថែមសម្រាប់ការធ្វើរបាយការណ៍សវនកម្មការិយបរិច្ឆេទត្រឹមខែមិថុនា ឆ្នាំ២០១៩ (ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា)។
- អនុម័តលើរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំត្រីមាសទី២ និងត្រីមាសទី៣ ឆ្នាំ២០១៩ សម្រាប់គណៈកម្មការមូលបត្រកម្ពុជា
- អនុម័តលើផែនការការងារប្រចាំឆ្នាំ២០២០ របស់សវនករផ្ទៃក្នុង
- អនុម័តលើផែនការ និងថវិកាសម្រាប់ការបណ្តុះបណ្តាលសវនករផ្ទៃក្នុងសម្រាប់ ឆ្នាំ២០២០
- អនុម័តលើការជ្រើសតាំងស្នងការគណនីឯករាជ្យសម្រាប់រយៈពេល៣ឆ្នាំ គិតចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២
- ត្រួតពិនិត្យ និងអនុម័តពីគោលដៅការងារសម្រាប់ឆ្នាំ២០២០ របស់នាយកនាយកដ្ឋានសវនកម្ម
- ត្រួតពិនិត្យ និងអនុម័តលើ មុខងារភារកិច្ច និងទំនួលខុសត្រូវ (Term of Reference) របស់គណៈកម្មាធិការសវនកម្ម
- ត្រួតពិនិត្យ និងពិភាក្សាពីអត្រាលាលែងតំណែងរបស់បុគ្គលិកសវនកម្មនិងពិភាក្សាពីកម្រិតប្រាក់បៀវត្សរបស់បុគ្គលិកសវនកម្ម។

## ២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម រួមមានសមាសភាពដូចខាងក្រោម៖

| ល.រ | ឈ្មោះ | តួនាទី | មុខតំណែង |
|---|---|---|---|
| ១ | លោក ម៉ៃឃីល ម៉ារម៉ែន | ប្រធាន | អភិបាលឯករាជ្យ |
| ២ | លោក ប្រ៊ីនលី ដេ ហ្សីលវ៉ា | សមាជិក | ប្រធានក្រុមប្រឹក្សាភិបាល |
| ៣ | លោក ខនរ៉ាត ដាយអឹស | សមាជិក | អភិបាល |

### លទ្ធផលការងាររបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

នៅក្នុងឆ្នាំ២០១៩ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម បានប្រារព្ធកិច្ចប្រជុំរបស់ខ្លួនចំនួន ៤លើក (រៀងរាល់មួយត្រីមាសម្តង) ដែលបានពិភាក្សា និងអនុម័តដូចខាងក្រោម៖

- ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងហានិភ័យរៀងរាល់ត្រីមាស
- វិភាគពីផលប៉ះពាល់ដល់អាជីវកម្ម ទាក់ទងនឹងការដក EBA តម្លៃកសិផលធ្លាក់ចុះ ។ល។
- ត្រួតពិនិត្យមើលពីការអនុលោមតាមគោលការណ៍ផ្តល់កម្ចីរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
- វិភាគពីហានិភ័យនៃការលាលែងតំណែងរបស់បុគ្គលិកសំខាន់ៗរបស់ស្ថាប័ន និងកំណត់យុទ្ធសាស្ត្រដើម្បីការពារហានិភ័យ
- ត្រួតពិនិត្យរបាយការណ៍ប្រតិបត្តិតាម (Compliance Report) រៀងរាល់ត្រីមាស
- ត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាពក្នុងការឆ្លើយតបទៅនឹងរបាយការណ៍ត្រួតពិនិត្យដល់ទីកន្លែងរបស់ ធនាគារជាតិនៃកម្ពុជា
- តាមដានការអនុវត្តរបស់គណៈគ្រប់គ្រងលើរបាយការណ៍ស្តង់ដារហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា
- អនុម័តគោលនយោបាយ (Transfer Pricing Policy)
- អនុម័តលើសេណារីយ៉ូ និងលទ្ធផលស្ត្រេសតេស្តក្របខណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាពក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩
- អនុម័តលើថវិកាសម្រាប់ទាញយករបាយការណ៍ CBC Portfolio Review
- ពិនិត្យ និងពិភាក្សាពី FinTech Risk
- ពិនិត្យ និងពិភាក្សាពីហានិភ័យអត្រាប្តូរប្រាក់ទៅលើការបោះមូលបត្របំណុល
- ពិនិត្យ និងពិភាក្សាពីបម្រែបម្រួលទៅលើចំនួនអតិថិជនឥណទានក្រុម និងអតិថិជនឥណទានឯកត្តជន
- ត្រួតពិនិត្យរបាយការណ៍កំណើនឥណទានសាខានៅរាជធានីភ្នំពេញ
- ត្រួតពិនិត្យ និងពិភាក្សាពីយុទ្ធសាស្ត្រក្នុងការរក្សាផលប័ត្រឥណទានជារូបិយវត្ថុខ្មែររៀលឱ្យធំជាង២០%
- វិភាគពីហានិភ័យនៃការគំរាមកំហែងពីដៃគូប្រកួតប្រជែង
- អនុម័តទៅលើវិធីសាស្ត្រនៃការធ្វើ ECL (CIFRS9)
- ពិភាក្សាពីរបាយការណ៍ស្ទង់មតិទៅលើចំណូលរបស់អ្នកបើកកង់បី
- ពិភាក្សា និងអនុម័តទៅលើការកំណត់អត្តសញ្ញាណរបស់ភាគីពាក់ព័ន្ធ (Related Parties)

## ៣. គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ រួមមានសមាសភាពដូចខាងក្រោម៖

| ល.រ | ឈ្មោះ | តួនាទី | មុខតំណែង |
|---|---|---|---|
| ១ | លោក អ៊ីនដ្រាជីត វីជេស៊ីរីវ៉ាដាណា | ប្រធាន | អភិបាលឯករាជ្យ |
| ២ | លោក ខនរ៉ាត ដាយអឹស | សមាជិក | អភិបាល |
| ៣ | លោក ឌូលីប រ៉ាស៊ីកា សាម៉ារ៉ាវីរ៉ា | សមាជិក | អភិបាល |

### លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ

នៅក្នុងឆ្នាំ២០១៩ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ បានប្រារព្ធកិច្ចប្រជុំរបស់ខ្លួនចំនួន៤ លើក (រៀងរាល់មួយត្រីមាសម្តង) ដែលបានពិភាក្សា និងអនុម័តដូចខាងក្រោម៖

- ត្រួតពិនិត្យរបាយការណ៍ធនធានមនុស្ស និងរបាយការណ៍បណ្តុះបណ្តាលបុគ្គលិករៀងរាល់ត្រីមាស
- ត្រួតពិនិត្យផែនការនៃការកសាងសមត្ថភាពរបស់គណៈគ្រប់គ្រង
- ពិភាក្សាពីការដំឡើងតំណែង និងកំណែប្រែរចនាសម្ព័ន្ធរបស់ស្ថាប័ន
- ត្រួតពិនិត្យរបាយការណ៍ស្ទង់មតិអំពីការពេញចិត្តរបស់បុគ្គលិក
- ត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវអំពីប្រាក់បៀវត្ស និងអត្ថប្រយោជន៍របស់ស្ថាប័នមីក្រូហិរញ្ញវត្ថុធំៗទាំង៥ ដែលធ្វើឡើងដោយ Mercer
- អនុម័តផ្តល់ប្រាក់ឧបត្ថម្ភមុខតំណែង
- អនុម័តផ្តល់ប្រាក់បន្ថែមដំណាច់ឆ្នាំ២០១៨ និងការដំឡើងបៀវត្សសម្រាប់ឆ្នាំ២០១៩
- វាយតម្លៃការងារក្នុងឆ្នាំ២០១៨ និងកំណត់គោលដៅការងារសម្រាប់ឆ្នាំ២០១៩ របស់ប្រធាននាយកប្រតិបត្តិ និងប្រធាននាយកហិរញ្ញវត្ថុ
- ពិភាក្សា និងអនុម័តលើការជ្រើសរើសប្រព័ន្ធគ្រប់គ្រងទិន្នន័យធនធានមនុស្ស
- ពិភាក្សាពីការអនុវត្តទៅតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការទូទាត់ប្រាក់អតីតភាពការងារសម្រាប់និយោជិត
- ពិភាក្សាពីសំណើររបស់គណៈគ្រប់គ្រង ស្តីពីការផ្លាស់ប្តូរឈ្មោះមុខតំណែងរបស់មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន និងគណនេយ្យករ
- ពិនិត្យ និងអនុម័តលើកម្មវិធីអាហារូបករណ៍ និងឱកាសហាត់ការការងារនៅ អិលអូអិលស៊ី
- អនុម័តលើថវិកាសម្រាប់ការបណ្តុះបណ្តាលបុគ្គលិក ឆ្នាំ២០២០
- អនុម័តដំឡើងប្រាក់ឧបត្ថម្ភថ្នាំពេទ្យដល់បុគ្គលិក
- អនុម័តលើការទិញធានារ៉ាប់រងសុខភាពដល់គណៈគ្រប់គ្រង
- អនុម័តផ្តល់សិទ្ធិដល់គណៈគ្រប់គ្រងក្នុងការដំឡើងកម្រិតប្រាក់បៀវត្សរបស់បុគ្គលិកបើកបរ បុគ្គលិកអនាម័យ និងសន្តិសុខស្របតាមប្រកាសរបស់រាជរដ្ឋាភិបាល
- អនុម័តលើការដំឡើងកម្រិតប្រាក់បៀវត្សរបស់បុគ្គលិក ទាំង Fiel Staff និង Support Staff
- ត្រួតពិនិត្យ និងអនុម័តគោលដៅការងារឆ្នាំ២០២០ សម្រាប់ប្រធាននាយកប្រតិបត្តិ និងបុគ្គលិកក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាននាយកប្រតិបត្តិ
- ត្រួតពិនិត្យ និងអនុម័តលើមុខងារភារកិច្ច និងទំនួលខុសត្រូវ (Term of Reference) របស់គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវបានធ្វើឡើងរៀងរាល់បីខែម្តង។ នៅក្នុងកិច្ចប្រជុំនីមួយៗ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលទ្ធផលការងាររបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាភិបាលក៏ត្រូវបានជូនដំណឹងអំពីការអភិវឌ្ឍនៅក្នុងវិស័យហិរញ្ញវត្ថុ រួមទាំងការផ្លាស់ប្តូរលក្ខន្តិកៈ ឬបទបញ្ញត្តិ និងរបៀបដែលការផ្លាស់ប្តូរទាំងនោះប៉ះពាល់មកលើក្រុមហ៊ុន។

## ទំនាស់ផលប្រយោជន៍របស់ក្រុមប្រឹក្សាភិបាលនៅក្នុងកិច្ចសន្យា

ក្រុមប្រឹក្សាភិបាលត្រូវប្រកាសទំនាស់ផលប្រយោជន៍ ទៅតាមការតម្រូវរបស់ក្រុមហ៊ុន។ ការប្រកាសអំពីទំនាស់ផលប្រយោជន៍នេះត្រូវបានកត់សម្គាល់ដោយក្រុមប្រឹក្សាភិបាល កត់ត្រានៅក្នុងកំណត់ហេតុប្រជុំ និងបញ្ចូលទៅក្នុងបញ្ជីទំនាស់ផលប្រយោជន៍ ដែលត្រូវរក្សាទុកដោយក្រុមហ៊ុន។ ទោះជាយ៉ាងនេះក្តី មកដល់ពេលបច្ចុប្បន្នគ្មានក្រុមប្រឹក្សាភិបាលរូបណាមានទំនាស់ផលប្រយោជន៍ជាមួយក្រុមហ៊ុនឡើយ។

## ការកាន់កាប់ភាគហ៊ុនដោយក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន គ្មានក្រុមប្រឹក្សាភិបាលរូបណាកាន់កាប់ភាគហ៊ុននៅក្នុងអិលអូអិលស៊ី (ខេមបូឌា) ឡើយ។

## អាណត្តិរបស់ក្រុមប្រឹក្សាភិបាល

អាណត្តិរបស់ក្រុមប្រឹក្សាភិបាលមិនត្រូវបានកំណត់ឡើយ និងអាចលាឈប់ ឬបញ្ឈប់ដោយភាគទុនិក។ ក្រុមប្រឹក្សាភិបាលអាចត្រូវបានបញ្ឈប់ដោយការបោះឆ្នោតសម្លេងភាគច្រើនដោយភាគទុនិកទាំងអស់នៅក្នុងកិច្ចប្រជុំទូទៅ។ ក្រុមប្រឹក្សាភិបាលអាចលាឈប់ពីមុខតំណែង ដោយជូនដំណឹងទៅភាគទុនិកយ៉ាងហោចណាស់ ១ខែមុន តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ និងមានការទទួលស្គាល់ការលាឈប់ពីភាគទុនិក។ តំណែងទំនេររបស់ក្រុមប្រឹក្សាភិបាលអាចត្រូវបានជំនួសដោយសេចក្តីសម្រេច ដែលអនុម័តដោយសម្លេងភាគច្រើន ២/៣ (ពីរភាគបី) នៃសម្លេងឆ្នោត ដោយភាគទុនិកនៅក្នុងកិច្ចប្រជុំទូទៅ។

## ការអនុលោមតាមច្បាប់ និងបទបញ្ញត្តិ

អិលអូអិលស៊ី អនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងអស់របស់ធនាគារជាតិនៃកម្ពុជា និងនិយ័តករពាក់ព័ន្ធ។

## អភិបាលកិច្ចសាជីវកម្ម

ក្រុមប្រឹក្សាភិបាលជឿជាក់ថា អភិបាលកិច្ចសាជីវកម្មល្អនាំមកនូវប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធទាំងអស់។ របាយការណ៍អំពីអភិបាលកិច្ចសាជីវកម្ម ត្រូវបានបង្ហាញលម្អិតនៅទំព័រទី ៣៥ ដល់ ៥៥។

## ការត្រួតពិនិត្យផ្ទៃក្នុង

នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនាយកដ្ឋានប្រតិបត្តិតាម ត្រួតពិនិត្យជាទៀងទាត់លើនីតិវិធី គោលនយោបាយ ការអនុវត្ត និងបញ្ជូនរបាយការណ៍ទៅគណៈកម្មាធិការគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម និងគណៈកម្មាធិការសវនកម្ម។ ការខ្វះចន្លោះ ឬភាពខ្សោយដែលបានរកឃើញ ត្រូវបានលើកយកមកពិភាក្សាជាមួយបុគ្គលិកដែលពាក់ព័ន្ធផ្នែកប្រតិបត្តិការ ដើម្បីធានាថាបុគ្គលិកពាក់ព័ន្ធទាំងអស់យល់ច្បាស់ពីភាពខ្វះចន្លោះទាំងនោះ និងចាត់វិធានការទាន់ពេលវេលា។ សេចក្តីសម្រេចនានាដែលបានព្រមព្រៀងគ្នានៅក្នុងកិច្ចប្រជុំ ត្រូវបានតាមដានឡើងវិញជាញឹកញាប់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការ ឬកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

## ប្រតិបត្តិការអាជីវកម្ម

នៅក្នុងអំឡុងឆ្នាំ ក្រុមប្រឹក្សាភិបាលបានត្រួតពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន និងរបាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំ ព្រមទាំងត្រួតពិនិត្យប្រតិបត្តិការជាទៀងទាត់ និងបរិយាកាសដែលក្រុមហ៊ុនកំពុងធ្វើប្រតិបត្តិការ រួមមានបរិយាកាសម៉ាក្រូសេដ្ឋកិច្ច ហានិភ័យដែលអាចកើតមានឡើង និងការបែងចែកធនធាន។ ផ្អែកលើព័ត៌មានដែលទទួលបាន ក្រុមប្រឹក្សាភិបាលយល់ឃើញថាក្រុមហ៊ុនកំពុងធ្វើប្រតិបត្តិការយ៉ាងល្អ និងមានលទ្ធភាពបន្តប្រតិបត្តិការរបស់ខ្លួនក្នុងពេលអនាគត។ ដូច្នេះហើយរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានថាក្រុមហ៊ុននឹងមានប្រតិបត្តិការដោយរលូន និងទទួលបានប្រាក់ចំណេញយ៉ាងល្អប្រសើរ។

## របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុជាមួយនឹងមតិយោបល់ ដែលត្រូវបានបង្ហាញនៅទំព័រទី ៥៧ ដល់ ១៤៥ ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

## សវនករ

សវនកររបស់ អិលអូអិលស៊ី គឺក្រុមហ៊ុន KPM ដែលត្រូវបានតែងតាំងសម្រាប់ធ្វើសវនកម្មរយៈពេល៣ឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធពី២០១៧ ដល់២០១៩។ ដូចដែលក្រុមប្រឹក្សាភិបាលបានជ្រាបមកហើយសវនករមិនមានទំនាក់ទំនងជាមួយក្រុមហ៊ុន ឬមិនមានទំនាស់ផលប្រយោជន៍ជាមួយក្រុមហ៊ុនឡើយ។ អនុលោមតាមគំនិតផ្តួចផ្តើមនៃអភិបាលកិច្ចល្អ ការផ្លាស់ប្តូរដៃគូសវនកម្មត្រូវបានអនុវត្ត។

# គណៈគ្រប់គ្រង



**លោក សុខ ឡឿន**
ប្រធាននាយកប្រតិបត្តិ

លោក សុខ ឡឿន ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ និងធនាគារ នៅសាកលវិទ្យាល័យបៀលប្រាយ ប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៥ និងសញ្ញាបត្របរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាស នៅអតីតមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០០។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលទាក់ទងនឹងផ្នែកមីក្រូហិរញ្ញវត្ថុ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Boulder ប្រទេសអ៊ីតាលី និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធដទៃៗទៀត នៅប្រទេសជាច្រើនដូចជា សហរដ្ឋអាមេរិក អាហ្វ្រិកខាងត្បូង ឥណ្ឌា បង់ក្លាដែស និងប្រទេសថៃ។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនផងដែរនៅក្នុងប្រទេសកម្ពុជា លើការគ្រប់គ្រងឥណទាន ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហានិភ័យ អភិបាលកិច្ច និងភាពជាអ្នកដឹកនាំល្អ និងជំនាញផ្សេងៗទៀត។ លោកធ្លាប់បានបម្រើការជាមន្ត្រីឥណទាននៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី ពីឆ្នាំ២០០០-២០០១ ហើយលោកត្រូវបានតំឡើងតំណែងជាប្រធានផ្នែកគ្រប់គ្រងឥណទាន នៅការិយាល័យកណ្តាលពីឆ្នាំ ២០០១ - ២០០៥។ ចាប់តាំងពី ឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ លោកគឺជានាយកប្រតិបត្តិការ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត ដែលទទួលខុសត្រូវលើប្រតិបត្តិការប្រចាំថ្ងៃរួមមានការគ្រប់គ្រងឥណទាន ប្រាក់បញ្ញើ ប្រតិបត្តិការផ្ទេរសាច់ប្រាក់ និងការពង្រីកទីផ្សារ។ លោកចាប់ផ្តើមបម្រើការងារឱ្យ អិលអូអិលស៊ី ជាប្រធាននាយកប្រតិបត្តិការ នៅក្នុងខែមេសា ឆ្នាំ២០១០ ហើយលោកត្រូវបានដំឡើងតំណែងជា អនុប្រធាននាយកប្រតិបត្តិ នៅខែធ្នូ ឆ្នាំ២០១២។ បច្ចុប្បន្ន លោកត្រូវបានក្រុមប្រឹក្សាភិបាលតែងតាំងជា ប្រធាននាយកប្រតិបត្តិ ចាប់តាំងពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៤។



**លោក សុខ សុផល**
អនុប្រធាននាយកប្រតិបត្តិ និង
ប្រធាននាយកហិរញ្ញវត្ថុ

លោក សុខ សុផល ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ជំនាញហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៧។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រភាសាអង់គ្លេស ជំនាញពាណិជ្ជកម្មអន្តរជាតិ នៅវិទ្យាស្ថានភាសាបរទេស ក្នុងឆ្នាំ២០០៥ និងសញ្ញាបត្របរិញ្ញាបត្រវិទ្យាសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាស នៅអតីតមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០០។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជា កម្មវិធីភាពជាអ្នកដឹកនាំនិងការបង្កើតថ្មី រៀបចំដោយ Women World Banking ដោយមានការគាំទ្រពីសាកលវិទ្យាល័យ Wharton University of Pennsylvania (USA), កម្មវិធីគ្រប់គ្រងជាន់ខ្ពស់ រៀបចំដោយ Cornell University at Colombo (Sri Lanka), Syndication Loan Pricing & Structuring រៀបចំដោយ Universal Network Intelligence (Malaysia) និងការចូលរួមសិក្ខាសាលា ក៏ដូចជាវគ្គបណ្តុះបណ្តាលជាច្រើនទៀតទាក់ទងទៅនឹងវិស័យហិរញ្ញប្បទានលើទីផ្សារមូលបត្រ ការផ្សព្វផ្សាយមូលបត្របំណុល ផលប៉ះពាល់នៃការវិនិយោគ សន្និសីទមីក្រូហិរញ្ញវត្ថុ ការវិភាគហិរញ្ញវត្ថុ គណនេយ្យ និងទីផ្សារ។ នៅក្នុងឆ្នាំ២០១៨ លោកបានចូលរួមវគ្គបណ្តុះបណ្តាល Certified Management Accountant Program Australia ដែលជាវគ្គបណ្តុះបណ្តាលលើកទី៦ ស្តីពីវិជ្ជាជីវៈពាណិជ្ជកម្ម ផ្តោតលើយុទ្ធសាស្ត្រគ្រប់គ្រងការចំណាយ និងយុទ្ធសាស្ត្រវិភាគអាជីវកម្ម កម្មវិធីគ្រប់គ្រងក្រុមប្រឹក្សាភិបាលជំនាន់ទី១ ឆ្នាំ២០១៨ នៅកម្ពុជា ដោយ Thai Institute of Director និងកម្មវិធីហ្វឹកហ្វឺនពីមីក្រូហិរញ្ញវត្ថុ នាទីក្រុង Turin ប្រទេសអ៊ីតាលី នាឆ្នាំ២០១៩។ លោកបានបម្រើការងារនៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី អស់រយៈពេលជិត១០ឆ្នាំ ពីឆ្នាំ២០០១ ដល់ឆ្នាំ២០១០ ក្នុងមុខតំណែងដូចជា គណនេយ្យករពីពេលចាប់ផ្តើម ជំនួយការប្រធានផ្នែកគណនេយ្យគ្រប់គ្រង ពីឆ្នាំ២០០៣-២០០៧ និងជាប្រធានផ្នែកគណនេយ្យគ្រប់គ្រង ពីឆ្នាំ២០០៧-២០០៨។ ក្នុងឆ្នាំ២០០៨ លោកត្រូវបានដំឡើងតំណែងជា ជំនួយការនាយកប្រតិបត្តិ (ទទួលបន្ទុកការងារវិនិយោគ) នៃនាយកដ្ឋានកិច្ចការច្បាប់នៃ ធនាគារ អេស៊ីលីដា។ ចាប់ពីខែមករា ឆ្នាំ២០០៩ លោកត្រូវបានដំឡើងតំណែងជា នាយកប្រតិបត្តិរង នៃនាយកដ្ឋានកិច្ចការវិនិយោគ និងមូលបត្រនៃ ធនាគារ អេស៊ីលីដា។ លោកបានចាប់ផ្តើមបម្រើការងារជាមួយ អិលអូអិលស៊ី នៅក្នុងខែសីហា ឆ្នាំ២០១០ ជាប្រធាននាយកហិរញ្ញវត្ថុ ហើយលោកត្រូវដំឡើងតំណែងជាអនុប្រធាននាយកប្រតិបត្តិ នៅក្នុងខែមីនា ឆ្នាំ២០១៩។



**លោកស្រី ស៊ីយ សុឌីណា**

ប្រធាននាយិកាគ្រប់គ្រងហានិភ័យ

លោកស្រី ស៊ីយ សុឌីណា ទទួលបានសញ្ញាបត្រវិជ្ជាជីវៈគណនេយ្យ ដែលទទួលស្គាល់ជាសាធារណៈ ពីវិទ្យាស្ថានអាជីពផ្នែកគណនេយ្យធំជាងគេរបស់ ចក្រភពអង់គ្លេស។ លោកស្រីទទួលបានសញ្ញាបត្របរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៦។ បន្ថែមលើនេះ លោកស្រីទទួលបានសញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យពី CAMED Business School នៅដើមឆ្នាំ២០១៣។ អ្នកស្រីបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដែលរួមមាន ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំគម្រោងយុទ្ធសាស្ត្រ និងវគ្គបណ្តុះបណ្តាលផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងមីក្រូហិរញ្ញវត្ថុ។ លោកស្រីធ្លាប់បានបម្រើការក្នុងក្រុមហ៊ុនគណនេយ្យ អន្តរជាតិធំមួយក្នុងចំណោមក្រុមហ៊ុនធំៗទាំង៤ ដែលមានតួនាទីជាសវនករជាន់ខ្ពស់ អស់រយៈពេលជិត៤ឆ្នាំ ដែលអ្នកស្រីទទួលខុសត្រូវក្នុងតួនាទីជាអ្នកដឹកនាំក្រុមសវនករ ចុះធ្វើសវនកម្មនៅក្នុងវិស័យជាច្រើនរួមមាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល និងវិស័យផ្សេងៗទៀត។ អ្នកស្រីបានចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី នៅក្នុងខែឧសភា ឆ្នាំ២០១១ និងត្រូវបានតំឡើងតំណែងជា ប្រធាននាយិកាគ្រប់គ្រងហានិភ័យ នៅក្នុងខែមីនា ឆ្នាំ២០១៨។



**លោក រ៉ូម៉េស ប៉េរ៉េរ៉ា**

ប្រធាននាយកបណ្តាញចែកចាយ

លោក Romesh Perera ប្រធាននាយកបណ្តាញចែកចាយ ធ្លាប់បានបម្រើការនៅ LOLC Finance Plc. (LOFC) ក្នុង ប្រទេសស្រីលង្កា ក្នុងតំណែងជាជំនួយការអគ្គនាយកអស់រយៈពេល១៣ឆ្នាំ មុនពេលដែលលោកមកបម្រើការនៅ អិលអូអិលស៊ី (ខេមបូឌា)។ ក្នុងកំឡុងពេល២០ឆ្នាំ មុនលោកបានបម្រើការងារនៅក្នុងវិស័យហិរញ្ញវត្ថុ មិនទទួលប្រាក់បញ្ញើទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារឯកទេសនៅក្នុង ប្រទេសស្រីលង្កា ដោយកាន់តំណែងជាមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ មុនពេលដែលលោកមកកាន់តំណែងជា ប្រធាននាយកបណ្តាញចែកចាយ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។ លោកមានជំនាញ និងបទពិសោធន៍ជាច្រើនទាំងនៅក្នុងវិស័យធនាគារឯកទេស និងវិស័យមីក្រូហិរញ្ញវត្ថុដោយគ្រប់គ្រងទៅលើផ្នែកលក់និងទីផ្សារ ផ្នែកគ្រប់គ្រងហានិភ័យឥណទាន និងផ្នែកគ្រប់គ្រងលើការដោះស្រាយបំណុល។ ទំនួលខុសត្រូវរបស់លោករួមមាន ការធ្វើហិរញ្ញប្បទានធម្មតា និងហិរញ្ញប្បទានសម្រាប់ជនជាតិអ៊ីស្លាម ការធ្វើហិរញ្ញប្បទានពាណិជ្ជកម្ម សេវាភតិសន្យាហិរញ្ញវត្ថុ ការធ្វើហិរញ្ញប្បទានលើសម្ភារប្រើប្រាស់ ការគ្រប់គ្រងកំណើនផលិតផលប្រាក់បញ្ញើសន្សំ ការគ្រប់គ្រងប្រតិបត្តិការបញ្ចាំ និងប្រតិបត្តិការឆ្លងតំបន់។ ជំនាញ និងការអនុវត្តការងារ ក្នុងតំណែងជាមន្ត្រីគ្រប់គ្រងជាន់ខ្ពស់នៅ ប្រទេសស្រីលង្កា បានធ្វើឱ្យលោកទទួលបានឱកាសបម្រើការងារថ្មីឱ្យ LOLC Group នៅក្នុងប្រទេសកម្ពុជា។ លោក Romesh បានមកបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ក្នុងខែមិថុនា ឆ្នាំ២០១៧ ក្នុងតំណែងជាមន្ត្រីឯកទេសហិរញ្ញប្បទានសម្ភារប្រើប្រាស់ និងសេវាភតិសន្យាហិរញ្ញវត្ថុ។ បច្ចុប្បន្នលោកមានតំណែងជាប្រធាននាយកបណ្តាញចែកចាយ ដែលមានប្រសិទ្ធភាពចាប់ពីខែសីហា ឆ្នាំ២០១៨។



**លោកស្រី ឈាង កញ្ញា**

ប្រធាននាយិកាប្រាក់បញ្ញើ និងសេវាហិរញ្ញវត្ថុ

លោកស្រី ឈាង កញ្ញា បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែក រដ្ឋបាលអាជីវកម្ម នៅសកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា ក្នុងឆ្នាំ២០១២។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា ក្នុងឆ្នាំ២០១០ និងបរិញ្ញាបត្រផ្នែកគ្រប់គ្រងសហគ្រាស នៅសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០០។ លោកស្រី បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាំងក្នុង និងក្រៅប្រទេស ទាក់ទងនឹងការរីកចម្រើន និងផលប៉ះពាល់នៃអាជីវកម្មមីក្រូហិរញ្ញវត្ថុ ផលិតផល-សេវាធនាគារឌីជីថល ទំនាក់ទំនងលក់ សេវាអតិថិជន អភិវឌ្ឍផលិតផល គ្រប់គ្រងប្រតិបត្តិការ និងភាពជាអ្នកដឹកនាំ។ លោកស្រីមានបទពិសោធន៍នៅក្នុងវិស័យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុចាប់តាំងពីដើមឆ្នាំ២០០០។ លោកស្រីបានចាប់ផ្តើមអាជីពការងារជាមួយ ធនាគារ អេស៊ីលីដា ក្នុងជំនាញគ្រប់គ្រងសាច់ប្រាក់ និងហិរញ្ញវត្ថុ នៅឆ្នាំដើមឆ្នាំ២០០០។ ចាប់ពីឆ្នាំ២០០៧ ដល់២០១៦ ក្នុងតួនាទីជានាយិកានាយកដ្ឋានគ្រប់គ្រងប្រាក់បញ្ញើ លោកស្រីបានផ្តួចផ្តើមគំនិត និងបង្កើតយុទ្ធសាស្ត្រក្នុងការដឹកនាំ និងកេណ្ឌប្រមូលប្រាក់បញ្ញើ និងសេវាហិរញ្ញវត្ថុជូន ធនាគារ ស្ថាបនា ប្រកបដោយភាពជោគជ័យ។ ជាងនេះទៅទៀត នៅក្នុងឆ្នាំ២០១៥-២០១៦ លោកស្រីបានចូលរួមក្នុងគម្រោងរួមបញ្ចូលគ្នាជាផ្លូវការរវាង ធនាគារ ម៉ារូហាន់ជប៉ុន និងស្ថាបនា លីមីតធីត និងធ្វើការកំលាយខ្លួនទៅជាធនាគារពាណិជ្ជ។ លោកស្រីចាប់ផ្តើមការងារជាមួយ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ចាប់ពីខែមករា ឆ្នាំ២០១៦ ក្នុងតួនាទីជា នាយិកានាយកដ្ឋានគ្រប់គ្រងប្រាក់បញ្ញើ និងសេវាហិរញ្ញវត្ថុ។



**លោក ឌូលីប លីយ៉ាណាគី**
ប្រធាននាយកបច្ចេកវិទ្យាព័ត៌មាន

លោក ឌូលីប លីយ៉ាណាគី ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ ពីវិទ្យាស្ថាន Postgraduate Institute of Management នៃសាកលវិទ្យាល័យ Sri Jayewardenepura នៅប្រទេសស្រីលង្កា។ លោក ឌូលីប ទទួលបានបរិញ្ញាបត្រផ្នែកកុំព្យូទ័រពាណិជ្ជកម្ម (កម្រិត២) ពីសកលវិទ្យាល័យ Wolverhampton នៅប្រទេសអង់គ្លេស។ បន្ថែមលើគុណវុឌ្ឍិសិក្សាខាងលើ លោកក៏មានជំនាញវិជ្ជាជីវៈផ្នែកអភិបាលកិច្ចសុវត្ថិភាពព័ត៌មាន និងបច្ចេកវិទ្យាព័ត៌មាន រួមមាន Certified Payment Card Industry Security Implementer (CPISI) និង Certified Android Security Specialist ហើយលោកក៏បានបំពេញគ្រប់លក្ខខណ្ឌ ដើម្បីទទួលបានវិញ្ញាបនបត្រ ISO 27001:2013 Lead Auditor certification ។ មុនពេលចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី លោកមានបទពិសោធន៍ជាង១៤ឆ្នាំ នៅក្នុងប្រទេសស្រីលង្កា លើគ្រប់កម្រិតនៃផ្នែកគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន។ លោកបានបម្រើការងារអស់រយៈពេលជាង១០ឆ្នាំ នៅ LankaPay (LankaClear (Pvt) Ld.) ដែលជាស្ថាប័នរដ្ឋផ្តល់សេវារចនាសម្ព័ន្ធទូទាត់ ក្រោមការត្រួតពិនិត្យពីធនាគារជាតិនៃប្រទេសស្រីលង្កា។ ក្នុងអំឡុងពេលបម្រើការងារនៅ LankaPay លោកបានបម្រើការជាអ្នកផ្តល់ដំណោះស្រាយផ្នែកសុវត្ថិភាពព័ត៌មាន ដោយគ្រប់គ្រងលើប្រព័ន្ធទូទាត់ថ្នាក់ជាតិ នៅក្នុងប្រទេសស្រីលង្កា។ បទពិសោធន៍ការងាររបស់លោករួមមាន Online Cheque Image and truncation System (CITS), JustPay ដែលជាប្រព័ន្ធទូទាត់រាយតាមរយៈទូរស័ព្ទដៃ, PKI based Digital Certification Authority និងប្រព័ន្ធផ្សេងទៀត។ លោក លីយ៉ាណាគី មានបទពិសោធន៍ និងជំនាញជាច្រើនផ្នែកបច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងគម្រោង បច្ចេកវិទ្យាទូរស័ព្ទចល័ត គម្រោងទូទាត់ដោយប្រើប្រាស់កាត និងមានជំនាញផ្នែកសុវត្ថិភាពព័ត៌មានវិជ្ជាផងដែរ។ លើសពីនេះទៀត លោកបានអភិវឌ្ឍខ្លួនមិនត្រឹមតែនៅក្នុងផ្នែកសុវត្ថិភាពព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែលោកក៏បានអភិវឌ្ឍខ្លួនលើផ្នែកអភិបាលកិច្ចប្រព័ន្ធបច្ចេកវិទ្យា ការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ផ្នែករៀបចំគម្រោង ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងផ្នែកលក់ និងការដោះស្រាយ។ លោក ឌូលីប មិនកំណត់ខ្លួនលោកនៅក្នុងពិភពការងារជំនាញប៉ុណ្ណោះទេ ប៉ុន្តែលោកក៏បានចូលរួមក្នុងការងារអប់រំបណ្តុះបណ្តាលផងដែរ ដោយបានបម្រើការងារជាសាស្ត្រាចារ្យរងនៅសាកលវិទ្យាល័យ Open University នៅក្នុងប្រទេសអង់គ្លេស នៅសាកលវិទ្យាល័យ Sri Jayewardenepura University និងសាកលវិទ្យាល័យ Wayamba University នៅក្នុងប្រទេសស្រីលង្កា លើផ្នែកបច្ចេកវិទ្យាព័ត៌មាន រចនាសម្ព័ន្ធទូទាត់តាមប្រព័ន្ធឌីជីថល និងសុវត្ថិភាពព័ត៌មានវិជ្ជា។

លោក លីយ៉ាណាគី ចាប់ផ្តើមបម្រើការងារនៅ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងមុខតំណែងជា ប្រធាននាយកបច្ចេកវិជ្ជាព័ត៌មាន ហើយនៅក្រោមការដឹកនាំរបស់លោក អិលអូអិលស៊ី បានដាក់ឱ្យដំណើរការប្រព័ន្ធជាច្រើនដូចជា ប្រព័ន្ធ Mobile Banking (នៅក្នុងខែមេសា ឆ្នាំ២០១៩), ភ្ជាប់ទៅប្រព័ន្ធ Cambodia Shared ATM Switch (នៅក្នុងខែកក្កដា ឆ្នាំ២០១៩), ភ្ជាប់ប្រព័ន្ធ NBC FAST system ទៅក្នុងទូរស័ព្ទដៃ (នៅក្នុងខែសីហា ឆ្នាំ២០១៩), ទទួលបានវិញ្ញាបនបត្រទទួលស្គាល់លើស្តង់ដារ ISO 27001:2013 certification សម្រាប់ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពព័ត៌មាន (នៅក្នុងខែមករា ឆ្នាំ២០២០), ភ្ជាប់ទៅបណ្តាញ Real Time Fund Transfer (នៅក្នុងខែកុម្ភៈ ឆ្នាំ២០២០) និងការកែលម្អជាច្រើនទៀតពាក់ព័ន្ធនឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន។



**លោក តេង ភាព**
នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក តេង ភាព ទទួលបាន សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ វេសស្ទើន ក្នុងឆ្នាំ២០០៨ និងទទួលបានសញ្ញាបត្របរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ នៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រក្នុងឆ្នាំ២០០៤។ លោកបានចូលរួម វគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងទម្រង់នីតិវិធី នៃការអនុវត្តន៍ផ្ទៃក្នុងជាលក្ខណៈអាជីពនៅក្នុង ប្រទេសម៉ាឡេស៊ី ផែនការអាជីវកម្ម និងការគ្រប់គ្រងភាពរីកចម្រើនក្នុង ប្រទេសហ្វីលីពីន ការគ្រប់គ្រងផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ក្នុងប្រទេសម៉ុងហ្គោល ការចែករំលែកបទពិសោធន៍ទាក់ទងនឹងធនាគារ ក្នុងប្រទេសស្រីលង្កា និងវគ្គបណ្តុះបណ្តាលផ្សេងៗទៀតជាច្រើនក្នុងប្រទេសកម្ពុជា មានដូចជា ការគ្រប់គ្រងហានិភ័យ សវនកម្មផ្ទៃក្នុងកម្រិតខ្ពស់ របៀបសរសេររបាយការណ៍ និងជំនាញក្នុងការដឹកនាំ។ លោកមានបទពិសោធន៍ បម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងស្ថាប័នក្រៅរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា ច្រើនជាង១៥ឆ្នាំ រួមមានបម្រើការងារនៅ Catholic Relief Services ចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៣ ក្នុងមុខតំណែងជា សវនករផ្ទៃក្នុង និងជានាយកសាខា ក្នុងឆ្នាំ២០០៤ បន្ទាប់ពី Catholic Relief Services ត្រូវបានដាក់បញ្ចូលជាមួយ អិលអូអិលស៊ី។ លោកបានបម្រើការងារឱ្យគ្រឹះស្ថានអង្គរ មីក្រូហិរញ្ញវត្ថុកម្ពុជា ក្នុងមុខដំណែងជាអ្នកដឹកនាំក្រុមសវនករផ្ទៃក្នុង និងជាប្រធានភូមិភាគ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨។ លោកចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី ជានាយកនាយកដ្ឋានសវកម្មផ្ទៃក្នុង នៅខែធ្នូ ឆ្នាំ២០០៨។



**លោកស្រី ឡេង ថាវី**

នាយិកានាយកដ្ឋានធនធានមនុស្ស

លោកស្រី ឡេង ថាវី ចាប់ផ្តើមចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៤។ មុនពេលចូលបម្រើការងារជាមួយ អិលអូអិលស៊ី លោកស្រីមានបទពិសោធន៍ការងារផ្នែកគ្រប់គ្រងធនធានមនុស្ស រយៈពេលជាង១០ឆ្នាំ ជាមួយអង្គការមនុស្សធម៌ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជាអង្គការទស្សនៈពិភពលោកកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជា និងអង្គការឃែរកម្ពុជា។ ក្រៅពីបទពិសោធន៍បម្រើការងារក្នុងប្រទេស លោកស្រីក៏ធ្លាប់បានបម្រើការងារក្រៅប្រទេសរយៈពេលជាង១ឆ្នាំ ដែលរួមមានការបម្រើការងារជាមួយអង្គការទស្សនៈពិភពលោក នៅប្រទេសស្រីលង្កា រយៈពេល៣ខែ និងការបម្រើការងារជាលក្ខណៈក្រៅម៉ោងរយៈពេល១៣ខែ ជាមួយសាកលវិទ្យាល័យម៉ូណាស់ នៅប្រទេសអូស្ត្រាលី។ អ្នកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធនធានមនុស្ស ពីសាកលវិទ្យាល័យម៉ូណាស់ ប្រទេសអូស្ត្រាលី តាមរយៈជំនួយអាហារូបករណ៍របស់រដ្ឋាភិបាលប្រទេសអូស្ត្រាលី។ បន្ថែមពីនេះទៀត លោកស្រីក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីវិទ្យាស្ថានជាតិគ្រប់គ្រង។ លោកស្រីក៏បានចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសមួយចំនួនមានដូចជា៖ នៅចក្រភពអង់គ្លេស ប្រទេសអូស្ត្រាលី ប្រទេសសិង្ហបុរី ប្រទេសហ្វីលីពីន ប្រទេសស្រីលង្កា និងប្រទេសថៃ។



**លោកស្រី ទ្រី សុទ្ធា**

នាយិកានាយកដ្ឋានរតនាគារ

លោកស្រី ទ្រី សុទ្ធា បច្ចុប្បន្នកំពុងបន្តការសិក្សាយកសញ្ញាបត្រវិជ្ជាជីវៈគណនេយ្យ ដែលទទួលស្គាល់ជាធារណៈ ពីវិទ្យាស្ថានអាជីពផ្នែកគណនេយ្យធំជាងគេរបស់ចក្រភពអង់គ្លេស។ លោកស្រី បានទទួលសញ្ញាបត្របរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០១១។ លោកស្រី បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដែលរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រឆាំងការសម្អាតសាច់ប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការគ្រប់គ្រងហានិភ័យសន្ទីយភាព Leadership and Diversity for Innovation Program និងវគ្គបណ្តុះបណ្តាលផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងមីក្រូហិរញ្ញវត្ថុ។ លោកស្រីធ្លាប់បានបម្រើការក្នុងក្រុមហ៊ុនគណនេយ្យអន្តរជាតិធំមួយក្នុងចំណោមក្រុមហ៊ុនធំៗទាំង៤ ដែលមានតួនាទីជាសវនករជាន់ខ្ពស់ អស់រយៈពេលជិត៤ឆ្នាំ ដែលលោកស្រីទទួលខុសត្រូវក្នុងតួនាទីជាអ្នកដឹកនាំក្រុមសវនករ ចុះធ្វើសវនកម្មនៅក្នុងវិស័យជាច្រើនរួមមាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល និងវិស័យផ្សេងៗទៀត។ លោកស្រីបានចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី នៅក្នុងខែមិថុនា ឆ្នាំ២០១៥ ក្នុងតួនាទីជានាយិកានាយកដ្ឋានរតនាគារ។



**លោកស្រី កែវ តារាទី**

នាយិកានាយកដ្ឋានហិរញ្ញវត្ថុ

លោកស្រី កែវ តារាទី បច្ចុប្បន្នកំពុងបន្តការសិក្សាយកសញ្ញាបត្រវិជ្ជាជីវៈគណនេយ្យ ដែលទទួលស្គាល់ជាសាធារណៈពីវិទ្យាស្ថានអាជីពផ្នែកគណនេយ្យធំជាងគេរបស់ចក្រភពអង់គ្លេស។ លោកស្រី បានទទួលសញ្ញាបត្របរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០១០ និងបរិញ្ញាបត្រផ្នែក អក្សរសាស្ត្រអង់គ្លេស ពីវិទ្យាស្ថានភាសាបរទេសក្នុងឆ្នាំ២០០៩។ លោកស្រីធ្លាប់បានបម្រើការក្នុងក្រុមហ៊ុនគណនេយ្យអន្តរជាតិធំមួយក្នុងចំណោមក្រុមហ៊ុនធំៗទាំង៤ ដែលមានតួនាទីជាសវនករជាន់ខ្ពស់ អស់រយៈពេល៣ឆ្នាំ ដែលលោកស្រីទទួលខុសត្រូវក្នុងតួនាទីជាអ្នកដឹកនាំក្រុមសវនករ ចុះធ្វើសវនកម្មនៅក្នុងវិស័យជាច្រើនរួមមាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល និងវិស័យផ្សេងៗទៀត។ មុននឹងចូលបម្រើការជាមួយ អិលអូអិលស៊ី លោកស្រីធ្លាប់បានបម្រើការជាប្រធានគណនេយ្យនៅ ធនាគារមេយប៊ែង អស់រយៈពេល៤ឆ្នាំ។ លោកស្រីបានចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ក្នុងតួនាទីជា នាយិកានាយកដ្ឋានហិរញ្ញវត្ថុ។



**លោកស្រី ស៊ីវ បូផា**

នាយិកានាយកដ្ឋានរដ្ឋបាល និងធុរកិច្ច

លោកស្រី ស៊ីវ បូផា បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែក គណនេយ្យ នៅវិទ្យាស្ថានវ៉ាន់ដា ក្នុងឆ្នាំ២០០៨។ លោកស្រីបានទទួលសញ្ញាបត្រ ភាសាអង់គ្លេស ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងឆ្នាំ២០០៣។ លោកស្រីបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗជាច្រើន ទាក់ទងនឹងគណនេយ្យហិរញ្ញវត្ថុ គណនេយ្យពន្ធដារ ការគ្រប់គ្រងផ្ទៃក្នុង និងសវនកម្ម កិច្ចការរដ្ឋបាល និងភាពជាអ្នកដឹកនាំ។ លោកស្រីបានបម្រើការងារក្នុងវិស័យវាយនភ័ណ្ឌ ចាប់ពីឆ្នាំ២០០២ ដល់ដើមឆ្នាំ២០២០ ក្នុងតួនាទីជាប្រធានគណនេយ្យ និងជាប្រធានហិរញ្ញវត្ថុ។ ក្នុងខែមេសា ឆ្នាំ២០២០ លោកស្រីចាប់ផ្តើមបម្រើការងារថ្មីជាមួយ អិលអូអិលស៊ី (ខេមបូឌា) ក្នុងតួនាទីជានាយិកានាយកដ្ឋានរដ្ឋបាល និងធុរកិច្ច។



**លោក ហ៊ុល សុវុត្ថា**

នាយកនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

លោក ហ៊ុល សុវុត្ថា នាយកនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកបច្ចេកវិទ្យាព័ត៌មាន ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០០៣។ លោកមានបទពិសោធន៍ជាង១២ឆ្នាំ ជាមួយវិស័យធនាគារក្នុងស្រុក និងធនាគារមកពីបរទេស។ បន្ថែមពីនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាព័ត៌មាន E-Banking និងសិក្ខាសាលាផ្សេងៗពាក់ព័ន្ធផ្នែកបច្ចេកវិទ្យាព័ត៌មាន ដូចជានៅប្រទេសកម្ពុជា ប្រទេសសឹង្ហបុរី និងប្រទេសម៉ាឡេស៊ី។ លោកបានបម្រើការងារនៅធនាគារអេស៊ីលីដា ភីអិលស៊ី មានតួនាទីជាអ្នកសរសេរកម្មវិធីកុំព្យូទ័រ នៅឆ្នាំ២០០៥ បន្ទាប់មកត្រូវបានតំឡើងជា អនុប្រធានផ្នែកអភិវឌ្ឍន៍ផ្នែកទន់ នៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៅឆ្នាំ២០០៨។ លោកបានចូលបម្រើការងារនៅ ធនាគារមេយប៊ែងកម្ពុជា ភីអិលស៊ី មានតួនាទីជាមន្ត្រីផ្នែក E-Banking (អេធីអឹម) នៅឆ្នាំ២០០៨ បន្ទាប់មកត្រូវបានតែងតាំងជាមន្ត្រីជាន់ខ្ពស់ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងអេធីអឹម នៅឆ្នាំ២០១០ និងត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងផ្នែកបច្ចេកវិទ្យាព័ត៌មាននៅឆ្នាំ២០១៤។ លោកបានចាប់ផ្តើមបម្រើការងារជាមួយ អិលអូអិលស៊ី ក្នុងខែតុលា ឆ្នាំ២០១៥ ជានាយកនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន។



**លោក មុត ពិសី**

នាយកនាយកដ្ឋានឥណទាន

លោក មុត ពិសី នាយកនាយកដ្ឋានឥណទាន ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ជំនាញហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៣។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជំនាញទេសចរណ៍ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៦។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនផងដែរនៅក្នុងប្រទេសកម្ពុជា លើការវាយតម្លៃអចលនទ្រព្យ ការចរចា និងការដោះស្រាយវិវាទការងារ ការគ្រប់គ្រងសាខា ការកសាងសមត្ថភាពសវនកម្មផ្ទៃក្នុង ច្បាប់ការងារ ការពង្រឹងអំណាចនៃភាពជាអ្នកដឹកនាំ និងជំនាញផ្សេងៗទៀត។ លោកធ្លាប់បានបម្រើការជាមន្ត្រីឥណទាននៅ ស្ថាបនា លីមីតធីត ពីឆ្នាំ២០០៦-២០០៨ ហើយលោកត្រូវបានតំឡើងតំណែងជា ប្រធានមន្ត្រីឥណទាន នៅសាខាស្រុកអង្គស្នួល ពីខែកុម្ភៈ ឆ្នាំ២០០៨ ដល់ ខែធ្នូ ឆ្នាំ២០០៨។ ចាប់តាំងពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០ លោកគឺជានាយកសាខាខេត្តកំពត នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត។ លោកចាប់ផ្តើមបម្រើការងារឱ្យ អិលអូអិលស៊ី ជាអ្នកហាត់រៀនការងារគ្រប់គ្រងសាខា នៅខែឧសភា ឆ្នាំ២០១០ ហើយលោកត្រូវបានតែងតាំងជានាយកសាខាក្រុងសួង នៅខែកក្កដា ឆ្នាំ២០១០។ នៅក្នុងខែឧសភា ឆ្នាំ២០១៤ លោកត្រូវបានតំឡើងតំណែងដោយថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ជានាយកនាយកដ្ឋានរដ្ឋបាល និងធុរកិច្ច។ ក្នុងខែមីនា ឆ្នាំ២០១៧ លោកបានផ្លាស់ប្តូរការងារមក នាយកដ្ឋានឥណទាន ក្នុងមុខតំណែងជា នាយករងនាយកដ្ឋានឥណទាន និងជានាយករងនាយកដ្ឋានអាជីវកម្មក្នុងខែវិច្ឆិកា ឆ្នាំ២០១៧។ បច្ចុប្បន្នលោកត្រូវបានតម្លើងតំណែងជា នាយកនាយកដ្ឋានឥណទាន ចាប់តាំងពីខែសីហា ឆ្នាំ២០១៨។



**លោក ទុន កង**

នាយករងនាយកដ្ឋានឥណទាន
និងទីប្រឹក្សាគណៈកម្មាធិការប្រតិបត្តិ

លោក ទុន កង ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងពាណិជ្ជកម្មជំនាញធនាគារ និងហិរញ្ញវត្ថុក្នុងឆ្នាំ២០១៤ និងសញ្ញាបត្របរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មជំនាញគ្រប់គ្រងទូទៅនៅ សាកលវិទ្យាល័យបៀលប្រាយ ក្នុងឆ្នាំ២០០៩។ លោកធ្លាប់បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងហិរញ្ញវត្ថុទាំងក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស។ លោក ទុន កង ពីមុនបម្រើការងារជាមន្ត្រីឥណទាននៅ អិលអូអិស៊ី បន្ទាប់មកត្រូវបានដំឡើងតំណែងជាប្រធានមន្ត្រីឥណទាន។ ចាប់ពីឆ្នាំ២០០២ ដល់ ២០០៩ លោកមានតួនាទីជានាយកគ្រប់គ្រងសាខា ហើយនៅក្នុងឆ្នាំ២០០៩ លោកត្រូវបានដំឡើងតំណែងជាប្រធានភូមិភាគ និងជាតំណាងភាគទុនិករបស់ ភីធីស៊ី-អ៊ុសប។ បច្ចុប្បន្ន លោកត្រូវបានតែងតាំងជា នាយករងនាយកដ្ឋានឥណទាន និងជាទីប្រឹក្សាគណៈកម្មាធិការប្រតិបត្តិ ចាប់តាំងពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៤។



**លោក នុត ថេង**

នាយកនាយកដ្ឋានអាជីវកម្ម

លោក នុត ថេង បានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពី សាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០១១ សញ្ញាបត្របរិញ្ញាបត្រ ផ្នែកអក្សរសាស្ត្រអង់គ្លេស ពី សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ក្នុងឆ្នាំ២០០៧ និងសញ្ញាបត្រមធ្យមសិក្សា គរុកោសល្យឯកទេសគណិតវិទ្យា និងរូបវិទ្យា ពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃវែង ក្នុងឆ្នាំ២០០០។ លោកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើននៅក្នុងប្រទេស ដូចជាការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិក ការកសាងសមត្ថភាពបុគ្គលិក ការគ្រប់គ្រងសាខាសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងឥណទាន វគ្គបណ្តុះបណ្តាលសម្រាប់អ្នកបណ្តុះបណ្តាលបន្ត ជំនាញគ្រប់គ្រងនិងដឹកនាំ ហិរញ្ញប្បទានទ្រព្យសកម្ម ការបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុ ការការពារអតិថិជន និងវគ្គសិក្សាសំខាន់ជាច្រើនទៀត។ មុនពេលចាប់ផ្តើមការងារជាមួយ អិលអូអិលស៊ី លោកធ្លាប់បានបម្រើការងារជាគ្រូបង្រៀនគណិតវិទ្យា រូបវិទ្យា និងភាសាអង់គ្លេស អស់រយៈពេល៥ឆ្នាំ គឺពីចាប់ពី២០០០ ដល់ឆ្នាំ២០០៥។ បន្ទាប់មក លោកក៏បានផ្លាស់ប្តូរអាជីពការងារមកក្នុងវិស័យឥណទាន ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ អស់រយៈពេល៦ឆ្នាំ ដោយចាប់ផ្តើមតាំងពីតួនាទីជាមន្ត្រីឥណទានហាត់ការ ជាមន្ត្រីឥណទាន និងជាប្រធានអនុសាខា។ លោកបានចាប់ផ្តើមការងារជាមួយ អិលអូអិលស៊ី ក្នុងឆ្នាំ២០១១ ហើយធ្លាប់កាន់តួនាទីសំខាន់ៗជាច្រើនដូចជា អ្នកហាត់ការគ្រប់គ្រងសាខា នាយកសាខា មន្ត្រីឯកសទេសផ្នែកឥណទាននៅការិយាល័យកណ្តាល ប្រធានភូមិភាគ ប្រធានគម្រោងឥណទានសម្ភារប្រើប្រាស់នៃនាយកដ្ឋានអាជីវកម្ម ហើយបន្ទាប់មកលោកត្រូវបានតែងតាំងជានាយកនាយកដ្ឋានឥណទានសម្ភារប្រើប្រាស់ក្នុងខែសីហា ឆ្នាំ២០១៨ និងប្តូរតួនាទីទៅជានាយកនាយកដ្ឋានអាជីវកម្មនៅក្នុងខែកញ្ញា ឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន។



**លោក បាន ផលឡេង**

នាយកនាយកដ្ឋានប្រតិបត្តិតាម

លោក បាន ផលឡេង នាយកនាយកដ្ឋានប្រតិបត្តិតាម បានបញ្ចប់ការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងហានិភ័យ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកវិស័យហិរញ្ញវត្ថុនិងធនាគារ ក្នុងតំបន់អាស៊ីអាគ្នេយ៍ ពីសាកលវិទ្យាល័យ NANTES។ លោកក៏ទទួលបានបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច អាជីវកម្ម បរិញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេស និងបានចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗជាច្រើនដូចជា ធនាគារិកអាជីពភាពជាអ្នកដឹកនាំ ច្បាប់ពន្ធដាកម្ពុជា ស្ថិតិកម្រិតឧត្តម ការគ្រប់គ្រងគម្រោងគោលការណ៍ការពារអតិថិជន ការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ និងការគ្រប់គ្រងគម្រោងនៅក្នុងស្រុក និងក្រៅប្រទេស។ បទពិសោធន៍របស់លោករួមមានការអភិវឌ្ឍន៍ផែនការអាជីវកម្មដើម្បីផ្លាស់ប្តូរពីអាជីវកម្មលក្ខណៈគ្រួសារ/អង្គការក្រៅរដ្ឋាភិបាល ទៅជាអាជីវកម្មតាមស្តង់ដារ ការវិភាគ ការស្រាវជ្រាវការគ្រប់គ្រងគម្រោង ការបង្កើតគោលនយោបាយ និងនីតិវិធីសម្រាប់ស្ថាប័ន។ មុនពេលចូលបម្រើការនៅ អិលអូអិលស៊ី លោកបានបម្រើការជា មន្ត្រីគ្រប់គ្រងគម្រោងនៅ VisionFund រហូតដល់ឆ្នាំ២០១០ បម្រើការជាមន្ត្រីបច្ចេកទេសនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា រហូតដល់ឆ្នាំ២០១២។ បន្ទាប់មកលោកចូលបម្រើការនៅ អិលអូអិលស៊ី ចុងឆ្នាំ២០១២ ជាអ្នកជំនាញគ្រប់គ្រងសកម្មភាពសង្គម បន្ទាប់មក លោកត្រូវបានតំឡើងតំណែងជានាយកនាយកដ្ឋានគ្រប់គ្រងសកម្មភាពសង្គម នៅក្នុងឆ្នាំ ២០១៥ និងនៅឆ្នាំ២០១៨ ប្តូរតួនាទីជានាយកនាយកដ្ឋានប្រតិបត្តិតាម ដើម្បីធានាការអនុលោមតាមច្បាប់បញ្ញត្តិពាក់ព័ន្ធផ្សេងៗ ហើយក៏គ្រប់គ្រងផ្នែកគ្រប់គ្រងសកម្មភាពសង្គម ផងដែរ។



**លោក ឈួន សុខចិត្ត**

នាយកនាយកដ្ឋានទីផ្សារ

លោក ឈួន សុខចិត្ត ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០១២ និងសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៣ ហើយលោកក៏ទទួលបានសញ្ញាបត្រមធ្យមឯកទេសផ្នែកផែនការសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការ និងស្ថិតិ ក្នុងឆ្នាំ២០០១។ លើសពីនេះទៅទៀត លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញសំខាន់ៗជាច្រើននៅក្នុងប្រទេសកម្ពុជា ហ្វីលីពីន ជប៉ុន និងថៃ។ ជាមួយបទពិសោធន៍រយៈពេល១៦ឆ្នាំ លោក សុខចិត្ត ធ្លាប់បម្រើការនៅក្នុងស្ថាប័នជាច្រើនដូចជា ធនាគារ អេស៊ីលីដា ភីអិលស៊ី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សីលានិធិ និងក្រុមហ៊ុនតូយ៉ូតា (ខេមបូឌា) ក្នុងតួនាទីជា មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន នាយកទីផ្សារ និងប្រធានផ្នែកលក់គ្រឿងបន្លាស់។ លោកបានចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី ក្នុងតំណែងជា ប្រធានផ្នែកស្លាកយីហោ និងផ្សព្វផ្សាយ នៅខែកញ្ញា ឆ្នាំ២០១០ និងត្រូវបានតំឡើងតំណែងជានាយកនាយកដ្ឋានទីផ្សារ ក្នុងខែសីហា ឆ្នាំ២០១៥។



**លោក យិន ផល្លី**

នាយកនាយកដ្ឋានឥណទានសម្ភារប្រើប្រាស់

លោក យិន ផល្លី ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញហិរញ្ញវត្ថុ ពីសកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រ ជំនាញគណនេយ្យពី សកលវិទ្យាល័យ វេទមហាឫស្សី និងចុងក្រោយ លោកបានបញ្ចប់វគ្គបណ្តុះបណ្តាល ទាក់ទងនឹងគណនេយ្យពី CamEd Business School។ ក្រៅពីទទួលបានការសិក្សាខាងលើ លោក យិន ផល្លី ក៏បានចូលរួមសិក្សាវគ្គបណ្តុះបណ្តាល Microfinance Winter Academy ពី Frankfurt School of Finance &Management ផងដែរ។ មុនពេលចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី គាត់មានបទពិសោធន៍ជាង១៥ឆ្នាំ នៅប្រទេសកម្ពុជា ទាក់ទងការគ្រប់គ្រង និងការអភិវឌ្ឍន៍អាជីវកម្មហិរញ្ញវត្ថុ និងពាណិជ្ជកម្ម សវនកម្ម និងអភិបាលកិច្ច។ គាត់បានបម្រើការងារអស់រយៈពេលជាង៥ឆ្នាំ នៅ GL Finance PL ក្នុងផ្នែកគ្រប់គ្រងប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ជាង៤ឆ្នាំ នៅ Toyota Tsusho Corporation ផ្នែកអភិវឌ្ឍន៍ និងគ្រប់គ្រងអាជីវកម្ម និងជាង៥ឆ្នាំ ទៅលើការងារសវនកម្មជាមួយស្ថាប័នដូចជា Coca Cola និងអាជ្ញាធរសវនកម្មជាតិ។ ក្នុងកំឡុងពេលជាង១៥ឆ្នាំ ក្នុងអាជីពការងារ លោក យិន ផល្លី សម្រេចបាននូវសមិទ្ធផលជាច្រើន ក្នុងការផ្តល់ជូនអតិថិជន នូវសេវាកម្មហិរញ្ញវត្ថុដែលមានភាពបត់បែន ទៅតាមតម្រូវការទីផ្សារ ការបង្កើតអាជីវកម្មថ្មីៗតម្រូវនឹងកាលានុវត្តភាពទីផ្សារ ដោយផ្តោតសំខាន់ជាពិសេសទៅលើគុណភាពនៃផលិតផល សេវាកម្មអតិថិជន និងផ្តល់ដំណោះស្រាយ ផ្នែកហិរញ្ញវត្ថុដែលសមស្រប ដើម្បីបំពេញតាមតម្រូវការជាក់លាក់របស់អតិថិជន ប្រកបដោយភាពច្នៃប្រឌិត និងងាយស្រួល។



**លោកស្រី ខេង ណារី**

លេខាធិការិកាក្រុមហ៊ុន

លោកស្រី ខេង ណារី ទទួលសញ្ញាបត្របរិញ្ញាបត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាស ពីសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១០ និងបរិញ្ញាបត្រអក្សរសាស្ត្រ ជំនាញទំនាក់ទំនង ពីវិទ្យាស្ថានភាសាបរទេសនៃ សកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០១២ ហើយបានបញ្ចប់កិច្ចការស្រាវជ្រាវនៅ សុខគង់ អាហារ៉េណ និហារ៉េណ ខូអិលធីឌី។ បន្ថែមលើនេះ លោកស្រី ទទួលបានវិញ្ញាបនបត្រ ភាសាអង់គ្លេស ពីវិទ្យាស្ថានភាសាបរទេសបញ្ញាសាស្ត្រ និងទទួលបានការបណ្តុះបណ្តាល និងសិក្សាវគ្គខ្លី ដូចជាមូលដ្ឋានគ្រឹះគណនេយ្យ ពីអង្គការអភិវឌ្ឍន៍ធនធានមនុស្សិត និងជំនាញសរសេររបាយការណ៍ ពីអង្គការសិក្សាដើម្បីអភិវឌ្ឍន៍។ មុនបំពេញការងារនៅ អិលអូអិលស៊ី លោកស្រីធ្លាប់បំរើការងារនៅក្រុមហ៊ុនវីង ផ្នែកបំពីសេវាកម្មអតិថិជនក្នុងឆ្នាំ២០១២។ លោកស្រីចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី ក្នុងតំណែងជាជំនួយការលេខាធិការិកានៅក្នុងឆ្នាំ២០១៣ និងត្រូវបានតំឡើងតំណែងជាលេខាធិការិកាក្រុមហ៊ុន ក្នុងខែមិថុនា ឆ្នាំ២០១៤។

# ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុង

ការគ្រប់គ្រងហានិភ័យ តែងតែផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រផែនការអាជីវកម្ម របស់ស្ថាប័នហិរញ្ញវត្ថុនីមួយៗ រួមទាំង អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ផងដែរ។ ទស្សនៈនៃការគ្រប់គ្រងហានិភ័យរបស់ អិលអូអិលស៊ី គឺការគ្រប់គ្រងហានិភ័យត្រូវចូលរួមចំណែកធ្វើឱ្យយុទ្ធសាស្ត្រអាជីវកម្មកាន់តែប្រសើរឡើង ជួយក្នុងដំណើរការសម្រេចចិត្ត និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង។ ក្របខណ្ឌគ្រប់គ្រងហានិភ័យរបស់ អិលអូអិលស៊ី មានគោលបំណងពង្រឹងសមត្ថភាពក្នុងការកំណត់ វាស់វែង និងគ្រប់គ្រងហានិភ័យ ដើម្បីបង្កើនតម្លៃរបស់ភាគទុនិកដោយសម្របការគ្រប់គ្រងហានិភ័យទៅនឹងយុទ្ធសាស្ត្ររួមរបស់ អិលអូអិលស៊ី វាយតម្លៃផលប៉ះពាល់នៃហានិភ័យដែលកំពុងកើតមានឡើងបង្កើតយុទ្ធសាស្ត្រដោះស្រាយ និងកាត់បន្ថយហានិភ័យ ដែលឆ្លុះបញ្ចាំងពីអភិបាលកិច្ចដ៏រឹងមាំរបស់ស្ថាប័ន។ អិលអូអិលស៊ី អនុវត្តគោលការណ៍គ្រប់គ្រងហានិភ័យនៅក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃដូចខាងក្រោម៖

- លើកកម្ពស់ប្រាក់ចំណេញ និងកំណើនសេដ្ឋកិច្ចរយៈពេលវែងប្រកបដោយចីរភាព ដោយអនុវត្តការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចដោយប្រុងប្រយ័ត្ន។
- ជួយដល់អាជីវកម្មក្នុងការបង្កើតប្រាក់ចំណេញដែលមានស្ថេរភាព និងនិរន្តរភាពសម្រាប់ភាគទុនិក។
- ធានាថាយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ អិលអូអិលស៊ី គឺផ្អែកលើការយល់ដឹងច្បាស់ពីហានិភ័យដែលកំពុងប្រឈម ការវាយតម្លៃវាស់វែង និងគ្រប់គ្រងហានិភ័យដែលមានបែបបទត្រឹមត្រូវ។

## អភិបាលកិច្ចគ្រប់គ្រងហានិភ័យ




**គណៈកម្មាធិការគ្រប់គ្រងហានិភ័យកម្រិតក្រុមប្រឹក្សាភិបាល** ត្រូវបានបង្កើតឡើង និងដឹកនាំដោយ សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យមួយរូប។ បេសកកម្មរបស់គណៈកម្មាធិការនេះ គឺត្រួតពិនិត្យមើលហានិភ័យនានាដែលកើតឡើងទាំងខាងក្នុង និងខាងក្រៅ ដែលទាក់ទងនឹងប្រតិបត្តិការឥណទាន និងហិរញ្ញវត្ថុ ដើម្បីធានាថាការអនុវត្តលើគោលការណ៍ និងនីតិវិធី មានប្រសិទ្ធភាពក្នុងការកំណត់ហានិភ័យ និងគ្រប់គ្រងហានិភ័យ និងអនុលោមតាមសេចក្តីណែនាំផ្ទៃក្នុង ក៏ដូចជាតម្រូវការពីខាងក្រៅ។ បន្ថែមលើនេះទៀត គណៈកម្មាធិការនេះ នឹងត្រួតពិនិត្យមើលលើការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាសុវត្ថិភាពទ្រព្យសកម្ម និងធនធានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ជាធម្មតា គណៈកម្មាធិការនេះជួបប្រជុំរៀងរាល់បីខែម្តង។

**ហានិភ័យហិរញ្ញវត្ថុ** ត្រូវបានត្រួតពិនិត្យ និងគ្រប់គ្រងដោយគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម ដោយមានគោលបំណងចម្បងក្នុងការវាយតម្លៃតាមដាន និងអនុម័តលើការអនុវត្តទាក់ទងនឹងហានិភ័យសន្ទនីយភាព ហានិភ័យអត្រាការប្រាក់ ហានិភ័យបទប្បញ្ញត្តិនានា ហានិភ័យរូបិយប័ណ្ណ និងហានិភ័យហិរញ្ញវត្ថុផ្សេងៗទៀត ដើម្បីបង្កើននូវប្រសិទ្ធភាពប្រាក់ចំណេញ ទន្ទឹមនឹងនេះក៏ធានាថាសាច់ប្រាក់ត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម ត្រូវបានដឹកនាំដោយប្រធាននាយកហិរញ្ញវត្ថុ ហើយជួបប្រជុំរៀងរាល់មួយខែម្តង។

## ហានិភ័យឥណទាន

**ហានិភ័យឥណទាន** ត្រូវបានឱ្យនិយមន័យថា ជាលទ្ធភាពនៃការខាតបង់ ដោយសារអ្នកជំពាក់ប្រាក់ ពុំបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាជាមួយអិលអូអិលស៊ី។ ហានិភ័យឥណទាន ត្រូវបានគ្រប់គ្រងដោយការអនុវត្តនូវរចនាសម្ព័ន្ធល្អនៃគោលនយោបាយហានិភ័យឥណទាន គោលការណ៍ណែនាំស្តីពីប្រតិបត្តិការឥណទាន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតដែលត្រូវបានអនុវត្តដើម្បីគ្រប់គ្រងគុណភាពផលប័ត្រឥណទានរបស់ អិលអូអិលស៊ី។

**ហានិភ័យឥណទាន** ត្រូវបានត្រួតពិនិត្យជាប្រចាំ តាមដានយ៉ាងសកម្ម និងរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងហានិភ័យជារៀងរាល់ខែ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងនាយកដ្ឋានពាក់ព័ន្ធ បានធ្វើការពិភាក្សាវិភាគ និងកំណត់អត្តសញ្ញាណបញ្ហាផ្សេងៗ ដោយមានចំណាត់ការសមស្រប និងទាន់ពេលវេលា។

## ហានិភ័យសន្ទនីយភាព

**ហានិភ័យសន្ទនីយភាព** កើតឡើងពីការអសមត្ថភាពរបស់ស្ថាប័នក្នុងការបំពេញកាតព្វកិច្ច និងតម្រូវការថវិកាប្រកបដោយប្រសិទ្ធភាព ទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត នៅពេលដល់កាលកំណត់។ ហានិភ័យសន្ទនីយភាព ត្រូវបានត្រួតពិនិត្យជាចម្បង និងគ្រប់គ្រងជាទៀងទាត់ ផ្អែកលើមូលដ្ឋាននៃការព្យាករណ៍លំហូរសាច់ប្រាក់ ដែលជាទូទៅកើតឡើងពីកាលកំណត់នៃទ្រព្យសកម្ម ទ្រព្យអកម្ម តារាងតុល្យការខាងក្រៅ និងស្ថានភាពស្ត្រេសផ្សេងៗ។

**អិលអូអិលស៊ី** តែងតែធ្វើស្ត្រេសតេស្តសាច់ប្រាក់ងាយស្រួលជារៀងរាល់ឆ្នាំ ដើម្បីកំណត់តំបន់ដែលងាយរងគ្រោះទៅលើផលប័ត្រឥណទានរបស់ខ្លួន ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដែលបានរំពឹងទុក និងជួយដល់គណៈគ្រប់គ្រងក្នុងការចាត់វិធានការទុកជាមុន។

## ហានិភ័យប្រតិបត្តិការ

**ហានិភ័យប្រតិបត្តិការ** គឺផ្សារភ្ជាប់ទៅនឹងការភាន់ច្រឡំរបស់បុគ្គលិក បរាជ័យប្រព័ន្ធបច្ចេកវិជ្ជា និងកង្វះនូវនីតិវិធី និងការត្រួតពិនិត្យពុំមានភាពគ្រប់គ្រាន់។ ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់បណ្តាលមកពីសក្តានុពលដែលប្រព័ន្ធបច្ចេកវិជ្ជាមានភាពខ្វះខាតការបរាជ័យនៃបច្ចេកវិជ្ជា ការបំពានលើការត្រួតពិនិត្យផ្ទៃក្នុង ការគៃបន្លំ ឬបញ្ហាប្រតិបត្តិការផ្សេងៗទៀត ដែលអាចបណ្តាលឱ្យមានការបាត់បង់នឹកស្មានពុំដល់ ឬបញ្ហាប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ។ ហានិភ័យប្រតិបត្តិការ មាននៅក្នុងគ្រប់ផលិតផល និងរាល់សកម្មភាពអាជីវកម្មទាំងអស់។ អិលអូអិលស៊ី បានធ្វើការកំណត់នូវអត្តសញ្ញាណ និងវាយតម្លៃហានិភ័យប្រតិបត្តិការដែលមាននៅក្នុងគ្រប់ផលិតផល រាល់សកម្មភាព ដំណើរការ និងប្រព័ន្ធបច្ចេកវិជ្ជាទាំងអស់ និងភាពងាយរងគ្រោះដោយសារហានិភ័យទាំងនេះ។ អិលអូអិលស៊ី តែងតែធានាថា មុនពេលដែលផលិតផល សកម្មភាពដំណើរការ និងប្រព័ន្ធបច្ចេកវិជ្ជាថ្មីៗត្រូវបានអនុវត្ត ឬដាក់ឱ្យប្រើប្រាស់ ហានិភ័យប្រតិបត្តិការដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យត្រឹមត្រូវតាមនីតិវិធី។

## ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ សំដៅទៅលើហានិភ័យនៃការខាតបង់នៅក្នុងបញ្ជីជួញដូររបស់ អិលអូអិលស៊ី ដោយសារការផ្លាស់ប្តូរថ្លៃមូលធន អត្រាការប្រាក់ អត្រាប្តូររូបិយប័ណ្ណបរទេស និងសូចនាករផ្សេងៗទៀត ដែលតម្លៃទាំងនោះត្រូវបានកំណត់នៅលើទីផ្សារសាធារណៈ។ ហានិភ័យអត្រាការប្រាក់កើតឡើងជាចម្បងពី ឥណប្រតិទានខុសៗគ្នា និងការប្តូរតម្លៃ ក្នុងលំហូរសាច់ប្រាក់។ បច្ចុប្បន្ន ហានិភ័យអត្រាការប្រាក់ ត្រូវបានវាស់វែងដោយការវិភាគលើគម្លាតនៃការប្រែប្រួលអត្រាការប្រាក់។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម ជាអ្នកទទួលខុសត្រូវក្នុងការតាមដានហានិភ័យអត្រាការប្រាក់របស់ អិលអូអិលស៊ី ដោយផ្អែកលើការវិភាគគម្លាតនៃការប្រែប្រួលអត្រាការប្រាក់។



# របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករឯករាជ្យ



- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
- របាយការណ៍លំហូរទឹកប្រាក់
- កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ (ទទួលប្រាក់បញ្ញើ និងផ្តល់ឥណទាន) ដល់ប្រជាជនកម្ពុជានៅតាមជនបទ និងសហគ្រាសខ្នាតតូច និងសហគ្រាសខ្នាតមធ្យម តាមរយៈទីស្នាក់ការកណ្តាល នៅរាជធានីភ្នំពេញ និងសាខានានានៅតាមបណ្តាខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទស្សនវិស័យរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មហិរញ្ញវត្ថុដែលអាចជឿជាក់បាន និងអាចលៃលកបានជូនសហគ្រិនខ្នាតតូច និងមធ្យម ។

ពុំមានការផ្លាស់ប្តូរជាសារវន្ត លើសកម្មភាពចម្បងរបស់ក្រុមហ៊ុន នៅក្នុងអំឡុងការិយបរិច្ឆេទធ្វើរបាយការណ៍ហិរញ្ញវត្ថុ នេះទេ ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | ឆ្នាំ ២០១៩ ពាន់រៀល | ឆ្នាំ ២០១៨ ពាន់រៀល | ឆ្នាំ ២០១៩ ដុល្លារអាមេរិក (កំណត់សម្គាល់ ៥) | ឆ្នាំ ២០១៨ ដុល្លារអាមេរិក (កំណត់សម្គាល់ ៥) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៦០.៩៩៨.៩១៤ | ៨២.២៩៤.៣០៣ | ៣៩.៧៣៣.១៩៦ | ២០.៣៤៤.៦៩៦ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១៧.២៦៦.០៧២) | (២០.៧៤៧.៩២២) | (៤.២៦១.១២៣) | (៥.១២៩.២៧៦) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ១៤៣.៧៣២.៨៤២ | ៦១.៥៤៦.៣៨១ | ៣៥.៤៧២.០៧៣ | ១៥.២១៥.៤២០ |

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភទេ ហើយក្រុមប្រឹក្សាភិបាល ក៏ពុំមានអនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានរងសវនកម្មនេះទេ។

## ដើមទុន

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្រុមហ៊ុនបានផ្ញើលិខិតស្នើសុំទៅ ធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនដើមទុនពី ១២០.០០០.០០០ ពាន់រៀល (សមមូល ២៩.២០៤.៣២៧ដុល្លារអាមេរិក) ទៅ ១៤០.៨៤៦.៦០០ពាន់រៀល (សមមូល ៣៤.៥៦៣.៥៨៣ដុល្លារអាមេរិក)។ សំណើសុំនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩។

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនបានផ្ញើលិខិតស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនដើមទុនពី ១៤០.៨៤៦.៦០០ ពាន់រៀល (សមមូល ៣៤.៥៦៣.៥៨៣ដុល្លារអាមេរិក) ទៅ ១៨២.៦១២.០០០ពាន់រៀល (សមមូល ៤៤.៨១២.៧៦១ដុល្លារអាមេរិក)។ សំណើសុំនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ។

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ក្រុមហ៊ុនបានផ្ញើលិខិតស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនដើមទុនពី ១៨២.៦១២.០០០ ពាន់រៀល (សមមូល ៤៤.៨១២.៧៦១ដុល្លារអាមេរិក) ទៅ ២២៤.៣៧៧.៤០០ពាន់រៀល (សមមូល ៥៥.៤៤៤.៧៤៦ដុល្លារអាមេរិក)។ សំណើសុំនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្ត នៃទុនបម្រុង និងសំវិធានធន នៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានផ្តល់ដល់អតិថិជន

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង អ្នកគ្រប់គ្រងបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយអភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថា មិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់លើការបាត់បង់ឥណទាន។

នាថ្ងៃចេញរបាយការណ៍នេះ អភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយ ដែលអាចនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធន លើការបាត់បង់ឥណទានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនខ្វះខាតជាសារវន្តនោះឡើយ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង អភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថា បណ្ដាទ្រព្យសកម្មចរន្តលើកលែងបំណុលដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលសន្និដ្ឋានថាមានតម្លៃមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថា នឹងអាចប្រមូលបានជាក់ស្ដែង។

នាថ្ងៃចេញរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថា មានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថា មានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយ របស់ក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយ ដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

អភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលក្រុមហ៊ុនត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

## ការប្រែប្រួលសភាពការណ៍

នាថ្ងៃចេញរបាយការណ៍នេះ អភិបាលរបស់ក្រុមហ៊ុន ពុំបានពិនិត្យឃើញសភាពការណ៍ណាមួយ ដែលមិនបានរៀបរាប់ នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចនឹងបណ្ដាលឱ្យមានតួលេខនៃចំនួនណាមួយ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់អភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការ របស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈមិនប្រក្រតីនោះទេ។

អភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់ សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ព្រឹត្តិការណ៍ចាប់តាំងពីកាលបរិច្ឆេទរាយការណ៍

នាការិយបរិច្ឆេទរបាយការណ៍នេះ លើកលែងការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពុំមានព្រឹត្តិការណ៍សំខាន់កើតមានឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យមានការធ្វើនិយ័តកម្ម ឬការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ក្រុមប្រឹក្សាភិបាល

អភិបាលដែលបានបម្រើការនៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅថ្ងៃដែលចេញរបាយការណ៍នេះ រួមមាន៖

លោក Brindley Chrishantha Gajanayake de Zylva ប្រធានក្រុមប្រឹក្សាភិបាល

លោក Indrajith Wijesiriwardana សមាជិក

លោក Hans Michael Theodor Moormann សមាជិក

លោក Dulip Rasika Samaraweera សមាជិក

លោក Francisco Kankanamalage Conrad Prasad Nirosh Dias សមាជិក។

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ អាចផ្ដល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃ។

នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍នេះ ពុំមានអភិបាលណាម្នាក់ របស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបទទួលបាន ឬដល់កំណត់ទទួលបានដោយអភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន ដែលអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវ របស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈ ធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុ បានរៀបចំឡើងយ៉ាងត្រឹមត្រូវ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(ខ) អនុលោមទៅតាមស្តង់ដារបាយការណ៍ ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) ឬ ប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុនឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុនហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា អភិបាលបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយដូចបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល៖




លោក សុខ រឿន
ប្រធាននាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃចន្ទ ៧កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិក អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មទៅលើ របាយការណ៍ហិរញ្ញវត្ថុ របស់អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី១១ ដល់ទី១៤២ (ដែលហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុ”) ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្តបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”)។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀត នៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុនដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវ លើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្ម របស់យើងខ្ញុំ ។

## បញ្ហាផ្សេងៗ

ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៣៥ នៃ របាយការណ៍ហិរញ្ញវត្ថុ ក្រុមហ៊ុនបានអនុវត្ត ស.រ.ទ.ហ.អ.ក នៅថ្ងៃទី១ ខែមករា ឆ្នាំ ២០១៩ ដែលមានកាលបរិច្ឆេទអន្តរកាលនៅថ្ងៃទី១ ខែមករា ឆ្នាំ ២០១៨។ ស្តង់ដារទាំងនេះ គឺត្រូវអនុវត្តតាមវិធីសាស្រ្តប្រតិសកម្មលើព័ត៌មានប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ព្រមទាំងរបាយការណ៍ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងកំណត់ពន្យល់ពាក់ព័ន្ធផ្សេងៗ។ យើងខ្ញុំមិនតម្រូវឱ្យធ្វើសវនកម្ម លើព័ត៌មានប្រៀបធៀបដែលបានកែប្រែឡើងវិញទេឡើយ ហើយព័ត៌មានទាំងនេះ មិនត្រូវបានធ្វើសវនកម្មទេ ។ ការទទួលខុសត្រូវរបស់យើងខ្ញុំ លើព័ត៌មានប្រៀបធៀបទាំងនេះ គឺត្រូវកំណត់ថាតើរបាយការណ៍ហិរញ្ញវត្ថុបានរួមបញ្ចូលនូវព័ត៌មានប្រៀបធៀបដែលតម្រូវដោយ ស.រ.ទ.ហ.អ.ក និងថាតើព័ត៌មានប្រៀបធៀបទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់សមស្របឬទេ ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី ៥៨ ដល់ទី ៦០ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថានឹងរួចរាល់ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។ មតិសវនកម្មរបស់យើងខ្ញុំទៅលើ របាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះមានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវកាបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ កាបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គង តែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យ ដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែ ការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាង ដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលកើតឡើងដោយសារតែការ ក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គងដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បី រៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិ លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។
- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុន បានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធ ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៣៥.៦៣៦.៩០៧ | ១២៤.២៩០.៣៨៥ | ១៦០.៨១៦.៤៦៧ | ៣១៨.២៣៦.១៣១ | ២១២.៩២៦.០៣៦ | - | - | ៩៥១.៩០៥.៩២៦ |
| ប្រាក់កម្ចី | ១២.៦៥០.០១៦ | ៦៧.០៧៤.២៤០ | ១០២.៩៩២.៦០២ | ១៦៣.៦១៧.៣៩១ | ៦១៥.៩៨៤.១១៣ | ៤០.៥៧២.២៤៥ | ៩.៣០៦.៦៣៦ | ១.០១១.៧៩៧.២៤៣ |
| អនុបំណុល | - | ៤.០៣០.៨២២ | ២.៤៥៧.៥៥១ | - | ៥៩.០២៣.៨៦៣ | ១៩.៥៩៣.៧២១ | - | ៨៥.១០៥.៩៥៧ |
| បំណុលផ្សេងៗ | - | - | - | - | - | - | ៦០.៥៧៣.២៩៥ | ៦០.៥៧៣.២៩៥ |
| | ១៤៨.២៨៦.៩២៣ | ១៩៥.៣៩៥.៤៤៧ | ២៦៥.៨៦៦.៦២០ | ៤៨១.៨៥៣.៥២២ | ៨៨៧.៩៣៤.០១២ | ៦០.១៦៥.៩៦៦ | ៦៩.៨៧៩.៩៣១ | ២.១០៩.៣៨២.៤២១ |
| ( សមមូលដុល្លារអាមេរិក- កំណត់សម្គាល់ ៥ ) | ៣៦.៩០៥.៦៥៥ | ៤៨.៦៣០.០២៧ | ៦៦.១៦៨.៩៥៥ | ១១៩.៩២៣.៧២៤ | ២២០.៩៩៩.០៥២ | ១៤.៩៧៤.១០៨ | ១៧.៣៩១.៧២០ | ៥២៤.៩៨៣.១៨១ |

## ង. ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការគឺជាហានិភ័យនៃការបាត់បង់ផ្ទាល់ឬប្រយោលដែលកើតមានឡើងពីការខ្វះខាត ឬការអនុវត្តមិនមានប្រសិទ្ធភាពនូវនីតិវិធីដំណើរការផ្ទៃក្នុង បុគ្គលិក ឬប្រព័ន្ធ ឬពីកត្តាខាងក្រៅ។ ហានិភ័យនេះត្រូវបានគ្រប់គ្រងតាមរយៈ ការបង្កើតប្រព័ន្ធដំណើរការ គ្រប់គ្រងប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឱ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្មតាមរយៈអង្គភាពគ្រប់គ្រង និងគាំទ្រដែលឯករាជ្យពីអង្គភាពអាជីវកម្ម និងគណៈគ្រប់គ្រង។ ទាំងនេះរួមមាន ហានិភ័យខាងផ្នែកច្បាប់តាមច្បាប់នៃការអនុលោមតាមគណនេយ្យ និងការក្លែងបន្លំ។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់ក្រុមហ៊ុន តម្រូវឱ្យបង្កើតនូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាពឱ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើនត្រូវបានអនុវត្តរួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខាប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ ការរៀបចំនូវនីតិវិធី និងឯកសារសំអាងនានាព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។ ដំណើរការទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការ ដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន។

## ច. ការគ្រប់គ្រងដើមទុន

### (i). បទប្បញ្ញត្តិដើមទុន

គោលដៅរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិ
- ការពារលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម ដូចនេះក្រុមហ៊ុនអាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងក្រុមហ៊ុន និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម។

គោលនយោបាយរបស់ក្រុមហ៊ុន គឺធានាឱ្យបាននូវមូលដ្ឋានដើមទុនរឹងមាំដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានាស្ថេរភាពនៃការអភិវឌ្ឍយូរអង្វែងរបស់អាជីវកម្ម។ ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើភាគលាភរបស់ការិយាល័យកណ្តាលក៏ត្រូវបានទទួលស្គាល់ហើយក្រុមហ៊ុនបានទទួលស្គាល់នូវតម្រូវការ ដើម្បធានាបាននូវតុល្យភាពរវាងភាគលាភខ្ពស់ដែលអាចនឹងកើតមានឡើង ជាមួយនឹងប្រាក់បម្រុងកម្រិតខ្ពស់ អត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ។

ដើមទុនបង្ហាញខាងលើនេះត្រូវបានគណនាឡើងដោយផ្អែកតាមសេចក្តីណែនាំ ដែលចេញផ្សាយដោយ ធនាគារជាតិនៃកម្ពុជា ដែលអាចមានភាពខុសគ្នាទៅលើគោលការណ៍សំខាន់ខ្លះៗបើប្រៀបធៀបទៅនឹងគោលការណ៍ដែលបានទទួលស្គាល់ជាទូទៅ ដែលស្ថាប័នហិរញ្ញវត្ថុនៅប្រទេសដ៏ទៃបានអនុវត្ត។ ដូច្នេះព័ត៌មានអំពីដើមទុនខាងលើមិនសមស្របសម្រាប់អ្នកប្រើប្រាស់ដែលមិនបានទទួលពត៌មានអំពីសេចក្តីណែនាំ របស់ធនាគារជាតិនៃកម្ពុជា។

### (ii). ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភដែលទទួលបានពីការបែងចែកនោះ។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់។

ឧបករណ៍ហិរញ្ញវត្ថុរួមមានទ្រព្យសកម្មហិរញ្ញវត្ថុបំណុលហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការ។ តម្លៃសមរម្យគឺជាថ្លៃដែលត្រូវទទួលដើម្បីលក់ទ្រព្យសកម្ម ឬបានទូទាត់ដើម្បីផ្ទេរបំណុលទៅតាមលំដាប់លំដោយនៅក្នុងប្រតិបត្តិការរវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែងចម្បង ឬប្រសិនអវត្តមានទីផ្សារដែលមានការរីកចម្រើនបំផុតដែលក្រុមហ៊ុនបានទទួលនៅកាលបរិច្ឆេទនោះ។ ព័ត៌មានដែលបានបង្ហាញនៅទីនេះ តំណាងឱ្យការប៉ាន់ស្មាននៃតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុ។

តម្លៃទីផ្សារដែលបានដកស្រង និងអាចអង្កេតបាន ហើយអាចរកបានត្រូវបានប្រើសម្រាប់វាស់វែងលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ។ នៅពេលដែលតម្លៃទីផ្សារដែលបានដកស្រង់ និងអាចសង្កេតបាន មិនអាចប្រើប្រាស់បាននោះតម្លៃសមស្របត្រូវបានប៉ាន់ស្មានដោយផ្អែកលើវិធីសាស្ត្រ និងការសន្មតជាច្រើនទាក់ទងទៅនឹងលក្ខណៈហានិភ័យនៃឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដែលមានអត្រាអប្បហារការប៉ាន់ស្មាននៃលំហូរទឹកប្រាក់នាពេលអនាគត និងកត្តាផ្សេងៗទៀត។

ព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម និងបំណុលមិនមែនហិរញ្ញវត្ថុមិនត្រូវបានរាប់បញ្ចូលទេ ពីព្រោះវាមិនស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក៧៖ ការបង្ហាញឧបករណ៍ហិរញ្ញវត្ថុ ដែលទាមទារឱ្យមានការបង្ហាញព័ត៌មាននៃតម្លៃសមស្រប។

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមាន ដូចជាសាច់ប្រាក់ និងមូលនិធិរយៈពេលខ្លីនៅធនាគារជាតិ និងប្រាក់បញ្ញើជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា ទ្រព្យសកម្មផ្សេងៗ បំណុលផ្សេងៗ និងប្រាក់កម្ចីរយៈពេលខ្លីមិនមានលក្ខណៈជាសារវន្តចំពោះការផ្លាស់ប្តូរអត្រាប្រាក់ចំណេញក្នុងទីផ្សារដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះមានរយៈពេលកំណត់ជាក់លាក់។ តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងនេះនៅកាលបរិច្ឆេទរាយការណ៍ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា។

តម្លៃសមស្របគឺផ្អែកលើវិធីសាស្ត្រ និងការសន្មតដូចខាងក្រោម៖

#### ការវិនិយោគ

តម្លៃសមស្របដែលបានប៉ាន់ស្មានជាទូទៅ គឺផ្អែកលើតម្លៃទីផ្សារដែលបានដកស្រង់និងអាចអង្កេតបាន។ នៅពេលមិនមានទីផ្សារដែលមានស្រាប់សម្រាប់មូលបត្រមួយចំនួននោះតម្លៃសមស្របត្រូវបានប៉ាន់ស្មានលើទិន្នន័យទីផ្សារប្រហាក់ប្រហែល ឬទ្រព្យសកម្មរូបីសុទ្ធរបស់វិនិយោគិន។

### ហិរញ្ញប្បទាន បុរេប្រទាន និងផ្សេងៗទៀត

តម្លៃសមស្របត្រូវបានប៉ាន់ស្មានដោយការធ្វើអប្បហារលើលំហូរទឹកប្រាក់ ដែលបានប៉ាន់ស្មាននាពេលអនាគតដោយប្រើអត្រាទីផ្សារនៃការផ្តល់ហិរញ្ញប្បទានដែលមានហានិភ័យឥណទាន និងកាលកំណត់ស្រដៀងគ្នា។

## ៣៤. តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

ចំណាត់ថ្នាក់តម្លៃសមស្រប ស.រ.ហ.អ.ក ៧ បញ្ជាក់ពីចំណាត់ថ្នាក់នៃបច្ចេកទេសវាយតម្លៃដោយផ្អែកលើថា តើទិន្នន័យនៃបច្ចេកទេសវាយតម្លៃទាំងនោះអាចអង្កេតបាន ឬមិនអាចអង្កេតបាន។ ទិន្នន័យដែលអាចអង្កេតបានឆ្លុះបញ្ចាំងពីទិន្នន័យទីផ្សារដែលទទួលបានពីប្រភពឯករាជ្យ និងទិន្នន័យដែលមិនអាចអង្កេតបានឆ្លុះបញ្ចាំងពីការសន្មតទីផ្សាររបស់ក្រុមហ៊ុន។

ចំណាត់ថ្នាក់នៃតម្លៃសមស្របមានដូចខាងក្រោម៖

- កម្រិត ១ - តម្លៃដកស្រង់ (មិនបានធ្វើនិយ័តភាព) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា។ កម្រិតនេះរាប់បញ្ចូលទាំងមូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជីនិងឧបករណ៍បំណុល។
- កម្រិត ២ - ទិន្នន័យក្រៅពីតម្លៃដែលបានដកស្រង់រាប់បញ្ចូលក្នុងកម្រិត១ដែលអាចអង្កេតបានចំពោះទ្រព្យសកម្ម ឬបំណុល ដោយផ្ទាល់ (ឧទាហរណ៍ តម្លៃ) ឬដោយប្រយោល (ឧទាហរណ៍ កើតចេញពីតម្លៃ)។
- កម្រិត ៣ - ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (ធាតុចូលដែលមិនអាចអង្កេតបាន)។ កម្រិតនេះរួមបញ្ចូលទាំងឧបករណ៍មូលធន និងឧបករណ៍ បំណុលដែលមានសមាសធាតុមិនអាចអង្កេតបានជាសារវន្ត។

តម្លៃយោង និងតម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរួមបញ្ចូលទាំងកម្រិតរបស់ពួកគេនៅក្នុងចំណាត់ថ្នាក់តម្លៃសមស្របមានដូចខាងក្រោម។ វាមិនបានរាប់បញ្ចូលព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលមិនត្រូវបានវាស់វែងតាមតម្លៃសមស្របទេប្រសិនបើតម្លៃយោងមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប។

| | | តម្លៃសមស្រប | |
|---|---|---|---|
| | កម្រិត ១<br>ពាន់រៀល | កម្រិត ២<br>ពាន់រៀល | កម្រិត ៣<br>ពាន់រៀល |
| **ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩** | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្រប** | | | |
| ការវិនិយោគ | - | - | ៦១.១២៥ |
| សរុប (ដុល្លារអាមេរិក) កំណត់សំគាល់ ៥ | - | - | ១៥.០០០ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុមិនបានវាស់វែងតាមតម្លៃសមស្រប** | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | - | - | ៧៥៣.១៩៦.៨៤៤ |
| ប្រាក់បញ្ញើជាមួយធនាគារនានា | - | - | ២០០.១៩១ |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | - | - | ៣.១១៥.៤៩១.៩២៥ |
| ផ្សេងៗ | - | - | ៩.០៩១.៦៦៨ |
| សរុប (ពាន់រៀល) | - | - | ៣.៨៧៧.៩៦០.៦២៨ |
| សរុប (ដុល្លារអាមេរិក) - កំណត់សម្គាល់ ៥ | - | - | ៩៥១.៦៤៦.៧៧៧ |

| | តម្លៃសមស្រប | | |
|---|---|---|---|
| | កម្រិត ១<br>ពាន់រៀល | កម្រិត ២<br>ពាន់រៀល | កម្រិត ៣<br>ពាន់រៀល |
| **ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨** | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្រប** | | | |
| ការវិនិយោគ | - | - | ៦០.២៧០ |
| សរុប (ដុល្លារអាមេរិក) កំណត់សំគាល់ ៥ | - | - | ១៥.០០០ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុមិនបានវាស់វែងតាមតម្លៃសមស្រប** | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | - | - | ៣៦៨.២៤៤.៦១៧ |
| ប្រាក់បញ្ញើជាមួយធនាគារនានា | - | - | ២០០.៣៤០ |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | - | - | ១.៩២២.៣៩៤.៧៥១ |
| ផ្សេងៗ | - | - | ៣.៧៥៩.៧១៣ |
| សរុប (ពាន់រៀល) | - | - | ២.២៩៤.៥៩៩.៤២១ |
| សរុប (ដុល្លារអាមេរិក) - កំណត់សម្គាល់ ៥ | - | - | ៥៧១.០៧៩.៩៩៥ |

## ៣៥. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានបង្ហាញនៅខាងក្រោមនេះត្រូវបានអនុវត្តដោយសង្គតិភាពនៅគ្រប់កាលបរិច្ឆេទដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ហើយនៅក្នុងការរៀបចំរបាយការណ៍ស្ថានហិរញ្ញវត្ថុតាម ស.រ.ហ.អ.ក ដំបូង នៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១៨ ក្នុងគោលបំណងផ្លាស់ប្តូរទៅ ស.រ.ហ.អ.ក លើកលែងតែមានការបង្ហាញផ្សេងពីនេះ។

### ក. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើមដំបូង។

### ខ. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់រៀល។ អ្នកគ្រប់គ្រងក៏បានកំណត់ថា ប្រាក់រៀលជារូបិយប័ណ្ណមុខងារ និងជារូបិយបណ្ណ័សម្រាប់ធ្វើការបង្ហាញព្រោះវាឆ្លុះបញ្ចាំងពីសារជាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានបង្ហាញជាប្រាក់រៀល ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ត្រូវបានកាត់ខ្ទង់ចំនួនមួយពាន់រៀលដែលជិតបំផុត បើមិនដូច្នេះទេលុះត្រាតែមានការបង្ហាញផ្សេងពីនោះ។

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

#### (i). ការទទួលស្គាល់ និងការវាស់វែងដំបូង

ក្រុមហ៊ុនទទួលស្គាល់ជាលើកដំបូងនូវឥណទានផ្តល់ដល់អតិថិជន ប្រាក់កម្ចី និងអនុបំណុល នៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ។ ទ្រព្យហិរញ្ញវត្ថុផ្សេងទៀតទទួលស្គាល់នៅ កាលបរិច្ឆេទដែលក្រុមហ៊ុនក្លាយជាភាគីកិច្ចសន្យា។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប (សម្រាប់ឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL")) បូកនឹងថ្លៃដើមប្រតិបត្តិការដែលកើតមកពីការទិញ ឬលក់ទ្រព្យ និងបំណុលទាំងនោះ។

#### (ii). ការចាត់ចំណាត់ថ្នាក់

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

នៅក្នុងការទទួលស្គាល់ដំបូងទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែងៈរំលស់ថ្លៃដើម FVOCI ឬ FVTP។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌដូចខាងក្រោមហើយមិនត្រូវបានកំណត់ជា FVTPL នោះទេៈ

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្មក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI")។

ឧបករណ៍បំណុលត្រូវបានវាស់វែងនៅ FVOCI លុះត្រាតែវាបានបំពេញនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ ជាFVTPL នោះទេៈ

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្មក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI")។

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនជាលើកដំបូងដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរក្រុមហ៊ុន ត្រូវតែជ្រើសរើសការបង្ហាញការប្រែប្រួលនាពេលបន្ទាប់តាមរយៈលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើការវិនិយោគនីមួយៗ។

### ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL

លើសពីនេះសម្រាប់ការទទួលស្គាល់ជាលើកដំបូង ក្រុមហ៊ុនអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង។

### ការវាយតម្លៃគំរូអាជីវកម្ម

ក្រុមហ៊ុនធ្វើការវាយតម្លៃអំពីគោលបំណងនៃ គំរូអាជីវកម្មលើទ្រព្យសកម្មក្នុងកម្រិតសំណុំឥណទាននីមួយៗ ព្រោះគំរូនេះបង្ហាញយ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានទៅអ្នកគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និង គោលបំណងដែលបានបញ្ជាក់សម្រាប់សំណុំឥណទាន និងអនុវត្តនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយធ្វើឱ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរទឹកប្រាក់តាមរយៈការលក់ទ្រព្យសកម្ម។
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសំណុំឥណទាន និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានចាត់ទុកថាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទូទៅអំពីរបៀបដែលធ្វើឱ្យសម្រេចបាននូវគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន។

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ការជួញដូរ ឬចាត់ចែងហើយ ដែលលទ្ធផលត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ។

### ការវាយតម្លៃថា តើលំហូរទឹកប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យ ដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងប្រាក់ចំណេញ។

ដើម្បីវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ក្រុមហ៊ុនត្រូវពិចារណាលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុរួមបញ្ចូលការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរទឹកប្រាក់តាមកិច្ចសន្យាដែលអាចធ្វើឱ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់។

ក្នុងការវាយតម្លៃ ក្រុមហ៊ុនពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរទឹកប្រាក់
- លក្ខខណ្ឌពិសេស
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យាពេលសង
- លក្ខខណ្ឌដែលកម្រិតក្រុមហ៊ុន ក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃប្រាក់តាមពេលវេលា (ឧទាហរណ៍៖ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់)។

### ឥណទានដែលមិនអាចប្រមូលមកវិញបាន

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយក្រុមហ៊ុនដែលត្រូវបានការពារដោយទ្រព្យដាក់ធានារបស់អតិថិជនក៏មានកំហិតក្រុមហ៊ុនក្នុងការទាមទារសាច់ប្រាក់មកវិញដែរ (ឥណទានដែលមិនអាចប្រមូលមកវិញបាន)។ ក្នុងករណីនេះ ក្រុមហ៊ុនធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះអាចប្រមូលមកវិញបានតែប្រាក់ដើមនិងការប្រាក់ឬទេ។

ជាទូទៅក្រុមហ៊ុនពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃការបង់សងកម្ចីដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជនក្នុងការទូទាត់សងតាមកិច្ចសន្យាទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ

- ថាតើអតិថិជនគឺ ជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ក្រុមហ៊ុនក្នុងការបាត់បង់ទ្រព្យសកម្មទាក់ទងនឹងឥណទានដែលមិនអាចប្រមូលមកវិញបាន
- ថាតើទ្រព្យដាក់ធានាគឺជាទ្រព្យទាំងអស់ដែលអតិថិជនមាន ឬជាផ្នែកមួយនៃទ្រព្យសកម្មផ្សេងៗទៀតរបស់អតិថិជន និង
- ថាតើក្រុមហ៊ុនទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មនេះ ឬទេ។

## ការចាត់ចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញបន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុងអំឡុងពេលដែលក្រុមហ៊ុនផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួនក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

### (iii). ការឈប់ទទួលស្គាល់

### ទ្រព្យសកម្មហិរញ្ញវត្ថុ

ក្រុមហ៊ុនឈប់ទទួលស្គាល់ ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យា ក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យា ក្នុងប្រតិបត្តិការដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរ ឬក្នុងករណីដែលក្រុមហ៊ុនមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i). តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបានដកបំណុលថ្មីដែលទទួលយក) និង (ii) ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត។

## បំណុលហិរញ្ញវត្ថុ

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលោយ ឬលុបចោល ឬផុតអាណត្តិ។

### (iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

### ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះក្រុមហ៊ុនវាយតម្លៃថាតើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាខ្លាំង ឬទេ។

ប្រសិនបើលំហូរទឹកប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតអាណត្តិ។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវឈប់ទទួលស្គាល់ (សូមមើល(iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការ។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានរាប់បញ្ចូលដូចខាងក្រោម៖

- ថ្លៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលទទួលបានមកវិញលើថ្លៃចំណាយប្រតិបត្តិការដែលកើតឡើងត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងចំណេញ និងខាតដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើទ្រព្យសកម្មដែលឈប់ទទួលស្គាល់។
- ប្រសិនបើលំហូរទឹកប្រាក់ត្រូវ បានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុនោះ គោលបំណងនៃការកែប្រែជាទូទៅគឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើមជាជាងបង្កើតទ្រព្យសកម្មថ្មី ដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើក្រុមហ៊ុនមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរទឹកប្រាក់ ទ្រព្យសកម្មនោះត្រូវបានយកមកពិចារណាជាមុនថាតើផ្នែកមួយនៃទ្រព្យសកម្ម គួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែឬទេ (សូមមើលខាងក្រោមសម្រាប់គោលនយោបាយការលុបចេញពីបញ្ជី)។ វិធីសាស្រ្តនេះជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណហើយក្នុងករណីនេះមានន័យថាលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យ ជាទូទៅមិនអាចអនុវត្តបាននោះទេ។
- ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមឬ FVOCI មិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះ នោះក្រុមហ៊ុននឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុនដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវជាចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបានដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវ ត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ។
- ប្រសិនបើការកែតម្រូវនេះត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុនោះ ចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃនៃទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀតវាត្រូវបានបង្ហាញជាចំណូលការប្រាក់ដែលគណនាដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ ប្រសិទ្ធភាព។

### បំណុលហិរញ្ញវត្ថុ

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុនៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវហើយលំហូរទឹកប្រាក់នៃបំណុលដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានទទួលស្គាល់ និងតម្លៃតបស្នងត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត។ តម្លៃតបស្នងរួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលរួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះមិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេនោះរំលស់ថ្លៃដើមនៃបំណុលត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរទឹកប្រាក់ដែលបានកែប្រែតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូងហើយលទ្ធផលនៃ ការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើ ដើម្បីគណនាចំណេញ ឬខាត ពីការកែតម្រូវត្រូវបានកែប្រែ ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមានត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបរកណ៍ហិរញ្ញវត្ថុ។

### (v). ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុអាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែក្រុមហ៊ុនមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

### (vi). ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតារវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោលគឺយកទីផ្សារជាអាទិភាពបំផុតដែលក្រុមហ៊ុនអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់ បំណុលឆ្លុះបញ្ចាំងពីហានិភ័យការមិនអនុវត្តកាតព្វកិច្ច ។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជា ទីផ្សារសកម្មប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្មឬបំណុលកើតឡើងញឹកញាប់ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

ប្រសិនបើពុំមាន សម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេនោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យ ដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យ ដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើសត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយនៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅ គឺជាតម្លៃប្រតិបត្តិការមានន័យថាជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើក្រុមហ៊ុនកំណត់ថាតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែងត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្របដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះក៏ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលត្រូវបានវាស់វែងតាមតម្លៃសមស្របមានតម្លៃលក់ និងតម្លៃទិញនោះក្រុមហ៊ុនវាស់វែងទ្រព្យសកម្ម និងស្ថានភាពវែងតាមតម្លៃលក់ ហើយវាស់វែងបំណុល និងស្ថានភាពខ្លីតាមតម្លៃទិញ។

សំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមានហានិភ័យទីផ្សារ និងហានិភ័យឥណទាន ដែលត្រូវបានចាត់ចែងដោយក្រុមហ៊ុនតាមមូលដ្ឋានចំនួនសុទ្ធដែលមានហានិភ័យទីផ្សារ ឬហានិភ័យឥណទានត្រូវបានវាស់វែងតាមមូលដ្ឋាន នៃតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្មដែលមានស្ថានភាពវែង (ឬការទូទាត់សងក្នុងការផ្ទេរទ្រព្យសកម្មសុទ្ធដែលមានស្ថានភាពខ្លី) សម្រាប់ហានិភ័យជាក់លាក់។ ការកែតម្រូវត្រឹមកម្រិតទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មានន័យថាការកែតម្រូវតម្លៃលក់-ទិញ ឬការកែតម្រូវហានិភ័យឥណទានដែលឆ្លុះបញ្ចាំងពីការវាស់វែងតាមមូលដ្ឋានតម្លៃសុទ្ធគឺត្រូវបានបែងចែកតាមទ្រព្យសកម្ម និងបំណុលនីមួយៗតាមមូលដ្ឋានការកែតម្រូវហានិភ័យដែលពាក់ព័ន្ធ នៃឧបករណ៍ហិរញ្ញវត្ថុនីមួយៗ នៃទ្រព្យសកម្ម និងបំណុលនោះ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុ មានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្របនៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

(vii). ឱនភាពនៃតម្លៃ

ក្រុមហ៊ុនទទួលស្គាល់សំវិធានធនលើការបាត់បង់ ECL ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាឧបករណ៍បំណុល និង
- កិច្ចសន្យាឥណទានដែលបានបោះផ្សាយ។

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ។

ក្រុមហ៊ុនវាស់វែងសំវិធានធនលើការខាតបងតាមចំនួនដែលស្មើនឹង ECL ពេញអាយុកាល លើកលែងគណនីខាងក្រោមដែលត្រូវវាស់វែងតាម ECL ១២ ខែ៖

- ការវិនិយោគលើមូលបត្របំណុល ដែលត្រូវបានកំណត់ថា មានហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

ECL ១២ខែ គឺជាផ្នែកនៃ ECL ដែលបណ្តាលមកពី ព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល ១២ខែបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ១២ខែ ត្រូវបានចាត់ទុកជា “ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី១”។

ECL មួយអាយុកាល (Life-time ECL) គឺជា ECL ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេលនៃអាយុកាលរំពឹងទុក (expected life) នៃឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានដែលមានឱនភាពនៃតម្លៃ (credit-impaired) ត្រូវបានចាត់ទុកជា “ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី ២”។

នៅកាលបរិច្ឆេទនៃរបាយការណ៍ក្រុមហ៊ុនវាយតម្លៃ ថាតើហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុបានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូង។ នៅពេលដែលហានិភ័យឥណទានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូងសំវិធានធន លើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងអាយុកាលនៃ ECL។

នៅពេលកំណត់ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូង និងនៅពេលប៉ាន់ស្មាន ECL នោះក្រុមហ៊ុនពិចារណាលើព័ត៌មានដែលសមហេតុសមផល និងព័ត៌មានគាំទ្រដែលពាក់ព័ន្ធ និងអាចរកបានដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងខ្ពស់។ ព័ត៌មានទាំងនេះ រួមបញ្ចូលព័ត៌មានបរិមាណ និងព័ត៌មានគុណភាព និងការវិភាគដោយផ្អែកលើបទពិសោធន៍របស់ក្រុមហ៊ុន និងការវាយតម្លៃឥណទានព្រមទាំងបញ្ចូលព័ត៌មានប្រមើលអនាគត។

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើគុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើឡើងដែលបណ្តាលឱ្យគ្មានការកើនឡើងជាសារវន្តនៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់លើកដំបូងសំវិធានធនលើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹង ECL ១២ខែ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មាន ECL គឺជារយៈពេលកិច្ចសន្យាអតិបរមាដែលក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទាន។

## ការកំណត់នៃការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន

ក្រុមហ៊ុនវាយតម្លៃថា តើមានហានិភ័យឥណទានបានកើនឡើងជាសារវន្តឬទេ ចាប់តាំងពីការទទួលស្គាល់លើកដំបូងនៅ កាលបរិច្ឆេទរាយការណ៍។ ការកំណត់ពីការកើនឡើងនៃហានិភ័យឥណទានផ្អែកជាសំខាន់លើចរិតលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអតិថិជន និងតំបន់ភូមិសាស្ត្រ។

ក្រុមហ៊ុនពិចារណាថាការកើនឡើងនៃ ហានិភ័យឥណទានជាសារវន្តកើតឡើងនៅ ពេលទ្រព្យសកម្មមានការខកខានសងមិនតិចជាងរយៈពេលចំនួន ៣០ថ្ងៃ។ ចំនួនថ្ងៃខកខានសងត្រូវបានកំណត់ដោយការរាប់ចំនួនថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ដែលការបង់សងទាំងអស់មិនទាន់បានទទួល។ កាលបរិច្ឆេទផុតកំណត់សងត្រូវបានកំណត់ដោយ មិនពិចារណាទៅលើរយៈពេលអនុគ្រោះណាមួយដែលអាចមានសម្រាប់អតិថិជនឡើយ។

ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មិនមានការកើនឡើងលើហានិភ័យឥណទានជាសារវន្ត ទាក់ទងនឹងការទទួលស្គាល់លើកដំបូងទេ នោះសំវិធានធននៃការបាត់បង់លើឧបករណ៍ហិរញ្ញវត្ថុនឹងត្រូវវាស់វែងតាម ECL ១២ខែ។

## និយមន័យនៃការខកខានសង

ក្រុមហ៊ុនចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុងដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- ក្រុមហ៊ុនពិចារណាថាការកើនឡើងជាសារវន្តនូវហានិភ័យឥណទានកើតឡើងមិនលើសពីពេលដែលទ្រព្យសកម្មហួសកាលកំណត់សងស្មើ ឬលើសពី ៣០ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង ឬច្រើនជាង ឬស្មើ ១៥ ថ្ងៃ សម្រាប់ឥណទានរយៈពេលខ្លី។

## ការវាស់វែង ECL

ECL គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេមធ្យម នៃការបាត់បង់ឥណទាន។ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនស្របតាមកិច្ចសន្យា និងលំហូរទឹកប្រាក់ដែលក្រុមហ៊ុនរំពឹងទុកថានឹងទទួលបាន)។

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលរំពឹងទុកនាពេលអនាគត។
- កិច្ចសន្យាឥណទានដែលនៅសល់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលជំពាក់ក្រុមហ៊ុនប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរទឹកប្រាក់ដែលក្រុមហ៊ុនរំពឹងទុកថា នឹងទទួលបានប្រសិនបើឥណទានត្រូវបានដកប្រើ។

## ទិន្នន័យការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ

សមាសធាតុសំខាន់ៗក្នុងការវាស់វែង ECL គឺបានមកពីអថេរដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានសង (“PD”);
- ការបាត់បង់ដែលបណ្តាលមកពីការខកខានសង (“LGD”) និង
- ទំហំនៃការខកខានសង (“EAD”)

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី១ ត្រូវបានគណនាដោយផលគុណនៃ PD ១២ខែ នឹង LGD នឹង EAD។ ECL ពេញអាយុកាលត្រូវបានគណនាដោយផលគុណនៃ PD ពេញអាយុកាល នឹង LGD នឹង EAD។

គំរូស្ថិតិត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យប្រមូលបានរួចបង្កើតនូវការប៉ាន់ស្មាន PD ពេញអាយុកាលដែលនៅសល់ និងថាតើសមតុល្យទាំងនោះរំពឹងថាប្រែប្រួលយ៉ាងណាលើរយៈពេលនោះ។

LGD គឺជាតំរិយាបទនៃភាពអាចបាត់បង់ប្រសិនបើមានការខកខានសង។ ក្រុមហ៊ុនប៉ាន់ស្មានលក្ខខណ្ឌ LGD យោងតាមប្រវត្តិនៃអត្រាការប្រមូលត្រលប់ពីអតិថិជនខកខានសង។ គំរូ LGD ត្រូវបានពិចារណាលើរចនាសម្ព័ន្ធអទិភាពនៃការទាមទារសំណងវិស័យដែលអតិថិជនស្ថិតនៅ ចំណាយលើការប្រមូលពីទ្រព្យបញ្ចាំដែលជាផ្នែកមួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ សម្រាប់ឥណទានដែលការពារដោយទ្រព្យអនុបាតឥណទានធៀបនឹងតម្លៃទ្រព្យបញ្ចាំ (“LTV”) គឺជាលក្ខខណ្ឌមួយក្នុងការកំណត់ LGD។ ការប៉ាន់ស្មាន LGD ត្រូវបានវាស់វែងសម្រាប់វិស័យផ្សេងៗគ្នាហើយសម្រាប់ឥណទានគេហដ្ឋានគឺ អាស្រ័យលើការប្រែប្រួលតម្លៃអចលនទ្រព្យ។ តម្លៃទាំងនោះនឹងត្រូវបានគណនាដោយអប្បហារដោយផ្អែកលើអត្រាការប្រាក់ប្រសិទ្ធភាព។

EADតំណាងឱ្យតម្លៃសមតុល្យនៅពេលមានការខកខានសង។ ក្រុមហ៊ុនទាញយក EAD ពីសមតុល្យបច្ចុប្បន្នរបស់អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាមកិច្ចសន្យា និងកើតចេញពីការបង់រំលស់។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុគឺតម្លៃយោងដុលនៅពេលមានការខកខានសង។ សម្រាប់កាតព្វកិច្ចឱ្យខ្ចី EAD គឺសមតុល្យអនាគតដែលអាចដកប្រើប្រាស់តាមកិច្ចសន្យាដែលត្រូវបានប៉ាន់ស្មានតាមការសង្កេតពីប្រវត្តិ និងការព្យាករណ៍នាពេលខាងមុខ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ EAD ត្រូវបានកំណត់ដោយគំរូនៃសមតុល្យដែលអាចកើតឡើងនៅពេលវេលាផ្សេងគ្នាដោយប្រើបច្ចេកទេសស្ថិតិ។

ដូចការរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD ១២ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី១ ក្រុមហ៊ុនវាស់វែង ECL ដោយពិចារណាលើហានិភ័យនៃការខូចខាតលើរយៈពេលពេញលេញនៃកិច្ចសន្យា (រួមបញ្ចូលទាំងរយៈពេលពន្យាប្រសិនបើមាន) ដែលមានហានិភ័យលើឥណទានទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ ក្រុមហ៊ុនពិចារណាលើរយៈពេលដែលវែងជាង។ រយៈពេលដែលវែងបំផុតគឺ គិតត្រឹមថ្ងៃដែលក្រុមហ៊ុនមានសិទ្ធិដើម្បីទាមទារការសងត្រឡប់នៃឥណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់ឥណទាន ឬការធានា។

## ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជននោះការវាយតម្លៃត្រូវបានធ្វើឡើងដើម្បីវាយតម្លៃថា តើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ឬទេហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើ ការរៀបចំឡើងវិញមិននាំឱ្យឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេនោះ លំហូរទឹកប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញនាំឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរទឹកប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន នៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ ទៅកាលបរិច្ឆេទរាយការណ៍ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

## ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថា តើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមរំលស់ថ្លៃដើម និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាតាម FVOCI មានឱនភាពនៃតម្លៃឬទេ (ដែលត្រូវបានកំណត់ជា “ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី ៣”)។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃនៅពេលដែលព្រឹត្តិការណ៍មួយឬច្រើនបានកើតឡើង ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគត ដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យាដូចជា ការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជនដែលក្រុមហ៊ុនមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

ឥណទានដែលត្រូវបានរៀបចំឡើងវិញដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជនត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃលុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសូចនាករផ្សេងទៀតដែលនាំឱ្យមានឱនភាពនៃតម្លៃ។ បន្ថែមលើនេះ ឥណទានដែលហួសកាលកំណត់សង ៩០ថ្ងៃ ឬលើសពីនេះត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ។

### សំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សំវិធានធននៃការខាតបង់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលវាស់វែងតាមរំលស់ថ្លៃដើម ដោយធ្វើការកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្ម។

### ការលុបចោល

ឥណទានផ្តល់ដល់អតិថិជនត្រូវបានលុបចេញពីបញ្ជី (មួយផ្នែកឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះមានជាទូទៅនៅពេលក្រុមហ៊ុនកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរទឹកប្រាក់គ្រប់គ្រាន់ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជីត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់សុទ្ធពីឱនភាពនៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងចំណេញ ឬខាត និង OCI។

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានលុបចេញពីបញ្ជីនៅតែតម្រូវឱ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធី របស់ក្រុមហ៊ុនក្នុងការប្រមូលទឹកប្រាក់ដែលនៅជំពាក់។

### ឃ. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យសាច់ប្រាក់ក្នុងធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លីដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល ៣ខែ ឬតិចជាងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បានដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

### ង. ដើមទុន

ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាមូលធន។ ថ្លៃដើមផ្ទាល់ក្នុងការបញ្ចេញភាគហ៊ុនត្រូវបានទទួលស្គាល់ដោយកាត់ចេញពីមូលធនបន្ទាប់ពីដកពន្ធរួច។ ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬបំណុលផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធន ត្រូវបានទូទាត់ដោយផ្ទាល់ពីមូលធន។

### ច. ទុនបម្រុងទូទៅ និងទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងទូទៅត្រូវបានអនុវត្តដើម្បីត្រួតពិនិត្យហានិភ័យហិរញ្ញវត្ថុជាទូទៅ។ ក្រុមប្រឹក្សាភិបាលជាអ្នកសម្រេចក្នុងការប្រើប្រាស់ និងរក្សាទុនបម្រុងទូទៅ។ ការផ្ទេរប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងទូទៅត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតលើភាពខុសគ្នារវាងសំវិធានធន ស្របតាម ស.រ.ហ.អ.ក និង សំវិធានធនតាមបទប្បញ្ញត្តិស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧ និងសារាចរណែនាំ លេខ ធ៧-០១៨-001 ស.រ.ឆ.ណ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ស្របតាមប្រការ ៧៣ គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមប្រការ ៤៩ ដល់ ប្រការ ៧១ ជាមួយនឹងសំវិធានធនដែលគណនាតាមប្រការ៧២ និងត្រូវកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីដែលសំវិធានធន តាមបទប្បញ្ញត្តិដែលគណនាតាមប្រការ ៧២ ទាបជាងសំវិធានធនដែលគណនាតាមប្រការ ៤៩ ដល់ប្រការ ៧១ នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធនដែលត្រូវគណនាអនុលោមតាម ស.រ.ហ.អ.ក និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិដែលគណនាតាមប្រការ ៧២ ខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ ៤៩ ដល់ប្រការ ៧១ នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ហ.អ.ក និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទប្បញ្ញត្តិមិនត្រូវបានបញ្ចូលក្នុងការគណនាមូលធនផ្ទាល់សុទ្ធរបស់ក្រុមហ៊ុនឡើយ។

### ឆ. ប្រាក់បញ្ញើនៅធនាគារនានា

ប្រាក់បញ្ញើនៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើមដកឱនភាពនៃតម្លៃដែលមិនអាចប្រមូលមកវិញបាន។

### ជ. ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃ ព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

### ឈ. ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទាន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមបញ្ចូល ឥណទាន និងបុរេប្រទាន ដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្របបូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ហើយនាពេលបន្ទាប់ត្រូវ កត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

### ញ. ទ្រព្យសកម្មផ្សេងទៀត

ទ្រព្យសកម្មផ្សេងទៀតត្រូវបានកត់ត្រាតាមតម្លៃដើមដកឱនភាពនៃតម្លៃ ប្រសិនបើមាន។

### ដ. ទ្រព្យ និងបរិក្ខារ

#### (i). ការទទួលស្គាល់ និងការវាស់វែង

ផ្នែកនៃទ្រព្យ និងបរិក្ខារត្រូវបានវាស់វែងតាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ។

ចំណាយថ្លៃដើមរួមបញ្ចូលទាំងការចំណាយដោយផ្ទាល់ទៅលើការទិញទ្រព្យ និងការចំណាយដោយផ្ទាល់ផ្សេងៗទៀត ក្នុងការនាំយកទ្រព្យសកម្មទៅក្នុងលក្ខខណ្ឌដែលអាចប្រើប្រាស់ដែលបានគ្រោងទុក និងថ្លៃដើមនៃការរុះរើ និងផ្លាស់ប្តូរទីកន្លែង និងការស្តារទីតាំងដែលពួកគេស្ថិតនៅ។ ថ្លៃដើមនៃទ្រព្យកម្មដែលបានសាងសង់ដោយខ្លួនឯង ត្រូវរួមបញ្ចូលទាំងថ្លៃដើមសម្ភារៈ និងកម្លាំងពលកម្មផ្ទាល់ផងដែរ។ ចំពោះទ្រព្យសកម្មដែលមានលក្ខណៈគ្រប់គ្រាន់ការចំណាយលើប្រាក់កម្ចីត្រូវបានធ្វើមូលធនកម្មស្របតាមគោលនយោបាយគណនេយ្យ លើថ្លៃដើមប្រាក់កម្ចី។ ថ្លៃដើមក៏អាចរួមបញ្ចូលទាំងការផ្ទេរមូលធនដែលជា ចំណេញ ឬខាតណាមួយផងដែរ លើការការពារហានិភ័យលំហូរសាច់ប្រាក់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះរូបិយប័ណ្ណបរទេសទាក់ទងនឹងការទិញទ្រព្យ និងបរិក្ខារ។

ការទិញសូហ្វវែរដែលមានសារៈសំខាន់ចំពោះមុខងារដែលទាក់ទងនឹងបរិក្ខារ ត្រូវបានធ្វើមូលធនកម្មជាផ្នែកមួយនៃបរិក្ខារនោះ។

ប្រសិនបើផ្នែកជាសារវន្តណាមួយនៃទ្រព្យ និងបរិក្ខារទាំងនោះមានអាយុកាលប្រើប្រាស់ខុសពីគ្នា ផ្នែកទាំងនោះត្រូវបានដាក់ជាផ្នែកដោយឡែក (សមាសភាពចម្បង) នៃទ្រព្យ និងបរិក្ខារ។

#### (ii). ចំណាយបន្ទាប់

ចំណេញ ឬខាត ពីការលក់នៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ជាចំណូលផ្សេងៗ "ចំណូលផ្សេងៗ" និង "ចំណាយផ្សេងៗ" នៅក្នុងចំណេញ ឬខាត។

ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយផ្នែកនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនហើយតម្លៃរបស់វាអាចធ្វើការវាស់វែងបានដោយភាពអាចជឿជាក់បាន។ តម្លៃយោងនៃធាតុដែលបានជំនួសនោះត្រូវឈប់ទទួលស្គាល់ជាចំណេញឬខាត។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

#### (iii). រំលស់

ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដល់ធនាគារលើសពីស្តង់ដារដើម។ រាល់ការចំណាយបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

រំលស់គឺផ្អែកទៅលើថ្លៃដើមនៃទ្រព្យសកម្មដកតម្លៃសំណល់របស់វា។ សមាសធាតុសំខាន់ៗនៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃហើយ ប្រសិនបើសមាសធាតុមួយមានអាយុកាលប្រើប្រាស់ខុសគ្នាពីទ្រព្យសកម្មដែលនៅសល់ សមាសធាតុនោះត្រូវបានធ្វើឡើងដាច់ដោយឡែក។

រំលស់ត្រូវ បានទទួលស្គាល់ថាជាការចំណាយនៅក្នុងរបាយ-ការណ៍ចំណេញ ឬខាតលើ [មូលដ្ឋានរំលស់ថេរ / រំលស់ថយចុះ] លើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មាននៃសមាសធាតុនីមួយៗនៃទ្រព្យ និងបរិក្ខារ។

ទ្រព្យសកម្មដែលបានជួល ត្រូវបានរំលស់រយៈពេលជួល ឬអាយុកាលប្រើប្រាស់របស់វាមួយណាដែលខ្លីជាង លើកលែងតែមានហេតុផលច្បាស់លាស់ថាក្រុមហ៊ុននឹងទទួលបាន កម្មសិទ្ធិនៅចុងបញ្ចប់នៃរយៈពេលនៃការជួល។ ដីទំនេរមិនត្រូវបានរំលស់លនោះទេ។

រំលស់ ត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទដែលទ្រព្យរោងចក្រ និងបរិក្ខារត្រូវបានតម្លើង និងអាចប្រើប្រាស់បាន ឬទ្រព្យសកម្មដែលបានសាងសង់ ចាប់ពីការិយបរិច្ឆេទដែលទ្រព្យសកម្មនោះ ត្រូវបានបញ្ចប់ និងអាចប្រើប្រាស់បាន។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នមាន ដូចខាងក្រោម៖

| | ឆ្នាំ |
|---|---|
| យានយន្ត | ៤ - ៥ |
| ការកែលំអរអគារ-រយៈពេលណាមួយដែលតិចជាងរវាងអាយុកាលសេដ្ឋកិច្ចរបស់ទ្រព្យនោះ និងថេរវេលានៃកិច្ចសន្យាជួល | ៥ - ៧ |
| កុំព្យូទ័រ | ៣ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ការិយាល័យ | ៣ - ៥ |

វិធីសាស្ត្ររំលស់លើអាយុកាលប្រើប្រាស់ និងតម្លៃសំណល់ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទនៃរបាយការណ៍ និងនិយ័តភាពប្រសិនបើសមស្រប។

## ឋ. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមាន ថ្លៃដើម អាជ្ញាប័ណ្ណ កុំព្យូទ័រដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀតត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។ អាជ្ញាប័ណ្ណ កុំព្យូទ័រដែលបានទិញត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។

ទ្រព្យសកម្មអរូបីត្រូវបានដករំលស់ទៅតាមការប៉ាន់ស្មានអាយុកាលប្រើប្រាស់ពី ៥ ទៅ ២០ឆ្នាំ តាមវិធីសាស្ត្ររំលស់ថេរ។

ថ្លៃដើមពាក់ព័ន្ធនឹងការបង្កើត ឬថែទាំកុំព្យូទ័រសូហ្វវែរត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង។

## ឌ. ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យាក្រុមហ៊ុនធ្វើការវាយតម្លៃថា តើកិច្ចសន្យាមួយមានទម្រង់ជាភតិសន្យាដែរឬទេ។ កិច្ចសន្យាជាទម្រង់មានភតិសន្យាប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រង ការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់មួយក្នុងរយៈពេលកំណត់មួយ ជាថ្នូរនឹងតម្លៃតបស្នង។

ដើម្បីវាយតម្លៃថា តើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រង ការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ ក្រុមហ៊ុនធ្វើការវាយតម្លៃថាតើ៖

- កិច្ចសន្យាមានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ ឬទេ ដែលនេះអាចបញ្ជាក់យ៉ាងជាក់លាក់ ឬប្រយោល ហើយគួរមានលក្ខណៈរូបវន្តដោយឡែក ឬតំណាងសមត្ថភាពផលិតសារវន្តរបស់ទ្រព្យសកម្មនោះ។ ប្រសិនបើអ្នកផ្គត់ផ្គង់មានសិទ្ធិផ្តល់ទ្រព្យសកម្មជំនួសជាសារវន្តក្នុងរយៈពេលប្រើប្រាស់ នោះទ្រព្យសកម្មមិនមែនមានលក្ខណៈជាទ្រព្យសកម្មជាក់លាក់នោះទេ
- ក្រុមហ៊ុន មានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចជាសារវន្តពីការប្រើប្រាស់ទ្រព្យសកម្ម ក្នុងរយៈពេលនៃការប្រើប្រាស់ និង
- ក្រុមហ៊ុនមានសិទ្ធិបញ្ជាការប្រើប្រាស់ទ្រព្យសកម្ម។ ក្រុមហ៊ុនមានសិទ្ធិនេះនៅពេលដែលក្រុមហ៊ុនមានសិទ្ធិសម្រេចចិត្តដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរអំពីរបៀប និងគោលបំណងក្នុងការប្រើប្រាស់ទ្រព្យសកម្ម។ ក្នុងករណីដែល ការសម្រេចចិត្តទាំងអស់អំពីរបៀប និងគោលបំណងនៃការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់ជាមុន នោះក្រុមហ៊ុនមានសិទ្ធិបញ្ជាការប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើ៖
  - ក្រុមហ៊ុនមានសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យសកម្ម ឬ
  - ក្រុមហ៊ុនបានរៀបចំទ្រព្យសកម្មទៅតាមវិធីដែលកំណត់ជាមុនពីរបៀប និងគោលបំណងដែលទ្រព្យសកម្មនោះនឹងត្រូវបានប្រើប្រាស់។

គោលនយោបាយនេះអនុវត្តចំពោះកិច្ចសន្យាដែលបានព្រមព្រៀង ឬបានធ្វើការផ្លាស់ប្តូរ ចាប់ពីថ្ងៃទី១ ខែ មករា ឆ្នាំ ២០១៨ មកប៉ុណ្ណោះ។

នៅពេលចាប់ផ្តើមកិច្ចសន្យាឬវាយតម្លៃឡើងវិញលើកិច្ចសន្យាដែលមានទម្រង់ជាភតិសន្យា និងសមាសធាតុ ដែលមិនមែនភតិសន្យា ក្រុមហ៊ុនបែងចែកតម្លៃតបស្នងនៅក្នុងកិច្ចសន្យាចំពោះសមាសធាតុនៃភតិសន្យានីមួយៗ និងសមាសធាតុដែលមិនមែនភតិសន្យាដោយផ្អែកតាមតម្លៃឯកតានីមួយៗ។ ក៏ប៉ុន្តែចំពោះការជួលដី និងអគារ ដែលក្រុមហ៊ុនជាអ្នកជួលក្រុមហ៊ុនមិនបែងចែកសមាសធាតុមិនមែនភតិសន្យានោះទេ ហើយសមាសធាតុភតិសន្យា និងមិនមែនភតិសន្យាត្រូវបានចាត់ទុកថាជាសមាសធាតុភតិសន្យា។

### ភតិសន្យាក្នុងករណីដែលក្រុមហ៊ុនជាអ្នកជួល

ការរៀបចំឱ្យមានសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ប្រសិនបើបំពេញតាមលក្ខខណ្ឌមួយក្នុងចំណោមខាងក្រោម៖

- អ្នកទិញមានសមត្ថភាព ឬសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យសកម្ម ខណៈពេលដែលទទួលបាន ឬគ្រប់គ្រងលើសពីបរិមាណដែលមិនសារវន្ត
- អ្នកទិញមានសមត្ថភាព ឬសិទ្ធិក្នុងការគ្រប់គ្រងលើការចូលទៅដល់ទ្រព្យសកម្ម ខណៈដែលទទួលបាន ឬគ្រប់គ្រងលើសពីបរិមាណដែលមិនសារវន្ត ឬ
- ដំណើរហេតុ និងកាលៈទេសៈបានបង្ហាញថា វាមានលក្ខណៈតិចតួចដែលភាគីដទៃទៀត នឹងទទួលបានច្រើនជាងបរិមាណដែលមិនសារវន្ត ហើយតម្លៃក្នុងមួយឯកតាមិនត្រូវបានកំណត់ក្នុងមួយឯកតានៃទិន្នផលទេហើយក៏មិនស្មើនឹងតម្លៃទីផ្សារបច្ចុប្បន្នក្នុងមួយឯកតានៃលទ្ធផលដែរ។

ក្រុមហ៊ុនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យានៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់វែងតាមថ្លៃដើមរួមមាន ថ្លៃដើមដំបូងនៃបំណុលភតិសន្យា និងនិយ័តភាពសម្រាប់ការចំណាយភតិសន្យាដែលធ្វើឡើងនៅថ្ងៃចាប់ផ្តើមភតិសន្យា ឬមុនថ្ងៃចាប់ផ្តើមភតិសន្យា បូកថ្លៃដើមផ្ទាល់ដំបូងដែលបានកើតឡើង និងការប៉ាន់ស្មានចំណាយក្នុងការរុះរើ និងដកចេញនូវទ្រព្យសកម្ម ឬស្តារឡើងវិញនូវទ្រព្យសកម្ម ឬទីតាំងដកប្រាក់លើកទឹកចិត្តភតិសន្យាដែលទទួលបាន។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានដករំលស់នាពេលតាមវិធីសាស្ត្ររំលស់ថេរ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា រហូតដល់ចុងបញ្ចប់នៃអាយុកាលប្រើប្រាស់ នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬនៅចុងកាលបរិច្ឆេទនៃភតិសន្យាមួយណាកើតមុន។ អាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់តាមមូលដ្ឋានដូចគ្នានឹងទ្រព្យ និងបរិក្ខារ។ បន្ថែមលើនេះសិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានកាត់បន្ថយជាប្រចាំទៅតាមការខាតបង់ឱនភាពនៃតម្លៃ និងកែតម្រូវសម្រាប់ការវាស់វែងឡើងវិញលើបំណុលភតិសន្យា។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ សម្រាប់អំឡុងការិយបរិច្ឆេទបច្ចុប្បន្ន មានដូចខាងក្រោម៖

- អគារ និងសាខាការិយាល័យ ៣ – ១០ ឆ្នាំ

បំណុលភតិសន្យាត្រូវបានវាស់វែងដំបូង តាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យា ដែលមិនទាន់បានបង់នៅពេលចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើអត្រាការប្រាក់ជាក់ស្តែង នៅក្នុងភតិសន្យា ឬករណីដែលអត្រាការប្រាក់នោះមិនអាចកំណត់បានភ្លាមៗ ត្រូវធ្វើទៅតាមអត្រាការប្រាក់កម្ចីបន្ថែមរបស់អ្នកជួល។

ការទូទាត់ភតិសន្យាដែលបញ្ចូលនៅក្នុងការវាស់វែងបំណុលភតិសន្យារួមមាន៖

- ការទូទាត់ភតិសន្យាថេរ រួមទាំងការទូទាត់ក្នុងទម្រង់ថេរ
- ការប្រែប្រួលនៃការទូទាត់ភតិសន្យាអថេរ ដោយផ្អែកលើសន្ទស្សន៍ ឬអត្រា នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា
- ចំនួនដែលរំពឹងថានឹងត្រូវទូទាត់ក្រោមការធានាតម្លៃនៅសល់ និង
- តម្លៃទិញក្រោមជម្រើសនៃការទិញ ដែលក្រុមហ៊ុនមានហេតុផលជាក់លាក់ក្នុងការអនុវត្ត។ ការទូទាត់ភតិសន្យានៅក្នុងអំឡុងពេលដែលមានជម្រើសក្នុងការបន្តប្រសិនបើក្រុមហ៊ុនមានហេតុផលជាក់លាក់ក្នុងការបន្ត និងការពិន័យលើការបញ្ចប់ភតិសន្យាមុនកាលកំណត់ លើកលែងតែក្រុមហ៊ុនមានហេតុផលច្បាស់លាស់ថានឹងមិនបញ្ចប់ភតិសន្យាមុនកាលកំណត់។

បំណុលភតិសន្យា ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញនៅពេលមានការកែប្រែរយៈពេលនៃភតិសន្យាការផ្លាស់ប្តូរលើការវាយតម្លៃសម្រាប់ជម្រើសក្នុងការទិញទ្រព្យសកម្ម ការប្រែប្រួលការទូទាត់ភតិសន្យានាពេលអនាគត ដែលកើតឡើងពីការប្រែប្រួលនៃសន្ទស្សន៍ ឬអត្រាណាមួយ ឬប្រសិនបើមានការកែប្រែចំនួនប៉ាន់ស្មានដែលរំពឹងថានឹងត្រូវទូទាត់លើការធានាតម្លៃដែលនៅសល់។

នៅពេលដែល បំណុលភតិសន្យាត្រូវបានវាស់វែងតាមវិធីសាស្ត្រនេះការកែតម្រូវត្រូវបានធ្វើឡើងលើតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬក៏ទទួលស្គាល់ក្នុងចំណេញ ឬខាតបើសិនជាសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបញ្ចុះរហូតដល់មានតម្លៃសូន្យ។

### ភតិសន្យាមានរយៈពេលខ្លីនិងភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប

ក្រុមហ៊ុនមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យារយៈពេលខ្លីដូចជាការជួលម៉ាស៊ីនដែលមានរយៈពេលតិចជាង ១២ខែ និងភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាបដែលរួមមានបរិក្ខារព័ត៌មានវិទ្យា។ ក្រុមហ៊ុនទទួលស្គាល់ចំណាយលើការជួលទាំងនេះតាមមូលដ្ឋានរំលស់ថេរ ទៅតាមរយៈពេលនៃភតិសន្យា។

## ឍ. ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានវាស់វែងដំបូង តាមតម្លៃសមស្របដកថ្លៃដើមប្រតិបត្តិការបន្ថែមដោយផ្ទាល់ និងវាស់វែងបន្ទាប់តាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## ណ. អត្ថប្រយោជន៍និយោជិត

### (i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានចំណាយនៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយត្រូវបានទទួលស្គាល់ជាបំណុលប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយដែលជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយ ដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿរជាក់។

### (ii). អត្ថប្រយោជន៍និយោជិតរយៈពេលវែង

កាតព្វកិច្ចរបស់ក្រុមហ៊ុនចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែងគឺជាចំណាយលើអត្ថប្រយោជន៍ដែលនិយោជិតត្រូវទទួលបានពីការបំពេញការងារក្នុងការិយបរិច្ឆេទកន្លងផុតទៅ និងបច្ចុប្បន្ន។ អត្ថប្រយោជន៍និយោជិតរយៈពេលវែងត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន។ ការវាស់វែងសារជាថ្មីត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតដែលចំណាយនេះបានកើតឡើង។

## ត. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្នដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើ ផលប៉ះពាល់មានលក្ខណៈជាសារវន្តសំវិធានធន ត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគតដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញប្បទាន។

## ថ. ការប្រាក់

### អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព ។ “អត្រាការប្រាក់ប្រសិទ្ធភាព” គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឱ្យមកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- រំលស់តម្លៃដើមរបស់បំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព សម្រាប់ឧបករណ៍ហិរញ្ញវត្ថុក្រៅពីទ្រព្យដែលបានទិញ ឬទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃ នៅពេលទិញក្រុមហ៊ុនធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគត ដោយពិចារណារាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានដែលរំពឹងទុកនោះទេ (ECL)។ សម្រាប់ទ្រព្យសកម្មដែលទិញ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនៅពេលទិញអត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យឥណទានត្រូវបានគណនាដោយប្រើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគតរួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក (ECL)។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាពរួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួលដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

### រំលស់ថ្លៃដើម និងតម្លៃយោងដុល

រំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូងដកការទូទាត់សងប្រាក់ដើមបូក ឬដករំលស់បង្គរ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់ជាលើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវធ្វើនិយ័តភាពចំពោះសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុកចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។

តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជារំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុមុនពេលកែតម្រូវសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក។

### ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាលើកដំបូង។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានប្រើផ្អែកលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ) ឬរំលស់ថ្លៃដើមនៃបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាព ត្រូវធ្វើការកែប្រែឡើងវិញដោយការប៉ាន់ស្មានឡើងវិញនូវលំហូរទឹកប្រាក់របស់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការកែតម្រូវតម្លៃសមស្របនៃឧបករណ៍ការពារនៅកាលបរិច្ឆេទដែលរំលស់ត្រូវបានចាប់ផ្តើមកែតម្រូវ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃបន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូងចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើរំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃនោះការគណនាការប្រាក់ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃចាប់តាំងពីទទួលស្គាល់ជាលើកដំបូងចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ដែលត្រូវបានកែតម្រូវនូវហានិភ័យផ្អែកលើរំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ។

### ការបង្ហាញ

ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួមបញ្ចូលការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

ចំណាយការប្រាក់ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម។

## ទ. កម្រៃ និងជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសារផ្សេងទៀតត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។

កិច្ចសន្យាជាមួយអតិថិជនដែលទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាចមានវិសាលភាពដោយផ្អែកនៅក្នុង ស.រ.ហ.អ.ក ៩ និងដោយផ្អែកនៅក្នុង ស.រ.ហ.អ.ក ១៥។ ក្នុងករណីនេះ ជាដំបូងក្រុមហ៊ុនត្រូវអនុវត្ត ស.រ.ហ.អ.ក ៩ ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យា ដែលចាត់ចូលនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក ១៥ ចំពោះផ្នែកដែលនៅសេសសល់។

## ធ. ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្រៅពីសន្និធិទ្រព្យសកម្មជាប់កិច្ចសន្យា និងពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់ការិយបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃឬទេ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង នោះការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។ ចំពោះទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ឬមិនទាន់អាចប្រើប្រាស់បានតម្លៃដែលអាចប្រមូលមកវិញបានត្រូវធ្វើការប៉ាន់ស្មានជារៀងរាល់ឆ្នាំក្នុងពេលតែមួយ។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ធំជាងការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាន។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគតត្រូវបានធ្វើអប្បហារទៅនឹងតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់។ សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។ ការខាតបង់លើឱនភាពនៃតម្លៃនៃឯកតាបង្កើតសាច់ប្រាក់ត្រូវបានបែងចែកដោយកាត់បន្ថយតម្លៃយោងនៃតម្លៃកេរ្តិ៍ឈ្មោះរបស់ឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) ជាមុន ហើយបន្ទាប់មកដើម្បីកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មដទៃទៀតនៅក្នុងឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) លើមូលដ្ឋានសមាមាត្រ។

ការខាតបង់លើឱនភាពនៃតម្លៃដែលទទួលស្គាល់ក្នុងពេលកន្លងផុតទៅ ត្រូវបានប៉ាន់ប្រមាណរាល់កាលបរិច្ឆេទនៃការរាយការណ៍ថាតើមានសញ្ញាណណាមួយដែលការខាតបង់បានថយចុះ ឬលែងមានការខាតបង់តទៅទៀត។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវកត់ត្រាបញ្ច្រាសមកវិញប្រសិនបើមានការប្រែប្រួលតម្លៃប៉ាន់ស្មានដែលប្រើប្រាស់ដើម្បីកំណត់តម្លៃដែលអាចប្រមូលមកវិញបាន។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានកត់ត្រាបញ្ច្រាសមកវិញត្រឹមកម្រិតមួយដែលមិនធ្វើឱ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះមិនលើសពីតម្លៃយោងដែលត្រូវកំណត់ (ដករំលស់) ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ ។

## ន. ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតលើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬលទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនបានកំណត់ថា ការប្រាក់ និងការដាក់ពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណេញរួមបញ្ចូលបំណកស្រាយពន្ធមិនច្បាស់លាស់មិនបំពេញទៅនឹងនិយមន័យនៃពន្ធលើប្រាក់ចំណេញ ដូច្នេះហើយវាត្រូវបានកត់ត្រាក្រោមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (ស.គ.អ.ក) ៣៧ សំវិធានធនបំណុលយថាភាព និងទ្រព្យសកម្មយថាភាព ហើយត្រូវបានទទួលស្គាល់ថាជាការចំណាយដែលពាក់ព័ន្ធ “ការចំណាយផ្សេងទៀត”។

### (i). ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំរួមមាន ពន្ធដែលត្រូវបង់ ឬទទួលលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

### (ii). ពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្នរវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបានត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។ ការកាត់បន្ថយនោះត្រូវកត់ត្រាបញ្ច្រាសមកវិញនៅពេលដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានលក្ខណៈប្រសើរឡើង។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារឆ្លុះបញ្ចាំងនូវពន្ធដែលក្រុមហ៊ុនរំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុលអាចកាត់កងបានតែក្នុងករណីវាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ។

### ប. បំណុលយថាភាព

ក្នុងករណីដែលមិនតម្រូវឱ្យមានការហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ ហើយវាត្រូវបានបង្ហាញថាជាបំណុលយថាភាពលើកលែងតែប្រូបាប៊ីលីតេនៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចគឺស្ទើតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ដែលអស្ថិរភាពនៃកាតព្វកិច្ច នឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយឬច្រើនក៏ត្រូវបានបង្ហាញថាជាបំណុលយថាភាពដែលអាចកើតមានឡើងលុះត្រាតែប្រូបាប៊ីលីតេនៃការហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ចគឺស្ទើតែគ្មាន។

### ផ. ទ្រព្យសកម្មយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាពហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាននោះ ទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឡើយ ហើយវាត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាព លើកលែងតែប្រូបាប៊ីលីតេនៃលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ចគឺស្ទើតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ដែលអស្ថិរភាពនៃទ្រព្យសកម្ម នឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើនក៏ត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាពដែលអាចកើតមានឡើងលុះត្រាតប្រូបាប៊ីលីតេនៃការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចគឺស្ទើតែគ្មាន។

## ៣៦. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក

### ការអនុវត្តក្របខណ្ឌស្តង់ដារ ស.រ.ទ.ហ.អ.ក

ក្រុមហ៊ុនបាន អនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) ដែលបានសង្គត់ភាពដូចស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (“ស.រ.ទ.ហ.អ”) ដែលចេញដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (“IASB”) នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩។ របាយការណ៍ហិរញ្ញវត្ថុនេះ ជារបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងស្របតាម ស.រ.ទ.ហ.អ.ក រួមទាំងការអនុវត្ត ស.រ.ហ.អ.ក ១ ការអនុវត្តជាលើកដំបូង ស.រ.ទ.ហ.អ.ក។

ហេតុដូច្នេះ ក្រុមហ៊ុនបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាម ស.រ.ទ.ហ.អ.ក ដែលមានប្រសិទ្ធភាពអនុវត្តសម្រាប់ការិយបរិច្ឆេទចាប់ផ្តើមនៅ ឬនៅក្រោយថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ រួមជាមួយនឹងព័ត៌មានប្រៀបធៀប នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដូចដែលបានរៀបរាប់នៅក្នុងគោលនយោបាយគណនេយ្យសំខាន់ៗនៅក្នុងកំណត់សម្គាល់ ៣៥។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងដំបូង នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ដែលជាការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក។ និយ័តភាពសំខាន់ៗដែលបានធ្វើឡើងដោយក្រុមហ៊ុនក្នុងការកត់ត្រាឡើងវិញនូវរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ និងរបាយការណ៍ហិរញ្ញវត្ថុដែលបានបោះផ្សាយពីមុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលរបាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានរៀបចំឡើងដោយ ស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហៅកាត់ថា (“ស្តង់ដារពីមុន”) ត្រូវបានបង្ហាញដូចខាងក្រោម។

### ការអនុវត្តការលើកលែងដែលអាចជ្រើសរើសបាន

ស.រ.ហ.អ.ក១ អនុញ្ញាតឱ្យអ្នកអនុវត្តជាលើកដំបូងនូវការលើកលែងមួយចំនួនពីការអនុវត្តតាមវិធីសាស្ត្រប្រតិសកម្មនូវតម្រូវការស.រ.ហ.អ.ក។ ក្រុមហ៊ុនបានអនុវត្តការលើកលែងដូចខាងក្រោម៖

### តម្លៃសមស្រប ឬការវាយតម្លៃឡើងវិញដោយចាត់ទុកជាថ្លៃដើម - ទ្រព្យ និងបរិក្ខារ

ក្រុមហ៊ុនបានជ្រើសរើសដើម្បីវាស់វែងធាតុនីមួយៗនៃទ្រព្យ និងបរិក្ខារដោយប្រើប្រាស់ស្តង់ដារពីមុន ដែលអាចប្រៀបធៀបបានទៅនឹងតម្លៃដើមដករំលស់ ស្របតាម ស.រ.ទ.ហ.អ.ក នៅការិយបរិច្ឆេទផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក។

### ភតិសន្យា

ស.រ.ហ.អ.ក១៦ណែនាំអំពីការធ្វើវិសោធនកម្មដែលមានសារៈសំខាន់ចំពោះ ស.រ.ហ.អ.ក ១ ដែលរួមមានជម្រើសសម្រាប់អ្នកអនុវត្តជាលើកដំបូង ដើម្បីអនុវត្តនិយមន័យភតិសន្យាថ្មីចំពោះកិច្ចសន្យាដែលមានស្រាប់នៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរដោយផ្អែកលើដំណើរហេតុ និងកាលៈទេសៈនៅការិយបរិច្ឆេទនោះ។

ក្រុមហ៊ុនបានអនុវត្តការលើកលែងដូចខាងលើ និងរក្សាការសន្និដ្ឋានដែលទទួលបានពីការវាយតម្លៃដែលបានធ្វើឡើងកាលពីឆ្នាំមុនក្រោមស្តង់ដារពីមុន សម្រាប់ការរៀបចំភតិសន្យាដែលមានស្រាប់។

ជម្រើសនៃការលើកលែងផ្សេងៗទៀតដែលមាននៅក្នុងស.រ.ហ.អ.ក១ ដែលមិនត្រូវបានពិភាក្សានៅទីនេះ គឺមិនមានផលប៉ះពាល់ជាសារវន្តដល់ក្រុមហ៊ុនឡើយ។

### ការលើកលែងដែលមិនអាចជ្រើសរើសបាន

### ការប៉ាន់ស្មាន

ការប៉ាន់ស្មាននៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ និងនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ គឺស្របគ្នានឹងការប៉ាន់ស្មានដែលមានការិយបរិច្ឆេទដូចគ្នាដោយស្របតាមស្តង់ដារពីមុន។ ការប៉ាន់ស្មានដែលក្រុមហ៊ុនបានប្រើដើម្បីបង្ហាញចំនួនទឹកប្រាក់ទាំងនេះដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក គឺឆ្លុះបញ្ចាំងពីលក្ខខណ្ឌដែលមាននៅ ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ដែលជាការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក និងនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨។

### ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

អ្នកអនុវត្តជាលើកដំបូងត្រូវតែអនុវត្តការឈប់ទទួលស្គាល់តាមតម្រូវការរបស់ ស.រ.ទ.ហ.អ.ក សម្រាប់ប្រតិបត្តិការដែលបានកើតឡើងនៅថ្ងៃ ឬនៅក្រោយថ្ងៃទី ១ ខែមករា ឆ្នាំ២០១៨ ជាការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក តាមវិធីសាស្ត្រទស្សនវិស័យ។ ទោះជាយ៉ាងណាក៏ដោយ អង្គភាពមួយអាចអនុវត្តការឈប់ទទួលស្គាល់តាមតម្រូវការរបស់ ស.រ.ទ.ហ.អ.ក ចាប់ពីការិយបរិច្ឆេទប្រតិសកម្មដែលអង្គភាពបានជ្រើសរើស ប្រសិនបើព័ត៌មានដែលតម្រូវឱ្យធ្វើបែបនេះ គឺទទួលបាននៅពេលចាប់ផ្តើមធ្វើប្រតិបត្តិការគណនេយ្យទាំងនោះ។

ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការនៃការឈប់ទទួលស្គាល់របស់ ស.រ.ទ.ហ.អ.ក តាមវិធីសាស្ត្រទស្សនវិស័យសម្រាប់ប្រតិបត្តិការ ដែលកើតឡើងនៅថ្ងៃ ឬនៅក្រោយថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨។

ការផ្ទៀងផ្ទាត់រួមមានជួរឈរពីរសម្រាប់ការិយបរិច្ឆេទនីមួយៗក៏ដូចជាលទ្ធផលនៃស្តង់ដារពីមុន និង ស.រ.ទ.ហ.អ.ក។ ជួរឈរនៃ “ការធ្វើចំណាត់ថ្នាក់ឡើងវិញ” រួមមានការធ្វើចំណាត់ថ្នាក់ឡើងវិញ និងការវិភាគចំនួនទឹកប្រាក់ឡើងវិញ តាមស្តង់ដារពីមុន និង ស.រ.ទ.ហ.អ.ក សម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ជួរឈរនៃ “ផលប៉ះពាល់នៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក” បានបង្ហាញពីផលប៉ះពាល់នៃការផ្លាស់ប្តូរការទទួលស្គាល់ និងការវាស់វែងដែលតម្រូវដោយការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក”។ ជួរឈរនៃ “ផលប៉ះពាល់ពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក” ត្រូវបានវិភាគបន្ថែមទៀតលើប្រភេទនៃនិយ័តភាព។

ការពន្យល់ពីរបៀបនៃការផ្លាស់ប្តូរពីស្តង់ដារពីមុន ទៅ ស.រ.ទ.ហ.អ.ក និងការអនុវត្ត ស.រ.ហ.អ.ក ៩ និងស.រ.ហ.អ.ក ១៥ បានជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនត្រូវបានកំណត់ដោយការសង្ខេបពីបរិមាណនៃការប៉ះពាល់ និងកំណត់សម្គាល់ដែលភ្ជាប់មកជាមួយ។

### ៣៦.១ ការផ្ទៀងផ្ទាត់មូលធន

ការផ្ទៀងផ្ទាត់ខាងក្រោមនេះ សង្ខេបពីផលប៉ះពាល់នៃការអនុវត្តដំបូង ស.រ.ទ.ហ.អ.ក ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ និងនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗទៀតរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨។

| | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | | ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | | ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក | | |
| | | ប្រាក់បញ្ញើមានកាលកំណត់ | កាចាត់ថ្នាក់ឡើងវិញ ពាន់រៀល | ការវាស់វែងឡើងវិញ ពាន់រៀល | ស.រ.ទ.ហ.អ.ក ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | | ១២៧.៣១៦.៤៣០ | - | - | ១២៧.៣១៦.៤៣០ |
| ប្រាក់បញ្ញើជាមួយធនាគារនានា | | ៥.០៤៤.៤០០ | ៣៣២.៧០៤ | - | ៥.៣៧៧.១០៤ |
| ប្រាក់តម្កល់តាមច្បាប់ | | ៤៣.៨៨០.៣៣៦ | - | - | ៤៣.៨៨០.៣៣៦ |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន – សុទ្ធ | ៣៦១ ក (ii) | ១.២៨៣.៨៣៩.៧៤៧ | ១៣.៥០៨.៩៣០ | (១២.៩០២.០៧៨) | ១.២៨៤.៤៤៦.៥៩៩ |
| ទ្រព្យសកម្មផ្សេងៗ | ៣៦ខ | ២៣.៩៧៩.១៧២ | (១៧.៣០៦.៨៨៤) | (២.០៥៤.៨៣៣) | ៤.៦១៧.៤៥៥ |
| ការវិនិយោគ – ឧបករណ៍មូលធន | | ៦០.៥៥៥ | - | - | ៦០.៥៥៥ |
| ទ្រព្យសកម្មអរូបី | | ៣.៣៨៩.៧៦៥ | - | - | ៣.៣៨៩.៧៦៥ |
| ទ្រព្យ និងបរិក្ខារ | | ៧.៥០០.០៩៨ | - | - | ៧.៥០០.០៩៨ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | | - | - | ១៨.៤៧៣.២៣៥ | ១៨.៤៧៣.២៣៥ |
| ពន្ធពន្យារជាទ្រព្យសកម្ម – សុទ្ធ | ៣៦ខ | ៤.៤០៤.៣៧៨ | - | - | ៤.៤០៤.៣៧៨ |
| | | ១.៤៩៩.៤១៤.៨៨១ | (៣.៤៦៥.២៥០) | ៣.៥១៦.៣២៤ | ១.៤៩៩.៤៦៥.៩៥៥ |

| | កំណត់សម្គាល់ | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | | ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ |
|---|---|---|---|---|---|
| | | | ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក | | |
| | | ប្រាក់បញ្ញើមានកាលកំណត់ | កាចាត់ថ្នាក់ឡើងវិញ ពាន់រៀល | ការវាស់វែងឡើងវិញ ពាន់រៀល | ស.រ.ទ.ហ.អ.ក ពាន់រៀល |
| **បំណុល និងមូលធន** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | | ៣៦៤.៥៩៩.២២៥ | ៦.១៣៧.៣៧២ | - | ៣៧០.៧៣៦.៥៩៧ |
| ប្រាក់កម្ចី | | ៧៨៨.៩៨៧.០៩៨ | ៦.៤៦០.០៦៩ | (៧.៦៤២.៩៧២) | ៧៨៧.៨០៤.១៩៥ |
| អនុបំណុល | | ៤១.៩៨៤.៨០០ | ៦៣២.៥០៥ | ២.៥៩៦.២៩២ | ៤៥.២១៣.៥៩៧ |
| បំណុលភតិសន្យា | ៣៦ខ | - | - | ១៦.៤១៨.៤០២ | ១៦.៤១៨.៤០២ |
| បំណុលផ្សេងៗ | | ៣៨.៤០០.៩៧៦ | (១៦.៦៩៥.១៩៦) | - | ២១.៧០៥.៧៨០ |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | | ១៣.៨៣៦.៨៣៦ | - | - | ១៣.៨៣៦.៨៣៦ |
| បំណុលសរុប | | ១.២៤៧.៨០៨.៩៣៦ | (៣.៤៦៥.២៥០) | ១១.៣៧១.៧២២ | ១.២៥៥.៧១៥.៤០៧ |
| **មូលធន** | | | | | |
| ដើមទុនក្រុមហ៊ុន | | ៧១.៦៨៤.១០០ | - | - | ៧១.៦៨៤.១០០ |
| ទុនបម្រុងទូទៅ | | ៧.១៦៨.៤១០ | - | - | ៧.១៦៨.៤១០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៣៦ក (iv) | - | - | ៤.៦៣២.២៤៤ | ៤.៦៣២.២៤៤ |
| ប្រាក់ចំណេញរក្សាទុក | ៣៦ក (iv) | ១៧២.៧៥៣.៤៣៦ | - | (១២.៤៨៧.៦៤២) | ១៦០.២៦៥.៧៩៤ |
| មូលធនសរុប | | ២៥១.៦០៥.៩៤៦ | - | (៧.៨៥៥.៣៩៨) | ២៤៣.៧៥០.៥៤៨ |
| **បំណុល និងមូលធនសរុប** | | ១.៤៩៩.៤១៤.៨៨១ | (៣.៤៦៥.២៥០) | ៣.៥១៦.៣២៤ | ១.៤៩៩.៤៦៥.៩៥៥ |

ការផ្ទៀងផ្ទាត់ខាងក្រោមនេះ សង្ខេបពីផលប៉ះពាល់នៃការអនុវត្តដំបូង ស.រ.ទ.ហ.អ.ក ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ និងនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗទៀតរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨។

| | កំណត់សម្គាល់ | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | | | ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ |
|---|---|---|---|---|---|
| | | | ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក | | |
| | | ប្រាក់បញ្ញើមានកាលកំណត់ | កាចាត់ថ្នាក់ឡើងវិញ ពាន់រៀល | ការវាស់វែងឡើងវិញ ពាន់រៀល | ស.រ.ទ.ហ.អ.ក ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| ទ្រព្យសកម្ម | | ៣៦៨.២៤៤.៦១៧ | - | - | ៣៦៨.២៤៤.៦១៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | | ២០០.០០០ | ៣៤០ | - | ២០០.៣៤០ |
| ប្រាក់បញ្ញើជាមួយធនាគារនានា | | ១០៦.២៤៨.០៤៧ | - | - | ១០៦.២៤៨.០៤៧ |
| ប្រាក់តម្កល់តាមច្បាប់ | | ១.៩២៨.៦៧៥.៧៦៧ | ១៨.២៥៩.៧១៥ | (២៤.៥៤០.៧៣១) | ១.៩២២.៣៩៤.៧៥១ |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន – សុទ្ធ | ៣៦ក (ii) | ៤៤.១០៥.៨៧៩ | (២៣.១៨៦.៧៨១) | (២.៧៨៤.៩១៩) | ១៨.១៣៤.១៧៩ |
| ទ្រព្យសកម្មផ្សេងៗ | | ៦០.២៧០ | - | - | ៦០.២៧០ |
| ការវិនិយោគ – ឧបករណ៍មូលធន | | ៤.៥០៥.៨០៩ | - | - | ៤.៥០៥.៨០៩ |
| ទ្រព្យសកម្មអរូបី | | ៦.៥៤៤.៥៤០ | - | - | ៦.៥៤៤.៥៤០ |
| ទ្រព្យ និងបរិក្ខារ | | - | - | ១៨.៣៨៤.៩៤១ | ១៨.៣៨៤.៩៤១ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | | ៧.៥៨១.៨៩៤ | - | - | ៧.៥៨១.៨៩៤ |
| ពន្ធពន្យារជាទ្រព្យសកម្ម – សុទ្ធ | ៣៦ខ | ២.៤៦៦.១៦៦.៨២៣ | (៤.៩២៦.៧២៦) | (៨.៩៤០.៧០៩) | ២.៤៥២.២៩៩.៣៨៨ |

| | កំណត់សម្គាល់ | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | | | ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ |
|---|---|---|---|---|---|
| | | | ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក | | |
| | | ប្រាក់បញ្ញើមាន កាលកំណត់ | កាចាត់ថ្នាក់ឡើងវិញ ពាន់រៀល | ការវាស់វែងឡើងវិញ ពាន់រៀល | ស.រ.ទ.ហ.អ.ក ពាន់រៀល |
| **បំណុល និងមូលធន** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | | ៩៣៥.០៨៤.២៦៤ | ១៦.៨២១.៦៦២ | - | ៩៥១.៩០៥.៩២៦ |
| ប្រាក់កម្ចី | | ១.០០៤.៨៨២.១១១ | ៥.៥៦២.០៨៩ | ១.៣៥៣.០៤៣ | ១.០១១.៧៩៧.២៤៣ |
| អនុបំណុល | | ៨៣.៥៧៤.៤០០ | ១.៣៧៧.០៨៦ | ១៥៤.៤៧១ | ៨៥.១០៥.៩៥៧ |
| បំណុលភតិសន្យា | ៣៦ខ | - | - | ១៦.៨៩១.១៩៤ | ១៦.៨៩១.១៩៤ |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | | ៤.៣២៣.៧៤០ | - | - | ៤.៣២៣.៧៤០ |
| បំណុលផ្សេងៗ | | ៦៤.២៩៥.៤២៩ | (២៨.៦៨៧.៥៦៣) | - | ៣៥.៦០៧.៨៦៦ |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | | ២០.៥២៣.៩៣៣ | - | - | ២០.៥២៣.៩៣៣ |
| បំណុលសរុប | | ២.១១២.៦៨៣.៨៧៧ | (៤.៩២៦.៧២៦) | ១៨.៣៩៨.៧០៨ | ២.១២៦.១៥៥.៨៥៩ |
| **មូលធន** | | | | | |
| ដើមទុនក្រុមហ៊ុន | | ១២០.០០០.០០០ | - | - | ១២០.០០០.០០០ |
| ដើមទុនបន្ថែម | | ២០.៨៤៦.៦០០ | - | - | ២០.៨៤៦.៦០០ |
| ទុនបម្រុងទូទៅ | | ១១០.៤១៥.១១៦ | - | - | ១១០.៤១៥.១១៦ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៣៦ក (iv) | - | - | ៨.៣៨៤.៧៦៩ | ៨.៣៨៤.៧៦៩ |
| ប្រាក់ចំណេញរក្សាទុក | ៣៦ក (iv) | ១០២.២២១.២៣០ | - | (៣៥.៧២៤.១៨៦) | ៦៦.៤៩៧.០៤៤ |
| មូលធនសរុប | | ៣៥៣.៤៨២.៩៤៦ | - | (២៧.៣៣៩.៤១៧) | ៣២៦.១៤៣.៥២៩ |
| **បំណុល និងមូលធនសរុប** | | ២.៤៦៦.១៦៦.៨២៣ | (៤.៩២៦.៧២៦) | (៨.៩៤០.៧០៩) | ២.៤៥២.២៩៩.៣៨៨ |

ការសង្ខេបពីការធ្វើចំណាត់ថ្នាក់ឡើងវិញនៃ តារាងតុល្យការ និង ការធ្វើនិយ័តភាពសំខាន់ៗ ដែលជាលទ្ធផលនៃការផ្លាស់ប្តូរពីស្តង់ដារពីមុនទៅ ស.រ.ហ.អ.ក។

## ក. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ស.រ.ទ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុបង្ហាញនូវតម្រូវការសម្រាប់ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងកិច្ចសន្យាមួយចំនួន ដើម្បីទិញ ឬលក់ធាតុដែលមិនមែនជាហិរញ្ញវត្ថុ។ វាក៏ណែនាំផងដែរនូវគំរូថ្មី "ការរំពឹងទុកឥណទានខាតបង់" (ECL) និងគំរូគណនេយ្យការពារហានិភ័យទូទៅថ្មី។ ក្រុមហ៊ុនបានអនុវត្ត ស.រ.ទ.ហ.អ.ក ៩ ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨។

ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ដែលបណ្តាលមកពីការអនុវត្ត ស.រ.ហ.អ.ក ៩ ត្រូវបានអនុវត្តជាទូទៅដោយក្រុមហ៊ុននាពេលក្រោយ លើកលែងតែចំណុចដែលបានពិពណ៌នាខាងក្រោម។

- ការវាយតម្លៃខាងក្រោមត្រូវបានធ្វើឡើងដោយផ្អែកលើដំណើរហេតុ និងកាលៈទេសៈដែលមានស្រាប់នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨។
  - ការកំណត់ចំពោះគំរូអាជីវកម្ម ដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកាន់កាប់
  - ការកំណត់ថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុបង្កើតឱ្យមានលំហូរទឹកប្រាក់ ដែលជាការទូទាត់សងប្រាក់ដើម និងការប្រាក់ទៅលើចំនួនទឹកប្រាក់ដែលនៅសល់
  - ការកំណត់នូវ ការវិនិយោគមូលធនដែលមិនសម្រាប់យកមកធ្វើការជួញដូរជា FVOCI និង
- ប្រសិនបើការវិនិយោគបំណុលមានហានិភ័យឥណទានទាបនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ក្រុមហ៊ុនបានសន្មតថាហានិភ័យឥណទានលើទ្រព្យសកម្មមិនមានការកើនឡើងជាសារវន្តទេចាប់តាំងពីការទទួលស្គាល់ដំបូង។

ផលប៉ះពាល់ដែលកើតឡើងពីការអនុវត្ត ស.រ.ទ.ហ.អ.ក ៩ រួមទាំងផលប៉ះពាល់លើពន្ធ ត្រូវបានពិពណ៌នាដូចខាងក្រោម។

### (i). ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ក្រោម ស.រ.ហ.អ.ក ៩ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមប្រភេទដូចខាងក្រោម៖ វាស់វែងតាមរំលស់ថ្លៃដើម FVOCI - ឧបករណ៍បំណុល FVOCI - ឧបករណ៍មូលធន ឬ FVTPL។ ការចាត់ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុក្រោម ស.រ.ទ.ហ.អ.ក ៩ ដែលជាទូទៅគឺផ្អែកលើគំរូអាជីវកម្មដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រង និងលក្ខណៈនៃលំហូរទឹកប្រាក់តាមកិច្ចសន្យា។

សម្រាប់ការពន្យល់អំពីវិធីដែលក្រុមហ៊ុនធ្វើការចាត់ថ្នាក់ និងវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ និងចំណេញ និងខាតដែលពាក់ព័ន្ធក្រោម ស.រ.ទ.ហ.អ.ក ៩ សូមមើលកំណត់សម្គាល់ ៣៥គ(ii)។

តារាងខាងក្រោម និងកំណត់សម្គាល់ដែលភ្ជាប់មកជាមួយខាងក្រោមពន្យល់ពីប្រភេទនៃការវាស់វែងដំបូងនៅក្រោមស្តង់ដារពីមុន និងប្រភេទប្រភេទនៃការវាស់វែងថ្មីក្រោម ស.រ.ហ.អ.ក ៩ សម្រាប់ថ្នាក់នីមួយៗ នៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨។

| | កំណត់សម្គាល់ | ការធ្វើចំណាត់ថ្នាក់ដំបូង ក្រោមស្តង់ដារពីមុន | ការធ្វើចំណាត់ថ្នាក់ថ្មី ក្រោម ស.រ.ហ.អ.ក ៩ | តម្លៃយោងដំបូង ក្រោមស្តង់ដារពីមុន ពាន់រៀល | តម្លៃយោងថ្មី ក្រោម ស.រ.ហ.អ.ក ៩ ពាន់រៀល |
|---|---|---|---|---|---|
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | | ថ្លៃដើម | រំលស់ថ្លៃដើម | ១២៧.៣១៦.៤៣០ | ១២៧.៣១៦.៤៣០ |
| ប្រាក់បញ្ញើជាមួយធនាគារនានា | | ថ្លៃដើម | រំលស់ថ្លៃដើម | ៥.០៤៤.៤០០ | ៥.៣៧៧.១០៤ |
| ការវិនិយោគ | (ក) | ថ្លៃដើម | តាម FVOCI | ៦០.៥៥៥ | ៦០.៥៥៥ |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | (ខ) | តម្លៃយោង | រំលស់ថ្លៃដើម | ១.២៨៣.៨៣៩.៧៤៧ | ១.២៨៤.៤៤៦.៥៩៩ |
| ទ្រព្យសកម្មផ្សេងៗ | (ខ) | តម្លៃយោង | រំលស់ថ្លៃដើម | ២៣.៩៧៩.១៧២ | ៤.៦១៧.៤៥៦ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប (ពាន់រៀល) | | | | ១.៤៤០.២៤០.៣០៤ | ១.៤២១.៨១៨.១៤៤ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប (ដុល្លារអាមេរិក - កំណត់សម្គាល់ ៥)** | | | | ៣៥៦.៧៦០.០៤៦ | ៣៥២.១៩៦.៧១៦ |

| | កំណត់សម្គាល់ | ការធ្វើចំណាត់ថ្នាក់ដំបូង ក្រោមស្តង់ដារពីមុន | ការធ្វើចំណាត់ថ្នាក់ថ្មី ក្រោម ស.រ.ហ.អ.ក ៩ | តម្លៃយោងដំបូង ក្រោមស្តង់ដារពីមុន ពាន់រៀល | តម្លៃយោងថ្មី ក្រោម ស.រ.ហ.អ.ក ៩ ពាន់រៀល |
|---|---|---|---|---|---|
| **បំណុលហិរញ្ញវត្ថុ** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | (គ) | ថ្លៃដើម | រំលស់ថ្លៃដើម | ៣៦៤.៥៩៩.២២៥ | ៣៦៤.៥៩៩.២២៥ |
| ប្រាក់កម្ចី | (គ) | ថ្លៃដើម | រំលស់ថ្លៃដើម | ៧៨៨.៩៨៧.០៩៩ | ៧៨៧.៨០៤.១៩៥ |
| អនុបំណុល | (គ) | តម្លៃយោង | រំលស់ថ្លៃដើម | ៤១.៩៨៤.៨០០ | ៤៥.២១៣.៥៩៧ |
| បំណុលផ្សេងៗ | (គ) | តម្លៃយោង | រំលស់ថ្លៃដើម | ៣៨.៤០០.៩៧៦ | ២១.១៦៣.៨៦៤ |
| **បំណុលហិរញ្ញវត្ថុសរុប (ពាន់រៀល)** | | | | ១.២៣៣.៩៧២.១០០ | ១.២១៨.៧៨០.៨៨១ |
| **បំណុលហិរញ្ញវត្ថុសរុប (ដុល្លារអាមេរិក - កំណត់សម្គាល់ ៥)** | | | | ៣០៥.៦៦៥.៦១៨ | ៣០១.៩០២.៦២១ |

(ក) នៅក្រោមស្តង់ដារពីមុន ការវិនិយោគមូលធនទាំងនេះត្រូវបានកំណត់តាមរំលស់ថ្លៃដើម។ ទ្រព្យសកម្មទាំងនេះត្រូវបានចាត់ថ្នាក់ដោយមិនអាចជ្រើសរើសបាន និងត្រូវវាស់វែងក្រោម FVOCI និងក្រោម ស.រ.ទ.ហ.អ.ក ៩។

(ខ) ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន ត្រូវបានចាត់ថ្នាក់ជាឥណទាន និងគណនីត្រូវទទួលនៅក្រោមស្តង់ដារពីមុន ហើយត្រូវបានចាត់ថ្នាក់តាមរំលស់ថ្លៃដើម។ ការកើនឡើងនៃចំនួនទឹកប្រាក់ ៤.៦៣២.២៤៤ពាន់រៀល នៅក្នុងសំវិធានធនសម្រាប់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញរក្សាទុកដំបូងរបស់ធនាគារ និងក្រុមហ៊ុននៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ រៀងៗខ្លួន លើការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក ៩។

(គ) នៅក្រោមស្តង់ដារពីមុន បំណុលហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់តាមថ្លៃដើម ឥឡូវត្រូវបានចាត់ថ្នាក់តាមរំលស់ថ្លៃដើមជំនួសវិញ ដែលធ្វើអោយមានការកើនឡើងនៃចំនួនទឹកប្រាក់ ១៥.១៩១.២១៩ពាន់រៀល គនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨។

### (ii). ឱនភាពនៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ស.រ.ហ.អ.ក ៩ ជំនួសឱ្យគំរូស្តង់ដារពីមុន "ការខាតបង់ដែលបានកើតឡើង" ជាមួយនឹងគំរូ "ការរំពឹងទុកឥណទានខាតបង់" (ECL)។ គំរូនៃឱភាពនៃតម្លៃថ្មីអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម (ទ្រព្យសកម្មកិច្ចសន្យា) ការវិនិយោគបំណុលនៅ FVOCI និងកិច្ចសន្យាធានាលើក្រុមហិរញ្ញវត្ថុ ប៉ុន្តែមិនត្រូវបានសម្រាប់ធ្វើការវិនិយោគមូលធនទេ។ ការប្រើប្រាស់គំរូនៃឱនភាពនៃតម្លៃថ្មីក្រោម ស.រ.ហ.អ.ក ១ មិនមានផលប៉ះពាល់ដល់តម្លៃយោងនៃកិច្ចសន្យាធានាលើក្រុមហិរញ្ញវត្ថុនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ នោះទេព្រោះថាចំនួនទឹកប្រាក់ដំបូងដែលបានទទួលស្គាល់ដកនឹងចំនួនបង្គរនៃចំណូលដែលបានទទួលស្គាល់ស្របតាម ស.រ.ហ.អ.ក ១៥ គឺខ្ពស់ជាងចំនួនដែលបានប៉ាន់ស្មាននៃការរំពឹងទុកឥណទានខាតបង់ (ECL)។

ការអនុវត្តនូវតម្រូវការឱនភាពនៃតម្លៃតាម ស.រ.ទ.ហ.អ.ក ៩ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ បង្កើតឱ្យមានសំវិធានធនសម្រាប់ឱនភាពនៃតម្លៃដូចខាងក្រោម៖

| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៥) |
|---|---|---|
| សំវិធានធនខាតបង់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ក្រោមស្តង់ដារពីមុន | ២២.៧១៤.៤០០ | ៥.៦២៦.៥៥៤ |
| ការថយសំវិធានធនបានទទួលស្គាល់នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ លើ៖ | | |
| បំណុលវិនិយោគ - រំលស់ថ្លៃដើម | (៤.៦៣២.២៤៤) | (១.១៤៧.៤៤៧) |
| សំវិធានធនខាតបង់នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ក្រោម ស.រ.ហ.អ.ក ៩ | ១៨.០៨២.១៥៦ | ៤.៤៧៩.១០៧ |

សំវិធានធនខាតបង់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្មនោះ។ ចំពោះ ការវិនិយោគបំណុលនៅ FVOCI សំវិធានធនខាតបង់ត្រូវបានទទួលស្គាល់នៅក្នុង OCI ជំនួសឱ្យការកាត់បន្ថយតម្លៃយោង នៃទ្រព្យសកម្ម។

ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រដែលក្រុមហ៊ុនប្រើសម្រាប់វាស់វែងឱនភាពនៃតម្លៃលើសំវិធានធនត្រូវបានពិពណ៌នានៅក្នុងកំណត់សម្គាល់លេខ៩។

### (iii). ការប្រាក់

នៅក្រោមស្តង់ដារពីមុនកម្រៃដែលជាផ្នែកមួយនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុមិនត្រូវបានបញ្ចូលជាអត្រាការប្រាក់ប្រសិទ្ធភាពនោះទេហើយត្រូវបានទទួលស្គាល់ថាជាចំណូលនៅពេលប្រតិបត្តិការកើតឡើង។

ការទទួលស្គាល់ចំណូលការប្រាក់ត្រូវបានផ្អាកនៅពេលដែលឥណទានមិនដំណើរការ។

តាម ស.រ.ហ.អ.ក ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងតាមតម្លៃទីផ្សារបូកនឹងថ្លៃដើមប្រតិបត្តិការដែលកើតមកពីការទិញ ឬលក់ទ្រព្យ និងបំណុលទាំងនោះ។

ផលប៉ះពាល់ដែលកើតឡើងពីការ ផ្លាស់ប្តូរត្រូវបានសង្ខេបដូចខាងក្រោម៖

| | ថ្ងៃទី១ ខែមករា ឆ្នាំ ២០១៨ ពាន់រៀល | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ពាន់រៀល |
|---|---|---|
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | (១២.៩០២.០៧៨) | (១៥.៣៩១.១៧៨) |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | - | (១.២៩១.១៧២) |
| ប្រាក់កម្ចី | ៧.៦៤២.៩៧២ | (៦.៣៩៩.៧២៣) |
| អនុបំណុល | (២.៥៩៦.២៩២) | (១៥៤.៤៧១) |
| និយ័តភាពលើប្រាក់ចំណេញរក្សាទុក | (៧.៨៥៥.៣៩៨) | (២៣.២៣៦.៥៤៤) |

| | |
|---|---|
| **របាយការណ៍លទ្ធផលលម្អិត** | |
| ចំណូលការប្រាក់ | ២២.៦៦២.៩៥៩ |
| ចំណាយការប្រាក់ | (១២.២១០.៦៦១) |
| ឱនភាពនៃតម្លៃលើសំវិធានធន | ៣.៧៥២.៥២៥ |
| ចំណូលពីកម្រៃ និងជើងសារ | (៣៨.០៥៤.១៣៧) |
| ចំណាយកម្រៃ និងជើងសារ | ៤.៣៦៥.២៩៥ |
| និយ័តភាពលើប្រាក់ចំណេញរក្សាទុក | (១៩.៤៨៤.០១៩) |

(iv). **ផលប៉ះពាល់នៃអន្តរកាលលើមូលធន**

តារាងខាងក្រោមសង្ខេបអំពីផលប៉ះពាល់ (ដកពន្ធ) នៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក ៩ ប្រាក់ចំណេញរក្សាទុក នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨។

| | ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក ៩ ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ | |
|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៥) |
| **ទុនបម្រុងតាមបទប្បញ្ញត្តិ** | | |
| សមតុល្យចុងគ្រាក្រោមស្តង់ដារពីមុន (ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧) | - | - |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅប្រាក់បម្រុងតាមបទប្បញ្ញត្តិ | ៤.៦៣២.២៤៤ | ១.១៤៧.៤៤៧ |
| សមតុល្យដើមគ្រាក្រោម ស.រ.ហ.អ.ក ៩ (ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨) | ៤.៦៣២.២៤៤ | ១.១៤៧.៤៤៧ |

| | ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក ៩ ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ | |
|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៥) |
| **ប្រាក់ចំណេញរក្សាទុក** | | |
| សមតុល្យចុងគ្រាក្រោមស្តង់ដារពីមុន (ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧) | ១៧២.៧៥៣.៤៣៦ | ៤២.៧៩២.៥២៨ |
| ការវាស់វែងឡើងវិញតាមរំលស់ថ្លៃដើមក្រោម ស.រ.ហ.អ.ក ៩ | (១២.៤៨៧.៦៤២) | (៣.០៩៣.២៩៧) |
| ការទទួលស្គាល់ឥណទានរំពឹងថានឹងបាត់បង់ក្រោម ស.រ.ហ.អ.ក ៩ | ៤.៦៣២.២៤៤ | ១.១៤៧.៤៤៧ |
| ផ្ទេរ ទៅប្រាក់បម្រុងតាមបទប្បញ្ញត្តិ | (៤.៦៣២.២៤៤) | (១.១៤៧.៤៤៧) |
| សមតុល្យដើមគ្រាក្រោម ស.រ.ហ.អ.ក ៩ (ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨) | ១៦០.២៦៥.៧៩៤ | ៣៩.៦៩៩.២៣១ |

## ខ. ភតិសន្យា

កាលពីមុនក្រុមហ៊ុនបានចាត់ថ្នាក់ភតិសន្យាថាជាកិច្ចសន្យាជួលប្រតិបត្តិការ ឬហិរញ្ញវត្ថុដោយផ្អែកលើការវាយតម្លៃរបស់ខ្លួនថាតើកិច្ចសន្យាជួលនោះបានផ្ទេរនូវហានិភ័យ និងផលប្រយោជន៍ជាសារវន្តនូវភាពជាម្ចាស់នៃទ្រព្យដល់ធនាគារ។ ក្រោម ស.រ.អ.ហ.ក ១៦ ធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាចំពោះកិច្ចសន្យាជួលការិយាល័យសាខា និងការិយាល័យ ឧទាហរណ៍កិច្ចសន្យាជួលទាំងនេះមានលើតារាងតុល្យការ។

| | ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨<br>ពាន់រៀល | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨<br>ពាន់រៀល |
|---|---|---|
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១៨.៤៧៣.២៣៥ | ១៨.៣៨៤.៩៤១ |
| ទ្រព្យសកម្មផ្សេងៗ | (២.០៥៤.៨៣៣) | (២.៧៨៤.៩១៩) |
| បំណុលភតិសន្យា | (១៦.៤១៨.៤០២) | (១៦.៨៩១.១៩៤) |
| **និយ័តភាពលើប្រាក់ចំណេញរក្សាទុក** | - | (១.២៩១.១៧២) |
| **(ដុល្លារអាមេរិក -កំណត់សម្គាល់ ៥)** | - | (៣១៩.២០២) |
| | | |
| **របាយការណ៍ចំណេញ ឬ ខាត** | | |
| រំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | | (៤.៨៦៥.១០៥) |
| ចំណាយការប្រាក់លើបំណុលភតិសន្យា | | (១.២៩៧.៤៥១) |
| ការចំណាយលើការជួល | | ៤.៨៧១.៣៨៤ |
| **និយ័តភាពមុនពន្ធលើប្រាក់ចំណេញ - ដុល្លារអាមេរិក** | | (១.២៩១.១៧២) |
| **និយ័តភាពមុនពន្ធលើប្រាក់ចំណេញ** | | |
| **(ដុល្លារអាមេរិក - កំណត់សម្គាល់ ៥)** | | (៣១៩.២០២) |

## ៣៦.២ ការផ្ទៀងផ្ទាត់របាយការណ៍ចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | កំណត់សម្គាល់ | ស្តង់ដារពីមុន | ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក | | ស.រ.ទ.ហ.អ.ក |
|---|---|---|---|---|---|
| | | | កាចាត់ថ្នាក់ឡើងវិញ | ការវាស់វែងឡើងវិញ | |
| | | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល |
| **ចំណូលពីប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់ | | ២៩២.១៩២.២៩៨ | - | ២២.៦៦២.៩៥៩ | ៣១៤.៨៥៥.២៥៦ |
| ចំណាយការប្រាក់ | | (១២៦.៣៥១.៨២៣) | - | (១២.២១០.៦៦១) | (១៣៨.៥៦២.៤៨២) |
| **ចំណូលពីការប្រាក់សុទ្ធ** | | ១៦៥.៨៤០.៤៧៥ | - | ១០.៤៥២.២៩៨ | ១៧៦.២៩២.៧៧៤ |
| សំវិធានធនលើការបាត់បង់ឥណទាន និងបុរេប្រទាន | | (១៦.០៦៦.៥៩២) | - | ៣.៧៥២.៥២៥ | (១២.៣១៤.០៦៧) |
| សំវិធានធនលើការខាតបង់លើ ឱនភាពនៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ | | (១.០៩២.៤៣៣) | - | - | (១.០៩២.៤៣៣) |
| **ចំណេញពីប្រតិបត្តិការសរុប** | | ១៤៨.៦៨១.៤៥១ | - | ១៤.២០៤.៨២៣ | ១៦២.៨៨៦.២៧៤ |
| | | | | | |
| ចំណូលប្រតិបត្តិការ | | ៧៨.៦៨៤.៨៩៨ | - | (៣៨.០៥៤.១៣៧) | ៤០.៦៣០.៧៦២ |
| ចំណាយកម្រៃជើងសារ | | (២.៣៩៨.៤៧៥) | - | - | (២.៣៩៨.៤៧៥) |
| ចំណាយលើបុគ្គលិក | | (៧៦.០៣៥.៣៨៩) | - | - | (៧៦.០៣៥.៣៨៩) |
| រំលស់ទ្រព្យ និងបរិក្ខារ និង ទ្រព្យសកម្មអរូបី | | (៤.១៦៩.៣៦៣) | - | (៤.៨៦៥.១០៥) | (៩.០៣៤.៤៦៨) |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | | (៤២.៦៧៥.២៤៣) | - | ៩.២៣០.៤០០ | (៣៣.៤៤៤.៨៤៣) |
| (ខាត)/ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | | (៣០៩.៥៥៧) | - | - | (៣០៩.៥៥៨) |
| **ចំណាយលើប្រតិបត្តិការសរុប** | | (៤៦.៩០៣.១២៩) | - | (៣៣.៦៨៨.៨៤២) | (៨០.៥៩១.៩៧១) |

| | កំណត់សម្គាល់ | ស្តង់ដារពីមុន | ផលប៉ះពាល់នៃអន្តរកាលលើ ស.រ.ទ.ហ.អ.ក | | ស.រ.ទ.ហ.អ.ក |
|---|---|---|---|---|---|
| | | | កាចាត់ថ្នាក់ឡើងវិញ | ការវាស់វែងឡើងវិញ | |
| | | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល |
| **ចំណេញមុនដកពន្ធលើប្រាក់ចំណេញ** | | ១០១.៧៧៨.៣២២ | - | (១៩.៤៨៤.០១៩) | ៨២.២៩៤.៣០៣ |
| ចំណាយពន្ធលើប្រាក់ចំណេញ | | (២០.៧៤៧.៩២២) | - | - | (២០.៧៤៧.៩២២) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | ៨១.០៣០.៤០០ | | (១៩.៤៨៤.០១៩) | ៦១.៥៤៦.៣៨១ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| ទុនបម្រុងលើការប្តូររូបិយប័ណ្ណ | | - | - | - | - |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | ៨១.០៣០.៤០០ | - | (១៩.៤៨៤.០១៩) | ៦១.៥៤៦.៣៨១ |

សេចក្តីសង្ខេបនៃរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដែលបានចាត់ថ្នាក់ឡើងវិញ និងនិយ័តភាពសំខាន់ៗដែលជាលទ្ធផលនៃការផ្លាស់ប្តូរពីស្តង់ដារពីមុនទៅ ស.រ.ទ.ហ.អ.ក។

## ក. កម្រៃ និងជើងសារ

ស.រ.ហ.អ.ក ១៥ បង្កើតក្របខ័ណ្ឌលម្អិតសម្រាប់កំណត់ថាតើត្រូវទទួលបានប្រាក់ចំណូលប៉ុន្មាន និងនៅពេលណាដែលប្រាក់ចំណូលនោះត្រូវបានទទួលស្គាល់។ វាក៏បានធ្វើការណែនាំថ្លៃដើមថ្មី ដែលទាមទារឱ្យមានការទទួលបានថ្លៃដើមជាក់លាក់ និងការបំពេញកិច្ចសន្យាដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មដាច់ដោយឡែកនៅពេលដែលមានលក្ខណៈវិនិច្ឆ័យជាក់លាក់ណាមួយ។

ក្រុមហ៊ុនបានអនុវត្ត ស.រ.ហ.អ.ក ១៥ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយប្រើវិធីសាស្ត្រប្រតិសកម្ម។ រាល់តម្រូវការទាំងអស់របស់ ស.រ.ហ.អ.ក ១៥ ត្រូវបានអនុវត្តប្រតិសកម្ម លើកលែងតែការអនុវត្តក្នុងទម្រង់ជាមធ្យោបាយងាយស្រួលដូចបានរៀបរាប់នៅខាងក្រោម ហើយព័ត៌មានដែលបានបង្ហាញសម្រាប់ឆ្នាំ ២០១៨ ត្រូវបានកំណត់ឡើងវិញ។

ក្រុមហ៊ុនបានប្រើប្រាស់នូវការអនុវត្តមធ្យោបាយងាយស្រួលដែលបានអនុញ្ញាតដោយ ស.រ.ហ.អ.ក ១។

- កិច្ចសន្យាដែលបានបំពេញរួច ដែលបានចាប់ផ្តើម និងបញ្ចប់ នៅក្នុងការិយបរិច្ឆេទដូចគ្នាក្នុងឆ្នាំ ២០១៨ និងកិច្ចសន្យាដែលបានបំពេញរួចនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ មិនត្រូវបានកំណត់ឡើងវិញនោះទេ។
- ចំពោះកិច្ចសន្យាដែលបានបំពេញរួច ដែលមានតម្លៃតបស្នងអថេរ ក្រុមហ៊ុនបានប្រើប្រាស់តម្លៃប្រតិបត្តិការនៅការិយបរិច្ឆេទ ដែលកិច្ចសន្យានោះត្រូវបានបំពេញ ដើម្បីកំណត់ព័ត៌មានប្រៀបធៀប។
- ចំពោះកិច្ចសន្យាដែលបានកែប្រែមុនថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ក្រុមហ៊ុនបានឆ្លុះបញ្ចាំងពីផលប៉ះពាល់បង្គរនៃការកែប្រែទាំងអស់ដែលបានកើតឡើងមុនថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ នៅពេលដែលការកំណត់នូវការអនុវត្តកាតព្វកិច្ចដែលបានបំពេញរួច និងមិនទាន់បានបំពេញ ការកំណត់តម្លៃប្រតិបត្តិការ និងការបែងចែកតម្លៃប្រតិបត្តិការនៃការអនុវត្តកាតព្វកិច្ចដែលបានបំពេញរួច និងមិនទាន់បានបំពេញ។ ប្រសិនបើក្រុមហ៊ុនបានជ្រើសរើសមធ្យោបាយងាយស្រួលនេះទេ ចំនួនប្រាក់ចំណូលដែលបានកត់ទុកសម្រាប់ឆ្នាំមុននឹងខ្ពស់ជាងនេះ។
- សម្រាប់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ក្រុមហ៊ុនមិនបានបង្ហាញពីចំនួនទឹកប្រាក់នៃតម្លៃប្រតិបត្តិការដែលបានបម្រុងទុកសម្រាប់ការអនុវត្តកាតព្វកិច្ចដែលនៅសល់ និងការពន្យល់នៅពេលដែលក្រុមហ៊ុនរំពឹងថានឹងទទួលស្គាល់ចំនួនទឹកប្រាក់នោះថាជាចំណូល។

ផលប៉ះពាល់ពីការអនុវត្ត ស.រ.ទ.ហ.អ.ក ១៥ រួមទាំងផលប៉ះពាល់លើពន្ធ ត្រូវបានបង្ហាញដូចខាងក្រោម៖

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | | ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៥) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៥) |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | | |
| ការកើនឡើងនៃពន្ធពន្យារជាបំណុល | - | - | - | - |
| ការកើនឡើងប្រាក់ចំណេញរក្សាទុក | (២៣.២៣៦.៥៤៤) | (៥.៧៤៥.៩៣១) | (១២.៤៨៧.៦៤២) | (៣.០៨៧.១៨០) |
| **របាយការណ៍ចំណេញ ឬខាត** | | | | |
| ការកើនឡើងនៃចំណូលការប្រាក់ | ២២.៦៦២.៩៥៩ | ៥.៦០៤.០៩៥ | ១៧.៥៣៤.០៩៥ | ៤.៣៣៤.៨១៥ |
| ការកើនឡើងនៃចំណាយការប្រាក់ | (១២.២១០.៦៦១) | (៣.០១៩.៤៥១) | ៩៩១.០០៨ | ២៤៤.៩៩៦ |
| ការថយចុះនៃសំវិធានធន | ៣.៧៥២.៥២៥ | ៩២៧.៩២៤ | ៤.៦៣២.២៤៤ | ១.១៤៥.១៧៨ |
| ការកើនឡើងនៃចំណូលកម្រៃ/ជើងសារ | (៣៨.០៥៤.១៣៧) | (៩.៤១០.០២៤) | (២៥.០៩៣.៦៦៧) | (៦.២០៣.៦២៦) |
| ការកើនឡើងនៃចំណាយកម្រៃ/ជើងសារ | ៤.៣៦៥.២៩៥ | ១.០៧៩.៤៥០ | ៣.៩៤២.១២៦ | ៩៧៤.៥៦៨ |
| ការកើនឡើងនៅក្នុងប្រាក់ចំណេញ សម្រាប់ការិយបរិច្ឆេទ | (១៩.៤៨៤.០១៩) | (៤.៨១៨.០០៦) | ២.០០៦.០៣៣ | ៤៩៥.៩៣០ |

## ៣៦.៣ ការផ្ទៀងផ្ទាត់ប្រាក់ចំណេញក្រោយដកពន្ធ

| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៥) |
|---|---|---|
| **ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨** | | |
| ប្រាក់ចំណេញក្រោយដកពន្ធក្រោមស្តង់ដារពីមុន | ៨១.០៣០.៤០០ | ២០.០៣៧.១៩១ |
| ចំណូលការប្រាក់ | (១១.៦៣៨.៦៥៣) | (២.៨៧៨.០០៥) |
| ចំណាយការប្រាក់លើកម្ចី | (៦.៣៩៩.៧២៣) | (១.៥៨២.៥២៣) |
| ចំណាយការប្រាក់លើអនុបំណុល | (១៥៤.៤៧១) | (៣៨.១៩៨) |
| ចំណាយការប្រាក់លើបំណុលភតិសន្យា | (១.២៩១.១៧២) | (៣១៩.២៨២) |
| ពន្ធប្រាក់ចំណូល | - | - |
| | (១៩.៤៨៤.០១៩) | (៤.៨១៨.០០៨) |
| ប្រាក់ចំណេញក្រោយដកពន្ធក្រោម ស.រ.ហ.អ.ក | ៦១.៥៤៦.៣៨១ | ១៥.២១៩.១៨៣ |

## ៣៦.៤ និយ័តភាពជាសារវន្តចំពោះរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ឆ្នាំ ២០១៨

របាយការណ៍លំហូរទឹកប្រាក់ ដែលបានបង្ហាញក្រោម ស.រ.ទ.ហ.អ.ក គឺស្រដៀងទៅនឹងរបាយការណ៍លំហូរទឹកប្រាក់ដែលបានបង្ហាញនៅក្រោមស្តង់ដារពីមុនជាសារវន្ត។

## ៣៧. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរបាយការណ៍

### វីរុសក្លូរ៉ូណា និងផលប៉ះពាល់លើការបាត់បង់ឥណទានរំពឹងទុក

ការបាត់បង់ឥណទានរំពឹងទុកនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៩ ត្រូវបានប៉ាន់ស្មានដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ចដែលបានព្យាករណ៍នាកាលបរិច្ឆេទនោះ។ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍មានការផ្ទុះឡើងនៃវីរុស ក្លូរ៉ូណា បានរីករាលដាលពាសពេញប្រទេសចិនដីគោក ប្រទេសកម្ពុជា និងបណ្តាប្រទេសដទៃទៀតដែលបង្កឱ្យមានការរំខានដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់លើការកើនឡើងនៃផលិតផលក្នុងស្រុក និងសូចនាករសំខាន់ផ្សេងៗ នឹងត្រូវបានពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងភាពដែលអាចទៅរួចនៃការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ដែលនឹងត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ប្រមាណការខាតបង់ឥណទានរំពឹងទុកនៃ ស.រ.ទ.ហ.អ.ក ៩ ក្នុងឆ្នាំ ២០២០។



# បណ្ដាញប្រតិបត្តិការរបស់ អិលអូអិលស៊ី

**ការិយាល័យកណ្ដាល**
អាគារលេខ ៦៦បេ ផ្លូវលេខ ២៧១ ភូមិក្បាលទំនប់១
សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរសព្ទ៖ (+៨៥៥) ០២៣ ៩៩១ ៩៩១
សារអេឡិចត្រូនិច៖ info@lolc.com.kh
គេហទំព័រ៖ www.lolc.com.kh

---

**១. ការិយាល័យប្រតិបត្តិការ**
អគារលេខ ៦៦បេ ផ្លូវលេខ ២៧១ ភូមិក្បាលទំនប់១
សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរសព្ទ៖ ០៨១ ៨០០ ៧៩៧

**២. សាខាខណ្ឌ៧មករា - សង្កាត់បឹងព្រលឹត**
ផ្ទះលេខ៤៣១ មហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងព្រលឹត
ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរសព្ទ៖ ០៨១ ៥០០ ២២២

**៣. សាខាខណ្ឌ៧មករា - សង្កាត់វាលវង់**
ដីឡូត៍លេខ៣៥អា ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ
ទូរសព្ទ៖  ០៨១ ៦០០ ៩៦៦

**៤. សាខាខណ្ឌសែនសុខ - សង្កាត់ទឹកថ្លា**
ផ្ទះលេខ អា២៥-អា២៧ ភូមិចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា
ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរសព្ទ៖ ០៨១ ៩០០ ២៦៨

**៥. សាខាខណ្ឌទួលគោក - សង្កាត់បឹងកក់ទី១**
ផ្ទះលេខ ១០១អា៣អ៊ី០អ៊ី១ & ១០១អា ផ្លូវ២៨៩ ភូមិភូមិ១
សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរសព្ទ៖ ០៨១ ៧០០ ០០១

**៦. សាខាខេត្តបន្ទាយមានជ័យ**
ផ្លូវជាតិលេខ៦អា ភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ
ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ទូរសព្ទ៖ ០៨១ ៨០០ ៣១៥

**៧. សាខាក្រុងប៉ោយប៉ែត - សង្កាត់ផ្សារកណ្ដាល**
ផ្លូវជាតិលេខ៥ ភូមិគីឡូលេខបួន សង្កាត់ផ្សារកណ្ដាល
ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ទូរសព្ទ៖ ០៨១ ៨០០ ៣២៤

**៨. សាខាស្រុកព្រះនេត្រព្រះ - ឃុំជប់វារី**
ផ្លូវជាតិលេខ៦ ភូមិជប់ ឃុំជប់វារី ស្រុកព្រះនេត្រព្រះ
ខេត្តបន្ទាយមានជ័យ
ទូរសព្ទ៖ ០៨១ ៨០០ ០២០

**៩. សាខាស្រុកថ្មពួក - ឃុំគោរ**
ផ្លូវជាតិលេខ៥៦A ភូមិអណ្ដូងខ្លុង ឃុំគោរ ស្រុកថ្មពួក
ខេត្តបន្ទាយមានជ័យ
ទូរសព្ទ៖ ០៨១ ៨០០ ៥៩៥

**១០. សាខាខេត្តបាត់ដំបង**
ផ្ទះលេខ ០១ - ០៣ F៥៩A ផ្លូវជាតិលេខ៥
ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
ខេត្តបាត់ដំបង
ទូរសព្ទ៖ ០៨១ ៨០០ ៣១៧

**១១. សាខាក្រុងបាត់ដំបង - សង្កាត់រតនៈ**
ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ទូរសព្ទ៖ ០៨១ ៨០០ ៥៣៦

**១២. សាខាស្រុកបវេល - ឃុំបវេល**
ផ្លូវជាតិលេខ៥៧ ភូមិស្ពានកណ្ដាល ឃុំបាវិល
ស្រុកបវិល ខេត្តបាត់ដំបង
ទូរសព្ទ៖ ០៨១ ៨០០ ៦០៩

**១៣. សាខាស្រុកកំរៀង - ឃុំបឹងរាំង**
ផ្ទះលេខ៧៩ ភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង
ទូរសព្ទ៖ ០៨១ ៨០០ ៧៨៥

**១៤. សាខាស្រុកមោងឫស្សី - ឃុំគារ**
ផ្លូវជាតិលេខ៥ ភូមិគារបី ឃុំគារ ស្រុកមោងឫស្សី
ខេត្តបាត់ដំបង
ទូរសព្ទ៖ ០៨១ ៨០០ ៣១៩

**១៥. សាខាស្រុករតនមណ្ឌល - ឃុំស្ដៅ**
ផ្ទះលេខ៤៩១ ក្រុមទី១ ភូមិស្ដៅ ឃុំស្ដៅ ស្រុករតនមណ្ឌល
ខេត្តបាត់ដំបង
ទូរសព្ទ៖ ០៨១ ៨០០ ៣១៨

**១៦. សាខាស្រុកសំឡូត - ឃុំតាសាញ**
ផ្លូវលេខ១០បេ ភូមិអូរទន្ទឹម ឃុំតាសាញ ស្រុកសំឡូត
ខេត្តបាត់ដំបង
ទូរសព្ទ៖ ០៨១ ៨០០ ៩៨៨

**១៧. សាខាស្រុកសំពៅលូន - ឃុំសន្តិភាព**
ផ្ទះលេខ១០២៥ ភូមិត្រពាំងព្រលិត ឃុំសន្តិភាព
ស្រុកសំពៅលូន ខេត្តបាត់ដំបង
ទូរសព្ទ៖ ០៨១ ៨០០ ៥៨៥

១៨. សាខាខេត្តកំពង់ចាម
ភូមិបឹងស្នាយ សង្កាត់សំបួរមាស ក្រុងកំពង់ចាម
ខេត្តកំពង់ចាម
ទូរសព្ទ៖ ០៨១ ៨០០ ២៩៨

១៩. សាខាស្រុកចំការលើ - ឃុំស្វាយទាប
ផ្លូវជាតិលេខ៧១ ភូមិថ្នល់បែកកើត ឃុំស្វាយទាប
ស្រុកចំការលើ ខេត្តកំពង់ចាម
ទូរសព្ទ៖ ០៨១ ៨០០ ៩៨៣

២០. សាខាស្រុកជើងព្រៃ - ឃុំសូទិព្វ
ផ្លូវជាតិលេខ៦ ភូមិតាសែន ឃុំសូទិព្វ ស្រុកជើងព្រៃ
ខេត្តកំពង់ចាម
ទូរសព្ទ៖ ០៨១ ៨០០ ៣០១

២១. សាខាស្រុកព្រៃឈរ - ឃុំជ្រៃវៀន
ផ្លូវជាតិលេខ៧ ភូមិស្លែង ឃុំជ្រៃវៀន ស្រុកព្រៃឈរ
ខេត្តកំពង់ចាម
ទូរសព្ទ៖ ០៨១ ៨០០ ០៤០

២២. សាខាខេត្តកំពង់ឆ្នាំង
ផ្ទះលេខអា០៩៦ ភូមិទី១ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង
ខេត្តកំពង់ឆ្នាំង
ទូរសព្ទ៖ ០៨១ ៤០០ ២៤១

២៣. សាខាស្រុកកំពង់ត្រឡាច - ឃុំថ្មឥដ្ឋ
ផ្លូវជាតិលេខ៥ ភូមិដើមពពេល ឃុំថ្មឥដ្ឋ ស្រុកកំពង់ត្រឡាច
ខេត្តកំពង់ឆ្នាំង
ទូរសព្ទ៖ ០៨១ ៨០០ ០៣៩

២៤. សាខាខេត្តកំពង់ស្ពឺ
ផ្លូវជាតិលេខ៣ ភូមិរំលោង សង្កាត់សុព័រទេព ក្រុងច្បារមន
ខេត្តកំពង់ស្ពឺ
ទូរសព្ទ៖  ០៨១ ៨០០ ៧៦៩

២៥. សាខាស្រុកឧដុង្គ - ឃុំវាំងចាស់
ផ្លូវជាតិលេខ៥ ភូមិស្រះកែវ ឃុំវាំងចាស់ ស្រុកឧដុង្គ
ខេត្តកំពង់ស្ពឺ
ទូរសព្ទ៖ ០៨១ ៨០០ ៣២១

២៦. សាខាស្រុកភ្នំស្រួច - ឃុំគិរីវន្ត
ផ្លូវជាតិលេខ៤ ភូមិផ្សារត្រពាំងក្រឡឹង ឃុំគិរីវន្ត ស្រុកភ្នំស្រួច
ខេត្តកំពង់ស្ពឺ
ទូរសព្ទ៖ ០៨១ ៥០០ ០៦០

២៧. សាខាខេត្តកំពង់ធំ
ផ្ទះលេខ០៨៣បេ ផ្លូវជាតិលេខ៦ ភូមិអាចារ្យលាក់
សង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
ទូរសព្ទ៖ ០៨១ ៨០០ ៩៧៧

២៨. សាខាស្រុកបារាយណ៍ - ឃុំបល្ល័ង្គ
ផ្លូវជាតិលេខ៦ ភូមិព្រៃតាត្រាវ ឃុំបល្ល័ង្គ ស្រុកបារាយណ៍
ខេត្តកំពង់ធំ
ទូរសព្ទ៖ ០៨១ ៨០០ ២៦៦

២៩. សាខាស្រុកសណ្ដាន់ - ឃុំសណ្ដាន់
ភូមិកំពង់ត្របែក ឃុំសណ្ដាន់ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ
ទូរសព្ទ៖ ០៨១ ៥០០ ៤៤៤

៣០. សាខាស្រុកស្ទោង - ឃុំកំពង់ចិនជើង
ផ្លូវជាតិលេខ៦ ភូមិឈើទាល ឃុំកំពង់ចិនត្បូង ស្រុកស្ទោង
ខេត្តកំពង់ធំ
ទូរសព្ទ៖ ០៨១ ៨០០ ៩៦៧

៣១. សាខាខេត្តកំពត
ផ្លូវជាតិលេខ៣ ភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត
ខេត្តកំពត
ទូរសព្ទ៖ ០៨១ ៨០០ ២៩៧

៣២. សាខាស្រុកអង្គរជ័យ - ឃុំភ្នំកុង
ភូមិពោធិ៍ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត
ទូរសព្ទ៖ ០៨១ ៨០០ ២៩៣

៣៣. សាខាស្រុកឈូក - ឃុំសត្វពង
ផ្លូវជាតិលេខ៣ ភូមិសត្វពង ឃុំសត្វពង ស្រុកឈូក
ខេត្តកំពត
ទូរសព្ទ៖ ០៨១ ៨០០ ២៩០

៣៤. សាខាស្រុកកំពង់ត្រាច - ឃុំអង្គសុរភី
ផ្លូវជាតិលេខ៣១ ភូមបឹងធំខាងលិច ឃុំអង្គសុរភី
ស្រុកកំពង់ត្រាច ខេត្តកំពត
ទូរសព្ទ៖ ០៨១ ៨០០ ២០២

៣៥. សាខាខេត្តកណ្ដាល
ផ្ទះលេខ១៣៨ ផ្លូវជាតិលេខ២ ភូមិក្រពើហា
សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរសព្ទ៖ ០៨១ ៨០០ ៣១២

៣៦. សាខាស្រុកអង្គស្នួល - ឃុំបែកចាន
ផ្លូវជាតិលេខ៤ ភូមិបូរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល
ខេត្តកណ្ដាល
ទូរសព្ទ៖ ០៨១ ៤០០ ២២២

៣៧. សាខាស្រុកកោះធំ - ឃុំព្រែកថ្មី
ផ្លូវជាតិលេខ២១ ភូមិព្រែកធន់ ឃុំព្រែកថ្មី ស្រុកកោះធំ
ខេត្តកណ្ដាល
ទូរសព្ទ៖ ០៨១ ៧០០ ១២៧

**៣៨. សាខាស្រុកកៀនស្វាយ - ឃុំគគីរ**
ផ្លូវជាតិលេខ១ ភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ
ខេត្តកណ្តាល
ទូរសព្ទ៖ ០៨១ ៨០០ ៦០១

**៣៩. សាខាស្រុកមុខកំពូល - ឃុំព្រែកអញ្ចាញ**
ផ្លូវជាតិលេខ៦ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល
ខេត្តកណ្តាល
ទូរសព្ទ៖ ០៨១ ៩០០ ០៤១

**៤០. សាខាក្រុងតាខ្មៅ - សង្កាត់រកាខ្ពស់**
ផ្លូវជាតិលេខ២១ ភូមិព្រែកខ្សេវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ
ខេត្តកណ្តាល
ទូរសព្ទ៖ ០៨១ ៨០០ ៣១៤

**៤១. សាខាខេត្តកោះកុង**
ផ្លូវជាតិលេខលេខ៤៨ ភូមិទី១ សង្កាត់ស្មាច់មានជ័យ
ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
ទូរសព្ទ៖ ០៨១ ៩០០ ២៨១

**៤២. សាខាខេត្តក្រចេះ**
ផ្លូវសង្គមរាស្ត្រនិយម ភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ
ខេត្តក្រចេះ
ទូរសព្ទ៖ ០៨១ ៩០០ ៣២៧

**៤៣. សាខាស្រុកឆ្លូង - ឃុំឆ្លូង**
ផ្លូវលេខ៣០៨ ភូមិជ្រោយថ្មក្រោម ឃុំឆ្លូង ស្រុកឆ្លូង
ខេត្តក្រចេះ
ទូរសព្ទ៖ ០៨១ ៩០០ ៣២៨

**៤៤. សាខាស្រុកស្នួល - ឃុំស្នួល**
ផ្លូវលេខ៧៤ ភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល
ខេត្តក្រចេះ
ទូរសព្ទ៖ ០៨១ ៧០០ ២១៥

**៤៥. សាខាខេត្តមណ្ឌលគិរី**
ផ្លូវជាតិលេខ៧៦ ភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ
ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
ទូរសព្ទ៖ ០៨១ ៧០០ ១១១

**៤៦. សាខាខេត្តព្រះវិហារ**
ភូមិអណ្តូងពោធិ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ
ខេត្តព្រះវិហារ
ទូរសព្ទ៖ ០៨១ ៨០០ ៩៩៦

**៤៧. សាខាស្រុកជាំក្សាន្ត - ឃុំជាំក្សាន្ត**
ផ្លូវជាតិលេខ៩បេ ភូមិជាំក្សាន្ត ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត
ខេត្តព្រះវិហារ
ទូរសព្ទ៖ ០៨១ ៩០០ ៨៥៥

**៤៨. សាខាខេត្តព្រះសីហនុ**
ផ្ទះលេខ១៩-២០ ផ្លូវប្ញូរីកម្មករ ភូមិ៣ សង្កាត់លេខ៣
ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរសព្ទ៖ ០៨១ ៩០០ ២៧៧

**៤៩. សាខាខេត្តព្រៃវែង**
ផ្ទះលេខ២១ ភូមិលេខ៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង
ខេត្តព្រៃវែង
ទូរសព្ទ៖ ០៨១ ៩០០ ៧៨១

**៥០. សាខាស្រុកកំពង់ត្របែក - ឃុំប្រសាទ**
ផ្លូវជាតិលេខ១ ភូមិដូងទុង ឃុំប្រាសាទ ស្រុកកំពងត្របែក
ខេត្តព្រៃវែង
ទូរសព្ទ៖ ០៨១ ៩០០ ៣០៥

**៥១. សាខាស្រុកមេសាង - ឃុំជីផុច**
ភូមិរាំង ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង
ទូរសព្ទ៖ ០៨១ ៧០០ ០១០

**៥២. សាខាស្រុកពារាំង - ឃុំរការ**
ផ្លូវជាតិលេខ៨ ភូមិស្នាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង
ទូរសព្ទ៖ ០៨១ ៣០០ ៤០០

**៥៣. សាខាស្រុកពាមរក៍ - ឃុំព្រែកខ្សាយ "ខ"**
ផ្លូវជាតិលេខ១ ភូមិ១ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍
ខេត្តព្រៃវែង
ទូរសព្ទ៖ ០៨១ ៨០០ ២៧៧

**៥៤. សាខាខេត្តពោធិ៍សាត់**
ផ្ទះ២៥៦ ផ្លូវជាតិលេខ៥ ភូមិថ្មល់បំបែក សង្កាត់លោប
ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
ទូរសព្ទ៖ ០៨១ ៨០០ ៨៨៩

**៥៥. សាខាខេត្តរតនគិរី**
ផ្ទះលេខB០៦-B០៧ ផ្លូវជាតិលេខ៧៨A ភូមិអភិវឌ្ឍន៍
សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី
ទូរសព្ទ៖ ០៨១ ៨០០ ២៤៤

**៥៦. សាខាស្រុកបរកែវ - ឃុំឡាមិញ**
ផ្លូវជាតិលេខ៧៨ ភូមិ១ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគិរី
ទូរសព្ទ៖ ០៨១ ៩០០ ២៤៨

**៥៧. សាខាខេត្តសៀមរាប**
ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប
ខេត្តសៀមរាប
ទូរសព្ទ៖ ០៨១ ៩០០ ២៩៤

**៥៨. សាខាស្រុកអង្គរជុំ- ឃុំចារឈូក**
ផ្លូវលេខ២៣១ ភូមិដូនស្វា ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប
ទូរសព្ទ៖ ០៨១ ៨០០ ១៥១

៥៩. សាខាស្រុកជីក្រែង - ឃុំកំពង់ក្តី
ផ្ទះលេខ០២៨ ផ្លូវជាតិលេខ៦ ភូមិកំពង់ក្តី១ ឃុំកំពង់ក្តី
ស្រុកជីក្រែង ខេត្តសៀមរាប
ទូរសព្ទ៖ ០៨១ ៨០០ ២៩៥

៦០. សាខាស្រុកពួក - ឃុំពួក
ផ្ទះលេខ២៧០៩ ភូមិគោកជួន ឃុំពួក ស្រុកពួក ខេត្តសៀមរាប
ទូរសព្ទ៖ ០៨១ ៨០០ ២៩៦

៦១. សាខាស្រុកសូទ្រនិគម - ឃុំដំដែក
ផ្ទះលេខ០៣៣ ភូមិដំដែកថ្មី ឃុំដំដែក ស្រុកសូទ្រនិគម
ខេត្តសៀមរាប
ទូរសព្ទ៖ ០៨១ ៨០០ ២៩៧

៦២. សាខាខេត្តស្ទឹងត្រែង
ផ្ទះលេខ២២ ភូមិកណ្តាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង
ខេត្តស្ទឹងត្រែង
ទូរសព្ទ៖ ០៨១ ៨០០ ៩៥៥

៦៣. សាខាខេត្តស្វាយរៀង
ផ្លូវជាតិលេខ១ សង្កាត់ព្រៃឆ្លាក់ ក្រុងស្វាយរៀង
ខេត្តស្វាយរៀង
ទូរសព្ទ៖ ០៨១ ៨០០ ៣០២

៦៤. សាខាក្រុងបាវិត - សង្កាត់ព្រៃអង្គុញ
ផ្លូវជាតិលេខ១ ភូមិជ្រៃធំ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត
ខេត្តស្វាយរៀង
ទូរសព្ទ៖ ០៨១ ៨០០ ៧៨៣

៦៥. សាខាស្រុករមាសហែក - ឃុំកំពង់ត្រាច
ភូមិកំពង់ត្រាច ឃុំកំពង់ត្រាច ស្រុករមាសហែក
ខេត្តស្វាយរៀង
ទូរសព្ទ៖ ០៨១ ៨០០ ៣០៤

៦៦. សាខាខេត្តតាកែវ
ផ្លូវជាតិលេខ២ ភូមិផ្សារតាកោ សង្កាត់រកាក្នុង ក្រុងដូនកែវ
ខេត្តតាកែវ
ទូរសព្ទ៖ ០៨១ ៨០០ ១៩៩

៦៧. សាខាស្រុកបាទី - ឃុំត្រពាំងសាប
ផ្លូវជាតិលេខ២ ភូមិស្មៅខ្ញី ឃុំត្រពាំងសាប ស្រុកបាទី
ខេត្តតាកែវ
ទូរសព្ទ៖ ០៨១ ៨០០ ៣០៧

៦៨. សាខាស្រុកគីរីវង់ - ឃុំព្រះបាទជាន់ជុំ
ផ្លូវជាតិលេខ២ ភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់
ខេត្តតាកែវ
ទូរសព្ទ៖ ០៨១ ៨០០ ២៨៩

៦៩. សាខាស្រុកព្រៃកប្បាស - ឃុំព្រៃល្វា
ភូមិល្វាត្មោត ឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ
ទូរសព្ទ៖ ០៨១ ៨០០ ៣០៩

៧០. សាខាស្រុកត្រាំកក់ - ឃុំអង្គតាសោម
ផ្លូវជាតិលេខ៣ ភូមិត្រពាំងខ្ទួត ឃុំអង្គតាសោម ស្រុកត្រាំកក់
ខេត្តតាកែវ
ទូរសព្ទ៖ ០៨១ ៨០០ ២៨៨

៧១. សាខាខេត្តឧត្តរមានជ័យ
ផ្លូវជាតិលេខ៦៨ ភូមិដូនកែន សង្កាត់សំរោង ក្រុងសំរោង
ខេត្តឧត្តរមានជ័យ
ទូរសព្ទ៖ ០៨១ ៨០០ ៣១៦

៧២. សាខាស្រុកអន្លង់វែង - ឃុំអន្លង់វែង
ផ្លូវជាតិលេខ៦៧ ភូមិអភិវឌ្ឍន៍ ឃុំអន្លង់វែង ស្រុកអន្លង់វែង
ខេត្តឧត្តរមានជ័យ
ទូរសព្ទ៖ ០៨១ ៨០០ ២១១

៧៣. សាខាស្រុកបន្ទាយអំពិល - ឃុំគោកមន
ផ្លូវជាតិលេខ៥៦អា ភូមិគោកមន ឃុំគោកមន
ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ
ទូរសព្ទ៖ ០៨១ ៣០០ ៣១១

៧៤. សាខាខេត្តប៉ៃលិន
ផ្លូវជាតិលេខ៥៧ ភូមិអូរតាពុកលើ សង្កាត់ប៉ៃលិន
ក្រុងប៉ៃលិន ខេត្តប៉ៃលិន
ទូរសព្ទ៖ ០៨១ ៨០០ ២៤២

៧៥. សាខាខេត្តត្បូងឃ្មុំ
ភូមិជើងឡង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ
ទូរសព្ទ៖ ០៨១ ៨០០ ៣២៦

៧៦. សាខាស្រុកតំបែរ - ឃុំតំបែរ
ផ្លូវជាតិលេខ៧៣ ភូមិសញ្ជ័យសែន ឃុំតំបែរ ស្រុកតំបែរ
ខេត្តត្បូងឃ្មុំ
ទូរសព្ទ៖ ០៨១ ៨០០ ៤២០

៧៧. សាខាស្រុកមេមត់ - ឃុំមេមត់
ផ្លូវជាតិលេខ៧ ភូមិម៉ាស៊ីនទឹក ឃុំមេមត់ ស្រុកមេមត់
ខេត្តត្បូងឃ្មុំ
ទូរសព្ទ៖ ០៨១ ៨០០ ២៥៥

៧៨. សាខាស្រុកអូររាំងឪ - ឃុំអំពិលតាពក
ភូមិស្វាយតាធម្ម ឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ
ទូរសព្ទ៖ ០៨១ ៨០០ ៥៧៨

៧៩. សាខាស្រុកពញាក្រែក - ឃុំកោងកាង
ផ្លូវជាតិលេខ៧ ភូមិកណ្តាលកោង ឃុំកោងកាង
ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ
ទូរសព្ទ៖ ០៨១ ៨០០ ៣៣៣

# គំនិតរីកចម្រើន


អាគារលេខ ៦៦៦B | ផ្លូវលេខ២៧១ | ភូមិក្បាលទំនប់១ | សង្កាត់បឹងទំពុនទី២ | ខណ្ឌមានជ័យ
រាជធានីភ្នំពេញ | ព្រះរាជាណាចក្រកម្ពុជា | ទូរសព្ទ៖ (+៨៥៥) ០២៣ ៩៩១ ៩៩១
អ៊ីម៉ែល៖ info@lolc.com.kh | គេហទំព័រ៖ www.lolc.com.kh
ហ្វេសប៊ុក៖ facebook.com/lolccambodia


ឯកសារសាធារណៈ